អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 21-Oct-2011, 08:31
CMS/CFO: Uch Arun

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ស្តីពី ការកំណត់ជាក់លាក់នូវសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១**

**សាធារណៈ**

**ម៉ោង ០៩: ០០នាទី**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម យូរ ឧត្តរា

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី
*(Ms. Faiza ZOUAKRI)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក វេង ហ៊ត់

លោក ច័ន្ទ តារារស្មី

លោក អាប់ឌុលឡាក់ ថារីក
*(Mr. Abdulhak TARIK)*

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

**មេធាវីការពារជនជាប់ចោទ អៀង ធីរិទ្ធ៖**

លោក ផាត់ ពៅស៊ាង

លោកស្រី ដាយអេណា អេលីស

*(Ms. Diana ELLIS)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ពេជ អង្គ

លោក សំ សុគង់

លោកស្រី ជេត វណ្ណលី

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោកស្រី ម៉ាទីន ហ្សាកកាំង

*(Ms. Martine JAQUIN)*

លោក អ៊ែរវេ យ៉ាគីសេ

*(Mr. Herve DIAKIESE)*

កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍ *(Ms.Phillipine SUTZ)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោកស្រី ជា លាង | ខ្មែរ |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក សុន អរុណ | ខ្មែរ |
| លោក សំ សុគង់ | ខ្មែរ |
| លោក ផាត់ ពៅស៊ាង | ខ្មែរ |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ឡោ ជុនធី | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោកស្រី ម៉ាទីន ហ្សាកកាំង | បារាំង |
| លោក ស៊ីណា ហ្វាស៊ែល | អង់គ្លេស |
| លោក ហ្គូត លីនណា | ខ្មែរ |
| លោក ឌុច ផារី | ខ្មែរ |

# ឧបសម្ព័ន្ធ

## សាក្សី

### វេជ្ជបណ្ឌិត ហួត លីនណា និង វេជ្ជបណ្ឌិត ស៊ីណា ហ្វាស៊ែល (Dr. seena FAZEL)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........................................ទំព័រ ៦៦
សួរដោយចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ផ្ដើមពី........................................ទំព័រ ៦៨
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី........................................ទំព័រ ៩៩

# កិច្ចដំណើរការនីតិវិធី

[០៩:០០:០០]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**លោក ឌុច ផារី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

ថ្ងៃនេះអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បើកសវនាការស្តីពីការកំណត់ជាក់លាក់នូវសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងបញ្ហាសម្បទា និងបញ្ហាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ដូចដែលបានគូសបញ្ជាក់រួចហើយនៅក្នុងដីកាកំណត់កាលបរិច្ឆេទសវនាការចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១។

សមាសភាពចៅក្រមចូលរួមនៅក្នុងសវនាការនេះ រួមមាន គឺរូបយើង និល ណុន ជាប្រធាន, លោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍, លោកចៅក្រម យ៉ា សុខន, លោកចៅក្រម ហ្សង់ ម៉ាកឡាវែន៍, លោកចៅក្រម យូរ ឧត្តារា និងមានចៅក្រមបម្រុងចំនួនពីររូប គឺ លោកចៅក្រម ធូ មណី និង លោកស្រីចៅក្រម ក្លូឌា ហ្វេនស៍។

ក្នុងនាមខ្ញុំជាប្រធាន និងជំនួសមុខឲ្យចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង ខ្ញុំសូមស្វាគមន៍សហព្រះរាជអាជ្ញា សហមេធាវីជនជាប់ចោទ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋ-ប្បវេណី ដែលមានវត្តមាននៅក្នុងសវនាការនានាថ្ងៃនេះ។

[០៩:០៣:២៥]

សវនាការនេះមានគោលបំណងពិចារណាទៅលើបញ្ហាទាំងឡាយ ដែលមាននៅក្នុងរបាយការណ៍ថ្មីៗរបស់អ្នកជំនាញវិកលវិទ្យា ដែលត្រូវបានតែងតាំងដោយអង្គជំនុំជម្រះសាលាដំបូង កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១ កន្លងទៅ។ អ្នកជំនាញវិកលវិទ្យាបានដាក់របាយការណ៍នេះរួមគ្នា និងបានបែងចែកទៅភាគី នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១។ របាយការណ៍នេះជារបាយការណ៍បន្ថែមពីលើសេចក្តីសន្និដ្ឋានកាលពីកន្លងទៅ របស់អ្នកជំនាញព្យាបាលជំងឺមនុស្សចាស់ ពាក់ព័ន្ធនឹងការធ្លាក់ចុះខ្សោយផ្នែកប្រព័ន្ធប្រសាទរបស់ជនជាប់ចោទ អៀង ធីរិទ្ធ។

[០៩:០៤:០៨]

អង្គជំនុំជម្រះបានស្នើសុំឲ្យអ្នកជំនាញវិកលវិទ្យា ផ្ដល់យោបល់ឯកទេសពាក់ព័ន្ធនឹងផ្នែកវិកលវិទ្យាជូនអង្គជំនុំជម្រះ ដើម្បីអង្គជំនុំជម្រះមានលទ្ធភាពសម្រេចអំពីបញ្ហាសម្បទា និងបញ្ហាស្មារតីជនជាប់ចោទរូបនេះក្នុងការចូលរួមសវនាការ។

សវនាការនេះនឹងអនុញ្ញាតឲ្យអង្គជំនុំជម្រះ និងភាគី មានឱកាសសួរសំណួរទៅកាន់អ្នកជំនាញវិកលវិទ្យា បន្ថែមពីការលើកទឡ្ហីករណ៍តទល់ ពីសំណាក់មេធាវីការពារក្ដីជនជាប់ចោទ អៀង ធីរិទ្ធ។ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងសេចក្ដីសន្និដ្ឋាននៃរបាយ-ការណ៍របស់អ្នកជំនាញវិកលវិទ្យា អំពីបញ្ហាសម្បទា និងបញ្ហាស្មារតី របស់ ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ។ កាលពីថ្ងៃ២៣ ខែកញ្ញា ឆ្នាំ២០១១ អង្គ ជំនុំ ជម្រះសាលាដំបូងបានបង្គាប់ឲ្យសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបំពេញបន្ថែម និងធ្វើបច្ចុប្បន្នភាពលើខ្លឹមសារបឋមនៃសំណង ដែលខ្លួនបានលើកឡើងនៅក្នុងសវនាការបឋម ដែលខ្លួនមានបំណងទាមទារនៅក្នុងបណ្ដឹងទាមទារចុងក្រោយ។

[០៩:០៥:៤៧]

អង្គជំនុំជម្រះសូមបញ្ជាក់ថា សវនាការនេះមានបំណងចង់ឲ្យសហមេធាវីនាំមុខបញ្ជាក់ច្បាស់លាស់អំពីប្រភេទនៃសំណង ដែលខ្លួនមានបំណងទាមទារដោយអនុលោមតាមវិធាន២៣ ស្ទួន៤ ចំណុច ៣ នៃវិធានផ្ទៃក្នុង។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីគ្រាន់តែត្រូវបញ្ជាក់បន្ថែម ធ្វើបច្ចុប្បន្នភាព និងកែសម្រួលខ្លឹមសារនៃសំណង ប្រសិនបើចាំបាច់ ដែលខ្លួនធ្លាប់បានបញ្ជាក់នៅក្នុងសវនាការបឋមកន្លងទៅ ដោយអនុលោមតាមការណែនាំនៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះ។

សាលាដំបូងចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១១ សវនាការនេះនឹងចាប់ផ្ដើមដោយផ្ដល់ឱកាសឲ្យសហមេធាវីនាំមុខធ្វើការបញ្ជាក់លើខ្លឹមសារនៃសំណង។

ខ្ញុំសូមប្រកាសបើកសវនាការ ចាប់ពីពេលនេះតទៅ។

ក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមាន ភាគីដែលត្រូវបានអង្គជំនុំជម្រះកោះហៅ និងអនុញ្ញាតឲ្យចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅថ្ងៃនេះ ដោយរួមទាំងអ្នកជំនាញខាងវិកលវិទ្យាចំនួនពីររូបផង ដែលអង្គជំនុំជម្រះបានអញ្ជើញឲ្យគាត់ឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការជាបន្តបន្ទាប់។ សូមអញ្ជើញ!

[០៩:០៧:២៣]

**លោក ឌុច ផារី៖**

សូមគោរពលោកប្រធាន! ស្ថានភាពវត្តមាន និងអវត្តមានរបស់ភាគីក្នុងសវនាការថ្ងៃនេះមានដូចខាងក្រោម៖

ការិយាល័យសហព្រះរាជអាជ្ញាមានចំនួនគ្រប់ចំនួន។

ក្រុមមេធាវីការពារជនជាប់ចោទ នួន ជា មានវត្តមានគ្រប់ចំនួន។ ក្រុមមេធាវីការពារជនជាប់ចោទ អៀង សារី មានវត្តមាន។ ក្រុមមេធាវីការពារជនជាប់ចោទ អៀង ធីរិទ្ធ មានវត្តមាន។ ក្រុមមេធាវីការពារជនជាប់ចោទ ខៀវ សំផន បានជូនដំណឹងថា ក្រុមរបស់លោកនឹងមិនចូលរួមនៅក្នុងសវនាការថ្ងៃនេះ។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងថ្ងៃនេះ។

[០៩:០៨:០២]

មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានវត្តមាន ហើយមានមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបរទេសម្នាក់ ដែលមិនទាន់បានទទួលស្គាល់ក៏មានវត្តមាននៅក្នុងពេលនេះផងដែរ។

អ្នកជំនាញទាំងពីររូបដែលអង្គជំនុំជម្រះបានកោះហៅ មានអ្នកជំនាញជាតិម្នាក់មានវត្តមាននិងបានធ្វើសម្បថរួចហើយ។ ចំណែកអ្នកជំនាញអន្តរជាតិ លោកនឹងអញ្ជើញមកដល់នៅម៉ោងដប់មួយ។ អ្នកជំនាញទាំងពីរនេះមិនមានចំណងញាតិលោហិត និងញាតិពន្ធជាមួយនឹងជនជាប់ចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ សូមអរគុណ។

[០៩:០៨:៥១]

**ប្រធានអង្គជំនុំ៖**

អរគុណលោកក្រឡាបញ្ជី។

ជាកិច្ចបន្ត គឺអង្គជំនុំជម្រះមុននឹងចូលដល់របៀបវារៈ ដែលបានគ្រោងទុកនៅក្នុងកិច្ចដំណើរការសវនាការសម្រាប់នៅថ្ងៃនេះ និងថ្ងៃស្អែក។ អង្គជំនុំជម្រះសូមចាប់ផ្តើមធ្វើនីតិវិធីនៃការទទួលស្គាល់មេធាវីបរទេសដោយមេធាវីជាតិជាមុន។

ដោយអនុលោមតាមវិធាន២២(២) ចំណុច (ក) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសូមអញ្ជើញមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោក ពេជ អង្គ ឡើងសុំធ្វើការទទួលស្គាល់មេធាវីបរទេស

ដែលកន្លងមកពុំទាន់បានទទួលស្គាល់ ហើយមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការនេះ។

សូមអញ្ជើញ!

[០៩:១០:០០]

**លោក ពេជ អង្គ៖**

សូមគោរពលោកចៅក្រមប្រធាន លោក លោកស្រីចៅក្រម លោកជំទាវ លោកដែលជាព្រះរាជអាជ្ញា សហព្រះរាជអាជ្ញារង លោក លោកស្រីមេធាវីទាំងអស់។ ខ្ញុំបាទ ពេជ អង្គ ជាមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមស្នើសុំឲ្យអង្គជំនុំជម្រះទទួលស្គាល់មេធាវីបរទេសម្នាក់ នៅក្នុងក្រុមមេធាវីគ្មានព្រំដែនបារាំង មានឈ្មោះថា អ៊ែរវ៉េ យ៉ាគីសេ ដែលលោកបានស្បថនៅសាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទទួលសិទ្ធិពេញលេញក្នុងការបំពេញការងារជាមេធាវីរួចហើយ។

សូមលោកប្រធានមេត្តាអនុញ្ញាតទទួលស្គាល់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ លោក ពេជ អង្គ។ លោក អ៊ែរវ៉េ យ៉ាគីសេ លោកត្រូវបានអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់លោកជាមេធាវីការពារក្តី អ៎! ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ដោយអនុលោមតាមការទទួលស្គាល់នេះ លោកមានសិទ្ធិ និងបុព្វសិទ្ធិដូចគ្នានឹងមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែរ។

សូមលោកអង្គុយចុះ!

បន្ទាប់ពីបានបំពេញកិច្ចនីតិវិធីពាក់ព័ន្ធនឹងការទទួលស្គាល់មេធាវីបរទេសរួចហើយ អង្គជំនុំជម្រះសូមបន្តកិច្ចដំណើរការសវនាការ។

[០៩:១១:៤៨]

អនុលោមតាមវិធានផ្ទៃក្នុងដែលបានធ្វើវិសោធនកម្ម សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើឡើងនូវគម្រោងសំណងដែលបានបង្កើតឡើង ឬចងក្រងបង្ហាញដោយសហការជាមួយនឹងអង្គភាពជនរងគ្រោះ នឹងត្រូវបានផ្តល់មូលនិធិពីខាងក្រៅ។

យោងតាមវិធាន២៣ ស្ទួនបី ចំណុច(ខ) គម្រោងនេះទទួលបានជោគជ័យ ឬយ៉ាងណា គឺវាអាស្រ័យទៅលើលទ្ធភាពរបស់អង្គភាពជនរងគ្រោះ ក្នុងការទទួលបានថវិកាគ្រប់គ្រាន់ដើម្បីអនុវត្តគម្រោងនីមួយៗ និងលទ្ធភាពពិនិត្យមើលការអនុវត្តគម្រោង។

គោលបំណងមួយនៃការបញ្ជាក់បឋមអំពីខ្លឹមសារនៃសំណងនេះ គឺដើម្បីទុកឱកាសឲ្យអង្គជំនុំជម្រះពិនិត្យថាតើសំណងដែលបានស្នើសុំនោះ ស្របជាមួយនឹងក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក ដែរឬទេ? និងដើម្បីឲ្យអង្គជំនុំជម្រះមានលទ្ធភាពផ្តល់ការណែនាំចាប់តាំងពីដំណាក់កាលដំបូងក្នុងករណីចាំបាច់។

[០៩:១៣:០៥]

អង្គជំនុំជម្រះយល់ឃើញថា ការបញ្ជាក់ជាមុននេះគឺជាផ្នែកមួយដ៏សំខាន់ដើម្បីធានាថាវិធានការមួយចំនួនដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿងលេខ ០០២ គឺស្ថិតនៅក្នុងវិសាលភាពនៃវិធានផ្ទៃក្នុង ហើយអាចនាំមកនូវលទ្ធផលជាផ្លែផ្កាសម្រាប់ជនរងគ្រោះ និងដើម្បីធានាថា អង្គភាពជនរងគ្រោះ និងម្ចាស់ជំនួយខាងក្រៅពិតជាបានប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព។

អនុលោមតាមវិធានផ្ទៃក្នុង សហមេធាវីនាំមុខមានកាតព្វកិច្ចបញ្ជាក់ជាមុននូវខ្លឹមសារនៃសំណង និងបែបបទនៃការអនុវត្តគម្រោងសំណងនីមួយៗដែលខ្លួនបានស្នើសុំ។ គោលបំណងនៃការបញ្ជាក់ជាមុននេះ គឺដើម្បីជំរុញឲ្យមានភាពច្បាស់លាស់គ្រប់គ្រាន់ និងបានរៀបចំផែនការជាមុន ធ្វើយ៉ាងណាដើម្បីធានាថា ដើមបណ្តឹងរដ្ឋប្បវេណីទទួលបានសំណងប្រកបដោយអត្ថន័យនៅក្នុងក្របខ័ណ្ឌអាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

[០៩:១៤:២០]

ដូច្នេះការបញ្ជាក់ជូនអង្គជំនុំជម្រះអំពីខ្លឹមសារនៃសំណងឲ្យបានច្បាស់លាស់តាមដែលអាចធ្វើទៅបាននៅដំណាក់កាលដំបូងនេះ គឺជាប្រយោជន៍ទាំងស្រុងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី។

នៅក្នុងអនុស្សរណៈរបស់ខ្លួន ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់មួយចំនួនពាក់ព័ន្ធនឹងការបញ្ជាក់ជាមុន អំពីខ្លឹមសារនៃសំណងរបស់សហមេធាវីនាំមុខ ដែលបានលើកឡើងនៅក្នុងសវនាការបឋមកន្លងទៅ។ ពេលនេះអង្គជំនុំជម្រះសាលាដំបូង សូមស្នើឲ្យសហមេធាវីនាំមុខយកឱកាសនេះ ដើម្បីបំពេញបន្ថែមទៅលើខ្លឹមសារបឋមនៃសំណង។

អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅ សហមេធាវីនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឡើងធ្វើបទបង្ហាញអំពីរូបភាពនៃសំណង ដែលដើមបណ្តឹងរដ្ឋប្បវេណីមានបំណងប្តឹងទាមទារ។

សូមអញ្ជើញបាទ!

[០៩:១៥:៥០]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមគោរពលោកប្រធាន។ សូមគោរពអស់លោក លោកស្រីចៅក្រមទាំងអស់ជាទីគោរព។ សូមគោរពអស់លោក លោកស្រីដែលមានវត្តមាននៅទីនេះ។

សហមេធាវីនាំមុខនិងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានសេចក្តីសប្បាយរីករាយណាស់ ដែលមានឱកាសអាចផ្តល់ជូនដល់អង្គជំនុំជម្រះនូវសេចក្តីបញ្ជាក់បន្ថែម ហើយនិង គឺជាការបញ្ជាក់ដ៏ច្រើនលើសលប់ទៅតាមការចង់បានរបស់អង្គជំនុំជម្រះ។ បន្ទាប់ពីយើងខ្ញុំបានផ្តល់ការចង្អុលបង្ហាញដំបូង កាលពីថ្ងៃទី២៩ មិថុនា កន្លងទៅនេះ។

យើងខ្ញុំបានដឹងច្បាស់ជាងអ្នកណាៗទាំងអស់ អំពីសារៈសំខាន់នៃសំណងនៅក្នុងដំណើរការយុត្តិធម៌ ហើយប្រសិនបើសំណងមិនមែនជាគោលដៅចុងក្រោយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ដើមបណ្តឹងរដ្ឋប្បវេណីក៏មិនមានតួនាទីអ្វីនៅក្នុងការជំនុំជម្រះនេះដែរ។ សំណងគឺ ដាច់ខាតគឺត្រូវតែកើតចេញពីការផ្តន្ទាទោសនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលបញ្ចូលដើមបណ្តឹងរដ្ឋប្បវេណីទៅក្នុងនោះ។

[០៩:១៦:៥៣]

យើងខ្ញុំមានសេចក្តីសប្បាយរីករាយណាស់ ដែល អ.វ.ត.ក បានបើកទ្វារដល់ដើមបណ្តឹងរដ្ឋប្បវេណីជាលើកដំបូងនៅក្នុងតុលាការអន្តរជាតិ ហើយជាការពិតការអនុញ្ញាតបែបនេះនឹងធ្វើឲ្យនីតិវិធីមានលក្ខណៈពិសេស ហើយពោរពេញទៅដោយឧបសគ្គបន្ថែម ភាពមិនច្បាស់លាស់បន្ថែម ហើយនិងការជជែកដេញដោលគ្នាបន្ថែមទៅទៀត។ ទោះបីជាតាមព្រឹត្តិន័យវាធ្វើឲ្យដំណើរការជំនុំជម្រះ កាន់តែមានរយៈពេលយូរក៏ដោយ ក៏ការជំនុំជម្រះក្តីរបបកម្ពុជាប្រជាធិបតេយ្យអាចបញ្ជាក់ពីវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីបាន។

ជាការពិត តើយើងអាចកាត់សេចក្តីចំពោះអ្វីដែលបានប៉ះពាល់ដល់គ្រួសារនីមួយៗ ភូមិនីមួយៗនៃកម្ពុជា ដែលបន្សល់ទុកនៅស្លាកស្នាមយ៉ាងច្បាស់នៅពេល៣០ឆ្នាំក្រោយមកដោយគ្មានវត្តមានរបស់ជនរងគ្រោះយ៉ាងម៉េចនឹងកើត? តើអ្នកណានឹងអាចរៀបរាប់អំពីរឿងរ៉ាវដ៏ឃោរឃៅដែលបានកើតឡើង ហើយស្នើសុំឲ្យលាតត្រដាងការពិត ហើយផ្តល់យុត្តិធម៌តាមផ្លូវច្បាប់បានប្រសើរជាងជនរងគ្រោះទាំងនោះៗ? អ្វីដែលជាទម្ងន់នៃអង្គហេតុដែលបានចោទប្រកាន់ អ្វីដែលធ្វើឲ្យអង្គហេតុចោទប្រកាន់ក្លាយទៅជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺថាអំពើ

ទាំងអស់នេះត្រូវបានប្រព្រឹត្តទៅលើបុគ្គល ដែលមកស្នើសុំឲ្យផ្តល់យុត្តិធម៌ ទោះបីជាដោយប្រយោល ឬដោយផ្ទាល់ក្តី។ ប្រសិនបើគ្មានជនរងគ្រោះនេះទេ គឺក៏គ្មានឧក្រិដ្ឋកម្មដែរ។ នេះចំណុចនេះហាក់ដូចជាច្បាស់លាស់ណាស់ ប៉ុន្តែចួនកាលគេប៉ុនប៉ងមិនបានផ្តល់តួនាទីទៅដល់ដើមបណ្តឹងរដ្ឋប្បវេណី ដែលជានិមិត្តរូប និងជាតំណាងដោយស្ម័គ្រចិត្ត នៃជនរងគ្រោះទាំងអស់។

[០៩:១៨:៣៩]

អង្គជំនុំជម្រះចង់បានសេចក្តីបញ្ជាក់ឲ្យកាន់តែច្បាស់អំពីសំណង យើងខ្ញុំមានសេចក្តីសប្បាយរីករាយអំពីការទាមទារនេះ ពីព្រោះយើងខ្ញុំយល់ថា នេះគឺជាកាយវិការមួយដែលបង្ហាញថា អង្គជំនុំជម្រះកំពុងតែយកចិត្តទុកដាក់ទៅដល់ដើមបណ្តឹងរដ្ឋប្បវេណី និងសំណងដែលត្រូវផ្តល់ដោយជនជាប់ចោទនៅពេលដែលពិរុទ្ធភាពត្រូវបានលាតត្រដាង។ អាស្រ័យទៅតាមពេលវេលាដែលបានផ្តល់ជូន យើងខ្ញុំនឹងជម្រាបជូនអង្គជំនុំជម្រះនូវរាល់សេចក្តីបញ្ជាក់ចាំបាច់ទាំងអស់។

ដំបូង គឺពាក់ព័ន្ធទៅនឹងស្ថានភាពនៃដំណើរការបង្កើត ព្រមទាំងការសហការរបស់យើងជាមួយនឹងអ្នកដែលធ្វើការជាមួយយើង ហើយជាពិសេស គឺអង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។ យើងនឹងបង្ហាញជូននូវបញ្ហាចោទរបស់យើង ជាពិសេសយោងទៅលើបរិបទច្បាប់ និងនីតិវិធីដែលលោកប្រធានបាននិយាយកាលពីអម្បាញ់មិញនេះ ហើយគឺពាក់ព័ន្ធនឹងបរិបទផ្ទៃក្នុង និងខាងក្រៅ អ.វ.ត.ក ហើយយើងនឹងផ្តល់សេចក្តីបញ្ជាក់ និងព័ត៌មានបន្ថែមទៅតាមការទាមទាររបស់អង្គជំនុំជម្រះ ហើយយើងក៏នឹងបង្ហាញជូនអំពីការពិចារណាផ្ទាល់ខ្លួនផងដែរ តាមរបៀបផ្សេងៗនៅក្នុងបរិបទច្បាប់ និងនីតិវិធីដែលនឹងចូលរួមចំណែកដល់ការតាក់តែងសំណងទាំងអស់នេះ។

[០៩:២០:01]

យើងនឹងផ្តល់បន្តមកទៀតនូវចម្លើយរបស់យើងទៅលើការកត់សម្គាល់របស់អង្គជំនុំជម្រះដែលដូចបានបង្ហាញជូននៅក្នុងអនុស្សរណៈលេខ E125 ហើយបន្ទាប់ពីការផ្តល់នូវការបញ្ជាក់បន្ថែម និងខ្លឹមសារបឋមដែលជាក្របខ័ណ្ឌច្បាប់នៃសំណងទាំងអស់នេះហើយ ដោយមិននិយាយដដែលៗជាមួយនឹងអ្វីដែលបាននិយាយរួចមកហើយនៅក្នុងសវនាការបឋមនោះ យើងនឹងងាកមកនិយាយអំពីគម្រោងនីមួយៗ ដើម្បីផ្តល់នូវសេចក្តីពន្យល់បំភ្លឺបន្ថែម និងព័ត៌មានលម្អិតបន្ថែមទៅទៀត។

[០៩:២០:៣៨]

ខ្ញុំសូមបញ្ជាក់ផងដែរថា សំណងទាំងអស់នេះ គឺកើតចេញពីការងារសមូហភាព ហើយមិនមែន

ការងារនោះមួយដែលធ្វើដោយអត្តនោម័តិនោះទេ គឺយើងធ្វើដើម្បីផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។

ដូច្នេះ នៅពេលនេះខ្ញុំសូមប្រគល់វេទិកានេះជូនមេធាវី ម៉ាទីន ហ្សាកកាំង ដែលជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ហើយមេធាវីទាំងអស់នេះ គឺតែងតែនៅប្រកៀកជាមួយនឹងសហមេធាវីនាំមុខ។ ហើយគឺជាការពារដើមបណ្តឹងរដ្ឋប្បវេណី ដែលយើងនឹងនិយាយនៅថ្ងៃនេះក្នុងសំលេងតែមួយគត់។

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ ខ្ញុំនឹងនិយាយពីប្រធានបទបីទីមួយ ខ្ញុំនិយាយអំពីដំណើរការនៃការតាក់តែងសំណង ដោយសហការជាមួយនឹងសង្គមស៊ីវិល ហើយបន្ទាប់មកខ្ញុំនឹងនិយាយនឹងបទបរិបទនីតិវិធី ហើយនិងឧបសគ្គដែលកើតចេញពីការធ្វើសំណងទាំងអស់នេះ ដោយនិងយើងនិយាយអំពីវិធាន៨០ស្ទួន ហើយនិងពីផលពិបាក ហើយនិងការបំបែកនីតិវិធី ដែលធ្វើឲ្យមានផលទៅលើដើមបណ្តឹងរដ្ឋប្បវេណី។

[០៩:២២:០៥]

ជាដំបូងសូមឲ្យខ្ញុំនិយាយយ៉ាងឆាប់រហ័ស អំពីថាតើយោងទៅតាមច្បាប់ និងការចង់បានរបស់ដើមបណ្តឹងរដ្ឋប្បវេណី យើងបានទៅដល់ចំណុចនេះយ៉ាងណា។ ចាប់ពីពេលមានដីកា ស្តីពីការទទួលយកដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេត ដែលបានប្រកាសទទួលដើមបណ្តឹងរដ្ឋប្ប-វេណីជាច្រើននៅក្នុងសំណុំរឿង០០២ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងអង្គភាពគាំពារជនរងគ្រោះនិងអង្គការដៃគូ បានដំណើរការពិគ្រោះយោបល់ជាមួយនិងដើមបណ្តឹងរដ្ឋប្បវេណី២.១២២នាក់ដែលរស់នៅកម្ពុជា និងនៅបរទេស។ ហើយយើងបន្ទាប់ពីបានទទួលនូវលទ្ធផលនៃការពិគ្រោះយោបល់នេះ សហមេធាវីនាំមុខហើយនិងមេធាវីទាំងអស់ ដោយសហការជាមួយនឹងអង្គភាពគាំពារជនរងគ្រោះហើយនិងអង្គការក្រៅរដ្ឋាភិបាល គឺបានធ្វើការវិភាគយ៉ាងពេញលេញ ហើយនិងការសំយោគទៅទិន្នន័យទាំងអស់ដើម្បីកម្រិតនៅដែនកំណត់ ដែលដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ចង់ទទួលចង់បាន។

[០៩:២៣:០៧]

ហើយយោងទៅតាមវិធានផ្ទៃក្នុង យើងមានកាតព្វកិច្ចក្នុងការផ្តល់នូវសេចក្តីបញ្ជាក់បន្ថែមអំពីខ្លឹមសារនៃសំណងដែលនឹងត្រូវស្នើសុំ ហើយយើងនឹងនិយាយអំពីបំណងរួមរបស់យើង ដើម្បីធ្វើជាគម្រោងមួយដែលមានលក្ខណៈរលូន ស៊ីសង្វាក់គ្នា ហើយនិងអាចប្រព្រឹត្តទៅបាន។

ធាតុដ៏សារៈសំខាន់នៅក្នុងដំណើរការនេះ គឺថាយើងត្រូវតែបញ្ជាក់នៅក្នុងសំណុំរឿង០០២ ដើមបណ្តឹងរដ្ឋប្បវេណី គឺគាត់ចង់បាននៅអ្វីសំណាងដែលមានបង្ហាញនៅក្នុងសំណុំរឿង០០១ ដែលត្រូវបានបដិសេធដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសាលក្រមថ្ងៃទី២៦ កក្កដា ឆ្នាំ២០១០។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ បានធ្វើបណ្តឹងសាទុក្ខទៅកាន់អង្គជំនុំជម្រះតុលាការកំពូលទៅលើបញ្ហាសំណង ហើយអង្គជំនុំជម្រះត្រូវតែសម្រេចទៅលើបញ្ហានេះ។

[០៩:២៣:៥៥]

ដូច្នេះ យើងត្រូវតែធ្វើសកម្មភាពទោះបីជាយើងមាននៅតម្រុយច្បាប់ក្នុងស្ថានភាពបែបបនេះក៏ដោយ។ ទោះបីជាមានឧបសគ្គបែបនេះក៏ដោយ ក៏យើងកាលពីខែមិថុនា ឆ្នាំ២០១១ យើងបានកំណត់នូវវិធានបួន (សុំទោស) នូវសំណើបួនប្រភេទ ហើយនៅក្នុងនោះមានសំណើតូចៗជាច្រើន។ ហើយនៅថ្ងៃទី២៤ មិថុនា គឺប្រាំថ្ងៃ មុនថ្ងៃដែលសហមេធាវីនាំមុខត្រូវផ្តល់នូវសេចក្តីបញ្ជាក់បឋម ១.៧៥០នាក់ដែលសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបដិសេធ ហើយត្រូវបានធ្វើបណ្តឹងសាទុក្ខ ហើយបន្ទាប់មកត្រូវបានប្រកាសទទួលស្គាល់។ ហើយធាតុផ្សំថ្មីនេះ គឺវាមានការពេញចិត្តណាស់ចំពោះយើង។ ប៉ុន្តែវាមានផលប៉ះពាល់យ៉ាងច្បាស់លាស់ទៅលើតម្លៃនៃការចង្អុលបញ្ជាក់បឋមដែលយើងបានរកឃើញ ហើយវាគឺតំណាងឲ្យពាក់កណ្តាលនៃការចង់បានរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

[០៩:២៤:៥៤]

នៅថ្ងៃទី២៩ មិថុនា យោងតាមវិធាន៨០ស្ទួន សហមេធាវីនាំមុខ បាននិយាយដោយផ្ទាល់មាត់នូវខ្លឹមសារបឋម ពាក់ព័ន្ធទៅនឹងសំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះ។ ហើយនៅពេលនោះ ក៏យើងបានលើកឡើងអំពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការជំនុំជម្រះក្តីពីព្រោះថា ពួកគាត់មានសិទ្ធិក្នុងការទាមទារសំណង ហើយយើងក៏បានបង្ហាញអំពីសំណើសុំសំណងដែលយើងនឹងចាត់ទុកថាវាគឺជាការចង្អុលបង្ហាញខ្លឹមសារបឋម។ ហើយយើងបានកំពុងតែធ្វើការបង្កើតគម្រោងនេះជាមួយនឹងអង្គការក្រៅរដ្ឋាភិបាល ដើម្បីឲ្យយើងទទួលបន្ទុកទៅលើការសម្រេចគម្រោងទាំងអស់នេះពាក់ព័ន្ធទៅនឹងភាពអាចសម្រេចបាន ហើយនិងនិរន្តរភាព។

ហើយការបញ្ជាក់ជូននេះ គឺថាអាចធ្វើឲ្យអង្គជំនុំជម្រះឃើញថា ការបង្កើតសំណងគឺវាមិនមែនជារឿងអរូបីនោះទេ គឺវាជាការដ្ឋានមួយដែលយើងកំពុងតែធ្វើឡើងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាមួយនឹងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។

នៅពេលនេះ យើងនឹងនិយាយអំពីបរិបទនីតិវិធី ហើយនិងឧបសគ្គដែលពាក់ព័ន្ធ ដែលជាប់ពាក់ព័ន្ធទៅនឹងធាតុផ្សំដែលបានកំណត់នៅក្នុងដីកាទាំងអស់។

[០៩:២៦:១៤]

យើងនិយាយអំពីការកត់សម្គាល់ទៅលើវិធាន៨០ស្ទួន។

វិធាន៨០ ស្ទួន ដែលនិយាយអំពីសវនាការបឋមបាននិយាយថា អង្គជំនុំជម្រះ-- ខ្ញុំសូមស្រង់៖ "អាចបង្គាប់ឲ្យសហមេធាវីនាំមុខតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី បង្ហាញជាលក្ខណៈបឋមនូវខ្លឹមសារជាក់លាក់នៃសំណើសុំសម្ងហភាព ហើយនិងផ្លូវចិត្តដែលខ្លួនចង់ទាមទារនៅក្នុងសំណើសុំចុងក្រោយ។

យើងមិននិយាយចំណាយពេលច្រើនទៅលើវិធីដែលយើងត្រូវធ្វើនោះទេ ហើយពាក់ព័ន្ធទៅនឹងការបកស្រាយដែលសហមេធាវីនាំមុខ និងមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងនៅវិធាន៨០ស្ទួន។ យើងគិតថា យើងបានធ្វើការវាយតម្លៃសមស្រប ហើយនិងមានភាពរឹងមាំខាងផ្នែកច្បាប់ពាក់ព័ន្ធទៅនឹងវិធាន កាតព្វកិច្ចទាំងអស់នេះយោងទៅតាមវិធាននេះ ហើយក៏វាមិនមានការចាំបាច់អីទេក្នុងការយើងផ្ដល់នូវការបកស្រាយដែលមានលក្ខណៈផ្សេងៗជាច្រើននោះ។

[០៩:២៧:២០]

ការជជែកដេញដោលនៅក្នុងច្បាប់ គឺថា គឺធ្វើឲ្យមានការ មិនមានការឯកភាពគ្នារវាងភាគីហើយនិងតុលាការ។ ដូច្នេះ ខ្ញុំសូមឲ្យខ្ញុំបញ្ជាក់អំពីការមិនយល់ឯកភាពគ្នានេះ។ យើងគិតថាវិធាន៨០ស្ទួន គឺថានៅក្នុងដំណាក់កាលនៃនីតិវិធីនេះ មិនតម្រូវឲ្យដើមបណ្ដឹងរដ្ឋប្បវេណីបង្ហាញនូវព័ត៌មានលម្អិតស្ដីអំពីសំណើសុំសំណងដែលកំពុងតែតាក់តែង ហើយនិងក៏មិនតម្រូវឲ្យមានការនិយាយអំពីវិធីនៃការអនុវត្តសំណងទាំងអស់នេះដែរ។

[០៩:២៧:៥០]

ដូច្នេះនៅក្នុងដំណាក់កាលនេះ យោងទៅតាមឯកសារលេខ E86 និងឯកសារ E86/1 គឺគេតម្រូវឲ្យយើងគ្រាន់តែបង្ហាញអំពីខ្លឹមសារបឋមតែប៉ុណ្ណោះនៃសំណង។ ក៏ប៉ុន្តែយើងចាត់ទុកថាសវនាការនៅថ្ងៃនេះ គឺជាឱកាសមួយដ៏មានតម្លៃសម្រាប់ផ្ដល់ជូនទៅនឹងតុលាការស្ដីអំពីបច្ចុប្បន្នភាពនៃការដំណើរការសំណងរបស់យើង។ យើងគិតថា វាក៏ជាចំណុចចាប់ផ្ដើមនៃការសន្ទនាគ្នាជាអចិន្ត្រៃយ៍ជាមួយតុលាការទៅលើបញ្ហាជាក់លាក់ពាក់ព័ន្ធទៅនឹងការអភិវឌ្ឍន៍ និងការសម្រេចបាននូវសំណើសុំចុងក្រោយនេះ។

[០៩:២៨:៣១]

នៅកថាខណ្ឌទី៨ នៃអនុស្សរណៈដែលចុងថ្ងៃទី២៣ កញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះបានបញ្ជាក់ថាគោលបំណងនៃការបង្ហាញពីខ្លឹមសារបឋមនេះ គឺអាចធ្វើឲ្យសំណងនេះមានលក្ខណៈច្បាស់លាស់ជាងមុន ហើយនិងមានការគ្រោងទុកជាមុន ដើម្បីជាផលប្រយោជន៍ដើមបណ្តឹងរដ្ឋប្បវេណីរួម ហើយនិងផ្តល់ទៅឲ្យអង្គជំនុំជម្រះនូវដំណាក់កាលមុនមួយឲ្យបានជាក់លាក់តាមដែលអាចធ្វើទៅបាន។

ដូច្នេះ យើងខ្ញុំសូមឆ្លៀតយកឱកាសនេះ ដើម្បីផ្តល់នូវការធានាជូនអង្គជំនុំជម្រះថា សហមេធាវីនាំមុខ ហើយនិងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺកំពុងតែមានការព្រួយបារម្ភនៅក្នុងការតាក់តែង ឬបង្កើតនូវសំណើសុំសំណងដែលមានលក្ខណៈរឹងមាំតាមផ្លូវច្បាប់ ហើយនិងមានផែនការច្បាស់លាស់។

[០៩:២៨:២០]

ដូច្នេះ អាណត្តិរបស់យើងគឺត្រូវតែធ្វើការស្នើសុំសំណងជាសមូហភាព និងតាមផ្លូវចិត្ត តាំងនាមឲ្យដើមបណ្តឹងរដ្ឋប្បវេណីយោងទៅតាមវិធាន២៣ នៃវិធានផ្ទៃក្នុង។ ដូច្នេះយើងខ្ញុំសូមបញ្ជាក់ម្តងជាថ្មីទៀតថា ការកំណត់ ហើយនិងការបង្កើតនូវសំណងទាំងអស់នេះ គឺវាជាតួនាទីរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ដោយមានការជួយជ្រោមជ្រែងពីអង្គភាពផ្សេងៗដែលខ្លួនធ្វើការជាមួយ ដូចជាអង្គភាពគាំពារជនរងគ្រោះ អង្គការក្រៅរដ្ឋាភិបាល ហើយនិងការជំនួយពីរដ្ឋាភិបាលផងដែរ។

[០៩:២៩:៥២]

ដូច្នេះ យើងសូមឆ្លើយតបទៅនឹងសេចក្តីប្រកាសរបស់អង្គជំនុំជម្រះនៅក្នុងអនុស្សរណៈ ចុះថ្ងៃទី២៣ កញ្ញា ដែលក្នុងគឺបានបញ្ជាក់ថា វិធានការដែលបានស្នើសុំដំបូងនោះ គឺមិនមានភាពគ្រប់គ្រាន់នោះទេ ហើយគឺថាវាមិនមាន លក្ខណៈឲ្យមានខ្លឹមសារគ្រប់គ្រាន់ទេនៅក្នុងដំណាក់កាលនេះ។

ដូច្នេះ សហមេធាវីនាំមុខ ហើយនិងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមបញ្ជាក់ថា វិធាន៨០ស្ទួន នៃវិធានផ្ទៃក្នុង គឺតម្រូវឲ្យខ្លួនបញ្ជាក់តែជាបឋមអំពីខ្លឹមសារនៃសំណងនោះតែប៉ុណ្ណោះ ហើយក្នុងវិធាននេះទៀត ហាក់ដូចជាមិនបានបញ្ជាក់ថា អង្គជំនុំជម្រះ គឺមិនអាចមានធ្វើអន្តរាគមន៍ទៅក្នុងការធ្វើផែនការ ឬក៏អាចបង្ហាញនូវសេចក្តីសម្រេច ឬក៏មានការសង្កេតអីមួយទៅលើលក្ខណៈនេះដែរ។

ដូច្នេះ យើងសូមបញ្ជាក់បន្ថែមទៀតថា ដើមបណ្តឹងរដ្ឋប្បវេណី គឺជាភាគីដាច់ដោយឡែក និងមានឯករាជ្យនៅក្នុងការដំណើរការក្តីនៅចំពោះមុខ អ.វ.ត.ក ។ ទោះបីជាយើងយល់ថា ការរៀបចំផែន

ការជាមុននោះមានលក្ខណៈសំខាន់ក៏ដោយ ហើយទោះបីជាយើងដឹងថា សំណងនេះ គឺត្រូវតែធ្វើឡើងនៅមុនពេលធ្វើសវនាការនេះក៏ដោយ ក៏យើងដឹងថា ក៏យើងផ្តល់សារៈសំខាន់ទៅលើបញ្ហាច្បាប់ និងអាចអនុវត្តបានដែលអាចប៉ះពាល់ទៅដល់ការអភិវឌ្ឍន៍សំណង ដូចដែលបានទាមទារដោយដើមបណ្តឹងរដ្ឋប្បវេណី ហើយនៅដំណាក់កាលនេះ នៅពេលដែលដំណើរការមិនទាន់បាននិយាយអំពីការប្រកាសពីពិរុទ្ធភាព ឬភាពគ្មានទោសនោះ គឺយើងវាពិបាកណាស់ក្នុងការពិភាក្សាឲ្យលម្អិតអំពីផែនការ ដែលត្រូវពាក់ព័ន្ធទៅនឹងគម្រោងទាំងអស់នេះ។

[០៩:៣១:៣២]

ហើយក្រោយពីសំណុំរឿង០០១ មក គឺយើងមានការធ្វើបណ្តឹងសាទុក្ខ ហើយកំពុងតែនៅក្នុងចំណាត់ការរបស់អង្គជំនុំជម្រះតុលាការកំពូល ទោះបីជាមានការផ្លាស់ប្តូរទៅលើវិធានផ្ទៃក្នុង ដែលមានការផ្លាស់ប្តូរទៅលើវិធានសំខាន់មួយចំនួននៅក្នុងសំណុំរឿង០០១ ក៏ដោយ ក៏ចំណុចអង្គច្បាប់មួយចំនួនក៏នៅដដែល ហើយក៏មិនមានការប៉ះពាល់ដល់ការផ្លាស់ប្តូរនេះដែរ ហើយក៏វាអាចមិនមានការពាក់ព័ន្ធទៅនឹងសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលដែរ។ វិធានច្បាប់ គឺចង់ឲ្យភាគីទាំងអស់ជជែកតវ៉ា ហើយនិងរិះគន់ទៅលើសេចក្តីសម្រេច ដែលបង្កើតបានជាច្បាប់ជាមូលដ្ឋានមួយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលគាត់អត់អាចប្រើប្រាស់បាន ហើយយើងនឹងបង្ហាញអំពីការមិនព្រមព្រៀងរបស់យើង។

[០៩:៣២:១៩]

ការលំបាកទីមួយ គឺថានៅសំណុំរឿងដែល០០១ នោះ ដែលមានពាក់ព័ន្ធនឹងសំណងនោះ អង្គជំនុំជម្រះមិនបានបង្ហាញអំពីសំអាងហេតុ ឬក៏មូលដ្ឋានគតិយុត្តនោះទេ ហើយដោយគ្មានការបង្ហាញបែបនេះ ដើមបណ្តឹងរដ្ឋប្បវេណី គឺថាគាត់ពិបាកក្នុងការធ្វើសម្មតិកម្មពាក់ព័ន្ធទៅនឹងការវិភាគដល់អង្គជំនុំជម្រះអាចធ្វើបានទៅលើសំណងទាំងអស់នេះ។ ដូច្នេះវាមានអត្ថទោសទៅដល់មេធាវីនៅក្នុងបេសកកម្មរបស់ខ្លួននៅក្នុងការការពារផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយក៏វាផ្ទុយទៅនឹងបទប្បញ្ញត្តិមួយចំនួននៃច្បាប់អន្តរជាតិ និងវិធានផ្ទៃក្នុងដោយធានានូវសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបាននូវសំណង។

[០៩:៣៣:០២]

ដូច្នេះ ខ្ញុំសូមបញ្ជាក់ជូនអង្គជំនុំជម្រះថា អង្គជំនុំជម្រះហាក់ដូចជាមានការបកស្រាយមួយដែលមានលក្ខណៈចង្អៀតទៅលើសញ្ញាណនៃសំណងសមូហភាពនិងផ្លូវចិត្ត ហើយអ្វីដែលនេះ អ្វីទាំងអស់

នេះ គឺយើងគិតថា វាមានលក្ខណៈបុគ្គល ហើយនិងហិរញ្ញវត្ថុ។

ជាថ្មីម្តងទៀត យើងប្រើពាក្យហាក់ដូចជានេះ ពីព្រោះថា អង្គជំនុំជម្រះ គឺថាមិនបានបង្ហាញនូវសំអាងហេតុជាក់លាក់នោះទេនៅក្នុងសាលក្រមរបស់ខ្លួននោះ ហើយបញ្ហាពាក់ព័ន្ធទៅនឹងការបង្កើតមូលនិធិស្ម័គ្រចិត្ត ហើយនិងវិធាននៅក្នុងសំណងដែលទាមទារឲ្យមានការឯកភាពពីរដ្ឋាភិបាលនោះ គឺថាទាមទារឲ្យមានការយល់ព្រមពីរដ្ឋាភិបាល ហើយកំពុងតែត្រូវបាន មានចំណាត់ការនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ ហើយនៅលើចំណុចនេះ មេធាវីក៏បានបង្ហាញថា នៅក្នុងសំណុំរឿង០០១ នេះអង្គជំនុំជម្រះ គឺថាមិនបានដោះស្រាយទៅលើបញ្ហាបង្កើតមានមូលនិធិសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ហើយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះ ចង់ឲ្យតុលាការកំពូល គឺប្រកាសសាលដីកាទៅលើការទាមទារនេះ។

[០៩:៣៤:១៨]

ទៅលើបញ្ហាទីពីរ គឺពាក់ព័ន្ធទៅនឹងវិធានការដែលតម្រូវឲ្យមានការឯកភាពពីរដ្ឋាភិបាលកម្ពុជា គឺថាចំណុចនេះត្រូវបានបដិសេធទៅដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តី ឌុច ហើយដែលគាត់ចាត់ទុកថា វាខុស វាក្រៅពីយុត្តាធិការរបស់ អ.វ.ត.ក។ ហើយជាថ្មីម្តងទៀត មេធាវីបានធ្វើបណ្តឹងសាទុក្ខដែលបញ្ជាក់ថា ប្រសិនបើតុលាការមិនមានយុត្តាធិការក្នុងការបង្គាប់ឲ្យមានសំណងទៅលើរដ្ឋាភិបាលកម្ពុជានោះទេ គឺខ្លួនអាចបង្គាប់ឲ្យជនជាប់ចោទមានវិធានការពាក់ព័ន្ធនឹងសំណងនេះ ហើយអាចទាមទារឲ្យមានការជួយជ្រោមជ្រែងពីរដ្ឋាភិបាល ហើយម្យ៉ាងវិញទៀតមេធាវីសូមរំឭកថា សិទ្ធិក្នុងការទទួលសំណងនេះគឺថាមានចែងនៅ --មានទទួលស្គាល់នៅច្បាប់អន្តរជាតិ ហើយព្រះរាជណាចក្រកម្ពុជា គឺថាគាត់មានកាតព្វកិច្ចផ្លូវច្បាប់ក្នុងការផ្តល់នូវសំណងទៅដល់ជនរងដែលទទួលរងនៅក្នុងរបបខ្មែរក្រហម។

អង្គជំនុំជម្រះតុលាការកំពូល គឺកំពុងតែចាត់វិធានការទៅលើបញ្ហាទាំងអស់នេះដើម្បីឲ្យមានលក្ខណៈច្បាស់លាស់ ហើយវាគឺជាបញ្ហាមួយទៀតដែលមានលក្ខណៈសំខាន់ណាស់សម្រាប់សហមេធាវីនាំមុខ ហើយនិងមេធាវីម្នាក់នោះដែលកំពុងតែបង្កើត ហើយនិងបញ្ជាក់នូវសំណង សំណើសុំសំណងនៅក្នុងសំណុំរឿង០០២ បន្ទាប់ពីសំណុំរឿង ឌុច។

ហើយនៅក្នុងបណ្តឹងសាទុក្ខនោះ គឺមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់យ៉ាងច្បាស់ថា អង្គជំនុំជម្រះមិនបានប្រាប់ជូនទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីនូវលក្ខណៈវិនិច្ឆ័យនៃការទទួលយកសំណើ

ដើម្បីទទួលបានសំណងនេះទេ។ ហើយចាប់ពីពេលដែលទទួលបាននូវការទាមទារបែបនេះ គឺថាវាគ្មានមូលដ្ឋានច្បាប់នោះទេនៅក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។ ហើយទោះបីជាថា កម្រិតនៃភាពជាក់លាក់នៅតែជាបញ្ហាមួយដែលបើកចំហ ដែលតាមរយៈនោះគឺអង្គជំនុំជម្រះតុលាការកំពូលអាចនឹងផ្ដល់នូវធាតុផ្សំមួយដែលមានលក្ខណៈសំខាន់។ ហើយនៅពេលដែលយើងអនុវត្តស្ដង់ដារខ្ពស់ពេកនៅក្នុងសំណុំរឿង០០១ នោះគឺអង្គជំនុំជម្រះរំលោភទៅលើសិទ្ធិទទួលបានសំណងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

[០៩:៣៦:១៧]

ដូច្នេះ យើងខ្ញុំសូមស្នើឲ្យតុលាការដកស្រង់នូវការអនុវត្តនៃតុលាការអន្តរជាតិផ្សេងទៀតទាំងនៅក្នុងតំបន់និងអន្តរជាតិទាក់ទងទៅនឹងបញ្ហាសំណងនេះ។ ឧទាហរណ៍ ដូចជារបស់តុលាការសិទ្ធិមនុស្សអន្តរអាមេរិក ហើយនិងតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ដូច្នេះ យើងកំពុងតែរង់ចាំនូវសាលាដីការបស់តុលាការកំពូលទៅលើបញ្ហានេះ ហើយយើងសង្ឃឹមថា សេចក្ដីបញ្ជាក់ដែលអង្គជំនុំជម្រះតុលាការកំពូលនឹងចេញនោះគឺថា នឹងជាការវិភាគទានមួយយ៉ាងសំខាន់ទៅដល់ការងារបង្កើតសំណង ហើយនិងការធ្វើឲ្យសំណងនោះមានភាពលក្ខណៈជាក់លាក់ល្អនោះ។

ហើយបន្ថែមទៅលើទឡ្ហីករណ៍ដែលបានបញ្ជាក់ជូននៅក្នុងនេះ គឺថាវាមានមូលហេតុបន្ថែមមួយទៀត ដោយសារគិតថា គឺវាមិនមានលក្ខណៈសមស្របនោះទេនៅក្នុងដំណាក់កាលនេះដែលទាមទារឲ្យដើមបណ្ដឹងរដ្ឋប្បវេណីបង្ហាញជាស្ថាពរទៅលើសំណង សំណើសុំសំណង ហើយនិងពីគំនូសបំព្រួញ ឬក៏ផែនការជាក់លាក់នៃសំណងទាំងអស់នេះ។ ដូច្នេះ យើងកំពុងតែរង់ចាំនូវសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលដើម្បីឲ្យមានព័ត៌មានជាក់លាក់ថា តើយើងត្រូវធ្វើបែបណាពាក់ព័ន្ធទៅនឹងសំណងរបស់យើងនេះ។

[០៩:៣៧:២១]

ដូច្នេះពេលនេះខ្ញុំនឹងនិយាយអំពីផលវិបាកទៅលើដើមបណ្ដឹងរដ្ឋប្បវេណីអំពីដីកាដែលបានបំបែកកិច្ចនីតិវិធី។ អង្គជំនុំជម្រះសាលាដំបូងបានចេញកាលពីថ្ងៃទី២២ កញ្ញា នូវដីកាមួយពាក់ព័ន្ធនឹងការបំបែកនីតិវិធីដោយយោងតាមវិធាន៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង ដែលក្នុងនោះអង្គជំនុំជម្រះបាននិយាយថា បំបែកបទចោទនៅក្នុងសំណុំរឿង០០២ ហើយនិងបែងចែកទៅជាសំណុំតូចៗ ហើយនៅក្នុងសំណុំរឿងទាំងអស់នោះគឺថា វាកាបែងចែកគ្នារវាងបទចោទ ហើយនិងមានបញ្ហាគតិយុត្តផ្សេងៗគ្នា។

ដូច្នេះ អង្គជំនុំជម្រះបានសម្រេចថា ដំណាក់កាលជំនុំជម្រះដំបូងនៅក្នុងសំណុំរឿង០០១ នោះគឺ

និយាយតែពីលើការចោទប្រកាន់ពីអង្គហេតុដែលពាក់ព័ន្ធទៅនឹងការជម្លៀសដោយបង្ខំប្រជាជន នៅក្នុងដំណាក់កាលទីមួយ ទីពីរ ហើយនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយលើកលែងទៅនឹងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា។

[០៩:៣៨:២១]

នៅពេលធ្វើបែនេះ គឺអង្គជំនុំជម្រះបានដកចេញនូវសហករណ៍ ការដ្ឋានការងារ មន្ទីរសន្តិសុខ ហើយនិងមន្ទីរពិឃាត ហើយដែល គឺអង្គហេតុទាំងនោះគឺវាពាក់ព័ន្ធទៅនឹងការជម្លៀសទៅនឹងដំណាក់កាលទីបី ហើយអង្គជំនុំជម្រះក៏ដកចេញនូវបទចោទពាក់ព័ន្ធទៅនឹងប្រល័យពូជសាសន៍ ហើយនិងការរំលោភធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩។

អង្គជំនុំជម្រះក៏-- ផ្ទុយទៅវិញ បានបញ្ជាក់ថាខ្លួនរក្សាសិទ្ធិក្នុងការបញ្ចូលគ្រប់ពេលទាំងអស់នូវការពិនិត្យនូវបទចោទផ្សេងទៀតនៅក្នុងក្របខ័ណ្ឌនៃការជំនុំជម្រះដំបូងនេះ ក្នុងលក្ខខណ្ឌដែលថាត្រូវតែគោរពសិទ្ធិក្នុងការការពារខ្លួន។

[០៩:៣៨:៥៨]

សហព្រះរាជអាជ្ញាបានដាក់នូវសំណើមួយដើម្បីឲ្យពិនិត្យឡើងវិញទៅលើដីកាបំបែកនីតិវិធីនេះនៅថ្ងៃទី១៤ តុលា ហើយសំណើនេះគឺថា បើតាមអ្នកច្បាប់របស់អង្គជំនុំជម្រះចុះថ្ងៃទី១៤ តុលា នោះបាននិយាយថា ថ្ងៃទី១៨ តុលា ដើមបណ្តឹងរដ្ឋប្បវេណី គឺបានជូនដំណឹងអំពីការស្នើសុំឲ្យមានការពិនិត្យឡើងវិញ ហើយដែលមានការគាំទ្រដោយផ្អែកទៅលើសំណើរបស់សហព្រះរាជអាជ្ញា។ ហើយការ--បើតាមតុលាការគឺថា ការណ៍នេះ គឺការបំបែកនីតិវិធីនេះ វាកម្រិតនូវការពិនិត្យទៅលើអង្គហេតុ។

ហើយដែលជាកម្មវត្ថុនៃការជំនុំជម្រះដំបូងនោះ ហើយវាអត់មានផលបះពាល់អីទៅលើខ្លឹមសារនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅក្នុងដំណាក់កាលនេះទេ ហើយវាក៏មិនមានពាក់ព័ន្ធអីទៅលើរបៀបដែលដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំសំណងតាំងនាមឲ្យដើមបណ្តឹងរដ្ឋប្បវេណីនោះដែរ។

នៅក្នុងការបដិសេធចំពោះសំណើសុំលើកពេលសវនាការនេះ អង្គជំនុំជម្រះបានទទួលស្គាល់ថាដីកាបំបែកនីតិវិធីនេះ គឺថាអាចមានផលប៉ះពាល់ទៅលើសំណង។ ដូច្នេះ យើងបាននិយាយថា ផលប៉ះពាល់នេះ វាមិនមែនជាលទ្ធភាពនោះ គឺវាច្បាស់លាស់តែម្តង។ វិធាន២៣ ស្ទួនបួន(២) ចំណុច(ខ) ចង់ឲ្យសារណាដែលបង្ហាញអំពីសំណើសំណងនោះ គឺថាបញ្ជាក់ថា--

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមរំឭកដល់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលជំនួសឲ្យសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានខិតខំនូវការធ្វើបទបង្ហាញរបស់ខ្លួន ប្រាសចាកឆ្ងាយអំពីខ្លឹមសារនៃរបៀបវារៈ ដែលអង្គជំនុំជម្រះកំណត់ឲ្យមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីលើកយកមកបង្ហាញនៅក្នុងសវនាការនេះហើយ។ សវនាការនេះ មិនជជែកពិភាក្សាអំពីកិច្ចដំណើរការនីតិវិធីនៃការបំបែកកិច្ចដំណើរការសវនាការនោះទេ។

[០៩:៤១:១៩]

បញ្ហាទីពីរ គឺសូមឲ្យមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីធ្វើការចូលមកក្នុងរបៀបវារៈដែលអង្គជំនុំជម្រះបានកំណត់ឲ្យធ្វើ គឺបង្ហាញអំពីរូបភាពនៃសំណងដែលខ្លួនទាមទារ។ ដោយហេតុថានៅក្នុងបទប្បញ្ញត្តិនៃវិធានដែលបានធ្វើវិសោធនកម្មតម្រូវឲ្យធ្វើដូច្នេះ ដើម្បីក្នុងគោលបំណងការពារនូវឧត្តមប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ដែលមានការពាក់ព័ន្ធនៅក្នុងរឿងក្ដីនេះ។

យើងជាប្រធានអង្គជំនុំជម្រះសង្ឃឹមថា មេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីយល់ច្បាស់អំពីការកំណត់នូវរបៀបវារៈនៅក្នុងការដែលលើកឡើងយកមកឲ្យជជែកពិភាក្សានៅក្នុងសវនាការនីមួយៗដោយដីកាកំណត់កាលបរិច្ឆេទសវនាការបានកំណត់ច្បាស់លាស់នូវរបៀបវារៈនៃបញ្ហាដែលត្រូវជជែកពិភាក្សា និងពេលវេលាដែលបានកំណត់រួចហើយ។

[០៩:៤២:៤៥]

ដូច្នេះ សុំមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសម្របសម្រួលជាមួយនឹងមេធាវីតំណាងរបស់ខ្លួនដែលប្រគល់សិទ្ធិឲ្យលើកឡើងចំបញ្ហាក្នុងករណីមិនមានទេ សូមបញ្ជាក់ឲ្យច្បាស់លាស់ ថាមិនមានរបាយការណ៍ពាក់ព័ន្ធនឹងបញ្ហាហ្នឹងទេ នោះអង្គជំនុំជម្រះនឹងបន្តនូវរបៀបវារៈផ្សេងទៀត ដែលជារបៀបវារៈទីពីរបន្ទាប់ពីរបៀបវារៈនេះទៅ ដើម្បីកាត់បន្ថយនូវពេលវេលាដែលលើកឡើងដោយនូវការណាមួយ ដែលវាប្រាសចាកទៅនឹងរបៀបវារៈដែលបានកំណត់។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន យើងបានស្ដាប់នូវការកំណត់ស្គាល់របស់លោកប្រធានហើយ។ យើងគិតថា នៅពេលនេះ គឺយើងគឺស្ថិតនៅក្នុងក្របខ័ណ្ឌនៃដីការបស់លោកចៅក្រម គឺយើងផ្ដល់នូវការសង្កេតបឋម។ ដូច្នេះ យើងមិនទាន់អាចបង្កើតនូវសំណងដោយមិនយោងទៅលើក្របខ័ណ្ឌដែលបានផ្ដល់ឲ្យយើងនោះ

ទេ។ ដូច្នេះ យើងគិតថា បញ្ហាដែលយើងបានលើកឡើងទាំងអស់នេះ គឺជាបញ្ហាដែលកំណត់នូវក្របខ័ណ្ឌគតិយុត្ត ហើយនិងមធ្យោបាយនៅក្នុងការបង្កើតសំណងទាំងអស់នេះ។ ហើយនៅផ្នែកខាងមុខនេះ គឺថាយើងនឹងនិយាយអំពីការបង្ហាញអំពីគម្រោងនីមួយៗដែលយើងនឹងផ្តល់ជូននូវអង្គជំនុំជម្រះ ហើយយើងនឹងផ្តល់ជូននូវការបញ្ជាក់បន្ថែមដែលមានលក្ខណៈបច្ចេកទេស ហើយនិងមានលក្ខណៈទៅតាមបរិបទបន្តិច។

[០៩:៤៤:២០]

ដូច្នេះ យើងនឹងត្រូវតែបង្ហាញអំពីក្របខ័ណ្ឌច្បាប់នៃសំណងទាំងអស់នេះ ដូចដែលបានសរសេរនៅក្នុងវិធានផ្ទៃក្នុង ហើយក៏ដូចបានអង្គជំនុំជម្រះបានរំឭកនៅក្នុងអនុស្សរណៈ E125 ដែលបានលើកយោងទៅលើសំណុំរឿង០០១ ហើយនិងបរិបទនីតិវិធីដែលតម្រូវឲ្យយើងធ្វើដូច្នេះ គឺថាសាលដីកា គឺថាវាមានលក្ខណៈមិនច្បាស់លាស់ទៅលើការចង្អុលបង្ហាញជាបឋមទៅលើសំណងទាំងអស់នេះ។ ដូច្នេះសុំឲ្យខ្ញុំ យើងខ្ញុំបន្តទៅទៀត ហើយខ្ញុំសូមបញ្ជាក់ជូនអង្គជំនុំជម្រះថា បរិបទនីតិវិធីនេះគឺថាជិតចប់ទៅហើយ គឺថាយើងសល់តែប៉ុន្មានភាគដែលយើងត្រូវតែបន្តបញ្ចប់បន្តិចទៀតនេះនោះទេ។ ហើយបន្តិចទៀត យើងនឹងនិយាយអំពីប្រភេទនៃសំណង ហើយចំណុចចុងក្រោយនេះ គឺខ្ញុំចង់បញ្ជាក់ជូនអង្គជំនុំជម្រះ ដូចក្នុង ខ្ញុំបាននិយាយនៅក្នុងសេចក្តីផ្តើមរួចហើយថា អ្វីដែលនិយាយនៅពេលព្រឹកនេះ គឺមិនកើតចេញពីគំនិតរបស់បុគ្គលណាមួយ គឺវាកើតចេញពីគំនិតរបស់សមូហភាពនៃដើមបណ្តឹងរដ្ឋប្បវេណី ហើយវាជាគំនិតរួម ហើយវាកើតចេញពីការសហការគ្នារវាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់។

ដូច្នេះ ខ្ញុំចង់ឲ្យអង្គជំនុំជម្រះទុកសិទ្ធិឲ្យយើងបញ្ចប់នូវអ្វីដែលយើងចង់និយាយនេះ គ្រាន់តែប៉ុន្មាននាទីបន្ថែមទេ។ ខ្ញុំគិតថា វាមានការលំបាកណាស់នៅក្នុងការនិយាយអំពីសំណង ដោយមិនបានលើកឡើងអំពីផលវិបាកនៃដីកាបំបែកនីតិវិធីនេះ។ សូមអរគុណលោកប្រធាន។

[០៩:៤៦:០៥]

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានលើកឡើងនេះ។ ប៉ុន្តែអង្គជំនុំជម្រះនៅតែប្រកាន់ជំហរជាក់លាក់ថា មិនអនុញ្ញាតឲ្យលោកស្រី និងមេធាវីការពារនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីទទួលសិទ្ធិនៅក្នុងការលើកឡើងនូវបញ្ហាពាក់ព័ន្ធនឹងការធ្វើការនីតិវិធី នៃការបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿងនោះទេ។

យើងមិនចង់បញ្ជាក់អីវែងឆ្ងាយទេ ដោយសារអង្គជំនុំជម្រះប្រកាន់ជំហរច្បាស់លាស់នៅក្នុងការគ្រប់គ្រងកិច្ចដំណើរការនីតិវិធី សម្រាប់ដំណើរការរឿងក្តីដ៏ធំធេង ដ៏ស្មុគស្មាញនេះ ដើម្បីឲ្យវាទៅមុខតាមរបៀបវារៈដែលធ្វើការកំណត់ក្នុងការធ្វើសវនាការនីមួយៗ។

ទីពីរ ពេលវេលាគឺមានកំណត់នៅក្នុងមួយព្រឹកនេះ គឺយើងធ្វើទាំងការបង្ហាញរបស់ភាគីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើបញ្ហានេះ ហើយនិងមានពេលវេលាខ្លះដើម្បីឲ្យភាគីដទៃទៀតធ្វើការកត់សម្គាល់លើទម្រង់នៃការប្តឹងទាមទារសំណង ដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់មួយព្រឹកនេះ។ អ៊ីចឹងហើយបានជាការគ្រប់គ្រងវេលាត្រូវតែច្បាស់លាស់ ដើម្បីច្បាស់លាស់លុះត្រាតែភាគីដែលពាក់ព័ន្ធនឹងរឿងក្តីនៅក្នុងកិច្ចដំណើរការ មិនមែនតែសវនាការនេះទេ សវនាការទៅមុខក៏ដូចគ្នា ត្រូវក្តាប់ឲ្យបាននូវរបៀបវារៈនៃការដាក់ឲ្យអនុវត្ត ឲ្យជជែកពិភាក្សាដំណាក់កាលនៃសវនាការនីមួយៗច្បាស់លាស់ ដើម្បីចៀសវាងការលើកឡើងចំណាយពេលវេលាដែលឥតប្រយោជន៍ដែលខុសពីរបៀបវារៈដែលបានកំណត់។

[០៩:៤៧:៥៥]

អ៊ីចឹងគឺច្បាស់លាស់ហើយ មិនអនុញ្ញាតឲ្យនិយាយក្រៅពីប្រធានបទដែលកំណត់នេះទេ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ដូច្នេះ ខ្ញុំមិននិយាយអ្វីអំពីដីកានៃកិច្ចបំបែកនីតិវិធីនេះទេ។ ដូច្នេះយើងគិតថា យើងមានរយៈពេលបីម៉ោង ដូច្នេះយើងមិននិយាយឲ្យហួសម៉ោងនេះទេ។ យើងនិយាយទៅតាមការពន្យល់បង្ហាញរបស់យើងតទៅទៀត។ សូមអរគុណ។

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

លោក លោកស្រីចៅក្រម លោកប្រធាន ខ្ញុំនឹងនិយាយទៅលើបញ្ហានៃការដំណើរការពិគ្រោះយោបល់។ ដូចបានសង្កេតឃើញសហមេធាវីនាំមុខ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺកំពុងតែពិភាក្សាពិគ្រោះយោបល់ជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី ១.៧០០នាក់ ដែលបានបញ្ចូលបន្ថែមនៅចុងខែមិថុនា។ ហើយការពិភាក្សានេះគឺថាកំពុងតែបន្ត ទោះបីជាមានឧបសគ្គពាក់ព័ន្ធទៅនឹងខាងការទំនាក់ទំនង ការដឹកជញ្ជូន ហើយវាមិនអាចលឿន ហើយឬក៏ស្រួលដែរ ទោះបីជាមានការលំបាកយ៉ាងណាក៏ដោយ គឺថាយើងព្យាយាមធ្វើម៉េចឲ្យមានការពិគ្រោះយោបល់ពេញលេញទៅលើដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់។

[០៩:៤៩:១៣]

នៅក្នុងដំណើរការពិគ្រោះយោបល់នេះ គឺថាយើងគិតថា វាជាធាតុមួយដែលមិនអាចជំនួសបាន នៃសំណង ដែលថាដើមបណ្តឹងរដ្ឋប្បវេណីគាត់មានសិទ្ធិ ហើយគាត់មានបង្ហាញនូវមនោសញ្ចេតនា ដែលថាគាត់ពេញចិត្តចំពោះតុលាការនេះ ហើយគាត់នឹងពេញចិត្តចំពោះយុត្តិធម៌។

សហមេធាវីនាំមុខ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីគឺថា គាត់មានភាពធានាក្នុងចិត្តពាក់ព័ន្ធទៅនឹងសារៈសំខាន់ដែលខ្លួនបានផ្តល់ទៅលើដំណើរការពិគ្រោះយោបល់ ដែលបានផ្តល់ជូនទៅដល់ច្បាប់ជាតិនិងអន្តរជាតិ។

ពាក់ព័ន្ធទៅនឹងបញ្ហានេះហ្នឹង នៅក្នុងកថាខណ្ឌ១១ នៃគោលការណ៍ជាមូលដ្ឋាន និងសេចក្តីណែនាំពាក់ព័ន្ធទៅនឹងសិទ្ធិក្នុងការទទួលបានដំណោះស្រាយ និងសំណង នៃជនជាប់ចោទដែលនៃការរំលោភដ៏ធ្ងន់ធ្ងរទៅលើសិទ្ធិអន្តរជាតិ និងសិទ្ធិមនុស្ស ហើយគឺថាបើបានលើកឡើងហើយអំពីសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបាននូវយុត្តិធម៌ ក្នុងលក្ខខណ្ឌសមភាព ហើយនិងទទួលបានព័ត៌មានចាំបាច់ពាក់ព័ន្ធទៅនឹងការរំលោភ និងយន្តការនៃសំណង។ អង្គការអន្តរជាតិ *អ៊ីនធឺ សិនធឺ ហ្វ័រ ត្រេនស៊ី ស៊ិនណល ចាស្ទីស*(និយាយភាសាអង់គ្លេស) បានបញ្ជាក់យ៉ាងច្បាស់ថា គឺវិធានការសំណងគឺកើតចេញពីការពិគ្រោះយោបល់ពិតប្រាកដជាមួយនឹងជនរងគ្រោះ ដែលមានឱកាសក្នុងការទទួលបាននូវយុត្តិធម៌ និងទទួលបាននូវប្រសិទ្ធភាព។

[០៩:៥០:២៩]

សហមេធាវីនាំមុខនិងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី នឹងបន្តពិភាក្សាជាមួយដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្របខ័ណ្ឌនៃដំណើរការពិគ្រោះយោបល់ ដោយគោរពទៅលើតួនាទីរបស់គាត់ក្នុងនាមជាភាគីនៅក្នុងរឿងក្តី ហើយនិងធ្វើយ៉ាងណាផ្តល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីទទួលបាននូវសំណាងក្នុងការទទួលឃើញនូវអ្វីដែលខ្លួនចង់បាន នៅពេលដែលខ្លួនបានចូលរួមនៅក្នុងដោះស្រាយនូវការបង្កើតសំណើសុំសំណងនេះ។ នៅពេលដែលយើងធ្វើដំណើរការតាមរបៀបនោះ គឺថាយើងមិនបានប៉ះពាល់ទៅដល់ការបង្ហាញសំណងដែលមានលក្ខណៈត្រឹមត្រូវ និងមានបញ្ជាក់ហេតុផលនៅចំពោះមុខអង្គជំនុំជម្រះទាំងនេះ។ ហើយទាំងអស់នេះ គឺវាពង្រឹងនូវឱកាសដែលថាវិធានការទាំងអស់នេះ គឺថាអាចត្រូវបានទទួលយកបាននៅចំពោះមុខច្បាប់។

[០៩:៥១:១៣]

លោក លោកស្រីចៅក្រម លោកប្រធាន ខ្ញុំសូមបញ្ចប់នូវការកត់សម្គាល់នេះ ហើយខ្ញុំសូមផ្ដល់វេទិកានេះជូនទៅសហភាតារបស់ខ្ញុំ គឺលោក អង្គ ពេជ។ ខ្ញុំសូមអរគុណដែលលោក លោកស្រីបានស្ដាប់ខ្ញុំ ហើយសូមបញ្ជាក់ថា ខ្ញុំនិយាយនេះក្នុងតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ១.៤០០នាក់ មិនមែនតែ២០០នាក់ជាង ដែលខ្ញុំទទួលបានអាណត្តិក្នុងការតំណាងឲ្យទេ គឺតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ដែលមានវត្តមាននៅក្នុងដំណើរការនេះ។

ដូច្នេះ គឺថាដើមបណ្ដឹងរដ្ឋប្បវេណី គាត់ធ្វើយ៉ាងឲ្យគេទទួលស្គាល់គាត់នៅក្នុងតុលាការនេះ ហើយគាត់នឹងមានការសង្ឃឹមថា នឹងទទួលបាននូវយុត្តិធម៌នៅក្នុងតុលាការនេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ពេជ អង្គ!

[០៩:៥២:០២]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អស់លោក លោកស្រី សាធារណជន និងព្រះសង្ឃគ្រប់ព្រះអង្គដែលមានវត្តមាននៅទីនេះ។ ជាបន្តទៀត យើងខ្ញុំសូមផ្ទេរជាបឋមជូនលោកមេធាវី សំ សុគង់ ដើម្បីលើកអំពីចម្លើយទៅនឹងសេចក្ដីសង្កេតរបស់អង្គជំនុំជម្រះអំពីការបង្ហាញជាបឋមអំពីប្រភេទសំណងដែលមេធាវីនាំមុខ មានបំណងស្នើសុំនៅក្នុងពាក្យសុំចុងក្រោយ ជូនទៅលោក សំ សុគង់ ហើយបន្ទាប់មកខ្ញុំបាទនឹងបន្តដោយធ្វើបច្ចុប្បន្នភាព និងផ្ដល់ជូនជាព័ត៌មានបន្ថែមពាក់ព័ន្ធទៅនឹងសេចក្ដីបញ្ជាក់បឋមនៃសំណងនេះជូនអង្គជំនុំជម្រះ។

អ៊ីចឹង សូមអនុញ្ញាតជូនលោក សុគង់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី សុគង់!

[០៩:៥៣:១១]

**លោក សំ សុគង់៖**

ជាបឋម ខ្ញុំបាទសូមគោរពលោកប្រធានក្រុមប្រឹក្សា សូមគោរពក្រុមប្រឹក្សា និងសូមគោរពអង្គសវនាការទាំងមូល។ ខ្ញុំបាទមេធាវី សំ សុគង់ ជាមេធាវីការពារឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ នៅក្នុង អ.វ.ត.ក។ ខ្ញុំបាទសូមធ្វើសេចក្ដីឆ្លើយតបទៅនឹងសេចក្ដីសង្កេតរបស់អង្គជំនុំជម្រះ

អំពីការបង្ហាញបឋមអំពីប្រភេទនៃសំណងដែលមេធាវីនាំមុខ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមានបំណងស្នើសុំនៅក្នុងពាក្យសុំចុងក្រោយ។

[០៩:៥៣:៥៤]

នៅក្នុងអនុស្សរណៈរបស់ខ្លួននៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះបានកំណត់នូវក្របខ័ណ្ឌដែលខ្លួនចង់កំណត់ពាក់ព័ន្ធទៅនឹងដំណើរនៃការស្នើសុំសំណង។ អង្គជំនុំជម្រះបានបង្ហាញអំពីការសង្កេតបឋម អំពីការបញ្ជាក់បឋមអំពីសំណង ដែលមេធាវីនាំមុខបានបង្ហាញនៅពេលសវនាការបឋម។

យើងឆ្លៀតឱកាសនេះដើម្បីឆ្លើយតបទៅនឹងសេចក្តីនៃការអង្កេតទាំងនេះ និងផ្តល់ការបញ្ជាក់បន្ថែមដែលយើងនឹងមានបំណងស្នើសុំ និងបញ្ជាក់អំពីកង្វល់របស់តុលាការ និងបញ្ហានានាដែលបានលើកឡើងនៅក្នុងការបង្ហាញបឋមអំពីសំណងរបស់ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចសហមេធាវីនាំមុខទាំងពីរ។

ទីមួយ យើងនិយាយអំពីការសហការជាមួយដៃគូ។ ទាំងមេធាវីនាំមុខ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដឹងថា តាមរយៈវិធានផ្ទៃក្នុងបន្ទុក និងការដាក់ តាក់តែងគម្រោងនានា គឺមិនស្ថិតនៅលើមេធាវីនាំមុខតែប៉ុណ្ណោះនោះទេ។

ជាការពិតអង្គភាពគាំពារជនរងគ្រោះ មានតួនាទីផងដែរនៅក្នុងការរៀបចំអនុវត្តវិធានមិនមែនបច្ចេកទេសតុលាការ និងរៀបចំគម្រោងសំណងនានា ដោយសហការជាមួយអង្គការអន្តរការី ស្របតាមវិធាន១២ ស្ទួន និងវិធាន២៣ ស្ទួនបី(ខ)។

ដោយមូលហេតុនេះហើយ ជាច្រើនខែមកហើយ ទន្ទឹមនឹងការសម្របសម្រួលនានាលើបញ្ហាផ្នែកច្បាប់ និងសំណុំរឿងមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានជួបប្រជុំផ្លាស់ប្តូរយោបល់ជាច្រើនលើកជាមួយនឹងប្រធានគម្រោងសំណងរបស់អង្គភាពគាំពារជនរងគ្រោះ។ ដោយសារការសម្រេចសម្របសម្រួលពីអង្គភាពគាំពារជនរងគ្រោះ ការងារកំណត់នូវគម្រោងសំណង និងភាពដែលអាចធ្វើបាននៃសំណងត្រូវបានលើកឡើង។

[០៩:៥៦:១៩]

ជាការពិតសំណងទាំងអស់នោះអាចត្រូវបានរៀបចំឡើងតាមរយៈគម្រោង ឬកម្មវិធីដោយសហការជាមួយសង្គមស៊ីវិល អាជ្ញាធររាជរដ្ឋាភិបាល និងម្ចាស់ជំនួយនានា។ អង្គភាពគាំពារជនរងគ្រោះ បានសហការយ៉ាងជិតស្និទ្ធពាក់ព័ន្ធទៅនឹងការរៀបចំ និងការអនុវត្តគម្រោង ការសហការរបស់

យើងទាំងពីរអង្គភាពកំពុងបន្ត និងត្រូវបន្តនៅពេលដែលអនាគត។ ក៏ប៉ុន្តែយើងត្រូវដឹងថា ភារកិច្ចដែលត្រូវផ្ដល់ឲ្យមេធាវីនាំមុខ និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជាដល់អង្គភាពគាំពារជនរងគ្រោះគឺជាកិច្ចការយ៉ាងច្រើន ដែលមិនអាចមានពីមុនមកនៅក្នុងតុលាការអន្តរជាតិ។

អាណត្តិអំពីសំណងដែលត្រូវផ្ដល់ឲ្យយើងខ្ញុំជាធម្មតា គួរត្រូវអនុវត្តដោយអង្គភាពជំនាញដែលមានបុគ្គលិកជាច្រើន ថវិកាជាច្រើន ពេលវេលា និងបទពិសោធន៍ជាច្រើន។

ដើម្បីធានានូវការរៀបចំគម្រោងឲ្យបានលឿន឵ឆាប់រហ័ស ដែលមិនមែនជាគម្រោងជានិមិត្តរូប និងមានអត្ថន័យដល់ដើមបណ្ដឹងរដ្ឋប្បវេណីបាន វាគួរតែអង្គភាពគាំពារជនរងគ្រោះមានក្រុមធ្វើការមួយដែលមានបុគ្គលិកគ្រប់គ្រាន់។ ចំណុច(ខ) ការបង្កើតមូលនិធិសំណង។

នៅក្នុងអនុស្សរណៈថ្ងៃទី២៣ កញ្ញា ឆ្នាំ២០១១ របស់អង្គជំនុំជម្រះបានបញ្ជាក់ថាការបង្កើតមូលនិធីសំណងក៏ដូចជាសំណងជាថវិការបស់ឯកជនមិនចូលនៅក្នុងក្របខ័ណ្ឌនៃសំណងដែលបានផ្ដល់ឡើងដោយ អ.វ.ត.ក ឡើយ។ នេះគឺជាចំណុចដែលយើងមាននៅក្នុងសាលក្រមរបស់ ឌុច និងនៅក្នុងវិធាន ២៣ ស្ទួនមួយ,៤(១), វាហាក់ដូចជាថា យើងយ៉ាងហោចណាស់ក៏យើងមិនអាចឈរលើមូលដ្ឋានមួយក្នុងចំណោមទាំងពីរនេះ ដើម្បីបដិសេធ ការស្នើសុំថវិកាជួសជុលសំណងដែលត្រូវបានបង្កើតឡើងជាក់លាក់ដើម្បីផ្ដល់ជាថវិកាទៅដល់សំណង សំណងជាដែលត្រូវ ជាផ្លូវច្បាប់អាចធ្វើទៅបាននោះទេ។

[០៩:៥៨:៤៨]

យើងខ្ញុំសូមបញ្ជាក់ថា អ្វីដែលយើងខ្ញុំស្នើសុំ គឺការបង្កើតនូវអង្គភាពមិនមែនរដ្ឋាភិបាលមួយ ឬក៏អង្គភាពដែលមានលក្ខណៈពាក់កណ្ដាលរដ្ឋាភិបាលមួយ ឬមានទម្រង់ដែលនឹងត្រូវបង្កើតឡើងដូចជាក្នុងនាមជាអង្គភាពឯករាជ្យ និងដាក់ដោយឡែកពីក្របខ័ណ្ឌនៃ អ.វ.ត.ក។ ក្របខ័ណ្ឌរបស់វានឹងមានគោលដៅអនុវត្ត និងផ្ដល់មូលនិធីដើម្បីធានាការអនុវត្តគម្រោងសំណងនេះ ដែលសម្រេចដោយតុលាការនេះ គម្រោងនេះនឹងត្រូវលើកឡើងលម្អិតដោយលោកស្រីមេធាវី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត នាពេលក្រោយ។

ចំពោះចំណុច(គ) ចំពោះវិធានការដែលតម្រូវឲ្យមានការឯកភាពពីរាជរដ្ឋាភិបាល។ ឆ្លើយតបចំពោះផ្នែកមួយនៃអនុស្សរណៈថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ដែលតាមរយៈអង្គជំនុំជម្រះបានសង្កេតឃើញថា វិធានមួយចំនួនដែលលើកឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណីអាចស្ថិតនៅខាងក្រៅក្របខ័ណ្ឌនៃវិធានដែលអាចតម្រូវបាន អនុញ្ញាតដោយ អ.វ.ត.ក ដោយសារវាឋិតនៅក្នុងវិស័យនៃសមត្ថកិច្ច

របស់អាជ្ញាធររាជរដ្ឋាភិបាល។ នៅក្នុងកថាខណ្ឌដដែល អង្គជំនុំជម្រះបានលើកឡើងដូចជា ការបង្កើតឡើងនូវថ្ងៃអនុស្សាវរីយ៍ ដែលមិនអាចសម្រេចបានដោយអង្គជំនុំជម្រះ ដោយមូលហេតុនៅក្នុងនាមជាសំណងត្រូវមានការសម្រេច និងត្រូវអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា។

មេធាវីនាំមុខសូមកត់សម្គាល់ដោយពេញចិត្តថា អង្គជំនុំជម្រះបានទទួលស្គាល់ថា សំណើបឋមដែលបានលើកឡើងនេះ ប្រសិនបើត្រូវការឲ្យមានការអនុញ្ញាតជាផ្លូវការ ឬការព្រមព្រៀងពីរាជរដ្ឋាភិបាលវាមិនត្រូវការជាចាំបាច់ពីសកម្មភាពណាមួយពីរាជរដ្ឋាភិបាលនោះទេ។ សកម្មភាពទាំងអស់នេះត្រូវអនុញ្ញាតដោយយ៉ាងពេញលេញដោយវិធានផ្ទៃក្នុងមុន ហើយនៅក្នុងអត្ថបទវិធានផ្ទៃក្នុងបច្ចុប្បន្ននៃវិធាន២៣ ស្ទួនបី(ខ) និយាយថា អង្គជំនុំជម្រះអាចទទួលស្គាល់នូវទម្រង់ជាក់លាក់ ដែលជាចម្លើយសមស្របទៅនឹងសំណើសុំសំណងដែលរៀបចំឡើង ឬកំណត់ដោយសហការជាមួយនឹងអង្គភាពការពារជនរងគ្រោះ។ ចំពោះគម្រោងដូចជាការបង្កើតនូវថ្ងៃរំឭកវិញ្ញាណក្ខន្ធ យើងនឹងមិនស្នើសុំថា អង្គជំនុំជម្រះកំណត់ឲ្យបានឲ្យមានការអនុវត្តពីរាជរដ្ឋាភិបាលនោះទេ។

[១០:០១:៤៨]

ផ្ទុយទៅវិញ មានការខំប្រឹងប្រែងពីអង្គភាពគាំពារជនរងគ្រោះ ក្នុងការទំនាក់ទំនងជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ច ដើម្បីទទួលបាននូវថ្ងៃបែបនេះមុននឹងសម្រេចពេលចុងក្រោយ ទៅដល់ការដាក់លើកជាគម្រោងសុំឲ្យមានការទទួលស្គាល់ពីតុលាការ ចៀសវាងការមិនទទួលស្គាល់ពីតុលាការ។

ចំពោះវិធានផ្ទៃក្នុង វាមានសមស្របទៅនឹងភារកិច្ចដែលថា មេធាវីនាំមុខបង្ហាញអំពីសំណើសុំទាក់ទងទាំងអស់នេះ និងអង្គជំនុំជម្រះទទួលស្គាល់សំណើទាំងនេះ។

ការបញ្ជាក់បន្ថែមសម្រាប់វិធាននានាដទៃទៀត នៅក្នុងអនុស្សរណៈថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ដូចខាងក្រោម៖

[១០:០២:៥២]

សំណើនានាផ្សេងៗទៀត ដែលស្នើសុំមិនមានភាពជាក់លាក់គ្រប់គ្រាន់ ដើម្បីអាចធ្វើសេចក្តីសង្កេតដោយមានអត្ថន័យបានឡើយនៅក្នុងដំណាក់កាលនេះ។ ចម្លើយនេះមានធាតុពីរដែលនាំឲ្យមានការផ្តល់ចម្លើយ។ ជាបឋម គឺនិយមន័យនៃពាក្យជាក់លាក់គ្រប់គ្រាន់ បន្ទាប់មកគឺជាការដែលចាំបាច់ ឬសមស្របឲ្យអង្គជំនុំជម្រះបង្ហាញអំពីសេចក្តីសង្កេត ឲ្យមានអត្ថន័យនៅក្នុងដំណាក់កាលនេះ។ ដោយមិនទាន់បានទទួលនូវសេចក្តីសម្រេច របស់អង្គជំនុំជម្រះតុលាការកំពូលក្នុងករណី០០១ មេធាវីនាំមុខ

និងមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី មិនអាចយោងទៅសាលក្រមករណី០០១ ឬក៏វិធានផ្ទៃក្នុង ដើម្បីកំណត់អំពីក្របខ័ណ្ឌនៃគម្រោងដើម្បីឲ្យវាមានភាពជាក់លាក់បានឡើយ។

[១០:០៣:៤៥]

នៅក្នុងករណី ឌុច អង្គជំនុំជម្រះបាននិយាយនៅក្នុងកថាខណ្ឌដូចតទៅៈ “ដើម្បីឲ្យមានសំណងមួយអាចត្រូវបានផ្តល់ជាដំបូងត្រូវបញ្ជាក់ឲ្យបានច្បាស់អំពីប្រភេទនៃវិធានការដែលបានស្នើសុំ”។ នៅក្នុងសេចក្តីសម្រេចទាក់ទងទៅនឹងបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះបានបដិសេធសំណើសុំនៃដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន ដោយមូលហេតុខ្វះភាពជាក់លាក់ និងទោះបីជាយ៉ាងណាក៏ដោយអង្គជំនុំជម្រះមិនបានបង្ហាញអំពីអ្វីដែលជាសំណើមានលក្ខណៈជាក់លាក់គ្រប់គ្រាន់នោះឡើយ។ គួរកត់សម្គាល់ថា វិធានផ្ទៃក្នុងកំណែប្រែទីបី ឬក៏ទោះជាសេចក្តីណែនាំពាក់ព័ន្ធនីតិវិធីនៅក្នុងការដាក់នីតិវិធីនៃសំណងនិងការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរចុងក្រោយក៏ដោយ ក៏មិនមានកំណត់នូវលក្ខណៈវិនិច្ឆ័យ ការបញ្ជាក់ឲ្យបានជាក់លាក់នោះឡើយ។

[១០:០៤:៤៧]

ជាការពិត អង្គជំនុំជម្រះមិនបានបង្ហាញនូវវិធានណាមួយ យុត្តិសាស្ត្រណាមួយ ឬក៏ប្រភេទគតិយុត្តណាមួយដើម្បីអនុញ្ញាតឲ្យលាតត្រដាងនូវការពិចារណានានាដែលអនុញ្ញាតឲ្យមានការជឿជាក់លាក់អំពីភាពជាក់លាក់ន័យនោះបានទេ។ ផ្ទុយទៅវិញ វាជាការពិតដែលថា វិធានផ្ទៃក្នុង វិធានកែប្រែទី៨ ប្រើប្រាស់នៅពាក្យបញ្ជាក់បន្ថែមនិងជាក់លាក់ ហើយមិនបានផ្តល់នូវសញ្ញាណ ការពន្យល់ពាក្យ ឬក៏ពន្យល់និយមន័យនូវអ្វីដែលបង្កើតបានជាពាក្យសុំជាក់លាក់គ្រប់គ្រាន់នោះឡើយ ហើយអង្គជំនុំជម្រះក៏មិនបានផ្តល់នូវការបកស្រាយរបស់ខ្លួនទាក់ទងទៅនឹងចរិតលក្ខណៈ ដើម្បីអនុវត្តនោះផងដែរ។

នៅក្នុងអនុស្សរណៈថ្ងៃទី២៣ កញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះបានរំឭកដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណី អំពីកាតព្វកិច្ចនៅក្នុងការបង្ហាញជាបឋមនៃសំណងម្តងទៀត ដោយមិនបានផ្តល់និយមន័យនៃពាក្យ ឬក៏បំភ្លឺផ្សេងៗឡើយ។ ដោយមិនមានការបញ្ជាក់ពីអង្គជំនុំជម្រះ ឬក៏វិធានផ្ទៃក្នុងឲ្យបានច្បាស់លាស់ ដើមបណ្តឹងរដ្ឋប្បវេណីមានការកំណត់សម្គាល់ជាក់លាក់ ឬក៏មានទិសដៅជាក់លាក់ ដើម្បីរៀបចំពាក្យសុំសំណងរបស់ខ្លួនឲ្យស្របទៅនឹងការទន្ទឹងរង់ចាំរបស់អង្គជំនុំជម្រះឡើយ។

[១០:០៦:២៧]

ដើមបណ្តឹងរដ្ឋប្បវេណីអាចបញ្ជាក់អំពីទីកន្លែងដែលត្រូវសាងសង់ស្តូប ឬចេតិយនានា តម្លៃនៃ

ការសាងសង់ អ្នកណាជាអ្នកផ្តល់មូលនិធិ ខ្លឹមសារនៃកម្មវិធី ដែលពេលនេះយើងមិនអាចផ្តល់បាន ប៉ុន្តែអាចផ្តល់នៅក្នុងពាក្យសុំចុងក្រោយ។ ហើយដែលជាពិសេសទៅទៀត វាគ្មានអំណះអំណាងផ្នែកផ្លូវច្បាប់ណាមួយ ឬក៏ចរិតលក្ខណៈជាក់លាក់ជាលក្ខណៈអន្តរជាតិអ្វីនោះទេ។

វិធាន៩៥ វិធាននីតិវិធី និងភស្តុតាងរបស់តុលាការអន្តរជាតិ បង្ហាញថា តុលាការអន្តរជាតិត្រូវផ្តល់នូវការជាក់លាក់អំពីសំណើនានានៃសំណង។

យោងតាមវិធានផ្ទៃក្នុងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ វិធាន៩៤(១)(ខ)នេះ ពាក្យសុំសំណងត្រូវតែមានការអត្ថាធិប្បាយអំពីការខូចខាត ការបាត់បង់ ព្យសនកម្ម ក៏ដូចជាពាក្យសុំ ការស្តារនីតិសម្បទា ឬក៏សំណងដែលមានទម្រង់អ្វីផ្សេងទៀត។

គ្មានកន្លែងណាមួយដែលតម្រូវឲ្យមានពាក្យសុំ មានលក្ខណៈជាក់លាក់គ្រប់គ្រាន់ ឬក៏មានការផ្តល់ឲ្យមានភាពជាក់លាក់ត្រូវបានប្រើប្រាស់នោះទេ យោងតាមវិធាននេះ។ វាជាក់ច្បាស់ណាស់ថា នៅក្នុងករណីដែលមានពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី មានភាពចាំបាច់យោងទៅលើព្យសនកម្ម អង្គជំនុំជម្រះត្រូវបានទទួលថា វាអាចទទួលយកបាន។ វិធានទាំងអស់នេះ មិនទាន់ត្រូវយកមកអនុវត្តនៅឡើយនៅក្នុងការអនុវត្តជាក់ស្តែង និងវាអត់ទាន់មានយុត្តិសាស្ត្រដែលអនុញ្ញាតឲ្យបកស្រាយថាតើតុលាការព្រហ្មទណ្ឌអន្តរជាតិបកស្រាយចរិតលក្ខណៈដែលអនុវត្តទៅនឹងពាក្យសុំនៃសំណង ឬយ៉ាងណានោះទេ។

ដូច្នេះវានៅតែជាព្យដែលគ្មានភាពច្បាស់លាស់គ្រប់គ្រាន់នៃវិធានផ្ទៃក្នុង ហើយពាក្យសុំសំណងមិនអាចត្រូវតម្រូវឲ្យឆ្លើយតបទៅនឹងចរិតលក្ខណៈខ្ពស់នៃភាពជាក់លាក់នោះបានទេ។

[១០:០៨:៤៦]

ខុសពីតុលាការព្រហ្មទណ្ឌអន្តរជាតិ តុលាការអន្តរអាមេរិកាំងនៃសិទ្ធិមនុស្សបានផ្តល់នូវយុត្តិ-សាស្ត្រផ្ទុយទៅនឹងចរិតលក្ខណៈខ្ពស់មែនទែននៃភាពជាក់លាក់ដែលតម្រូវឲ្យចៅក្រមសាលាដំបូង។ តាមរយៈយុត្តិសាស្ត្រនេះនៃតុលាការជាន់ខ្ពស់អាមេរិកាំង ជនរងគ្រោះមិនចាំបាច់ស្នើសុំសំណងដោយបញ្ជាក់ឲ្យមានភាពជាក់លាក់ខ្ពស់នេះទេ។ ដូចជានៅក្នុងសំណុំរឿង *ម៉ាពីរីផាន ម៉ាស់សាគ្រឺ. ៥* (Mapiripán Massacre. v ) កូឡុំប៊ី ចៅក្រមបានសន្និដ្ឋានដូចខាងក្រោម៖

ដោយពិនិត្យឃើញភាពធ្ងន់ធ្ងរនៃអង្គហេតុនៅក្នុងករណីនេះដែលមានដូចជាអំពើមនុស្សឃាដោយចេតនា ការបាត់ខ្លួន និងការបញ្ជូនមនុស្សដោយបង្ខំនៃជនជាតិ *ម៉ាពីរីផិន* (Mapiripán) ស្ថានភាព

នៃទិដ្ឋភាពទាក់ពាក់ព័ន្ធនៃចារីភាពធ្ងន់ធ្ងរនៃការឈឺចាប់ដែលបង្កើតមានដល់ជនរងគ្រោះ។ ការប្រែប្រួលយ៉ាងខ្លាំងក្នុងលក្ខខណ្ឌរស់នៅ និងផលវិបាកសេដ្ឋកិច្ច និងហិរញ្ញវត្ថុផ្សេងៗទៀត។ វាហាក់ដូចជាចាំបាច់តាមលក្ខខណ្ឌសមធម៌ក្នុងការផ្តល់សំណងផ្នែកហិរញ្ញវត្ថុ អាស្រ័យទៅតាមព្យសនកម្មតែមិនមានលក្ខណៈហិរញ្ញវត្ថុ។

នៅក្នុងសេចក្តីសម្រេចនេះ ចៅក្រមបាននិយាយថា រដ្ឋត្រូវតែស្ថាបនានៅក្នុងរយៈពេលមួយឆ្នាំនូវស្តូបសមស្រប និងមានលក្ខណៈថ្លៃថ្នូរជាការរំឭកអនុស្សាវរីយទៅដល់ការស្លាប់ ការសម្លាប់រង្គាលដល់ពួក *ម៉ាពីរីផិន* ដែលត្រូវបង្កើតឡើងនៅក្នុងទីកន្លែងសាធារណៈនៅ *ម៉ាពីរីផិន* ។

[១០:១០:៤៧]

ចៅក្រមមិនបានបង្ខំឲ្យជនរងគ្រោះនៅក្នុងការផ្តល់នូវការបញ្ជាក់បន្ថែមពាក់ព័ន្ធទៅនឹងចំនួនប្រភេទនៃស្តូប រំឭកវិញ្ញាណក្ខន្ធដែលបានសាងសង់នោះឡើយ។ ទោះបីជាកន្លែងដែលត្រូវសាងសង់ ឬក៏តម្លៃដែលបញ្ជាក់បន្ថែមនោះក៏ដោយមិនដូចនៅក្នុងករណី០០១ ដែលអង្គជំនុំជម្រះបានឆ្លើយតបទៅនឹងពាក្យសុំស្រដៀងគ្នានេះអំពីស្តូប និងចេតិយដែលស្នើសុំដោយភាគីដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។

ដោយហេតុថា អង្គជំនុំជម្រះមិនបានបញ្ជាក់ដល់និយមន័យនូវអ្វីដែលខ្លួនបាននិយាយអំពីភាពជាក់លាក់គ្រប់គ្រាន់ ឬក៏ឲ្យមានការជាក់លាក់ ហើយដោយហេតុថា--

**ប្រធានអង្គជំនុំ៖**

ឈប់មេធាវីសម្រាកបន្តិច!

សូមអញ្ជើញ!

[១០:១១:៤៨]

**លោក សុន អរុណ៖**

សូមគោរពលោកប្រធាន កូនក្តីខ្ញុំ មានមិនស្រួលខ្លួនដោយមានការឈឺក្បាលខ្លាំងពីយប់មិញគាត់សម្រាន្តមិនលក់ ហើយឈាមឡើងដល់ ប្រាំ-ប្រាំមួយដណ្តប់ ប៉ុន្តែព្រឹកនេះគាត់ព្យាយាមនឹងមករួម ប៉ុន្តែឥឡូវគាត់ឈឺក្បាលខ្លាំង សូមចាកចេញពីកន្លែងបន្ទប់សវនាការដើម្បីទៅសម្រាក ដោយអនុគ្រោះបាទ។

**ប្រធានអង្គជំនុំ៖**

បាទ, អង្គជំនុំជម្រះយល់ព្រមតាមការស្នើសុំនេះ ដោយហេតុថានេះជាការចូលរួមដោយមានការអនុញ្ញាត។ អ៊ីចឹងគឺ ដោយសារមានមូលហេតុបញ្ហាសុខភាព។ អ៊ីចឹងគឺអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់

ចោទ នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញចុះ ហើយដោយមិនបាច់នាំគាត់មកទៀតទេនៅក្នុងដំណើរការសវនាការសម្រាប់ថ្ងៃនេះ និងថ្ងៃស្អែក។ ប៉ុណ្ណឹងចុះ។

សូមអញ្ជើញលោកមេធាវីបន្តបទបង្ហាញ!

[១០:១៣:០៧]

**លោក សំ សុគង់៖**

បាទ, សូមអរគុណលោកប្រធាន។

ដោយហេតុថា អង្គជំនុំជម្រះមិនដែលបានបញ្ជាក់ដល់និយមន័យនៅអ្វីដែលខ្លួនបាននិយាយអំពីភាពជាក់លាក់គ្រប់គ្រាន់ ឬក៏ឲ្យមានការជាក់លាក់ ហើយដោយហេតុថា វាក្យខណ្ឌទាំងនេះមិនដែលមានពីមុនមកនៅក្នុងច្បាប់អន្តរជាតិ។

ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែទាយថាតើអ្វីដែលខ្លួនត្រូវបង្ហាញ ដើម្បីបំពេញចិត្តទៅនឹងចរិតលក្ខណៈដែលកំណត់ដោយអង្គជំនុំជម្រះ? ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវមានការទទួលខុសត្រូវបន្ថែមពីបញ្ហានេះឡើយ។ តែទោះជាយ៉ាងណាក៏ដោយ សំណាងដែលដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិទទួលកំពុងមានបញ្ហា ហើយសំណាងនេះត្រូវមានព័ត៌មានគ្រប់គ្រាន់អំពីអ្វីដែលចៅក្រមកំពុងចង់បាន ហើយវាត្រូវតែស្របទៅនឹងច្បាប់អន្តរជាតិ។

[១០:១៤:០៧]

វិធានដែលស្ថិតនៅក្នុងក្របខ័ណ្ឌគតិយុត្តនៃ អ.វ.ត.ក ដើម្បីបញ្ជាប់អំពីប្រភេទចុងក្រោយនៃពាក្យសុំទាក់ទងទៅនឹងសំណង អង្គជំនុំជម្រះបានផ្តល់នូវសេចក្តីសង្កេតពាក់ព័ន្ធទៅនឹងវិធានការដែលអង្គជំនុំជម្រះពិនិត្យឃើញថាស្ថិតនៅក្នុងក្របខ័ណ្ឌគតិយុត្តនៃ អ.វ.ត.ក វាអាចមានការផ្សព្វផ្សាយនៃសាលក្រមនៅក្នុងករណី០០២ និងការប្រមូលផ្តុំនូវបញ្ជីនៃដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់។

ទាំងមេធាវីនាំមុខ ក៏ដូចជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីឯកភាពគ្នាថា នេះគឺជាចំណុចចាប់ផ្តើមដែលមានតម្លៃខ្ពស់សម្រាប់សំណងនានា ហើយថាវិធានទាំងនេះស្ថិតនៅក្នុងក្របខ័ណ្ឌគតិយុត្តនៃ អ.វ.ត.ក ហើយវាគួរតែអាចទទួលយកបាននូវក្នុងក្របខ័ណ្ឌនៃករណី០០២។ ស្នើសុំសំណងតែប៉ុណ្ណោះដែលមានលក្ខខណ្ឌកម្រិតធ្ងន់ធ្ងរបំផុត គឺជាការធ្វើឲ្យប៉ះពាល់ដល់គោលការណ៍គតិយុត្តិជាមូលដ្ឋាន ដែលតម្រូវឲ្យមានការជួសជុលសំណងដល់ព្យសនកម្មដែលបានទទួលរងដោយដើមបណ្តឹងរដ្ឋប្បវេណី។ លើសពីនេះទៅទៀត គឺជាវិធានការដែលមានលក្ខណៈឃ្លាតឆ្ងាយពីប្រភេទរួមនានា ដែលបង្កើតឡើង

ក្នុងក្របខ័ណ្ឌនៃវិធានផ្ទៃក្នុង និងក្របខ័ណ្ឌអន្តរជាតិ។

[១០:១៥:៤៥]

ជាគោលការណ៍ចម្បងទាក់ទងទៅនឹងសិទ្ធិក្នុងការទទួល ការប្តឹងទាមទារ ឬការទទួលបាននូវសំណងរបស់ជនរងគ្រោះ ដែលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៃការរំលោភបំពានជាក់ស្តែងនៃច្បាប់អន្តរជាតិស្តីអំពីសិទ្ធិមនុស្ស និងការរំលោភបំពានធ្ងន់ធ្ងរអំពីច្បាប់មនុស្សធម៌អន្តរជាតិបានរំឭកថា៖ "សំណងត្រូវមានតែមានសមាមាត្រនឹងភាពធ្ងន់ធ្ងរនៃការរំលោភបំពាន និងព្យសនកម្មដែលទទួលបាន។ ទោះជាតុលាការនេះប្រឈមមុខទៅនឹងការលំបាកជាច្រើនក៏ដោយ នៅក្នុងការផ្តល់សំណងតុលាការត្រូវតែមានលទ្ធភាព និងអាចផ្តល់សំណងដែលមានសារៈសំខាន់ផ្សេងៗទៀត ក្រៅពីការបោះពុម្ពផ្សាយសាលក្រម ដែលជនជាតិកម្ពុជាជាច្រើនគ្មានលទ្ធភាពក្នុងការទទួលបាន និងការយល់ដឹង"។

ដោយសារដូចខាងសហមេធាវីនាំមុខជាតិគាត់បានលើកពីខាងលើ ខ្ញុំបាទក៏សូមធ្វើបទអន្តរាគមន៍ក៏ដូចជាឆ្លើយតបត្រង់ចំណុចនេះ ហើយនឹងទាក់ទងសំណងជាក់លាក់ និងទុកតួនាទីនេះជូនឲ្យសហមេធាវីនាំមុខជាតិ ដើម្បីគាត់លើកដាក់ជូនទៅអង្គជំនុំជម្រះ ក៏ដូចជាៗអង្គសវនាការទាំងមូលដើម្បីធ្វើការស្តាប់ និងពិចារណាទាំងអស់គ្នា ហើយខ្ញុំទុកតួនាទីនេះជូនដល់ខាងសហមេធាវីជាតិដើម្បីធ្វើការបង្ហាញ។ សូមអរគុណ។

[១០:១៧:០០]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន ខ្ញុំបាទនឹងលើកអំពីព័ត៌មានអំពីបច្ចុប្បន្នភាព និងផ្តល់ការបញ្ជាក់បន្ថែមអំពីគម្រោងនានាដែលមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងស្នើសុំ ក៏ដូចមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែរ ដែលមានបំណងស្នើសុំក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួន។

ជាបន្តទៀតនេះ យើងខ្ញុំត្រូវការសម្រាប់ខ្លួនខ្ញុំមានរយៈពេលម្ភៃនាទី ដើម្បីលើកគម្រោងជាក់លាក់នេះ ចំពោះពាក់ព័ន្ធនឹងបីជំពូក ហើយនៅមួយជំពូកទៀត គឺលោកស្រីមេធាវី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត នឹងលើបន្ថែម។ បន្ទាប់មកលោកស្រីនឹងធ្វើសេចក្តីសន្និដ្ឋាន។

[១០:១៨:១៥]

ពេលនេះម៉ោងដប់ និងម្ភៃនាទីហើយ មិនដឹងថាតើលោកប្រធានចង់ឲ្យខ្ញុំចំណាយពេលម្ភៃនាទីសម្រាប់លើករួច ឬក៏សម្រាក ឬក៏លោកប្រធានចង់ឲ្យខ្ញុំបាទលើកនៅបន្ទាប់ពីពេលសម្រាក?

**ប្រធានអង្គជំនុំ៖**

បាទ, អញ្ជើញលោកមេធាវីបន្តកិច្ចបង្ហាញរបស់លោក។

**លោក ពេជ អង្គ៖**

ជាបន្ត គឺពាក់ព័ន្ធនឹងគម្រោងជាក់លាក់នេះបន្ទាប់ពីបានធ្វើកិច្ចការជាច្រើនជាមួយដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី អង្គភាពគាំពារជនរងគ្រោះ និងអង្គការអន្តរការីជាច្រើនដែលមានចេតនានៅក្នុងការជួយរកសំណងជូនដើមបណ្តឹងរដ្ឋប្បវេណី។ មេធាវីនាំមុខ ក៏ដូចជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានលើករួចមកហើយនូវជំពូកចំនួនបួនពាក់ព័ន្ធទៅនឹងសំណងនេះ ហើយពេលនេះយើងខ្ញុំសាកល្បងនឹងធ្វើ លើកជូនជាគម្រោងជាក់លាក់ដែលអាចធ្វើទៅបាន ដែលក្នុងលទ្ធភាពដែលយើងខ្ញុំអាចធ្វើទៅបាន។

[១០:២០:០៣]

គម្រោងទីមួយ គឺពាក់ព័ន្ធទៅនឹងការរំឭក និងការគោរពវិញ្ញាណក្ខន្ធ ដែលទីពីរមានគម្រោងពាក់ព័ន្ធទៅនឹងការស្តារនីតិសម្បទា ទីបីមានគម្រោងពាក់ព័ន្ធទៅនឹងការចងក្រងឯកសារ និងការអប់រំ។ បន្ទាប់ពីនោះគឺមានគម្រោងពាក់ព័ន្ធទៅនឹងសំណើផ្សេងទៀតដែលត្រូវឲ្យមានការពិចារណាលម្អិតបន្ថែម។ នៅក្នុងប្រភេទផ្សេងៗនៃសំណើទាំងអស់នេះ គេអាចរៀបចំជាគម្រោង ដោយសារថាយើងកំពុងតែពិភាក្សាគ្នានៅឡើយ ហើយអ្វីដែលផ្តល់ជូននៅពេលនេះ គឺជាការអធិប្បាយបឋមអំពីគម្រោងនីមួយៗតែប៉ុណ្ណោះ។

ប្រភេទទីមួយ គឺគម្រោងពាក់ព័ន្ធទៅនឹងការរំឭកនិងការគោរពវិញ្ញាណក្ខន្ធ។ ការរំឭកនិងការគោរពវិញ្ញាណក្ខន្ធនៅក្នុងនោះមានវិធានការនៃសំណងជាច្រើន ដែលមានគោលដៅគោរពវិញ្ញាណក្ខន្ធដល់អ្នកដែលបានស្លាប់ ហើយជាឱកាសមួយដើម្បីឲ្យអ្នកដែលបាននៅរស់ ជាពិសេសដើមបណ្តឹងរដ្ឋ-ប្បវេណីក៏ដូចជាមនុស្សជំនាន់ក្រោយបានពិចារណាអំពីអ្វីដែលបានកើតឡើង ហើយជាពិសេសដល់ការសោកស្តាយដល់អ្នកដែលបានស្លាប់ទៅ។

[១០:២១:៣៦]

ដោយបានធ្វើការច្របាច់បញ្ចូលគ្នានូវសំណើនីមួយៗចំនួន២៨ ដែលដាក់ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សំណើទាំងនោះអាចចាត់ទុកជាអនុប្រភេទផ្សេងៗគ្នា នៃការរំឭកវិញ្ញាណក្ខន្ធដែលក្នុងនោះវាពាក់ព័ន្ធទៅនឹងថ្ងៃនៃការចងចាំ ចេតិយ និងស្តូប ឬបូជនីយដ្ឋាន។ ទីបី គឺការប្រារព្ធពិធី

និងការរក្សាទីកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្ម។ គម្រោងទីមួយ ដំបូងបំផុតមានឈ្មោះថា គម្រោងតស៊ូមតិ ដើម្បីបង្កើតឱ្យមានថ្ងៃចងចាំជាតិ និងអន្តរជាតិ។ គម្រោងនេះបង្កើតឱ្យមានថ្ងៃចងចាំមួយ ដើម្បីឱ្យមានការទទួលស្គាល់ជាអន្តរជាតិនិងជាតិ ហើយការទទួលស្គាល់នេះមានលក្ខណៈជាអចិន្ត្រៃយ៍ ជានិមិត្តរូប ហើយជាការរំឭកនៃការចងចាំនៃឧក្រិដ្ឋកម្ម ដែលបានការឡើងនាសម័យខ្មែរក្រហម។

[១០:២២:៤០]

សំណងនេះនឹងបានជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងអាចជាថ្ងៃមួយដែលនឹងត្រូវកំណត់នៅក្នុងឆ្នាំដែលដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាប្រជាជនកម្ពុជាអាចជួបជុំគ្នា និងរៀបចំពិធីបុណ្យតាមសាសនា ឬក៏មិនមានលក្ខណៈសាសនាសម្រាប់ជនរងគ្រោះ និងសាច់ញាតិទៅតាមជំនឿ និងវប្បធម៌របស់ខ្លួន។ សំណងនេះនឹងត្រូវផ្តល់ប្រយោជន៍ទៅដល់ដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលវាអាចជួយដើមបណ្តឹងរដ្ឋប្បវេណីស្តារនូវសេចក្តីថ្លៃថ្នូរ និងទទួលពីរដ្ឋ និងសហគមន៍អន្តរជាតិ ឱ្យមានការទទួលស្គាល់នូវថ្ងៃជាផ្លូវការមួយនៅក្នុងការគោរពវិញ្ញាណក្ខន្ធ ការធ្វើការបួងសួង និងការរៀបចំពិធីបុណ្យរំឭកដល់អ្នកដែលគាត់ស្រឡាញ់ ហើយដែលបានបាត់បង់ជីវិតទៅ។

[១០:២៣:៣៧]

រហូតមកដល់ពេលនេះមិនទាន់មានការព្រមព្រៀង រវាងតំណាងដើមបណ្តឹងរដ្ឋប្បវេណី ថាថ្ងៃណាមួយឱ្យបានជាក់លាក់នោះទេ។ ក្រុមមេធាវីផ្សេងៗបានស្នើថា គួរតែសមស្របត្រូវបានបង្កើតថ្ងៃចងចាំនេះនៅក្នុងថ្ងៃមួយនៃរយៈពេលនៃភ្ជុំបិណ្ឌ ឬក៏ថ្ងៃ១៧ មេសា ឬក៏ជាថ្ងៃ២០ ឧសភា។ ការពិភាក្សានេះនៅកំពុងតែបន្ត។ ក្រៅពីនោះមានក្រុមមេធាវីមួយចំនួនក៏ចង់ស្នើឱ្យមានការចងចាំសម្រាប់ឧក្រិដ្ឋកម្មមួយចំនួនដែលទទួលរង។ ការពិគ្រោះយោបល់បន្ថែមទៀតនឹងត្រូវការដើម្បីឱ្យគម្រោងនេះកាន់តែរីកចម្រើន និងកំណត់ថ្ងៃមួយឱ្យបានជាក់លាក់ និងកំណត់ពីវិធីនៅក្នុងការគោរពវិញ្ញាណក្ខន្ធជូនជនរងគ្រោះផងដែរ។ គម្រោងនេះត្រូវពាក់ព័ន្ធទៅនឹងអាជ្ញាធរ រាជរដ្ឋាភិបាល ឬក៏សហគមន៍អន្តរជាតិបង្កើតឱ្យមានថ្ងៃជាតិ និង/ឬ ថ្ងៃអន្តរជាតិមួយនៅក្នុងការគោរពវិញ្ញាណក្ខន្ធ។

[១០:២៤:៥១]

ចំណែកគម្រោងទីពីរ នៃសំណងគឺគម្រោងសាងសង់ចេតិយ និង/ឬ ស្តូប ឬបូជនីយដ្ឋាន ដែលមានលក្ខណៈជាសាសនា ឬក៏គ្មានលក្ខណៈជាសាសនា។ គម្រោងនេះត្រូវបានស្នើសុំស្ទើតែគ្រប់ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់។ ការសាងសង់ស្តូបនេះនឹងអាចធ្វើឡើងដើម្បីរម្លឹកដល់

វិញ្ញាណក្ខន្ធរបស់ជនរងគ្រោះដែលផ្តល់ឱកាសដល់ជនរងគ្រោះដែលជាសាច់ញាតិរបស់គាត់ និងក្មេងជំនាន់ក្រោយ ដើម្បីរម្លឹកអំពីជនរងគ្រោះដែលបានបាត់បង់ជីវិតទៅនៅក្នុងរបបខ្មែរក្រហម ក្នុងលក្ខណៈមួយដែលយូរអង្វែង និងជាសមូហភាព។

គោលបំណងនៃសំណងនេះនឹងផ្តល់ជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ក៏ដូចជាជនរងគ្រោះ និងប្រជាជនកម្ពុជាគ្រប់រូប។ ទោះជាយ៉ាងណាក៏ដោយ ក្រុមជាក់លាក់មួយចំនួនត្រូវបានត្រូវតែបានស្តាប់ និងបានផ្តល់លទ្ធភាពឲ្យស្នើសុំឲ្យមានសំណងជាក់លាក់សម្រាប់ប្រយោជន៍ទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ ដូចជាជនរងគ្រោះដែលពាក់ព័ន្ធទៅនឹងការរំលោភបំពានផ្នែកផ្លូវភេទ ឬក៏ជាជនរងគ្រោះដោយសារអំពើអាពាហ៍ពិពាហ៍ដោយបង្ខំ។

[១០:២៦:២៨]

មានការពិភាក្សាមួយចំនួនថាតើទម្រង់នៃសំណងជាក់លាក់អំពីស្តូប ឬក៏ចេតិយ ឬមួយក៏ត្រូវសាងសង់នៅទីកន្លែងណា នៅក្នុងខេត្តណា នៅក្នុងកម្រិតខេត្ត ឬក៏នៅក្នុងកម្រិតស្រុក ឬក៏ឃុំ។ មេធាវីទាំងអស់គ្នានឹងបន្តពិភាក្សាតទៅទៀត ជាពិសេស ក៏គិតផងដែរថាតើនៅក្នុងកន្លែងដែលខ្លួនមានបំណងស្នើសុំសាងសង់នេះមានជនរងគ្រោះពាក់ព័ន្ធចំនួនប៉ុន្មាន?

មិនមានការកំណត់ថា តើសំណងត្រូវបានរៀបចំ និងអនុវត្តបែបណានៅឡើយទេ វាក៏អាចជាការសំណូមពរទៅដល់អាជ្ញាធរ រាជរដ្ឋាភិបាល ដើម្បីឲ្យមានការឯកភាពពីទីកន្លែងដែលត្រូវសាងសង់ចេតិយ ឬស្តូបនេះដែរ។

ខ្ញុំសូមបញ្ជាក់ថា អង្គភាពគាំពារជនរងគ្រោះក៏កំពុងតែធ្វើការងារយ៉ាងសកម្មអំពីបញ្ហារកទីកន្លែងសម្រាប់សាងសង់នេះ ហើយក៏បានទាក់ទងទៅនឹងលោកឯកឧត្តមដែលជាអភិបាលខេត្តមួយចំនួនដែលខ្លួនបានមានឱកាសជួប ហើយក៏មានការឯកភាពមួយចំនួនដែលផ្តល់សេចក្តីសង្ឃឹមទៅដល់ដើមបណ្តឹងរដ្ឋប្បវេណី។

[១០:២៧:៥៦]

ប្រភេទទីបីនៃគម្រោង គឺជាគម្រោងដើម្បីរៀបចំឲ្យមានកម្មវិធីបុណ្យនៅបន្ទាប់ពីថ្ងៃចេញសាលក្រម ឬក៏នៅពេលផ្សេងទៀត។ គម្រោងទាំងនេះកំណត់អំពីការរៀបចំកម្មវិធីបុណ្យបន្ទាប់ពីសាលក្រមចូលជាស្ថាពរ។ វាអាចប្រមូលផ្តុំដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឲ្យគាត់លើកឡើងអំពីការឈឺចាប់ជារួមដោយសារការបាត់បង់សាច់ញាតិរបស់គាត់ ឬក៏សម្តែងអារម្មណ៍របស់គាត់បន្ទាប់ពីមានសាលក្រមចូល

ជាស្ថាពរ។ លើសពីនេះទៅទៀត ត្រូវបានស្នើសុំឲ្យមានការរៀបចំកម្មវិធីបុណ្យនេះផងដែរនៅថ្ងៃចងចាំសម្រាប់រយៈពេលប៉ុន្មានឆ្នាំបន្ទាប់ពីសាលក្រម ឬក៏សេចក្ដីសម្រេចបានចូលជាស្ថាពរ។ ដែលពេលវេលា និងទីកន្លែង និងត្រូវជម្រាបជូននៅពេលក្រោយ។

សំណងទាំងនេះត្រូវផ្ដល់ជាប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណី ដោយពួកគេនឹងត្រូវទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណី ពួកគេនឹងត្រូវបានទទួលជាដើមបណ្ដឹងរដ្ឋប្បវេណីជាសាធារណៈ និងត្រូវផ្ដល់ឱកាសដល់ជនរងគ្រោះ និងអ្នកជំនាន់ក្រោយឲ្យនឹកឃើញអំពីជនរងគ្រោះនាសម័យខ្មែរក្រហមដោយក្នុងទម្រង់ជាសមូហភាព។

មិនទាន់មានការបញ្ជាក់កំណត់ថា តើវិធីនៃសំណងនេះត្រូវរៀបចំឡើង ឬក៏អនុវត្តយ៉ាងណានោះទេ។ អង្គភាពគាំពារជនរងគ្រោះ និងទទួលបន្ទុកក្នុងការរៀបចំកម្មវិធីដំបូងបន្ទាប់ពីមានសាលក្រម។

[១០:២៩:៣៣]

គម្រោងទីបួន ជាគម្រោងចុងក្រោយនៅក្នុងប្រភេទនេះ គឺមានឈ្មោះថា “គម្រោងចូលរួមក្នុងការរក្សាទីកន្លែងឧក្រិដ្ឋកម្ម”។ គម្រោងនេះ គឺមានគោលដៅចូលរួមនៅក្នុងការៀបចំការថែរក្សាកន្លែងឧក្រិដ្ឋកម្មដែលមាននៅក្នុងដីកាដំណោះស្រាយ ក៏ដូចជានៅក្នុងសំណុំរឿងទាំងមូលតែម្ដង។ ហើយវានឹងផ្ដល់ប្រយោជន៍ទៅដល់ដើមបណ្ដឹងរដ្ឋប្បវេណី និងជនរងគ្រោះផងដែរ។

ការរក្សាទីកន្លែងឧក្រិដ្ឋកម្មទាំងនេះ មានសារៈសំខាន់ណាស់ ដើម្បីជាភស្តុតាងឲ្យឃើញស្ដែងអំពីទីកន្លែងណាខ្លះ ដែលអំពើព្រៃផ្សៃទាំងនេះត្រូវបានប្រព្រឹត្តឡើង។

ដើមបណ្ដឹងរដ្ឋប្បវេណីអាចរំឭកវិញ្ញាណក្ខន្ធដល់ព្រលឹងអ្នកដែលបានស្លាប់ ដែលជាសាច់ញាតិ គឺរំឭកដល់សាច់ញាតិរបស់ខ្លួន អំពីការឈឺចាប់នៅក្នុងសម័យនោះ នៅទីកន្លែងដែលមានឧក្រិដ្ឋកម្មនោះកើតឡើង។ លើសពីនេះទៅទៀត កន្លែងនេះ គឺជាទីកន្លែងដែលដើមបណ្ដឹងរដ្ឋប្បវេណីអាចចូលរួមនៅក្នុងការបង្ហាញទៅដល់មនុស្សជំនាន់ក្រោយ ឲ្យយល់ស្គាល់អំពីព្រឹត្តិការណ៍ទាំងឡាយដែលកើតនៅក្នុងសម័យនោះ ហើយកន្លែងនេះគឺជាភស្តុតាងមួយនៃប្រវត្តិសាស្ត្រនាសម័យនោះ។

[១០:៣០:៥២]

ដោយរាជរដ្ឋាភិបាលកម្ពុជាបានចេញសារាចរមួយនៅចុងឆ្នាំ២០០១ ក្នុងគោលដៅថែរក្សាទីកន្លែងពិឃាតមនុស្ស ហើយយើងក៏កំពុងតែធ្វើអត្ថសញ្ញាណជាមួយនឹងអង្គភាពជនរងគ្រោះ ថាតើកន្លែងណាខ្លះដែលគួរតែកំណត់បង្កើតជាគម្រោងសម្រាប់ថែរក្សា ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច។

កិច្ចការនេះកំពុងតែត្រូវបានបន្ត ជាពិសេសអង្គភាពគាំពារជនរងគ្រោះ ក៏បានសហការជាមួយអាជ្ញាធរសាធារណៈ ដើម្បីរៀបចំគម្រោងទាំងអស់នោះ ហើយក៏បានចុះទៅដល់ទីកន្លែងមួយចំនួន ដែលមានឧក្រិដ្ឋកម្មនេះកើតឡើងផងដែរ ដើម្បីរៀបចំគម្រោង។

ពាក់ព័ន្ធទៅនឹងបញ្ហាស្តារនីតិសម្បទា នេះគឺជាជំពូកទីពីរ នៅក្នុងប្រភេទនៃសំណងដែលមេធាវីនាំមុខ ក៏ដូចជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានចេតនានៅក្នុងការស្នើសុំ។ គម្រោងទាំងអស់នោះមានគម្រោងដែលមានគោលដៅសម្រាប់ស្តារនូវសុខភាពផ្លូវចិត្ត និងផ្នែកស្មារតីរបស់ជនរងគ្រោះ ឬក៏សម្រាប់ធ្វើឲ្យធូរស្បើយនូវការឈឺចាប់ ដែលកើតឡើងអំពីព្យសនកម្មនៅក្នុងសម័យខ្មែរក្រហម។

[១០:៣២:២៧]

គម្រោងទីមួយមានឈ្មោះថា “គម្រោងបង្កើតសេវាសុខភាពផ្លូវចិត្ត និងរូបរាងកាយ”។ គម្រោងនេះមានគោលដៅបង្កើតសេវាសុខភាពផ្លូវចិត្តនិងសុខភាពរូបកាយ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលរងការឈឺចាប់ ឬក៏មានជំងឺ ដោយហេតុឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងសម័យខ្មែរក្រហម។ គម្រោងនេះ មានសំណើជាច្រើនដែលនៅក្នុងនោះ មានផងដែរការស្នើឲ្យបង្កើតមជ្ឈមណ្ឌលសុខភាពសម្រាប់មនុស្សចាស់ ដែលរួមមានដើមបណ្តឹងរដ្ឋប្បវេណី ដែលមានវ័យចាស់ជរា។

ការបង្កើតមជ្ឈមណ្ឌលផ្លូវចិត្តសម្រាប់ជនរងគ្រោះ និងការចុះឈ្មោះផងដែររបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកម្មវិធីរដ្ឋដែលមានស្រាប់ ដោយអនុញ្ញាតឲ្យគាត់មានកាតសម្គាល់ជនរងគ្រោះ ដើម្បីទទួលបាននូវសេវាសុខភាពមួយ ដោយមានការចំណាយតិចតួច ឬក៏មិនចាំបាច់ឲ្យពួកគាត់ចំណាយថវិកា។

[១០:៣៣:១៨]

អ្នកដែលទទួលផលប្រយោជន៍នៃគម្រោងនេះ គឺជាដើមបណ្តឹងរដ្ឋប្បវេណី ដែលទទួលរងការឈឺចាប់ និងមានបញ្ហាសុខភាព ដែលជាផលវិបាកនៃឧក្រិដ្ឋកម្ម ដែលបានកើតឡើងនៅក្នុងសម័យនោះ។ គម្រោងនេះ នឹងផ្តល់ផលប្រយោជន៍ដល់ពួកគាត់តាមរយៈការថែរក្សាសុខភាពផ្លូវកាយនិងផ្លូវចិត្ត និងជួយឲ្យពួកគាត់មានការធូរស្បើយមួយចំនួន អំពីការឈឺចាប់ទាំងផ្នែករូបរាងកាយនិងផ្លូវចិត្ត។

គម្រោងទាំងអស់នេះអាចត្រូវបានបង្កើតឡើងនៅក្នុងរចនាសម្ព័ន្ធដែលមានស្រាប់ ដូចជាបច្ចុប្បន្នមានដូចជាអង្គការចិត្តសង្គមអន្តរវប្បធម៌ អង្គការ និងមជ្ឈមណ្ឌលសុខភាពផ្សេងៗទៀតដែលមានដែលអាចចូលរួមនៅក្នុងការសហការ ដើម្បីបំពេញកិច្ចការជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី។

ទោះជាយ៉ាងណាក៏ដោយ ការពិពណ៌នានៃភាពជាក់លាក់នៃគម្រោងទាំងអស់នេះ មិនអាចផ្តល់លើសពីនេះបានឡើយ ហើយនិងអាចផ្តល់ជូននៅពេលក្រោយទៀត។

[១០:៣៤:២៦]

គម្រោងទីពីរ គឺជាគម្រោងគាំទ្រទៅដល់ក្រុមជួយគ្នាទៅវិញទៅមក។ គម្រោងនេះមានគោលដៅជួយដល់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងការលើកឡើងអំពីការឈឺចាប់ និងឈានទៅដល់ការផ្សះផ្សា។ គម្រោងនេះ រួមមានការបង្កើតឲ្យមានបណ្តាញជាក់លាក់សម្រាប់ជនរងគ្រោះ ផ្នែកហិង្សាខាងយេនឌ័រផងដែរ។ គម្រោងនៃសំណងនេះ ផ្តល់ជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលមានបំណងចូលរួមនៅក្នុងកម្មវិធីជួបជុំគ្នា ដែលពួកគាត់អាចចែករំលែកនូវអារម្មណ៍របស់ពួកគាត់ និយាយអំពីរឿងរ៉ាវរបស់គាត់ ដែលនេះជាវិធីមួយដើម្បីបំភ្លេច ឬក៏រំសាយនៃរឿងរ៉ាវដែលមានការឈឺចាប់ ហើយឆ្ពោះទៅរកជីវិតថ្មីមួយដែលជួយឲ្យគាត់មានភាពធូរស្រាលនៅក្នុងផ្លូវចិត្ត ដោយជម្នះការឈឺចាប់។ គម្រោងជួយគ្នាទៅវិញទៅមកត្រូវបានអនុវត្តរួចហើយ ដោយអង្គការចិត្តសង្គមអន្តរវប្បធម៌ ធី.ភី.អូ។ ដូច្នេះ គម្រោងទាំងអស់ដែលនឹងត្រូវបង្កើតឡើង នឹងអាចមានការសហការជាមួយអង្គការអន្តរការី អង្គការមិនមែនរដ្ឋាភិបាលនានា អង្គភាពគាំពារជនរងគ្រោះជាពិសេស ហើយក៏អនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាជនរងគ្រោះផ្សេងទៀតចូលរួម។

[១០:៣៦:៥៩]

នៅក្នុងប្រភេទទីបីនៃសំណង ដែលមេធាវីនាំមុខក៏ដូចជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងនៅក្នុងការស្នើសុំ គឺគម្រោងដែលពាក់ព័ន្ធទៅនឹងការចងក្រងឯកសារ និងការអប់រំ។ គម្រោងប្រភេទទីបីនេះ រួមមានគោលដៅរក្សា និងជំរុញឲ្យមានការយល់ដឹងអំពីប្រវត្តិសាស្ត្រនៅក្នុងសម័យខ្មែរក្រហម និងបទពិសោធន៍នីមួយៗរបស់ជនរងគ្រោះ។

គម្រោងដំបូង គឺគម្រោងបង្កើតឲ្យមានកម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ គម្រោងនេះមានការបញ្ចូលប្រវត្តិសាស្ត្រខ្មែរក្រហម និងឯកសារស្តីពីការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងកម្មវិធីជាតិ រួមទាំងការកសាងមជ្ឈមណ្ឌលអប់រំផងដែរ។ គម្រោងនេះអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីផ្ទេរនូវចំណេះដឹង និងការលើកឡើងអំពីឧក្រិដ្ឋកម្មដែលខ្លួនបានទទួលរងជូនទៅមនុស្សជំនាន់ក្រោយ ហើយបង្ហាញដល់អ្នកទាំងនោះនូវអតីតកាល ដែលនៅក្នុងនោះមានឧក្រិដ្ឋកម្មដែលមិនគួរត្រូវបានបំភ្លេច ហើយដែលគេមិនត្រូវប្រព្រឹត្តបែបនេះតទៅទៀតនៅពេលក្រោយ។

[១០:៣៧:១១]

សំណាង់នេះនឹងផ្តល់ជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងមនុស្សជំនាន់ក្រោយទៀត។ ជាការពិតនៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ នេះ អង្គជំនុំជម្រះបានលើកថា គម្រោងទាំងអស់នេះមានការពាក់ព័ន្ធទៅនឹងអាជ្ញាធរសាធារណៈ។ ជាការពិត គឺពាក់ព័ន្ធទៅនឹងគោលនយោបាយរបស់ក្រសួងអប់រំពិតប្រាកដមែន ហើយក៏រហូតមកដល់ពេលនេះក្រសួងអប់រំក៏បានទទួលនូវគម្រោងប្រភេទនេះនៅក្នុងកម្មវិធីរបស់ក្រសួងអប់រំផងដែរ។ ក៏ប៉ុន្តែវាជាការល្អដែរដែលមានការរៀបចំគម្រោង ក៏ដូចជាកម្មវិធីសិក្សាផ្សេងពាក់ព័ន្ធនឹងសម័យខ្មែរក្រហមនេះបញ្ចូលឲ្យមានលក្ខណៈជាក់លាក់ ដោយមានធនធាន ហើយនិងអ្នកជំនាញស្ថិតនៅក្នុងក្របខ័ណ្ឌនៃគម្រោងរបស់សាលាខ្មែរក្រហមនេះ ដើម្បីផ្តល់ជាជំនួយបន្ថែមទៅដល់ការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ហើយដែលមានលទ្ធភាពនៅក្នុងការស្នើសុំឲ្យមានការចូលរួមជាមួយនឹងអាជ្ញាធរ ដែលពាក់ព័ន្ធនឹងវិស័យអប់រំនេះ។

[១០:៣៨:៣២]

គម្រោងទីពីរ គឺជាគម្រោងតស៊ូមតិ ដើម្បីរៀបចំមជ្ឈមណ្ឌលឯកសារ សារមន្ទីរ បណ្ណសារ និងបណ្ណាល័យ។ គម្រោងទាំងនេះមានគោលដៅបង្កើតឡើងនៅទីកន្លែង ដើម្បីជាប្រយោជន៍ដល់សាធារណជន ក្នុងការទទួលបាននូវឯកសារប្រវត្តិសាស្ត្រ សម្ភារផ្សេងៗដែលមាននៅក្នុងបណ្ណសារ បណ្ណាល័យ សារមន្ទីរ សម្រាប់គោលដៅថែរក្សាសម្ភារទាំងអស់នោះ និងអនុញ្ញាតឲ្យមានការសិក្សារៀនសូត្រស្វែងយល់អំពីរបប និងដំណើរការនៃសាលាក្តីខ្មែរក្រហម។

គម្រោងនេះផ្តល់ឱកាសសម្រាប់ប្រមូលផ្តុំឯកសារអំពីរបបខ្មែរក្រហម និងបង្កភាពងាយស្រួលដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបាននូវព័ត៌មានទាំងនោះ និងការចែករំលែកទៅដល់អ្នកដទៃទៀត។

[១០:៤០:២១]

មជ្ឈមណ្ឌលឯកសារមានតួនាទីនៅក្នុងការប្រមូល រក្សា ធ្វើការវិភាគ បែងចែកឯកសារពាក់ព័ន្ធនឹងរបបខ្មែរក្រហមសម្រាប់សារមន្ទីរ បណ្ណាល័យ មជ្ឈមណ្ឌល ប្រហាក់ប្រហែលក្នុងគោលដៅថែរក្សា និងអនុញ្ញាតឲ្យមានការប្រើប្រាស់ទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីក៏ដូចជាមនុស្សជំនាន់ក្រោយដទៃទៀត។

[១០:៤០:២៧]

សំណងនេះនឹងត្រូវផ្តល់ជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងប្រជាជនកម្ពុជា ជាពិសេសក្មេងជំនាន់ក្រោយក្នុងការអនុវត្ត និងធានាថាឯកសារទាំងអស់នោះនឹងអាចផ្តល់ជាប្រយោជន៍ដល់មនុស្សច្រើនគ្នា ហើយបច្ចុប្បន្ននេះមានអង្គការនានា ជាពិសេសអង្គការ ឌី.ស៊ី.ខេម ដែលកំពុងតែបានធ្វើកិច្ចការមួយចំនួនពាក់ព័ន្ធនឹងបញ្ហានេះ ហើយដោយមានការសហការជាមួយអង្គភាពគាំពារជនរងគ្រោះនៅក្នុងការគិតគូរពិចារណាអំពីបញ្ហាបង្កើតមជ្ឈមណ្ឌលឯកសារនេះ។ ហើយគម្រោងសំណាងនេះនឹងត្រូវបានរៀបចំឡើង និងអនុវត្តសម្រាប់ជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងសហគមន៍នានាក្នុងព្រះរាជាណាចក្រកម្ពុជា។

[១០:៤០:៤០]

គម្រោងទីបី គឺជាគម្រោងដែលមានឈ្មោះថា "បញ្ជីចុះឈ្មោះជនរងគ្រោះ ឬក្រាំងមាស"។ គម្រោងនេះសំដៅបង្កើតឯកសារប្រវត្តិសាស្ត្រដែលរម្លឹកដល់ជនរងគ្រោះ ហើយដែលអ្នកជំនាន់ក្រោយអាចពិនិត្យមើលបាន។ បញ្ជីទាំងនេះអនុញ្ញាតឲ្យមានលទ្ធភាពនៅក្នុងការកត់បញ្ចូលអំពីឈ្មោះនៃជនរងគ្រោះក៏ដូចជាដើមបណ្តឹងរដ្ឋប្បវេណីនៃរបបខ្មែរក្រហមច្រើនដែលអាចធ្វើទៅបាន ហើយអនុញ្ញាតឲ្យមានបញ្ជីធំទូលាយមួយនៃ-- ដែលនៅក្នុងនោះមានលទ្ធភាពនៅក្នុងការកត់បញ្ចូលនូវអង្គហេតុបទឧក្រិដ្ឋដែលកើតឡើងចំពោះជនរងគ្រោះ។ ជនរងគ្រោះទាំងឡាយណាដែលចង់និយាយអំពីរឿងរ៉ាវរបស់ខ្លួន។

[១០:៤១:៣៧]

សំណងនេះនឹងផ្តល់ជាប្រយោជន៍ដល់ជនរងគ្រោះដែលជាដើមបណ្តឹងរដ្ឋប្បវេណីនិងជនរងគ្រោះទាំងឡាយណាដែលមានបំណងចូលរួមទាក់ទងទៅនឹងការអនុវត្តរបស់វា តាមរយៈទម្រង់នៃបញ្ជីដែលបានលើកឡើងផ្សេងៗគ្នានេះ។

ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីស្នើថា សៀវភៅបញ្ជីដ៏ធំទូលាយមួយនឹងត្រូវបញ្ចូលនូវការរៀបរាប់នានារបស់ជនរងគ្រោះ និងអ្នកដទៃទៀត ព្រមទាំងមានបញ្ជីរបស់ជនរងគ្រោះដែលជាបញ្ជីសាមញ្ញដែលមានតែឈ្មោះ ហើយទាំងពីរនេះគឺមានគោលដៅដូចគ្នា។ លើសពីនេះ គេបានត្រៀមថាបញ្ជីជនរងគ្រោះត្រូវរក្សានៅក្នុងទម្រង់ជាសៀវភៅសរសេរដៃ ព្រមទាំងជាទម្រង់សរសេរតាមរយៈរក្សានៅក្នុងអ៊ីនធឺណេតផងដែរ។ ដោយដាក់នៅក្នុងប្រព័ន្ធតុលាការ ទូរនិមិត្តរបស់អង្គជំនុំជម្រះដែលនឹងមាននៅពេលក្រោយទៀតដើម្បីឲ្យមនុស្សជាច្រើនអាចចូលមើលបាន។

[១០:៤២:៣៨]

គម្រោងចុងក្រោយនៃប្រភេទនេះ គឺជាការចុះឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសាលក្រម វាមានគោលដៅស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការបញ្ចូលឈ្មោះពេញលេញផងដែរ របស់ដើមបណ្ដឹងរដ្ឋប្បវេណី និងប្រសិនបើ-- និងទីកន្លែងស្នាក់នៅ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត និងមុខងារ និងការទទួលបានជាដើមបណ្ដឹងរដ្ឋប្បវេណីផងដែរនៅក្នុងសាលក្រម។ ហើយដែលនឹងស្នើសុំឲ្យមានការចែកផ្សាយជាទូលាយពាសពេញផ្ទៃប្រទេសដែលធ្វើឡើងជាប្រយោជន៍ដល់សាធារណជន ដើម្បីឲ្យដឹងពីការរកឃើញរបស់តុលាការ។

[១០:៤៣:១៩]

វិធានការនេះនឹងផ្ដល់ជាប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណីដោយសារវាជាការទទួលស្គាល់អំពីការចូលរួមរបស់ពួកគាត់នៅក្នុងនីតិវិធី។ នេះគឺជាវិធានការមួយក្នុងចំណោមវិធានការសំណងជាច្រើនដែលមាននៅក្នុងករណី០០១ រួចហើយ ហើយវានឹងអាចមានលទ្ធភាពនៅក្នុងការទទួលស្គាល់ដោយអង្គជំនុំជម្រះនៅក្នុងករណី០០២ នេះ។

សូមជម្រាបលោកប្រធាន និងលោក លោកស្រីចៅក្រមទាំងអស់គ្នា ខ្ញុំបានលើកអំពីជំពូកចំនួនបីនៃគម្រោងស្ដីពីសំណងដែលមេធាវីនាំមុខមានបំណងស្នើសុំសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយនៅជំពូកមួយទៀតដែលជាជំពូកផ្សេងៗ និងសេចក្ដីសន្និដ្ឋានដែលនឹងត្រូវលើកឡើងដោយលោកស្រីមេធាវីនាំមុខ អេលីហ្សាបេត ស៊ីម៉ុនណូហ្វត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ឥឡូវនេះឃើញថាដល់ពេលសមល្មមឈប់សម្រាកហើយ អង្គជំនុំជម្រះសាលាដំបូងប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ និងប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

[១០:៤៤:៣៥]

**លោក ឌុច ផារី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១០:៤៥នាទី ដល់ម៉ោង១១:០៩នាទី)*

[១១:០៨:៥៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ! អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធី។

ជាកិច្ចបន្តសូមអញ្ជើញសហមេធាវីអន្តរជាតិ នៃមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីឡើងធ្វើបទបង្ហាញ។ សូមអញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ដូចដែលលោក ពេជ អង្គ បានលើកឡើងហើយខ្ញុំនឹងនិយាយពីផ្នែកក្រោយនៃគម្រោងសំណង ដែលយើងបានចាប់ផ្តើមបង្កើតនោះ។ ចេញពីការពិគ្រោះជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីគឺថា យើងបង្កើតចេញជាគម្រោងជាក់លាក់ ដែលថាមានការឯកភាពទាំងអស់គ្នាហើយនិងឥឡូវនេះចូលទៅនិយមន័យអន្តរជាតិចម្បងនៃសំណង គឺបានន័យថា ការរំឭកអនុស្សាវរីយ៍ការចងចាំ ហើយនិងស្តារនីតិសម្បទា ឯកសារ ហើយនិងការអប់រំ ដែលសហភាតាខ្ញុំបាននិយាយរួចមកហើយ។ បើនៅក្បែរគម្រោងនេះគឺថាមានគម្រោងជាច្រើនទៀត ដែលខ្ញុំមិនប៉ាននិយាយថា វាមានលក្ខណ:ពិសេសនោះទេ ក៏ប៉ុន្តែវាលក្ខណ:ប្លែកពីគេនេះ មិនឱ្យយើងនិយាយឱ្យបានក្បោះក្បាយទេនៅពេលនេះ ដើម្បីបង្ហាញថា វាជាគម្រោងដែលថាអាចប្រភេទ ហើយនិងទ្រង់ទ្រាយនោះយើងបានកំណត់រវាងយើងរួចមកហើយ។

[១១:១១:០៨]

ដូច្នេះ ខ្ញុំសូមនាំយកមកនូវព័ត៌មានលម្អិតមួយចំនួន ដែលអាចបំភ្លឺដល់អង្គជំនុំជម្រះបាន។ ក្នុងចំណោមគម្រោងទាំងអស់នេះ គឺថាមានគម្រោងដំបូងនោះ នៅក្នុងចំណោមគម្រោងទាំងបួននោះ គឺថាមូលនិធិសំណងនោះ ដែលថាឈ្មោះ ហើយនិងចំណងជើងនោះ អាច ឬក៏ថាត្រូវផ្លាស់ប្តូរបាននៅពេលក្រោយ។

កថាខណ្ឌ៦៧០ នៃសាលក្រមរបស់ ឌុច អង្គជំនុំជម្រះបានប្រកាសថា ខ្ញុំសូមស្រង់ "សំណើទាំងអស់ដែលថា ទោះបីផ្ទាល់ ឬក៏ដោយប្រយោលក្តី ដែលស្នើសុំសំណងប្រាក់ជាលក្ខណ:បុគ្គលសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ឬការបង្កើតមូលនិធិក្នុងភារកិច្ចគ្រប់គ្រងសម្រាប់ជនរងគ្រោះមិនស្ថិតនៅក្នុងវិសាលភាពនៃប្រភេទសំណងដែល អ.វ.ត.ក អាចសម្រេចបានទេ"។ ចប់សម្រង់។ នៅលើឃរមូលដ្ឋាននេះហើយដែលអង្គជំនុំជម្រះបានបដិសេធសំណើមួយចំនួន ដែលសុំឱ្យដោយប្រយោល ឬក៏

ដោយផ្ទាល់ គឺថាសុំឲ្យមានផ្តល់សំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី ហើយអង្គជំនុំជម្រះបានបដិសេធសំណើមួយចំនួន ឧទាហរណ៍ដូចជាការបង្កើតការមូលនិធិសំណងជាដើមនោះ។

[១១:១២:៤៤]

អង្គជំនុំជម្រះបានលើកឡើងថា សំណងហិរញ្ញវត្ថុមិនអាចធ្វើឡើងបានឡើយ ទោះបីជាឯកជនឬក៏សមូហភាពក្តី ក៏ប៉ុន្តែចំពោះយើងខ្ញុំវិញ យើងដឹងពីដែនកំណត់នេះ ហើយបើនិយាយឲ្យត្រង់តែម្តងទៅគឺថាយើងគិតថាវាមានមូលហេតុ មូលហេតុនេះគឺថា វាដោយសារចំនួនដើមបណ្តឹងរដ្ឋប្បវេណីច្រើនពេក។ លើសពីនេះទៅទៀតនោះគឺថា លក្ខណៈសមូហភាពនៃសំណងមានតម្លៃ វាសំខាន់ណាស់នៅក្នុងការជម្រះសេចក្តីនេះ ហើយខ្ញុំសូមលើកឡើងម្តងទៀត គឺថាមិនមែនថាត្រឹមតែចំនួនដើមបណ្តឹងរដ្ឋប្បវេណី៣.៩០០នាក់នោះទេ គឺថាប្រជាជនកម្ពុជាទាំងមូលតែម្តង។ គឺដោយសារទំហំនៃព្យសនកម្មសមូហភាព ហើយនិងអត្ថន័យជានិមិត្តរូបនៃសំណង ដែលនឹងផ្តល់ជូននេះហើយ ដែលជាមូលហេតុនៃការបង្កើតមូលនិធិសំណងជំងឺចិត្តនោះ។ អ៊ីចឹង យើងអាចហៅគម្រោងនេះបានថា គម្រោងបង្កើតមូលនិធិសំណងដែលនឹងផ្តល់ហិរញ្ញប្បទានដល់សំណងផ្លូវចិត្ត និងសមូហភាព។

វិធានផ្ទៃក្នុងបានចេញវិធានការថែងអំពីហិរញ្ញវត្ថុសំណង ដែលជាលក្ខណៈនិមិត្តរូប ហើយនិងផ្លូវចិត្តនេះ។ អ៊ីចឹងហើយបានជាមាត្រា២៣ ស្ទួនបួន (៣)(ខ) នេះតម្រូវឲ្យការធានាផ្នែកហិរញ្ញវត្ថុនៃគម្រោងត្រូវផ្តល់ជូនដល់អង្គជំនុំជម្រះនៅក្នុងសំណើសំណងចុងក្រោយនោះ។ ដូច្នេះ វាជាការសមហេតុសមផលក្នុងការបង្កើតគម្រោងមូលនិធិសំណង ឬក៏ថាជាអង្គការផ្តល់ហិរញ្ញប្បទាននោះ។ អង្គការនេះគឺថាធ្វើឲ្យអ្នកផ្តល់មូលនិធិ ដែលថាទុកចិត្តក្នុងការដាក់មូលនិធិទៅនឹងអង្គការឯករាជ្យមួយដែលប្រមូលអ្វីដែលថាអាចធ្វើឲ្យសម្រេចគម្រោងទាំងឡាយនេះបាន។

[១១:១៤:៥២]

មានមូលនិធិសំណងជាច្រើន ឧទាហរណ៍ទីមួយ គឺថាឧទាហរណ៍របស់ តុលាការព្រហ្មទណ្ឌអន្តរជាតិ អង្គជំនុំជម្រះប្រហែលជាអាចជំទាស់ថា អង្គការនេះគឺថាបង្កើតឡើងដោយលក្ខន្តិកៈរ៉ូម នៅក្នុងពេលដែលបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយជាអង្គការដែលនៅក្នុងចំណុះតុលាការនោះផ្ទាល់តែម្តង។ យើងមិនមានករណីនេះនៅ អ.វ.ត.ក នោះទេ ក៏ប៉ុន្តែមិនមានអ្វីដែលរាំងស្ទះមិនឲ្យបង្កើតមូលនិធិនេះ ក្រោមទម្រង់ណាមួយផ្សេងទៀត ធ្វើយ៉ាងណាដើម្បីឲ្យធានានូវការប្រើប្រាស់មូលនិធិយើងប្រមូលបាន។ ឧទាហរណ៍មួយទៀត គឺថាអាចជាមូលនិធិសហព័ន្ធអាល្លឺម៉ង់ ដែលគោលបំណង

គេនោះ គឺថាវាមានហួសពីការប្រមូលមូលនិធិ ឬក៏ការប្រើប្រាស់មូលនិធិនោះទៅទៀត។

[១១:១៥:៤៨]

មានឧទាហរណ៍ច្រើនទៀតដែលយើងអាចលើកមកបង្ហាញបាន ដែលចេញមកពីរឿងកាត់ក្តីផ្សេងៗទៀត ឧទាហរណ៍ដូចជារឿងកាត់ក្តីនៅតុលាការអន្តរអាមេរិកាំងសិទ្ធិមនុស្សនោះ ដែលមាននៅក្នុងកម្រិតផ្ទៃក្នុង។ នេះគឺជាឧទាហរណ៍មួយដែលបង្ហាញថា អង្គការមួយដែលថាសឹងតែរដ្ឋបាលសុទ្ធ ហើយដែលធ្វើការក្នុងការអនុវត្ត ឬក៏ថាជាគណៈកម្មការពិគ្រោះ ឬក៏អង្គការដែលថាមានឈ្មោះខុសពីនេះទៀត ដែលអាចចូលរួមវិភាគទានក្នុងការផ្តល់ហិរញ្ញប្បទាន ដើម្បីសម្រេចសំណងស្នូគស្មាញដែលថាតម្រូវឲ្យមានការចំណាយការប្រើប្រាស់ថវិកានោះ។ យើងសុំឲ្យមានគម្រោងបែបនេះ ដើម្បីអនុវត្តសំណង។ យន្តការដែលយើងនេះ គឺថាយើងចង់បង្កើតនេះ គឺថាវានៅមានជាគម្រោងនៅឡើយទេ យើងយល់អំពីឧបសគ្គផ្លូវច្បាប់ ដែលថាមិនអាចឲ្យអង្គជំនុំជម្រះអនុញ្ញាតធ្វើរបៀបនេះបាន។ ក៏ប៉ុន្តែទោះជាយ៉ាងណាក្តី គម្រោងបែបនេះ គឺថាអាចឆ្លើយតបនឹងសំណួរមួយដែលចោទឡើងដែលថា តើយើងត្រូវធានាការសម្រេចគម្រោងសំណងពិតប្រាកដយ៉ាងម៉េចបាន បើយោងទៅតាមឧបសគ្គផ្នែកសម្ភារដ៏សម្បើមនោះ?

[១១:១៧:២០]

គម្រោងនេះ គឺជាចម្លើយដ៏ច្បាស់លាស់មួយ ដោយឆ្លើយតបទៅនឹងការសិទ្ធិទទួលបានសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងអាចធ្វើឲ្យយើងសម្រេចបាននូវគម្រោងជាច្រើន ហើយដើម្បីប្រយោជន៍ដើមបណ្តឹងរដ្ឋប្បវេណី ដែលថានឹងទទួលប្រយោជន៍ពីគម្រោងទាំងអស់នេះ។ ហើយក្រៅពីដើមបណ្តឹងរដ្ឋប្បវេណីហ្នឹង គឺថាមានជនរងគ្រោះទាំងអស់តែម្តងដែលអាចទទួលប្រយោជន៍បានពីនេះព្រោះថាវាមានលក្ខណៈទូលំទូលាយ។ អ៊ីចឹងគឺថា ពាក្យថា សមូហភាពនេះ វាអាចឲ្យយើងយល់ឃើញថា ជនរងគ្រោះទាំងមូលតែម្តងដែលអាចទទួលប្រយោជន៍ពីនេះបាន។

គម្រោងទីពីរនៃប្រភេទនេះ គឺថា គឺជាដៃគូមូលនិធិសំណង ដែលសំណងនៃអង្គការផ្តល់ហិរញ្ញប្បទាននេះ គឺជាគម្រោងដែលគម្រោងបង្កើតអង្គការសម្រាប់ត្រួតពិនិត្យការអនុវត្តសំណង បន្ទាប់ពីការប្រកាសសាលក្រម ហើយនិងផ្តល់ព័ត៌មានដល់ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសហគមន៍អន្តរជាតិ ស្តីអំពីការអនុវត្តគម្រោងសំណងនេះ។

[១១:១៨:៤០]

បើយើងដឹងណាស់ថា អង្គការនេះគឺថាត្រូវមានហិរញ្ញប្បទាន រកហិរញ្ញប្បទានដោយខ្លួនឯងហើយនិងពិបាកអនុវត្ត ក៏ប៉ុន្តែវាមិនមែនថាមិនអាចធ្វើទៅកើតនោះទេ។ ហើយកង្វល់របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺថាត្រូវធានាយ៉ាងណាដើម្បីគឺថា សំណងទាំងអស់ដែលនឹងផ្តល់ជូននោះត្រូវបានអនុវត្តដោយពិតប្រាកដ។ យើងដឹងថាអង្គជំនុំជម្រះនឹងមិនអាចផ្តល់សំណង ឬក៏ថាការអនុវត្តសំណងបានទេនៅពេលដែលថាតុលាការនេះបិទទ្វារទៅនោះ។ ប៉ុន្តែផ្ទុយទៅវិញ អង្គការឯករាជ្យមួយនឹងធានាថាធ្វើយ៉ាងណា ដើម្បីឲ្យការអនុវត្តសំណងនេះនឹងសម្របសម្រួល បើសិនជាអាចមានបាន គឺថាក្នុងការអនុវត្តសំណងនៅពេលក្រោយ។

ដូច្នេះ ដែលបេសកកម្មអន្តរជាតិ លក្ខណៈជាតិ និងអន្តរជាតិ អង្គការនេះអាចអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណី ឬក៏ជនរងគ្រោះ និងសហគមន៍អន្តរជាតិដឹងអំពីការវិវត្តន៍នៃសំណងនីមួយៗ។ សំណងមួយភាគនោះនៅក្នុងការប្រកាសសាលក្រម ហើយមួយភាគទៀតមាននៅក្នុងការសម្រេចដ៏ពិតប្រាកដនៃគម្រោងនេះ ហើយភាគទៀតគឺថានៅក្នុងការដែលថាយើងផ្តល់ព័ត៌មានពីសំណងនេះទៅអ្នកផ្សេងទៀតដែលថាក្រៅពីអ្នកដែលថាទទួលសំណងនេះ។

[១១:២០:២១]

គម្រោងទីបី នៃប្រភេទនេះគឺគម្រោងដែលអាចយើងថា ដាក់ឈ្មោះបានថាគម្រោងសម្របសម្រួលនៃការផ្តល់សញ្ជាតិខ្មែរ ខ្ញុំនិយាយថាប្រើពាក្យសម្រួលទេ។ អ៊ីចឹងបានន័យថា គឺថានេះចំណងជើងនេះគឺថាយើងដាក់ឲ្យហ្នឹងគឺថាវា ដាក់មិនសមស្របដែលថាលឿនពេក នៅក្នុងសវនាការបឋម។ គម្រោងនេះគឺ ចំណងជើងថា ផ្តល់សញ្ជាតិខ្មែរដល់វៀតណាម ហើយអង្គជំនុំជម្រះនៅក្នុងអនុស្សរណៈរបស់ខ្លួនបានធ្វើការកត់សម្គាល់ អង្គជំនុំជម្រះថា អង្គជំនុំមិនអាចបង្ខំរដ្ឋាភិបាលឲ្យផ្តល់សញ្ជាតិកម្ពុជាឲ្យវៀតណាមនោះទេ។

[១១:២១:២១]

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីយល់ពីព្រំដែនកំណត់នេះ ដើម្បីឲ្យច្បាស់នៅថ្ងៃនេះតែម្តងគឺថាទម្រង់សំណងដែលជនជាតិវៀតណាមដែលរួចផុតពីឧក្រិដ្ឋកម្មនៅប្រទេសកម្ពុជានោះ ថាមិនមែនមិនចង់រំលោភលើអំណាច ឬក៏អាជ្ញាធររបស់រដ្ឋាភិបាលកម្ពុជានោះទេ ទាក់ទងទៅនឹងការផ្តល់សញ្ជាតិនេះ។

ដូច្នេះយើងខ្ញុំសូមថា ការសំណូមពររបស់យើងនេះគឺវាលក្ខណៈស្របច្បាប់ដោយសារគាត់ទទួល

ព្យសនកម្មដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ការជម្លៀសដោយបង្ខំរបស់វៀតណាមចេញ ដេញវៀតណាមចេញពីប្រទេសកម្ពុជាជាដើម។

[១១:២២:១៥]

អ៊ីចឹង ផលវិបាកនៃការជម្លៀសវៀតណាមចេញពីប្រទេសកម្ពុជា នេះគឺថាបណ្ដាលឲ្យគាត់បាត់លិខិត ឬក៏អត្តសញ្ញាណប័ណ្ណអីជាដើម។ អ៊ីចឹងផលវិបាកនេះគឺថាយើងអាចដោះស្រាយដោយគម្រោងដែលថាយើងផ្ដល់សញ្ជាតិឲ្យជនជាតិវៀតណាមនេះ ដែលថាគម្រោងនេះវាស្ថិតនៅក្នុងគម្រោងសំណងសមូហភាព ហើយនិងតាមផ្លូវចិត្តដែលស្ថិតនៅក្នុងអាណត្តិរបស់ អ.វ.ត.ក។ វិធានការសំណងនេះគឺជាគម្រោងដែលសម្រាប់សម្របសម្រួលសុំសញ្ជាតិកម្ពុជាពីសំណាក់វៀតណាម ដែលទទួលរងនូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយខ្មែរក្រហមដូចជាការដេញចេញពីប្រទេសកម្ពុជា ហើយដែលថា គាត់ទាំងអស់គ្នានោះបាត់អត្តសញ្ញាណប័ណ្ណ ឬក៏បាត់មធ្យោបាយនៅក្នុងការផ្ទៀងផ្ទាត់អត្តសញ្ញាណប័ណ្ណរបស់គាត់ ឬក៏បំបាត់ទំនាក់ទំនងរបស់គាត់ជាមួយនឹងទឹកដីកម្ពុជា អ្នកខ្លះនោះកើតឡើងនៅប្រទេសកម្ពុជា ដែលជីដូនជីតាមកមិនសល់។

[១១:២៣:២៦]

អ៊ីចឹង ដូច្នេះបន្ទាប់ពីការជម្លៀសគាត់ចេញពីប្រទេសខ្មែរទៅដោយពួកខ្មែរក្រហមនោះ ជនរងគ្រោះទាំងនោះមិនអាចដឹងថាគាត់ៗនៅស្រុកខ្មែរប៉ុន្មានឆ្នាំ ហើយឯកសារអីទាំងឡាយមានទំនាក់ទំនងជាមួយជីដូនជីតា។ អ៊ីចឹងបានន័យថា គាត់បានទទួលព្យសនកម្មបន្ថែមទៀត គឺថាដែលគាត់មិនអាចទទួលបានការផ្ដល់សញ្ជាតិខ្មែរនោះ អនុលោមតាមច្បាប់ជាតិ ជនរងគ្រោះទាំងអស់នេះគឺថាប្រឈមមុខទៅនឹងហានិភ័យពិតប្រាកដ ដែលថាខ្លួននឹងអាចរស់ដោយគ្មានសញ្ជាតិ ហើយនិងរស់នៅក្រៅសង្គមដោយមិនដែលបានប្រព្រឹត្តកំហុសអ្វីទាស់តែសោះ។

[១១:២៤:២៦]

អ៊ីចឹងការសម្របសម្រួលនៃការផ្ដល់-- សុំពាក្យសុំសញ្ជាតិនេះគឺថាអាចដូចជា ជាគម្រោងគឺថាលើកកម្ពស់ឲ្យយល់ពីច្បាប់ អំពីសញ្ជាតិរបស់ប្រទេសកម្ពុជា ហើយនិងលក្ខណៈវិនិច្ឆ័យផ្លូវច្បាប់នានាដែលខ្លួនចង់សុំបំពេញ អនុលោមទៅតាមនីតិវិធីកម្ពុជានោះ។

គម្រោងមួយទៀតដែលពាក់ព័ន្ធ គឺថាអាចបង្កើតទៅជា សេវាកម្មច្បាប់ដែលស្ថិតនៅក្នុងកន្លែងដែលដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់នោះនៅ ហើយដែលជួយឲ្យប្រមូលឯកសាររបស់អ្នកដាក់ពាក្យសុំ

ទាំងអស់ ហើយនិងជួយដល់បេក្ខជនទាំងអស់នោះដែលធ្វើពាក្យសុំនោះ ហើយនិងយើងដាក់ជូនសំណុំពាក្យសុំទាំងអស់នេះទៅស្ថាប័នរដ្ឋកម្ពុជានោះ។ អ៊ីចឹង គឺថាយើងអាចថាឲ្យមានសម្របសម្រួលជាមួយនឹងអាជ្ញាធររដ្ឋាភិបាល ដើម្បីឲ្យគាត់អាចដឹងដំណឹងអំពីច្បាប់ អំពីស្ថានភាពរបស់ជនជាតិវៀតណាមទាំងអស់នេះ និងឲ្យអាជ្ញាធរនេះគាត់ធ្វើដោយអនុលោមតាមច្បាប់ជាតិស្ដីអំពីសញ្ជាតិ ហើយនិងគាត់អាចអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួននៅក្នុងការសម្រេចថា តើផ្ដល់សញ្ជាតិឲ្យជនជាតិវៀតណាមនេះ ឬក៏អត់នោះ? ពាក្យសុំ សញ្ជាតិខ្មែរណាមួយដែលត្រូវកើតឡើងពីសំណើសុំទាមទារសំណងមួយ ឬក៏វិធានដែលផ្ដល់សំណងដោយ-- គេប្រមើលមើលពាក្យសុំដែលធ្វើសម្រេចដោយអាជ្ញាធរកម្ពុជា។ ហើយអាជ្ញាធរកម្ពុជានឹងកំណត់លក្ខខណ្ឌតិកៈលើរបស់អ្នកសុំទាំងអស់នេះទៅតាមនីតិវិធីធម្មតា។

[១១:២៦:៣០]

ខ្ញុំនិយាយយូរបន្តិចហើយអំពីគម្រោងសញ្ជាតិនេះ ពីព្រោះថាវានឹងគួរតែចៀសវាងនូវការមិនយល់គ្នាច្បាស់លាស់អំពីសំណាក់អង្គជំនុំជម្រះសាលាដំបូង ឬក៏ពីសាធារណជន ឬក៏ពីសំណាក់ប្រជាជនកម្ពុជាទាំងមូលតែម្ដង ទាក់ទងទៅនឹងសំណើសុំសំណងដើមបណ្ដឹងរដ្ឋប្បវេណីជនជាតិវៀតណាមនេះ។ ដើម្បីចៀសវាងកុំឲ្យ ថាឲ្យមានការរើសអើងដែលអាចជះឥទ្ធិពលអាក្រក់ទៅលើក្រុមជនជាតិវៀតណាមនេះ។ អ៊ីចឹងភាពស្របច្បាប់នៃការសុំសំណងនេះ ស្ថិតនៅ ផ្អែកទៅលើ គឺថាទំនាក់ទំនងដែលមិនអាចជំទាស់បានទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ហើយនិងព្យសនកម្មដែលទទួលរង។ អ៊ីចឹងគម្រោងនេះ អាចជាទម្រង់នៃសំណងមួយដ៏មានន័យចំពោះដើមបណ្ដឹងរដ្ឋប្បវេណីជនជាតិវៀតណាម។

នៅទីបញ្ចប់ ខ្ញុំនិយាយអំពីគម្រោងទីបួន ហើយដោយខ្លី គម្រោងទីបួននៃគម្រោងចុងក្រោយនេះគឺថា គឺជាគម្រោងដែលយើងអាចដាក់ចំណងជើងបានថា គម្រោងកំណត់តម្រូវការហើយនិងបំណងប្រាថ្នាពាក់ព័ន្ធនឹងមុខរបរបរិជ្ជាជីវៈរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលជាជនរងគ្រោះនៃការរៀបការដោយបង្ខំ ហើយអ្នកខ្លះកើតនៅពេលក្រោយដែលពេលខ្មែរក្រហមធ្លាក់ពីអំណាចទៅនោះ។ អ៊ីចឹងការកំណត់តម្រូវការ ហើយនិងសេចក្ដីប៉ងប្រាថ្នាទាំងអស់នេះនឹងធ្វើនៅជាមួយនឹងកុមារទាំងអស់ដែលពាក់ព័ន្ធ អ៊ីចឹងក្រុមការងារនឹងបង្កើតទៅតាមតំបន់នីមួយៗ ហើយនិងនៅក្នុងផ្នែកសំខាន់ៗនៃការបណ្ដុះបណ្ដាលនោះ។ រដ្ឋាភិបាលអាចថាជាសមាជិកនៃក្រុមនេះដែរ បើសិនជារដ្ឋាភិបាលគាំទ្រគំនិតរបស់យើងខ្ញុំ បើពុំដូច្នោះទេ ការផ្ដល់ហិរញ្ញប្បទានពីខាងក្រៅ គឺជាការចាំបាច់។ អ្វីដែលទាក់ទងទៅនឹងការអនុវត្តនោះ រដ្ឋាភិបាលនឹងត្រូវបានអញ្ជើញមកជាមួយក្រុមការងារ ហើយយើងនឹងផ្ដល់ពីលទ្ធផល

ដល់រដ្ឋាភិបាល។ អ៊ីចឹងការបណ្តុះបណ្តាលក្រុមវិជ្ជាជីវៈនេះនឹងមានរយៈពេលមួយឆ្នាំ ហើយការផ្តល់ហិរញ្ញប្បទានត្រូវតែអាចជួយផ្តល់ថវិកាដល់គ្រូ។ បន្ទាប់ពីបញ្ចប់គម្រោងបណ្តុះបណ្តាល ក្រុមការងារនឹងជួយបុគ្គលទាំងអស់នោះឲ្យរកការងារបាន ហើយនិងជួយគាត់នៅក្នុងកិច្ចការរកស៊ីរបស់គាត់។ ឧទាហរណ៍ ដូចជាការបង្កើតសហគ្រាស ឬក្រុមហ៊ុនតូចៗអីជាដើម។

[១១:២៩:៤១]

ដើម្បីបញ្ចប់លើប្រភេទចុងក្រោយនេះ យើងខ្ញុំសូមជម្រាបជូនដល់អង្គជំនុំជម្រះថា លក្ខណៈពិសេសនៃគម្រោងទាំងអស់នេះមិនអាចឲ្យយើងទាំងអស់គ្នា រវាងយើងនឹងយើងនេះពិភាក្សាឲ្យបានលម្អិតទៅលើគម្រោងទាំងអស់នេះទេ។ គឺថាមានការពិភាក្សាគ្នារវាងមេធាវីទាំងអស់ ហើយនិងយើងត្រូវតែពិភាក្សាលម្អិតតទៅទៀតនៅថ្ងៃអនាគត នៅក្នុងក្របខ័ណ្ឌនៃការពិគ្រោះ ហើយនិងការស្វែងរកកិច្ចព្រមព្រៀងឯកច្ឆន្ទមួយរវាងគ្នាយើងទាំងអស់គ្នានេះ។ នេះមិនមែនដើម្បីឲ្យធ្វើយ៉ាងណាដើម្បីឲ្យយើងអាចអនុវត្តបាន។ ហើយដូចដែលយើងសព្វថ្ងៃនេះស្ថិតនៅក្នុងដំណាក់កាលពិភាក្សា។ យើងផ្តល់ជូនអង្គជំនុំជម្រះនូវព័ត៌មានទាំងអស់នេះ អ៊ីចឹងយើងខ្ញុំសូមថាឲ្យអង្គជំនុំជម្រះជួយវាយតម្លៃ ហើយនិងលក្ខណៈចាំបាច់ជានិមិត្តរូបនៃគម្រោងទាំងនេះ ក៏ប៉ុន្តែយើងក៏មិនបំភ្លេចដែរអំពីឧបសគ្គដែលអាចមាននៅពេលដែលយើងអនុវត្តនូវគម្រោងទាំងអស់នេះ ហើយយើងនឹងព្យាយាមជម្នះ ឧបសគ្គនេះឲ្យបាន។

[១១:៣០:៥១]

ដើម្បីបញ្ចប់ការបទបង្ហាញរបស់ខ្ញុំនេះ នៅពេលព្រឹកនេះ ខ្ញុំមានតែពីរបីម៉ាត់ទៀតទេចង់បន្ថែមយើងសង្ឃឹមថា ផ្តល់ការបំភ្លឺដល់អង្គជំនុំជម្រះនិងសេចក្តីលម្អិតមួយចំនួន ដែលថាអង្គជំនុំជម្រះទន្ទឹងរង់ចាំ យើងសង្ឃឹមថា យើងអាចផ្តល់ព័ត៌មានលើសពីនេះទៅទៀត ហើយយើងសង្ឃឹមថាអ្វីដែលយើងនិយាយមានលក្ខណៈច្បាស់លាស់ទាក់ទងនឹងបញ្ហាប្រឈមរបស់យើង ដែលកើតចេញពីការបំបែកសំណុំ ដំណើរការនីតិវិធី ហើយនិងភាពមិនច្បាស់លាស់នៅលើសញ្ញាណមួយចំនួន ឬក៏និយមន័យមួយចំនួនទាក់ទងទៅនឹងសំណងនេះ។ ការចង្អុលបង្ហាញបឋមរបស់យើងលើសំណងនេះគឺថា យើងចង់ឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មទាំងឡាយ ដែលបានប្រព្រឹត្តលើដើមបណ្តឹងរដ្ឋប្បវេណី ហើយការបំបែកសំណុំនីតិវិធីនេះគឺថាធ្វើឲ្យអ្វីៗទាំងអស់ប្រែប្រួលទាំងអស់ ហើយធ្វើឲ្យយើងធ្លាក់ទៅក្នុងស្ថានភាពមួយមិនច្បាស់លាស់។

[១១:៣២:០១]

យើងចង់បញ្ចប់ គឺនៅពេលនេះគឺយើងចង់សុំសួរសំណួរមួយចំនួន ដែលថាអង្គជំនុំជម្រះនឹងអាចឆ្លើយបាននៅពេលក្រោយ។ តើអង្គជំនុំជម្រះយល់យ៉ាងម៉េចអំពីការចង្អុលបង្ហាញដំបូងបឋមរបស់យើងនេះ ពាក់ព័ន្ធទៅនឹងការបំបែកសំណុំនីតិវិធីនេះ តើអង្គជំនុំជម្រះយល់ឃើញយ៉ាងណាអំពីការសុំសំណងខ្លឹមសារសំខាន់ចម្បងរបស់អង្គជំនុំជម្រះ? តើអង្គជំនុំជម្រះបានកំណត់លក្ខណៈពិសេសយ៉ាងម៉េចចំពោះគម្រោងរបស់យើងនីមួយៗនេះ? នេះគឺជាសំណួរដែល មួយក្នុងចំណោមសំណួរផ្សេងៗទៀត ដែលថាជាការងារយើងនៅពេលក្រោយនោះយើងត្រូវធ្វើ។

[១១:៣២:៥៣]

នៅទីបញ្ចប់យើងចង់បន្ថែមពីរបីម៉ាត់ដូចតទៅនេះ៖ សំណងមិនមែនត្រឹមតែជាវិធានការបច្ចេកទេសនោះទេដែលថា ធ្វើឡើងដោយគ្មានបេះដូង ហើយដែលថាធ្វើទៅដែលអាចសម្រេចបានទេ ក៏ប៉ុន្តែត្រូវតែបំពេញចិត្តដល់ដើមបណ្ដឹងរដ្ឋប្បវេណី ធ្វើយ៉ាងណាដើម្បីឲ្យគាត់មានអារម្មណ៍ថា គាត់បានទទួលសំណងដែលថាធ្វើយ៉ាងណាសំណង ដែលអាចឲ្យគាត់បន្ថយការឈឺចាប់បាន។ គឺថានេះជាការពិតណាស់ពីព្រោះថា ការជម្រះសេចក្ដីនេះគឺត្រូវតែបំបែកចេញជាផ្នែកតូចៗ ហើយពេលខ្លះហ្នឹងត្រូវផ្ដាច់ដកដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនចេញ។ អ៊ីចឹង សំណងត្រូវតែធ្វើយ៉ាងណាឲ្យ គិតយ៉ាងណាធ្វើឲ្យហួសពីអ្វីដែលស្រួលធ្វើ ហើយដែលមិនមានតម្លៃសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី សំណងមិនមានតម្លៃអ្វីនោះទេ បើសិនជាដើមបណ្ដឹងរដ្ឋប្បវេណីយល់ថាគ្មានន័យ ហើយនិងគ្មានឥទ្ធិពលអ្វីទាំងអស់សម្រាប់ខ្លួននោះ។

[១១:៣៤:១៤]

អង្គជំនុំជម្រះ-- អង្គបុរេនៅរឿងក្ដី សហព្រះរាជអាជ្ញា លូបាងហ្គា នៅឆ្នាំ២០០៦ គាត់លើកឡើងថា "ការជោគជ័យរបស់តុលាការមួយគឺជាការជោគជ័យនៃប្រព័ន្ធសំណងរបស់តុលាការនោះក្នុងកម្រិតណាមួយ"។ ខ្ញុំបញ្ចប់សម្រង់។ អ៊ីចឹង យើងគាំទ្រគំនិតរបស់តុលាការនេះ យើងដឹងថា យើងដូចជាលោភលន់ពេកហើយនៅថ្ងៃនេះ ដែលថាយើងបង្កើតគម្រោងជាច្រើន ដែលថាការលំបាកជាច្រើនដែលយើងនឹងប្រឈមនៅថ្ងៃក្រោយនោះ ក៏ប៉ុន្តែជាកាតព្វកិច្ចរបស់យើងដែលថា យើងត្រូវតែមានការលោភលន់បែបនេះ បើយើងមិនលោភលន់ទេ យើងក៏មិនអាចជាអ្នកការពារដើមបណ្ដឹងរដ្ឋប្បវេណីនោះដែរ។ ក៏ប៉ុន្តែយើងដឹងថា គម្រោងមួយចំនួននឹងត្រូវកែប្រែ ហើយនិង បោះបង់ចោលក៏មានដែរ ហើយនិងខ្លះទៀតគឺថា កែប្រែទៅតាមវិធានការក្រៅផ្លូវតុលាការ។ ឥឡូវនេះ យើងកំពុងតែធ្វើ ហើយជា

សិទ្ធិរបស់យើងក្នុងការធ្វើនេះ សិទ្ធិរបស់យើងតែមួយគត់។ ប្រសិនជាយើង មានបន្ទុកក្នុងការបង្ហាញសំណងក្នុងការអនុវត្ត ដែលថាត្រូវតែអាចធ្វើទៅបាននោះ យើងមានទំនួលក្នុងការបង្ហាញគម្រោងដែលយើងថាយើងវាស់ពីកម្រិត ដែលថាធ្វើបានឬមិនបាននោះ។ ក៏ប៉ុន្តែ ទន្ទឹមនឹងនោះ អង្គជំនុំជម្រះក៏មានទំនួលខុសត្រូវក្នុងការស្វែងរកឲ្យលើសពីអ្វីដែលងាយស្រួលសម្រេចបាន។ ខ្ញុំសូមអភ័យទោសដែលខ្ញុំប្រើពាក្យថា "វាងាយស្រួលនោះ" គឺថាត្រូវរកវិធានការណា ដែលថាវាត្រូវគោរពច្បាប់ ហើយក៏ប៉ុន្តែទន្ទឹមនឹងនោះគឺថា ធ្វើយើងយ៉ាងម៉េចឲ្យការផ្ដល់សំណងនោះវាមានលក្ខណៈជាក់ស្ដែង។

[១១:៣៦:៣១]

អ្វីដែលជាសំណងក្នុងសំណុំរឿងនេះគឺជាផ្លែផ្កានៃការខិតខំប្រឹងប្រែង និងឆន្ទៈរួមរបស់យើងខ្ញុំក្នុងការផ្ដល់សំណង ដែលមិនមែនគ្រាន់តែជាកាយវិការ គ្មានខ្លឹមសារជ្រាលជ្រៅ បង្កឲ្យមានភាពជូរចត់ និងការខកចិត្តទៀតនោះទេ។ យើងមានកាតព្វកិច្ចធ្វើយ៉ាងណាដើម្បីឲ្យសាលក្រមដែលនឹងចេញនោះគឺថានិមិត្តរូបដ៏មានអំណាច យើងទុកចិត្តអង្គជំនុំជម្រះក្នុងការសម្រេចលើសំណងនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកស្រីមេធាវី។ សូមអញ្ជើញលោក ពេជ អង្គ!

បើកក្បាលមីក្រូ!

**លោក ពេជ អង្គ៖**

សូមគោរពលោកចៅក្រមប្រធាន លោក លោកស្រីចៅក្រម អស់លោក លោកស្រីទាំងអស់។ នៅមានចំណុចគម្រោងពីរដែលយើងខ្ញុំមិនបានបញ្ចូលនៅក្នុងសេចក្ដីថ្លែងរបស់យើងខ្ញុំ ហើយដែលត្រូវមាន ដែលខ្ញុំបាទសូមស្នើសុំលោកចៅក្រមប្រធានអនុញ្ញាតឲ្យលោកមេធាវី ឡោ ជុនធី ចំណាយពេលរយៈពេលបួននាទីដើម្បីលើកពីគម្រោងនេះ ហើយគម្រោងនេះពាក់ព័ន្ធទៅនឹងជំពូកទីបី នៃសំណើសុំសំណងដែលជាគម្រោងពាក់ព័ន្ធទៅនឹងការចងក្រងឯកសារនិងការអប់រំ។

សូមលោកចៅក្រមប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញលោក ឡោ ជុនធី!

[១១:៣៨:២៦]

**លោក ឡៅ ជុនធី៖**

បាទ, សូមអរគុណ។ ដោយមានការអនុញ្ញាតពីសហមេធាវីនាំមុខ ហើយសុំការអនុញ្ញាតពីតុលាការផងដែរ ខ្ញុំបាទ ឡៅ ជុនធី ដែលជាមេធាវីក្នុងដើមបណ្ដឹងរដ្ឋប្បវេណីនេះ សុំធ្វើការលើកឡើងនូវបរិបទសំណងចំនួនពីរចំណុចទៀតដែលពាក់ព័ន្ធនឹងក្រុមយើងខ្ញុំដែលហៅថា“ជាក្រុមម៉ាអាត”(maat) នោះ ហើយសូមបញ្ជាក់បន្តិចថា ក្រុមនេះគឺនៅក្នុងអង្គការជំនួយផ្នែកច្បាប់របស់យើង ហើយបានទទួលនូវការឧបត្ថម្ភពីស្ថានទូតបារាំង ហើយក្នុងនោះក៏មានលោក អូលីវីយេ បាហ្វូញ គាត់នៅក្នុងក្រុមខ្ញុំបាទដែរ។

ដូច្នេះ ទីមួយនេះគឺខ្ញុំសុំជម្រាបជូនអង្គជំនុំជម្រះថា ជាគម្រោងសំណងនៃការហៅថា “ការបង្កើតនូវមជ្ឈមណ្ឌលផ្សព្វផ្សាយនៃដួងព្រលឹងនៃប្រជាជនកម្ពុជា”។ នេះគឺមានគោលបំណងមួយថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ គឺបានលុបបំបាត់នូវអ្វីដែលជាជំនឿ សាសនា ហើយអ្វីដែលជាព្រលឹងរបស់ប្រជាជនកម្ពុជា។ ដូច្នេះក្នុងគោលបំណងដើម្បីឱ្យបង្កើតឡើង ធ្វើយ៉ាងណាឱ្យអ្នកដែលរស់នៅក្នុង ប្រទេសកម្ពុជាមានជំនឿឡើងវិញ ហើយដើម្បីប្រឆាំងនឹងអ្វីដែលក្រុមខ្មែរក្រហមបានបង្កើតឡើង ហើយក្រុមខ្មែរក្រហមបានបង្កើតឡើងនោះគឺថា ជាការលុបបំបាត់នូវអ្វីដែលជាដួងព្រលឹងនេះឯង។

ហើយជាទីបំផុត គឺថា យើងស្នើសុំឱ្យមានមជ្ឈមណ្ឌលនេះ ដើម្បីឱ្យជាថាជំនឿហ្នឹងឡើងវិញ។ ហើយពាក់ព័ន្ធនឹងជាតិ សាសនា និងជាតិពន្ធុទាំងឡាយ គឺមានការកត់សម្គាល់នូវព័ត៌មានមួយចំនួនដែលជាពាក់ព័ន្ធនឹងការជំនឿរបស់ខ្លួន។

មជ្ឈមណ្ឌលនេះគឺជាការប្រមូលផ្ដុំនូវព័ត៌មានទាំងឡាយ ដូចជា លក្ខណៈសាសនា លក្ខណៈជំនឿ ដោយមិនប្រកាន់ថាសាសនាមួយណាទេ គឺថា យើងអាចប្រមូលផ្ដុំនូវឯកសារទាំងអស់ដាក់នៅទីនោះ ហើយបង្កើតឡើងដើម្បីឱ្យមានអ្នកដែលចូលរួមនោះ ហើយបង្កើតជាដួងព្រលឹងឡើងវិញ មានជំនឿឡើងវិញ ធ្វើឱ្យមានការជាសះស្បើយនូវការឈឺចាប់របស់អ្នកទាំងអស់ន៎ុង។

[១១:៤១:២៦]

ចំណុចទីពីរ ដែលខ្ញុំសូមលើកឡើងផងដែរ គឺថា មជ្ឈមណ្ឌលសម្រាប់អភិរក្សអក្សរសាស្ត្រដែលពាក់ព័ន្ធនឹងបងប្អូនជនជាតិចាម ហើយនិងការអភិរក្សនូវវប្បធម៌ដល់ជនជាតិចាមនេះឯង។ ចំណុចនេះខ្ញុំសូមលើកឡើងថា ដោយសារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានធ្វើឱ្យមានការប៉ះពាល់យ៉ាងធ្ងន់

ធូរទៅដល់បងប្អូនជនជាតិចាមទាំងអស់នេះ ធ្វើឲ្យគាត់បាត់បង់នូវអ្វីដែលជាទំនៀមទម្លាប់ប្រពៃណីរបស់ពួកគាត់ ដូចជាអក្សរសាស្ត្រក៏ដោយ ក៏បានបាត់បង់ផងដែរ។

ដូច្នេះ អ្វីដែលយើងស្នើសុំនេះគឺថា ចង់បង្កើតនូវចំណុចទាំងអស់នេះ ដើម្បីឲ្យមានការរួបរួមនូវជាតិសាសន៍របស់យើងឡើងវិញ។ ការផ្ដល់ផលប្រយោជន៍ទៅដល់អ្នកដែលជាដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិងជនរួមជាតិទាំងអស់ ដើម្បីជាផលប្រយោជន៍រួម ហើយទីតាំងដែលអាចសមស្របនោះគឺថា នៅក្នុងសហគមន៍ ដែលមានបងប្អូនជាច្រើន ដែលរស់នៅ គឺអាចនៅកំពង់ឆ្នាំង និងកំពង់ចាម សហគមន៍ចាម។

ដូច្នេះ ខ្ញុំបាទមានតែពីរចំណុចនេះ ដើម្បីបញ្ជាក់ជូនអង្គជំនុំជម្រះ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ជាកិច្ចបន្តអង្គជំនុំជម្រះសូមសួរទៅភាគីដទៃទៀត នៃសំណុំរឿង០០២ ថាតើមានចង់ត្រូវឡើងធ្វើការសង្កេត ឬក៏មានមតិយោបល់អ្វីតបទៅនឹងបទបង្ហាញរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានធ្វើបទបង្ហាញកន្លងមកនេះដែរឬទេ? ប្រសិនបើមាន សូមអញ្ជើញបាទ។

[១១:៤៥:០២]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ, សូមអរគុណលោកប្រធាន លោកប្រធានចៅក្រមជាទីគោរព។

ការជម្រះសេចក្ដីព្រហ្មទណ្ឌ គោលបំណងគឺថាផ្ដល់យុត្តិធម៌ យើងនិងការកំណត់បទឧក្រិដ្ឋ ហើយនិងថាតើជនជាប់ចោទមានពិរុទ្ធភាព ឬក៏អត់ ហើយនិងផ្ដល់យុត្តិធម៌ដល់ជនរងគ្រោះ ក្នុងករណីដែលយើងប្រកាសពិរុទ្ធភាព។ នៅក្នុងប្រទេសនេះ ដែលថាមានមនុស្សស្លាប់ ឬក៏នៅរស់ និងសមាជិកគ្រួសារផ្ទាល់នោះ គឺថាមានច្រើនស្មើនឹងប្រជាជននៅសម័យកម្ពុជាប្រជាធិបតេយ្យ។ សហព្រះរាជអាជ្ញានៅពេលដែលតួនាទីរបស់ខ្លួនក្នុងការរកឃើញរកឧក្រិដ្ឋកម្មនោះ ហើយនិងតំណាងឲ្យប្រយោជន៍ប្រជាជនកម្ពុជា ហើយនិងសហគមន៍អន្តរជាតិដោយផ្ទាល់ និងដោយមិនផ្ទាល់។ ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងភាគច្រើននៃប្រជាជនកម្ពុជា ដោយអាស្រ័យហេតុនេះហើយបានយើងចង់គូសបញ្ជាក់សារៈសំខាន់បំផុត មិនមែនថាវត្តមាននៃដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងដំណើរការកាត់សេចក្ដីនេះទេ ហើយនិងការអនុវត្តសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងការជម្រះសេចក្ដីនេះ តាមរយៈ

មេធាវីរបស់ខ្លួន ហើយនិងមេធាវីនាំមុខ ហើយនិងលទ្ធភាពដែលទទួលបានសំណងរបស់ពួកគាត់។ ទោះជា ជាសមូហភាព ហើយនិងផ្លូវចិត្តដែលនឹងមានលក្ខណៈជានិមិត្តរូប។

[១១:៤៥:៥១]

ជនរងគ្រោះនៅប្រទេសនេះ គឺថាអាចតាំងខ្លួនថាជាដើមបណ្តឹងរដ្ឋប្បវេណីដោយខ្លួនឯង ដោយថាការជំនុំជម្រះនេះ គឺថាដើមបណ្តឹង-- ជនរគ្រោះទាំងអស់នោះ គឺថាតំណាងឲ្យប្រយោជន៍របស់ខ្លួន គឺថាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះ គឺថាជាសំឡេងរបស់តំណាងឲ្យសំឡេងរបស់ជនរងគ្រោះទាំងអស់ ដែលទទួលរងគ្រោះពីរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះការជម្រះសេចក្តីនេះនឹងមិនអាចទៅដល់គោលដៅរបស់ខ្លួនបានទេ បើសិនជាគិតថា ជនជាប់ចោទមួយចំនួននោះ មួយ ឬក៏ច្រើននោះត្រូវកាត់ទោស។ ឧទាហរណ៍ ដូចជាក្នុងសំណុំរឿង០០១ ទៅហើយ ថាតើគាត់មិនបានទទួលសំណងទេ ដើមបណ្តឹងរដ្ឋប្បវេណីនោះ។ ហើយពេលខ្លះមិនមានការទទួលស្គាល់ឋានៈគាត់ជាដើមបណ្តឹងរដ្ឋប្បវេណី ឬការឈឺចាប់របស់គាត់ផង។

[១១:៤៦:៤៤]

ដូច្នេះមិនអាចគ្រប់គ្រាន់ទេ។ ដូច្នេះ សហព្រះរាជអាជ្ញាសូមឲ្យលើកចិត្តដល់ដើមបណ្តឹងរដ្ឋប្បវេណី មេធាវីនាំមុខ មេធាវីរបស់ខ្លួន ហើយនិងអង្គភាពគាំពារជនរងគ្រោះ រដ្ឋាភិបាលអ្នកផ្តល់មូលនិធិ ហើយនិងអាជ្ញាធរមូលដ្ឋាន ហើយនិងដៃគូមូលដ្ឋានទាំងអស់ និងអង្គជំនុំជម្រះទាំងអស់ហ្នឹងនឹងអនុវត្តធ្វើយ៉ាងណាឲ្យសំណងនេះមានខ្លឹមសារ ហើយនិងស្មើនឹងព្យសនកម្មដែលបានទទួលរង ហើយនិងធ្វើឲ្យជនរងគ្រោះទាំងអស់ ដែលទទួលបានប្រយោជន៍នៅក្នុងរយៈពេលមួយសមរម្យ ហើយនិងគម្រោងនេះត្រូវធ្វើយ៉ាងណាឲ្យមានផែនការច្បាស់លាស់ ហើយនិងមានតួលេខត្រឹមត្រូវ ហើយគាំទ្រដោយជំនួយពីខាងក្រៅ។ ហើយគម្រោងទាំងអស់នេះត្រូវឲ្យអង្គជំនុំជម្រះទទួលយកដោយអនុគ្រោះ ទោះបីជាគម្រោងនោះថាបង្កើតមុនពេលតុលាការនេះបញ្ចប់អាណត្តិរបស់ខ្លួនក៏ដោយ។ ហើយនិងមានការធ្វើការតាមដាននៅពេលក្រោយទៀត។ បាទ, ខ្ញុំសូមអរគុណ។

[១១:៤៧:៥៩]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ សហព្រះរាជអាជ្ញា សូមអញ្ជើញ!

**លោកស្រី ជា លាង៖**

សូមអរគុណ ហើយសូមគោរពសវនាការទាំងមូល។ តាងនាមឲ្យសហព្រះរាជអាជ្ញា ហើយក្នុងថា ស្វែងរកយុត្តិធម៌ឲ្យជនរគ្រោះ ហើយនិងធ្វើការកត់សម្គាល់នូវអ្វីខាងដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងមេធាវីនាំមុខទាំងពីរ ដែលបានលើកឡើងកាលពីព្រឹកមិញនេះ។

[១១:៤៨:៣៨]

ខ្ញុំសូមធ្វើការកត់សម្គាល់ជាទូទៅទៅលើផ្នែកច្បាប់ ដោយឡែកគម្រោងជាក់លាក់នោះមេធាវីនាំមុខ ក៏ដូចជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីហ្នឹង គាត់បានលើកឡើងហើយ។ ចំណុចបីដែលខ្ញុំមានការកត់សម្គាល់ គឺទីមួយ សូមឲ្យអង្គជំនុំជម្រះពិនិត្យទៅលើច្បាប់ អ.វ.ត.ក យើង ដោយត្រង់មាត្រា៣៦ថ្មី ដែលអនុញ្ញាតឲ្យជនរងគ្រោះចូលរួមក្នុងដំណើរការសាលាក្តីកូនកាត់យើងនេះ។ វាក៏ស្រប គ្នាជាមួយនឹងនីតិវិធីព្រហ្មទណ្ឌកម្ពុជា ត្រង់មាត្រា១៤ មាត្រា២ កថាខណ្ឌ២ ក៏ដូចជាមាត្រា៣៥៥ នៃនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ រួមទាំងវិធានផ្ទៃក្នុងត្រង់មាត្រា១២៣ ស្ទួនបួន និង១១៣ ផងដែរ។

[១១:៤៩:២៣]

ដូច្នេះតាមការពិនិត្យទៅលើផ្នែកច្បាប់ សំណងរដ្ឋប្បវេណីវាសំខាន់ណាស់សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ដែលជនជាប់ចោទបានប្រព្រឹត្តក្នុងករណី ដែលអង្គជំនុំជម្រះរកឃើញថា មានពិរុទ្ធភាពនោះដូចដែលមានចែងនៅក្នុងមាត្រា៣ មាត្រា៤ មាត្រា៥ និងមាត្រា៦ នៃច្បាប់ អ.វ.ត.ក។ ឧក្រិដ្ឋកម្មនោះក៏មានឧក្រិដ្ឋកម្មជាតិ ឧក្រិដ្ឋកម្មបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។ ប្រសិនបើ ធី.ស៊ី អង្គជំនុំជម្រះរកឃើញថា មានពិរុទ្ធភាព ហើយផ្តន្ទាទោសទៅលើជនជាប់ចោទ។ ប្រសិនបើមិនបានពិចារណាទៅលើចំណុចទាំងអស់នោះទេ ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក៏គ្មានន័យនៅក្នុងដំណើរការសាលាក្តីនេះដែរ។

ទីពីរយោងទៅលើមាត្រា២៣ស្ទួនបួន បានចែងអង្គជំនុំជម្រះអាចបង្គាប់អំពីសោហ៊ុយនៃសំណងត្រូវតែជាបន្ទុកពិរុទ្ធជន។ ទីពីរអង្គជំនុំជម្រះក៏អាចទទួលស្គាល់គម្រោងជាក់លាក់ណាមួយ ដែលមេធាវីនាំមុខបានស្នើសុំ និងអាចអនុវត្តបាន។ ដូច្នេះ ការលើកឡើងកាលពីព្រឹកមិញនេះ វាមានសំណើសុំច្រើនហើយអង្គជំនុំជម្រះអាចពិចារណាមើល ថាតើគម្រោងដែលស្នើសុំដោយមេធាវីនាំមុខ ក៏ដូចជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីហ្នឹង តើគម្រោងណាមួយដែលអាចអនុវត្តបាន? ដូច្នេះ នៅក្នុងមាត្រា

២៣ ស្ពួនបួនហ្នឹង គឺមានចែងច្បាស់អំពីចំណុចនេះ។

[១១:៥០:៥០]

ចំណុចទីបី ដែលយើងធ្វើការកត់សម្គាល់កន្លងមកនៅក្នុងសាលក្រមមុន មិនបានសរសេរច្បាស់លាស់អំពីសំណងនេះទេ នូវអ្វីដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំនាពេលសវនាការ។ ដូច្នេះ អង្គជំនុំជម្រះគួរបង្ហាញអំពីនីតិវិធីឲ្យបានច្បាស់លាស់ទៅ ហើយងាយស្រួលឲ្យដើមបណ្តឹងរដ្ឋប្បវេណី ឬក៏មេធាវីតំណាងហ្នឹងនាំមុខហ្នឹងរៀបចំបែបបទផ្សេងៗ ដែលពាក់ព័ន្ធទៅលើផ្នែកសំណងនេះ។ ដូច្នេះនេះជាការកត់សម្គាល់ផ្នែកច្បាប់ ហើយអ្វីៗដែលស្នើសុំជាក់លាក់នោះ ខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីគាត់បានស្នើសុំហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកជំទាវសហព្រះរាជអាជ្ញាជាតិ។

ជាកិច្ចបន្ត ខាងមេធាវីការពារក្តីតើមានអ្វីចង់កត់សម្គាល់ ឬក៏តបតទៅលើបញ្ហានៃការលើកឡើងរបស់សហមេធាវីនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដែលបានលើកឡើងពាក់ព័ន្ធជាមួយនឹងកំណត់ជាក់លាក់នូវសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានលើកឡើងអម្បាញ់មិញដែរឬទេ?

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។

ខ្ញុំមិនមានអ្វីជាការកត់សម្គាល់ទេ។ សូមអរគុណលោកចៅក្រម។

[១១:៥២:១២]

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញ!

**លោក សុន អរុណ៖**

មេធាវី សុន អរុណ សូមគោរពលោកប្រធានសាជាថ្មី។

ខ្ញុំមានគ្រាន់តែបញ្ជាក់អំមិញខាងដើមបណ្តឹងរដ្ឋប្បវេណី បាននិយាយអំពីរឿងសំណង។ ធម្មតាកាលណានៅតុលាការក្តី សំណងនៅក្រៅតុលាការក្តី បើកាលណានិយាយពីរឿងសំណងទាល់តែយើងដឹងពីរឿងព្យសនកម្មប្រាកដជាក់លាក់ បានយើងសងហ្នឹងវាត្រូវ។ អាហ្នឹងរឿងមួយ មកដល់ថ្ងៃនេះការ

ទាយទុក និងការប្រមើលមើលការប៉ាន់ស្មាន យកមកធ្វើការវិនិច្ឆ័យនៅតុលាការនេះ តាមព័ត៌មានមិនជាក់លាក់ទេ គឺ១.៧០០.០០០ ហើយមិនដឹងបានតួលេខមកពីណាទេ។ រឿងហ្នឹងមួយ។ អ៊ីចឹងមានន័យថា បើកាលណាឲ្យតុលាការសង ឬឲ្យអ្នកណាដែលធ្វើសំណងទៅដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមិនប្រឆាំងទេក្នុងរឿងនេះ ក៏ប៉ុន្តែសុំឲ្យមានព័ត៌មានជាក់លាក់ច្បាស់លាស់ ដើម្បីសំណងហ្នឹងវាត្រូវ។

[១១:៥៣:៣៨]

រឿងទីពីរ និយាយអំមិញបាន ដើមបណ្តឹងរដ្ឋប្បវេណីបានពោលពីរឿងជនភាគតិចដែលបានបាត់បង់ជីវិត ហើយត្រូវមានសំណង ឧទាហរណ៍ដូចជាជនជាតិចាម និងជនជាតិវៀតណាម។ ជនជាតិចាមខ្ញុំសូមបញ្ជាក់ថា តាមខ្ញុំដឹងមក ជនជាតិចាមជាជនជាតិខ្មែរ ដែលមានកាន់សាសនាចាមរស់នៅស្រុកខ្មែរ គឺជាខ្មែរហើយ។ ចំពោះជនជាតិវៀតណាម មានពីរយ៉ាង ម៉្យាងជនជាតិវៀតណាមពេញច្បាប់ចូលមកដោយមានច្បាប់ ម៉្យាងទៀតមិនមានច្បាប់ទេ ជាអន្តោប្រវេសន៍ខុសច្បាប់។ មិនដឹងថាតើតុលាការពិចារណាមើលគួរសង ឬមិនសង? យើងអត់ទទួលស្គាល់ថា អ្នកហ្នឹងពេញច្បាប់ក្នុងស្រុកខ្មែរស្លាប់ ឬមិនស្លាប់ អាហ្នឹងទាល់តែយករឿងទៅពិចារណាឲ្យច្បាស់លាស់ផង។ កាលណាចង់សងចង់បានដូចដើមបណ្តឹងរដ្ឋប្បវេណីពោលហ្នឹង អាហ្នឹងខ្ញុំថា ដូចជាមិនមានអីច្បាស់លាស់ជាក់លាក់ទេ សូមឲ្យធ្វើជាផែនការឲ្យបានច្បាស់លាស់ក្នុងរឿងនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ សូមអញ្ជើញលោកមេធាវី ផាត់ ពៅស៊ាង!

[១១:៥៥:០៣]

**លោក ផាត់ ពៅស៊ាង៖**

សូមគោរពអង្គសវនាការទាំងមូល!

ខ្ញុំបាទចាប់អារម្មណ៍ទៅលើចំណុចដែលដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើង គឺបញ្ហាទាមទារសំណង ដោយផ្អែកទៅតាមវិធានផ្ទៃក្នុង គឺវិធាន២៣ ស្ទួនបួន គឺសំណងមានសំណងរដ្ឋប្បវេណី--សំណងផ្លូវចិត្ត និងសំណងសមូហភាព។ ប៉ុន្តែដោយការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី គាត់ទាមទារឲ្យសំណងឲ្យជនជាតិវៀតណាម ជនជាតិចាម។ ខ្ញុំបាទយល់ឃើញថាមិនត្រឹមត្រូវ គឺនៅលើទឹកដីកម្ពុជាប្រជាជនកម្ពុជាស្លាប់ភាគច្រើន អត់មានទាមទារសម្រាប់ប្រជាជនកម្ពុជា បែរទៅទាមទារឲ្យជនជាតិភាគតិចមួយចំនួនតូច មានវៀតណាម មានចាម។ ខ្ញុំបាទកត់សម្គាល់ឃើញថា ទាំងវៀតណាម

ទាំងចាម ទាំងខ្មែរ សុទ្ធតែជាមនុស្ស គឺយើងទាមទារឲ្យមនុស្សដែលស្លាប់ត្រឹមត្រូវជាង កុំបែងចែកវៀតណាម កុំបែងចែកចាម។ ហើយយើងសួរថា ភាគច្រើនអត់ប្រយោជន៍បែរទៅជាទាមទារឲ្យភាគតិច។

[១១:៥៦:១៨]

ដូច្នេះបើតាមការសរុបចំនួនស្ថិតិជនជាតិចាមនៅលើទឹកដីកម្ពុជាមុនមានហៅថា អំពើប្រល័យពូជសាសន៍ គេកត់សម្គាល់ថា ស្ថិតិមិនផ្លូវការ មានប្រហែលជា៥០ម៉ឺននាក់។ ដូច្នេះ នៅក្នុង៥០ម៉ឺននាក់នៅក្នុងករណីហ្នឹង ហើយថាប្រជាជនកម្ពុជាភាគច្រើនដែលស្លាប់មានចំនួនច្រើនជាងប្រជាជនចាម ប្រជាជនវៀតណាម។ អីចឹងបានខ្ញុំស្នើសុំថា កុំឲ្យលើកចាម កុំឲ្យលើកវៀតណាម និយាយអំពីមនុស្សដែលស្លាប់ អ្នករងគ្រោះដែលបានស្លាប់ហើយតែប៉ុណ្ណោះបានហើយ។

ទន្ទឹមនឹងនោះ ខ្ញុំសូមជម្រាបជូនថា ប្រជាជនកម្ពុជា ខ្ញុំអត់ដែល-- អត់ឮនិយាយព្រឹកមិញទេ ថាប្រជាជនកម្ពុជាដែលស្លាប់ភាគច្រើនទាមទារឲ្យមានអីៗហូរហែអត់។ អ៊ីចឹងហើយបានខ្ញុំស្នើសុំលើកនាពេលនេះ ថាគឺស្នើសុំថាកុំឲ្យបែងចែកអ៊ីចឹង គឺទាំងវៀតណាម ទាំងចាម ទាំងខ្មែរ ខ្ញុំទទួលស្គាល់ថាមានស្លាប់ គឺសុទ្ធតែជាមនុស្សជាតិទាំងអស់។ យើងទាមទារដើម្បីមនុស្សជាតិ បាទហ្នឹងបានពាក្យសមរម្យសម្រាប់គេស្តាប់ទៅ វាសមស្រប ហើយបើលើកតែបញ្ហាហ្នឹងតែចាម ហើយនិងវៀតណាមមក ដល់អ៊ីចឹងប្រជាជនកម្ពុជាស្លាប់ទៅ ហ្អី! ខ្មែរឯងស្លាប់ភាគច្រើន អត់មានអ្នកណាលើក។

ដូច្នេះបានន័យថាអត់បានការ ឬមួយក៏យ៉ាងណា ខ្ញុំសូមកែសម្រួលឡើងវិញបញ្ហាហ្នឹង។ បាទ, សូមអរគុណ។

[១១:៥៧:៤៧]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ហើយសូមអញ្ជើញលោកមេធាវីការពារក្តី ហើយលោក សូមអញ្ជើញលោក កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម សហការី បងប្អូនសាធារណជនទាំងអស់។ ខ្ញុំសូមលើកយកវិធីដែលអនុញ្ញាតឲ្យមានការទទួលខុសត្រូវ ដោយវាមានការសងសឹក ប៉ុន្តែត្រូវមានការស្តារនីតិសម្បទាទៅវិញ។ ខ្ញុំគាំទ្រទៅនឹងសំណើសុំសំណងដែលបានដាក់ជូននេះ ខ្ញុំយល់ថានេះសម្រាប់

អង្គជំនុំជម្រះត្រូវពិចារណាទេទៅលើសំណើដែលបានស្នើសុំ គឺអ្វីដែលរដ្ឋាភិបាលអាចនឹងធ្វើទៅបាន ហើយនិងអ្វីដែលច្បាប់អនុញ្ញាតទៅបាន។ អ៊ីចឹងនោះគឺវាថាសេចក្ដីសម្រេច ឬក៏ជាច្បាប់មួយដែលត្រូវចេញពីអង្គជំនុំជម្រះតែម្ដង។ យើងខ្ញុំគាំទ្រទៅដល់រចនាសម្ព័ន្ធរដ្ឋាភិបាល ក្នុងការស្នើសុំទៅដល់ដំឡើងបូជនីយដ្ឋាន ចេតិយ ជាដើម។ល។ ខាងអង្គការឃ្លាំមើលសិទ្ធិមនុស្ស គឺជាស្ថាប័នមួយដែលពិនិត្យមើលទៅលើការរំលោភសិទ្ធិមនុស្ស ដែលគាំទ្រទៅដល់ការបង្កើតនូវអង្គការជំនួយសេវាកម្មច្បាប់ដោយមិនយកថវិកា ដែលនឹងជួយជម្រាបជូននូវដំណើររឿងនេះពេញលេញតែម្ដង មិនមែនគ្រាន់តែប្រាប់ដំណើររឿងតែពីឆ្នាំ៧៥ ទៅដល់៧៩ តែប៉ុណ្ណោះទេ។

[១១:៥៩:៣៧]

ប៉ុន្តែ អ្វីដែលបានស្នើសុំភាគច្រើននោះ គឺវាជាចំណុចមួយដែលយើងថាអាចនឹងទទួលយកបានប្រហែលជាអ្វីដែលរដ្ឋាភិបាលគួរណាស់តែធ្វើ ហើយខ្ញុំសូមលើកឡើងថា ប្រសិនណាជាតុលាការអាចលើកជាសំណើណាមួយ ខ្ញុំមិនមែនទាក់ទាញតុលាការនោះទេ ក៏ប៉ុន្តែបើតុលាការអាចបង្គាប់នូវអ្វីដែលបានស្នើសុំនេះទៅបាន នេះគឺមិនមែនមានន័យថាយើងខ្ញុំមិនគាំទ្រទៅដល់សំណើជាច្រើនដែលបានលើកឡើងនេះទេ ឬក៏គម្រោងជាច្រើនដែលបានលើកឡើងនេះទេ។ ខ្ញុំសូមប្រគល់បញ្ហានេះទុកជូនអង្គជំនុំជម្រះទៅតាមលទ្ធភាពក៏ដូចជាទៅតាមច្បាប់ ក៏ដូចជាទៅតាមអ្វីដែលអាចនឹងគិតប្រមើលទៅបានជាអ្នកសម្រេចទៅចុះ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ លោក កាណាវាស។ សូមអញ្ជើញលោក!

**លោក អាង ឧត្តម៖**

សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈ ព្រះសង្ឃ ព្រះតេជគុណ ព្រះសង្ឃគ្រប់ព្រះអង្គ។ សូមគោរពលោកប្រធាន លោកចៅក្រម សូមគោរពអង្គសវនាការ។

[១២:០១:00]

ខ្ញុំបាទមិនបន្ថែមអ្វីដែលសហភាតារបស់ខ្ញុំបានលើកឡើងទេ ហើយខ្ញុំក៏មិនលើកផ្ទួននឹងសហភាតាជាតិរបស់ខ្ញុំបានលើកដែរ តែខ្ញុំមានចំណុចមួយសូមតុលាការមេត្ដាពិចារណា។ ដើមបណ្ដឹងរដ្ឋប្បវេណីនេះ គាត់បានលើកសំណូមពរមួយសុំឲ្យផ្ដល់ជាសំណងផ្ដល់សញ្ជាតិខ្មែរដល់ពលរដ្ឋវៀតណាមដែលរងគ្រោះ។ ខ្ញុំបាទមិនយល់ទាស់ទេ ក៏ប៉ុន្តែសូមតុលាការមេត្ដាពិចារណាព្រោះថា ការសម្រេចទាំងឡាយ

វាផ្អែកទៅលើច្បាប់ យើងមិនដឹងថាច្បាប់ដែលត្រូវអនុវត្តជំនាន់នោះ អនុញ្ញាតថាពលរដ្ឋបរទេសដែលរស់នៅកម្ពុជា ដែលកាលនោះមិនទាន់មានសញ្ជាតិកម្ពុជា ហើយពេលរងវិបត្តិធ្ងន់ធ្ងរ ជួបអន្តរាយគ្រោះថ្នាក់ដល់អាយុជីវិតបែបអ៊ីចឹង តើតុលាការសម្រេចផ្តល់សញ្ជាតិជាសំណងឲ្យយ៉ាងម៉េច?

[១២:០២:០៩]

បើសិនជាឲ្យពលរដ្ឋដែលរងគ្រោះជាជនជាតិវៀតណាមជំនាន់ហ្នឹងជាសញ្ជាតិខ្មែរ ហើយកូនចៅដែលកើតមកក្រោយៗទៀតដែលសល់ពីជនរងគ្រោះវៀតណាមដែលស្លាប់ហ្នឹង តើនឹងបានទទួលសញ្ជាតិជាខ្មែរហ្នឹងដោយស្វ័យប្រវត្តិ ឬយ៉ាងម៉េច?

បើតាមការ បើខ្ញុំបាទមិនយល់ខុសទេ សញ្ជាតិបរទេសគឺយើងផ្អែកទៅលើច្បាប់របស់យើងស្តីពីសញ្ជាតិ។ ពលរដ្ឋបរទេសអាចបានសញ្ជាតិខ្មែរ ផ្អែកទៅលើកត្តាប្រហែលជាបួនក្នុងពេលបច្ចុប្បន្ននេះ។

១) គឺជនបរទេសដែលបានកើតនៅស្រុកខ្មែរ ទី២) សញ្ជាតិខ្មែរផ្តល់ឲ្យជនបរទេសតាមរយៈអាពាហ៍ពិពាហ៍ គឺបរទេសរៀបការជាមួយនឹងខ្មែរ។ ទី៣) ផ្តល់សញ្ជាតិខ្មែរឲ្យដល់វិនិយោគិនដែលវិនិយោគមួយចំនួនណាឲ្យត្រូវនឹងតម្រូវការដែលរដ្ឋាភិបាលតម្រូវ ហើយទី៤)ទាក់ទងទៅរឿងអំណោយបើសិនជាមានអំណោយផ្តល់ដល់រដ្ឋាភិបាលក្នុងចំនួនណាមួយនោះគឺអាចទទួលសញ្ជាតិខ្មែរ សញ្ជាតិកម្ពុជាបាន។ ប៉ុន្តែករណីយើងនេះ តើតុលាការនឹងផ្តល់សញ្ជាតិឲ្យជនជាតិវៀតណាមដែលស្លាប់ទៅនោះតាមមាត្រា តាមច្បាប់ណា តាមយុត្តិសាស្ត្រណា?

សូមតុលាការមេត្តាពិចារណាចំណុចនេះផងទាន សូមអរគុណ។

[១២:០៤:០៨]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ដែលបានធ្វើការកត់សម្គាល់ ហើយចុងក្រោយនេះអង្គជំនុំជម្រះប្រគល់វេទិកាជូនទៅមេធាវីជាតិ មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី នាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលមានការប៉ុនប៉ងក្នុងការឆ្លើយតប។ ហើយទីមួយ សូមសង្ខេប ហើយទីពីរ គឺបញ្ជាក់ថានេះជាការលើកឡើងចុងក្រោយនៃកិច្ចដំណើរការសវនាការសម្រាប់របៀបវារៈទីមួយនេះហើយ។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

សូមអរគុណលោកចៅក្រមប្រធាន។ សូមគោរពលោកចៅក្រមប្រធាននិងអស់លោក លោកស្រីព្រមទាំងថ្វាយបង្គំព្រះអង្គដែលមានព្រះវត្តមាននៅទីនេះសាជាថ្មី។ សូមថ្លែងអំណរគុណនូវមេធាវីរបស់

ជនជាប់ចោទដែលបានថ្លែងគាំទ្រ ហើយក៏មានការចាប់អារម្មណ៍លើបញ្ហាសំណង សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី។ ឆ្លើយទៅនឹងអ្វីដែលលើកឡើងដោយមេធាវីខាងជនជាប់ចោទ គឺមានចំណុចមួយចំនួនដែលលោកបានលើកអាចមានសារៈសំខាន់ ក៏ប៉ុន្តែមានចំណុចមួយចំនួនហាក់ដូចជាមានការដែលមិនយល់គ្នាបន្តិចបន្តួច។ ពាក់ព័ន្ធទៅនឹងសំណងនេះ ជាការពិតគឺសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែគ្រាន់តែផលវិបាកវាអាចផ្តល់ជាផលប្រយោជន៍ដល់ជនរងគ្រោះផ្សេងទៀត។ អ៊ីចឹងហើយដែលជនរងគ្រោះផ្សេងទៀត ក៏អាចទទួលផលប្រយោជន៍នៃសំណងក្រៅវិធានការតុលាការផងដែរ។

[១២:០៥:៤៥]

ចំពោះបញ្ហាដែលពាក់ព័ន្ធទៅនឹងការផ្តល់សញ្ជាតិជូនជនជាតិវៀតណាម ដែលរស់នៅឆ្លងកាត់សម័យខ្មែរក្រហមនេះ ខ្ញុំនឹងសូមទុកជនសហភាតារបស់ខ្ញុំលើក ប៉ុន្តែគ្រាន់ថាបញ្ជាក់បន្ថែមថា ច្បាប់ខ្មែរ អត់ដែលមានផ្តល់សញ្ជាតិទៅដល់ជនជាតិណា ដែលបានកើតនៅលើស្រុកខ្មែរទេ ឬក៏ថាបានរស់នៅក្នុងស្រុកខ្មែរក៏អត់ដែលមានដែរ។ ក៏ប៉ុន្តែអាចមានលក្ខខណ្ឌផ្សេងទៀត ដែលជនជាតិវៀតណាមដែលបានរស់នៅទីនេះ គាត់អាចមានលទ្ធភាពនៅក្នុងការទទួលនូវសញ្ជាតិពីមុនមក ហើយគាត់អាចបាត់បង់ឯកសារបញ្ជាក់សញ្ជាតិរបស់គាត់ ហើយសូមបញ្ជាក់ផងដែរថា ជាការពិតសំណងទាំងអស់នេះមានចំនួនច្រើន ក៏ប៉ុន្តែនឹងត្រូវមានការខំប្រឹង ដើម្បីស្វះស្វែងបំពេញគម្រោងនៃសំណងនេះឲ្យបានគ្រប់លក្ខណៈ ដើម្បីឲ្យតុលាការទទួលស្គាល់គម្រោងនេះបាន។

ហើយជាបន្តទៅទៀត សូមលោកចៅក្រមប្រធានអនុញ្ញាតលោក សំ សុគង់ បាននិយាយមួយនាទី ពាក់ព័ន្ធនឹងការផ្តល់សញ្ជាតិជូនជនជាតិវៀតណាមនេះ ដែលជាគម្រោងមួយដែលមានលក្ខណៈជាក់លាក់ ហើយដើម្បីបំភ្លឺកុំឲ្យមានការយល់ច្រឡំ ហើយបន្ទាប់មកសូមអនុញ្ញាតផ្តល់លោកស្រីមេធាវីនាំមុខអន្តរជាតិ អេលីហ្សាបេត ស៊ីម៉ុនណូហ្វូត។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញលោកមេធាវី សុគង់!

[១២:០៧:៣០]

**លោក សំ សុគង់៖**

បាទ, ជាបឋមខ្ញុំបាទសូមគោរពលោកប្រធានម្តងទៀត។ ទាក់ទងនឹងសំណង ដោយសារខ្ញុំជាមេធាវីការពារឲ្យតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលជាជនរងគ្រោះជាជនជាតិវៀតណាមដែលគាត់

រងគ្រោះនៅសម័យខ្មែរក្រហម ហើយដែលមានសហមេធាវីអន្តរជាតិឈ្មោះ លីម៉ា គាត់មិនបានមានវត្តមានថ្ងៃនេះទេ ហើយខ្ញុំបាទសូមឆ្លើយតបទៅនឹងអ្វីដែលខាងមេធាវីជនជាប់ចោទបានលើកឡើង គឺថាមូលហេតុដែលខាងក្រុមខ្ញុំដាក់សំណូមពរ ឬក៏សុំទាមទារនូវសំណងជាសញ្ជាតិឲ្យជនរងគ្រោះ ដែលជាជនជាតិវៀតណាមនោះ គឺដោយសារតែ យើងយោងទៅលើឯកសារ E125 យើងឃើញថា នៅក្នុងឯកសារនោះបានបញ្ជាក់ថា “ការផ្តល់សញ្ជាតិខ្មែរឲ្យជនរងគ្រោះជនជាតិវៀតណាមនោះ ហួសវិសាលភាព របស់ អ.វ.ត.ក”។ ត្រង់នេះហើយបានជានៅសវនាការថ្ងៃនេះ ដើមបណ្តឹងរដ្ឋប្បវេណីដែលជាមេធាវីហ្នឹងបានលើកឡើងអំពីសញ្ជាតិ ដើម្បីចៀសវាងនូវការយល់ច្រំ ក៏ដូចជាការមិនយល់គ្នាក្នុងការទាមទាររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីតំណាងឲ្យកូនក្តី ដែលជាជនរងគ្រោះជនជាតិវៀតណាមនេះ។

[១២:០៨:៥៧]

ដោយសារតែយើងឃើញមានជនជាតិវៀតណាម ដែលគាត់រងគ្រោះនៅសម័យខ្មែរក្រហម ហើយគាត់បានដាក់ពាក្យបណ្តឹងធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលាក្តី ក៏ដូចជាតុលាការកូនកាត់មួយនេះ ក្នុងគោលបំណងសំខាន់ គឺគាត់ចង់ទាមទារនូវសំណងមួយដែលគាត់មិនទាន់បានទទួលនៅឡើយនោះ។ ហើយយើងឃើញថា ក្នុងការដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ យើងឃើញថា មួយចំនួននៃពួកគាត់ត្រូវបានសហការិយាល័យចៅក្រមស៊ើបសួរ បានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងមួយចំនួនទៀតនោះក៏ត្រូវបាន ភី.ធី.ស៊ី ទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីនៅពេលថ្មីៗនេះ។ នេះបញ្ជាក់ឲ្យឃើញថា ពួកគាត់ពិតជាមានការរងគ្រោះ ឬក៏មានព្យសនកម្មពាក់ព័ន្ធនឹងសម័យខ្មែរក្រហមនោះពិតប្រាកដមែន។ ប៉ុន្តែអ្វីដែលជាការលើកឡើងពីខាងលើ គឺក្រុមមេធាវីរបស់យើងខ្ញុំចង់ឲ្យតុលាការនេះផ្តល់នូវការសម្រេចជាក់លាក់មួយ ដើម្បីឲ្យជួយសម្របសម្រួលឲ្យដល់ការសុំសញ្ជាតិរបស់កូនក្តីដែលជាជនរងគ្រោះដែលជាជនជាតិវៀតណាម ហើយដែលគាត់ចង់បានសញ្ជាតិជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជានេះ ដោយសារតែការបាត់បង់នូវឯកសារ ឬមធ្យោបាយនៅក្នុងការបញ្ជាក់បំភ្លឺ ឬបង្ហាញអំពីអត្តសញ្ញាណរបស់ពួកគាត់ដែលទាក់ទងរបួសគាត់នៅក្នុង-- ជាមួយនឹងទឹកដីកម្ពុជា នៅពេលដែលខ្មែរក្រហមគាត់បានចូលកាន់អំណាចនៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ ១៩៧៩ ហើយឯកសារទាំងនោះត្រូវបានដុតបំផ្លាញ ឬក៏ត្រូវបានធ្វើឲ្យបាត់ ឬក៏រប៉ាត់រប៉ាយបាត់មិនដឹងជានៅទីណា។ ប៉ុន្តែអ្វីដែលជាសំខាន់ គឺថាកូនក្តីខ្ញុំបាទសុំសញ្ជាតិនេះមិនមែនបានន័យថាឲ្យតុលាការគាត់សម្រេច

ផ្តល់ថាត្រូវតែផ្តល់ឲ្យសញ្ញាតិនោះទេ គឺធ្វើយ៉ាងណាដោយមានការសេចក្តីសម្រេចពីតុលាការ ហើយ សូមឲ្យមានការសម្របសម្រួល ធ្វើយ៉ាងណាឲ្យរដ្ឋាភិបាលជួយសម្របសម្រួលធ្វើយ៉ាងណាឲ្យគាត់ហ្នឹង ផ្តល់សញ្ញាតិ ឬអាចនឹងជួយសម្របសម្រួលធ្វើឲ្យមានការទទួលបាននូវសញ្ញាតិតាមរយៈតុលាការនេះ ដោយសារគាត់ជាជនរងគ្រោះពិតប្រាកដ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ជាចុងក្រោយនេះអង្គជំនុំជម្រះផ្តល់វេទិកាទៅសហមេធាវីអន្តរជាតិជា មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែពេលវេលាខ្លី សូមលោកស្រីសង្ខេប ហើយចៀសវាង ការនិយាយច្រំដែល។ សូមអញ្ជើញ!

[១២:១១:៥៩]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំគ្រាន់តែនិយាយពីរបីពាក្យទេ លោកប្រធាន ព្រោះថាយើងតំណាងឲ្យក្រុមដើមបណ្តឹងរដ្ឋប្ប-វេណីរួម ហើយខ្ញុំមិនចង់ឲ្យនៅពេលចប់សវនាការនេះទៅ គឺថាយើងនិយាយតែពីគម្រោងមួយ ឬក៏ពីរ ទេ ហើយយើងបានបង្ហាញគម្រោងច្រើន។ ខ្ញុំសូមបញ្ជាក់ថា វាប្រហែលមិនសំខាន់ទេ តែខ្ញុំចង់រំឭកពី វិធាន៨៣ ស្ទួនបួន ឬក៏អនុញ្ញាតឲ្យយើងបង្ហាញនូវគម្រោងដែលពាក់ព័ន្ធទៅនឹងក្រុមនៃដើមបណ្តឹងរដ្ឋ ប្បវេណីជាក់លាក់ណាមួយ។ ហើយនៅពេលនោះ យើងត្រូវបញ្ជាក់ថាតើសម្រាប់ក្រុមណាមួយដែល យើងធ្វើនោះ?

[១២:១២:៤៦]

ហើយប្រសិនបើវិធានផ្ទៃក្នុងអនុញ្ញាតឲ្យយើងធ្វើបែបនោះហើយ គឺមានន័យថាអង្គជំនុំជម្រះគឺ ថាត្រូវតែអនុញ្ញាតទៅតាមនោះ។ បើអ៊ីចឹងវាមិនមានការគួរឲ្យកត់សម្គាល់អីទេ បើសិនជាយើងបង្ហាញ គម្រោងហើយ តុលាការបដិសេធចោលនោះ។ ដូច្នេះ ខ្ញុំចង់បញ្ជាក់ជូនផងដែរថា ដើម្បីឲ្យវាមានច្បាស់ លាស់ ហើយដែលយើងបាននិយាយ ហើយនិងនិយាយឡើងវិញនៅក្នុងពេលធ្វើបទបង្ហាញអម្បាញ់មិញ នេះ ហើយនិងត្រូវនិយាយឡើងវិញថែមទៀតផង គឺមិនមែនជាការផ្តល់សញ្ញាតិនោះទេ។ អ្វីដែលយើង បានបញ្ជាក់ជូននោះគឺថា វាជាការសម្របសម្រួលក្នុងការទទួលបានសញ្ញាតិ។

[១២:១៣:២៦]

ចុងក្រោយនេះយើងសូមអរគុណដែរចំពោះខាងការពារក្តីដែល-- ចំពោះគោលជំហរ ហើយនិង

អរគុណដែរ ចំពោះគោលជំហររបស់សហព្រះរាជអាជ្ញាដែលបានគាំទ្រដល់តួនាទីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះ។ ដូច្នេះ សូមអរគុណយ៉ាងស្មោះស្ម័គ្រ។ ហើយជាថ្មីម្ដងទៀត ខ្ញុំចង់បញ្ជាក់ថា បទបង្ហាញរបស់យើងនៅថ្ងៃនេះ គឺពាក់ព័ន្ធនឹងក្រុមរួមនៃដើមបណ្ដឹងរដ្ឋប្បវេណី គឺមានគម្រោងជាច្រើន ហើយដែលអាចតម្រូវឲ្យមានការជជែកដេញដោលគ្នា គឺថាយើងមិនមែនថាដើម្បីទទួលយកតែគម្រោងណាមួយក្នុងចំណោមគម្រោងទាំងអស់នោះទេ។

[១២:១៤:០១]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ឥឡូវនេះឃើញថា ដល់ពេលវេលាសមរម្យនឹងសម្រាកហើយ ហើយខ្ញុំគិតថាបញ្ហានេះយើងនឹងមានពេលវេលាច្រើនទៀត នៅក្នុងអំឡុងពេលនៃដំណើរការសវនាការអង្គសេចក្ដីនោះ។ អ៊ីចឹង គឺកិច្ចដំណើរការសវនាការបង្ហាញអំពីការកំណត់ជាក់លាក់នូវសំណងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវលើកបង្ហាញដោយសហមេធាវីនាំមុខតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានការគាំទ្រដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីផ្ទាល់នោះ ឃើញថាដល់ទីបញ្ចប់ហើយ។ ហើយនៅរសៀលនេះ អង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគី អ្នកដែលត្រូវអញ្ជើញចូលរួមនៅក្នុងកិច្ចដំណើរការ ហើយនិងសាធារណជនថា សវនាការទីពីរអំពីបញ្ហាសម្បទា និងស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការនឹងចាប់ផ្ដើមធ្វើនៅរសៀលនេះចាប់ពីម៉ោងមួយកន្លះ។

ហើយឥឡូវនេះដល់ពេលត្រូវសម្រាកអាហារថ្ងៃត្រង់ហើយ ហើយអង្គជំនុំជម្រះសូមប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់បី និងសាមសិបនាទី។ នៅរសៀលនេះភាគី និងអ្នកដែលត្រូវបានអង្គជំនុំជម្រះអនុញ្ញាតឲ្យចូលរួមនៅកិច្ចដំណើរការសវនាការនៅរសៀលនិងសាធារណជនសូមអញ្ជើញចូលមកកាន់ទីកន្លែងរៀងៗខ្លួនឲ្យបានមុនម៉ោងដប់បី និងសាមសិបនាទី ដើម្បីបន្តកិច្ចដំណើរការសវនាការ។

**លោក ឌុច ផារី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:១៦ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:២៩:១៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តកិច្ចដំណើរការនីតិវិធី។ ជាកិច្ចបន្តនេះគឺសវនាការពិភាក្សាដេញដោលអ្នកជំនាញលើរបាយការណ៍របស់ពួកគាត់ ដែលបានពិនិត្យវាយតម្លៃលើសម្បទាបញ្ហាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការសវនាការ។

កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១ មេធាវីការពារក្តីជនជាប់ចោទ អៀង ធីរិទ្ធ បានដាក់ញត្តិមួយជូនមកអង្គជំនុំជម្រះ ដោយតវ៉ាអំពីបញ្ហាសម្បទា ខាងរាងកាយ និងបញ្ហាស្មារតីរបស់កូនក្តីរបស់ខ្លួនក្នុងការចូលរួមការជំនុំជម្រះ។ ការឆ្លើយតបនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានតែងតាំងសាស្ត្រាចារ្យ ចន ខាំប៊ែល អ្នកជំនាញព្យាបាលជំងឺមនុស្សចាស់ ជាអ្នកជំនាញនិងបានស្នើឲ្យគាត់វាយតម្លៃអំពីស្ថានភាពសម្បទារបស់ជនជាប់ចោទ។

[១៣:៣១:០៧]

សាស្ត្រាចារ្យ ចន ខាំប៊ែល ក៏ត្រូវបានអង្គជំនុំជម្រះស្នើសុំឲ្យរៀបចំនូវរបាយការណ៍លាយលក្ខណ៍អក្សរពាក់ព័ន្ធនឹងជនជាប់ចោទ និងបញ្ជាក់ថា តើត្រូវមានការពិនិត្យផ្នែកជំងឺផ្លូវចិត្ត ឬរបាយការណ៍ពាក់ព័ន្ធនឹងជំងឺផ្លូវចិត្តថែមទៀត ដល់ជនជាប់ចោទ ដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូងមានលទ្ធភាពសម្រេចលើបញ្ហាសមត្ថភាពខាងកាយសម្បទា និងបញ្ហាស្មារតីរបស់ជនជាប់ចោទម្នាក់ៗ ក្នុងការចូលរួមសវនាការ។

[១៣:៣១:៤១]

នៅក្នុងរបាយការណ៍ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ សាស្ត្រាចារ្យ ចន ខាំប៊ែល បានសន្និដ្ឋានថា ជនជាប់ចោទ អៀង ធីរិទ្ធ មានបញ្ហាស្មារតីនិងប្រព័ន្ធសរសៃប្រសាទ ដែលរារាំងលទ្ធភាពរបស់គាត់ក្នុងការចូលរួមពេញលេញនៅក្នុងការជំនុំជម្រះលើរូបគាត់ និងរារាំងដល់ការអនុវត្តសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌លើរូបគាត់។ ក្រោយពីមានរបាយការណ៍នេះ អង្គជំនុំជម្រះសាលាដំបូងបានតែងតាំងអ្នកជំនាញវិកលវិទ្យាចំនួនបួនរូប នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១។ សមាសភាពអ្នកជំនាញទាំងបួនរូបរួមមាន៖ វេជ្ជបណ្ឌិត ហួត លីនណា, វេជ្ជបណ្ឌិត កើត ឈុនលី, វេជ្ជបណ្ឌិត ស៊ីណា ហ្សាស៊ែល និងវេជ្ជបណ្ឌិត កាល់វីន ហ្វូនស៊ុនឡេង ដើម្បីបំពេញបន្ថែមទៅនឹងសេចក្តីសន្និដ្ឋាន

របស់សាស្ត្រាចារ្យ ខាំប៊ែល ពាក់ព័ន្ធនឹងបញ្ហាបញ្ញាស្មារតី និងប្រព័ន្ធសរសៃប្រសាទរបស់ជនជាប់ចោទ អៀង ធីរិទ្ធ។

[១៣:៣២:៥៧]

អ្នកជំនាញវិកលវិទ្យាបានពិនិត្យវាយតម្លៃសមត្ថភាពខាងកាយសម្បទា និងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ កាលពីខែកញ្ញា ឆ្នាំ២០១១ កន្លងមក។ ហើយអ្នកជំនាញទាំងអស់នោះ បានដាក់របាយការណ៍របស់ខ្លួនជូនមកអង្គជំនុំជម្រះ និងភាគី កាលពីថ្ងៃទី10 ខែតុលា ឆ្នាំ២០១១។

គោលបំណងនៃសវនាការនេះ គឺដើម្បីពិចារណាលើបញ្ហាទាំងអស់ដែលលើកឡើងនៅក្នុងរបាយការណ៍របស់អ្នកជំនាញវិកលវិទ្យា ពាក់ព័ន្ធនឹងជន់ជាប់ចោទ អៀង ធីរិទ្ធ។ អង្គជំនុំជម្រះសូមធ្វើការកត់សម្គាល់មួយចំនួនពាក់ព័ន្ធនឹងលំដាប់លំដោយនៃសវនាការនេះ។ អង្គជំនុំជម្រះសាលាដំបូងជាអ្នកផ្តើមតាំងសំណួរទៅដល់អ្នកជំនាញវិកលវិទ្យាមុននឹងផ្តល់ឱកាសដល់ភាគីជាអ្នកសួរសំណួរទៅអ្នកជំនាញ។

[១៣:៣៣:៥២]

ប្រសិនបើមានការស្នើសុំពីភាគី អង្គជំនុំជម្រះនឹងស្តាប់ការទាញហេតុផលដោយផ្ទាល់មាត់ និងបទដ្ឋានគតិយុត្តសមស្របដែលត្រូវអនុវត្តក្នុងការសម្រេចអំពីសម្បទានិងស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ។ កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ របាយការណ៍របស់អ្នកជំនាញវិកលវិទ្យាជាភាសាអង់គ្លេសត្រូវបានផ្ញើទៅកាន់ភាគីដោយដាក់ជាឯកសារសម្ងាត់បំផុត រង់ចាំការចំណាត់ថ្នាក់ជាឯកសារនោះជាស្ថាពរដោយអង្គជំនុំជម្រះ។ របាយការណ៍នេះ ជាភាសាខ្មែរ និងភាសាបារាំង ត្រូវបានជូនដំណឹងស្រដៀងគ្នានេះរួចហើយ នៅប៉ុន្មានថ្ងៃក្រោយមក គឺមុនពេលសវនាការនេះ។

នៅក្នុងដីកាកំណត់កាលបរិច្ឆេទសវនាការរបស់ខ្លួន អង្គជំនុំជម្រះស្នើសុំឱ្យភាគីយកចិត្តទុកដាក់ទៅនឹងសំណួរដូចតទៅនេះ ក្នុងអំឡុងពេលភាគីធ្វើការដេញដោលដោយផ្ទាល់មាត់នាពេលសវនាការនេះ។ តើជនជាប់ចោទរូបនេះ មួយរូបអាចត្រូវបានចាត់ទុកថា ពុំមានសម្បទាផ្នែកបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការដែរឬទេ ដោយគ្រាន់តែរកឃើញថា លក្ខណៈវិនិច្ឆ័យមួយក្នុងចំណោមលក្ខណៈវិនិច្ឆ័យនានា ដូចដែលបានបង្ហាញនៅក្នុងសំណុំរឿងក្តី *ស្ត្រូហ្គា* ត្រូវបានបំពេញនោះ ឬមួយក៏ត្រូវពិនិត្យលក្ខណៈវិនិច្ឆ័យទាំងអស់រួមបញ្ចូលគ្នា នៅពេលធ្វើការវាយតម្លៃសម្បទាជនជាប់ចោទ?

២) តើការធ្លាក់ចុះខ្សោយធ្ងន់ធ្ងរផ្នែកប្រព័ន្ធប្រសាទរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដែលសាស្ត្រាចារ្យ ចន ខាំប៊ែល និងអ្នកជំនាញវិកលវិទ្យាបានរកឃើញ ពិតធ្វើឱ្យជនជាប់ចោទរូបនេះគ្មាន

លទ្ធភាពអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ ស្របតាមបទដ្ឋានតម្រូវចាំបាច់នៅក្នុងសំណុំរឿង *ស្ទ្រូហ្កា* មែនដែរឬទេ?

៣) តើកម្រិតនៃការធ្លាក់ចុះខ្សោយធ្ងន់ធ្ងរផ្នែកសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការឆ្លើយនឹងសំណួរណែនាំមេធាវីផ្ដល់សក្ខីកម្ម យល់អំពីប្រភេទនៃបទចោទ ដំណើរការនីតិវិធី យល់លម្អិតអំពីភស្តុតាង និងលទ្ធភាពនៃកិច្ចដំណើរការនីតិវិធីបញ្ជាក់ថា ជនជាប់ចោទរូបនេះពុំមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការដែរទេ ដោយពិចារណាលើកត្តាដែលថា ជនជាប់ចោទមានមេធាវីតំណាង និងអាចអនុវត្តសិទ្ធិទាំងនេះបានមួយផ្នែកតាមរយៈមេធាវីរបស់ខ្លួននោះ?

[១៣:៣៦:៥០]

៤) ដូចដែលអ្នកជំនាញទាំងអស់បានរកឃើញថា ស្ថានភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ គឺកាន់តែទ្រុឌទ្រោមទៅៗ និងអាចពន្យារពេលកិច្ចដំណើរការនីតិវិធីមិនឈប់ឈរ ដូចជាត្រូវត្រួតពិនិត្យបន្ថែម ឬជាប្រចាំ ឬស្ថានភាពប្រចាំថ្ងៃរបស់គាត់មិននឹងនរជាដើម។ ដោយសារកត្តាទាំងនេះ អាចប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទផ្សេងទៀត ក្នុងការទទួលបានការជំនុំជម្រះក្ដីដោយឆាប់រហ័ស និងអាចអូសបន្លាយកិច្ចដំណើរការនីតិវិធីលើសំណុំរឿង០០២ទាំងមូល តើភាគីយល់ឃើញថា វាជាផលប្រយោជន៍នៃយុត្តិធម៌ដែរឬទេ ដែលត្រូវបំបែកជនជាប់ចោទ អៀង ធីរិទ្ធ ចេញពីដំណើរការនីតិវិធីទាំងនេះ ដោយអនុលោមតាមវិធាន៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដូចជាជម្រើសដើម្បីបញ្ចប់កិច្ចដំណើរការនីតិវិធីលើជនជាប់ចោទ អៀង ធីរិទ្ធ នៅពេលដែលជនជាប់ចោទត្រូវបានរកឃើញថាពុំមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមក្នុងកិច្ចដំណើរការសវនាការ។

៥) តើបច្ច័យអ្វីខ្លះចំពោះជនជាប់ចោទ អៀង ធីរិទ្ធ ដែលអាចកើតចេញពីការបំបែកកិច្ចដំណើរការនីតិវិធី ដោយអនុលោមតាមវិធាននេះ?

[១៣:៣៨:១៥]

អង្គជំនុំជម្រះជាអ្នកចាប់ផ្ដើមសួរសំណួរទៅអ្នកជំនាញអំពីបញ្ហាទាំងនេះ និងបញ្ហាផ្សេងៗ។ បន្ទាប់មក អង្គជំនុំជម្រះនឹងផ្ដល់ឱកាសដល់សហព្រះរាជអាជ្ញាជាអ្នកសួរសំណួរ។ សហមេធាវីនាំមុខអាចសួរនៅពេលបន្ទាប់ ដើម្បីឱ្យសវនាការមានប្រសិទ្ធភាព សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី គួរកម្រិតកិច្ចអន្តរាគមន៍របស់ខ្លួនត្រង់ចំណុច ដែលខ្លួនយល់ឃើញថា មានភាពខុសគ្នាពីសហព្រះរាជអាជ្ញាប៉ុណ្ណោះ។ ជាចុងក្រោយ សហមេធាវីការពារក្ដីនឹងត្រូវបានផ្ដល់ឱកាសសម្រាប់ការ

ឆ្លើយតប។

នៅពេលចប់សវនាការនេះ ក្រុមមេធាវីការពារក្តីដទៃទៀត នឹងមានឱកាសលើកឡើងអំពីផលប៉ះពាល់លើសិទ្ធិរបស់ជនជាប់ចោទផ្សេងទៀត ក្នុងការទទួលបានការជំនុំជម្រះក្តីដោយឆាប់រហ័ស។

[១៣:៣៩:១២]

ដោយសារស្ថានភាពសុខភាពធ្លាក់ចុះរបស់ជនជាប់ចោទ អៀង ធីរិទ្ធ អង្គជំនុំជម្រះនឹងស្នើសុំឲ្យក្រុមមេធាវីការពារក្តីដទៃទៀតបញ្ជាក់ថា តើការបំបែកជនជាប់ចោទ អៀង ធីរិទ្ធ ចេញពីដំណើរការនីតិវិធីដោយអនុលោមតាម ៨៩ ស្ទួនពីរ ជាផលប្រយោជន៍នៃយុត្តិធម៌ដែរឬទេ?

អនុលោមតាមវិធាន៧៩(៦) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសូមបញ្ជាក់ថា សវនាការទាំងនេះនឹងត្រូវប្រព្រឹត្តទៅជាសាធារណៈឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ ប៉ុន្តែអង្គជំនុំជម្រះធ្លាប់បានបញ្ជាក់ពីភាពចាំបាច់នៃការថ្លឹងថ្លែងរវាងសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការការពារនូវភាពសម្ងាត់របស់ឯកជនរបស់ខ្លួន អំពីព័ត៌មានខាងផ្នែកវេជ្ជសាស្ត្រទៅនឹងសិទ្ធិរបស់សាធារណជន ក្នុងការដឹងអំពីព័ត៌មានជាមូលដ្ឋាននៃការសម្រេចអំពីកាយសម្បទា និងបញ្ញាស្មារតី។

ដូច្នេះហើយសវនាការស្តីពីសម្បទា និងបញ្ញាស្មារតីជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះនឹងប្រព្រឹត្តទៅជាសាធារណៈ។ ចំណុចណាដែលភាគីយល់ថា សវនាការគួរធ្វើជាសម្ងាត់ ភាគីអាចស្នើសុំមកអង្គជំនុំជម្រះដោយផ្ទាល់មាត់ សំណើទាំងនេះនឹងត្រូវស្តាប់នៅក្នុងសវនាការជាសាធារណៈ ហើយអង្គជំនុំជម្រះនឹងអនុញ្ញាត ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា ផលប្រយោជន៍យុត្តិធម៌តម្រូវឲ្យធ្វើដូច្នេះ។

[១៣:៤១:០២]

ក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមានរបស់អ្នកជំនាញទាំងពីររូប។

**លោក ឌុច ផារី៖**

សូមគោរពលោកប្រធាន! អ្នកជំនាញទាំងពីររូបដែលអង្គជំនុំជម្រះបានកោះហៅ គាត់មានវត្តមានរួចហើយ។ រង់ចាំការកោះហៅពីអង្គជំនុំជម្រះដើម្បីចូលមកកាន់បន្ទាប់សវនាការ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ មន្ត្រីតុលាការសូមអញ្ជើញអ្នកជំនាញទាំងពីររូប ដែលមានវត្តមាននៅពេលនេះចូលមកកាន់ទីកន្លែង។

[១៣:៤១:៣៥]

សួស្តីលោកអ្នកជំនាញ! ជាដំបូងនេះអង្គជំនុំជម្រះ សូមសួរទៅអ្នកជំនាញជាតិជាមុនទាក់ទិននឹងសាវតារ និងភាពពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធី។ លោកអ្នកជំនាញជាតិ តើនាមត្រកូល និងនាមខ្លួនរបស់លោក ហួត លីនណា អ៊ីចឹងពិតមែនដែរឬទេ?

[១៣:៤២:២៤]

**លោក ហួត លីនណា៖**

បាទៗ ពិតមែនបាទ។

**ប្រធានអង្គជំនុំ៖**

លោក ហួត លីនណា តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

**លោក ហួត លីនណា៖**

៤៨ឆ្នាំហើយ។

**ប្រធានអង្គជំនុំ៖**

តើសព្វថ្ងៃនេះលោកមានមុខរបរធ្វើអ្វីដែរ?

**លោក ហួត លីនណា៖**

ខ្ញុំបាទមានជំនាញជាវេជ្ជបណ្ឌិតឯកទេសវិកលវិទ្យា ហើយធ្វើការនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មានឋានៈជាប្រធានផ្នែក។

[១៣:៤៣:០៣]

**ប្រធានអង្គជំនុំ៖**

ទីលំនៅរបស់លោកបច្ចុប្បន្ននៅទីកន្លែងណាដែរ?

**លោក ហួត លីនណា៖**

ទីលំនៅបច្ចុប្បន្នរបស់ខ្ញុំបាទ គឺនៅផ្ទះលេខ២៩១ E0 ផ្លូវកម្ពុជាក្រោម ខាងកើតភោជនីយដ្ឋានលី ឡាយ ភ្នំពេញ។

**ប្រធានអង្គជំនុំ៖**

តាមសេចក្តីរាយការណ៍ផ្ទាល់មាត់របស់ក្រឡាបញ្ជីកាលពីព្រឹកមិញ ថាលោកបានធ្វើសម្បថរួចហើយ មុននឹងលោកចូលមកកាន់បន្ទប់សវនាការនេះ តើពិតមែនដែរឬទេ?

**លោក ហួត លីនណា៖**

បាទៗ ពិតមែនបាទ។

[១៣:៤៣:៣៤]

**ប្រធានអង្គជំនុំ៖**

អរគុណលោក ហួត លីនណា។ ជាបន្តអង្គជំនុំជម្រះសូមសួរទៅលោកអ្នកជំនាញអន្តរជាតិ។ តើនាមត្រកូល និងនាមខ្លួនរបស់លោក ស៊ីណា ហ្វាស៊ែល អ៊ីចឹងពិតមែនដែរទេ?

**លោក ស៊ីណា ហ្វាស៊ែល៖**

បាទ, ខ្ញុំឈ្មោះដូច្នោះមែន។

**ប្រធានអង្គជំនុំ៖**

តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

**លោក ស៊ីណា ហ្វាស៊ែល៖**

ខ្ញុំអាយុ៤២ឆ្នាំ។

**ប្រធានអង្គជំនុំ៖**

តើលោកមានទីលំនៅសព្វថ្ងៃនៅទីកន្លែងណា? ប្រទេសណាដែរ?

**លោក ស៊ីណា ហ្វាស៊ែល៖**

ខ្ញុំរស់នៅទីក្រុង អុកហ្វ៊ឺត នៃចក្រភពអង់គ្លេស។

**ប្រធានអង្គជំនុំ៖**

តើលោកមានមុខរបរសព្វនេះធ្វើអ្វីដែរ?

[១៣:៤៤:៣៤]

**លោក ស៊ីណា ហ្វាស៊ែល៖**

ខ្ញុំជាសាស្ត្រាចារ្យជាន់ខ្ពស់ផ្នែករិកលវិទ្យានីតិវេជ្ជសាស្ត្រ។

**ប្រធានអង្គជំនុំ៖**

ដោយអនុលោមតាមវិធាន៣១(២) នៃវិធានផ្ទៃក្នុង អ.វ.ត.ក លោកសាស្ត្រាចារ្យក្នុងនាមជាអ្នកជំនាញ លោកត្រូវធ្វើសម្បថ ឬសច្ចាប្រណិធានតាមជំនឿសាសនារបស់ខ្លួនជាមុនសិន មុននឹងផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះ។

លោកស្រី ហ្វៃហ្សា ជួយសម្របសម្រួលដល់លោកអ្នកជំនាញ ដើម្បីឱ្យធ្វើសម្បថឬសច្ចាប្រណិធាននៅចំពោះមុខអង្គជំនុំជម្រះជាមុនសិន មុននឹងឱ្យគាត់ផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងរបាយការណ៍អ្នកជំនាញ។

**លោក ស៊ីណា ហ្វាស៊ែល៖**

ខ្ញុំសូមប្រកាសសច្ចាថានឹងជួយអង្គជំនុំជម្រះដោយស្មោះត្រង់ ដោយគោរពគោលការណ៍រក្សាការណ៍សម្ងាត់ និងឱ្យអស់ពីសមត្ថភាពរបស់ខ្ញុំ។

[១៣:៤៥:៤២]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

សូមអរគុណលោកសាស្ត្រាចារ្យ។

ជាកិច្ចបន្តអង្គជំនុំជម្រះសូមសួរទៅលោកសាស្ត្រាចារ្យ ស៊ីណា ហ្វាស៊ែល។

**ស៖** តើលោកអាចជម្រាបដល់អង្គជំនុំជម្រះបានទេ អំពីគុណវុឌ្ឍិដោយបញ្ជាក់អំពីភាពជំនាញនិងបទពិសោធន៍របស់លោក ពាក់ព័ន្ធនឹងឯកទេសខាងវិកលវិទ្យា? បើបាន សូមអញ្ជើញបាទ!

**លោក ស៊ីណា ហ្វាស៊ែល៖**

**ឆ៖** ខ្ញុំអាចជម្រាប ខ្ញុំសិក្សាវេជ្ជសាស្ត្រនៅសាកលវិទ្យាល័យអាដាមប្រា។ ខ្ញុំទទួលការបណ្តុះបណ្តាលផ្នែកវិកលវិទ្យានៅអុកហ្វឺត ដែលនៅទីនោះខ្ញុំក៏ជាអ្នកស្រាវជ្រាវទៅលើជំងឺវិកលវិទ្យារបស់មនុស្សចាស់ ហើយខ្ញុំក៏ទទួលការបណ្តុះបណ្តាលថ្នាក់ជាន់ខ្ពស់ នៅក្នុងជំនាញកោសល្យវិច័យផ្នែកវិកលវិទ្យា ដែលបានបញ្ចប់នៅក្នុងឆ្នាំ២០០២។ តាំងពីពេលនោះមករហូត ខ្ញុំបានបម្រើការងារជាអ្នកសិក្សាស្រាវជ្រាវ ហើយនិងជាគ្រូពេទ្យក្នុងជំនាញកោសល្យវិច័យផ្នែកវិកលវិទ្យា។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកសាស្ត្រាចារ្យ។

ជាបន្តអង្គជំនុំជម្រះសូមសួរទៅលោកវេជ្ជបណ្ឌិត ហ្វូត លីនណា។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** តើលោកសាស្ត្រាចារ្យ-- លោកវេជ្ជបណ្ឌិតអម្បាញ់មិញលោកបានបញ្ជាក់ហើយលោកជាប្រធានផ្នែកនៃជំងឺចិត្តសាស្ត្រនៃមន្ទីរពេទ្យមិត្តភាពកម្ពុជាសូវៀត អ៊ីចឹងមែនដែរទេ?

**លោក ហួត លីនណា៖**

**ឆ៖** បាទ, មែនបាទ។

**ស៖** ហើយតាមជីវប្រវត្តិរបស់លោក ក៏លោកជាសាស្ត្រាចារ្យបង្រៀនមុខវិជ្ជាជំងឺផ្លូវចិត្តដល់និស្សិតវេជ្ជសាស្ត្រនៃសាកលវិទ្យាល័យវេជ្ជសាស្ត្រសុខាភិបាល អ៊ីចឹងពិតមែនដែរទេ?

**ឆ៖** បាទៗ មែនបាទ។

**ស៖** លោកវេជ្ជបណ្ឌិតតើលោកអាចជម្រាបដល់អង្គសវនាការបានដែរទេ អំពីគុណវុឌ្ឍិបញ្ជាក់អំពីភាពជំនាញ និងបទពិសោធន៍របស់លោកពាក់ព័ន្ធនឹងឯកទេសខាងវិកលវិទ្យានេះ?

[១៣:៤៨:១២]

**ឆ៖** ខ្ញុំបាទបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យសុខាភិបាលភ្នំពេញ ថ្នាក់វេជ្ជបណ្ឌិត នៅឆ្នាំ ១៩៩០ ហើយបន្ទាប់មកខ្ញុំធ្វើការនៅផ្នែកសង្គ្រោះបន្ទាន់ ផ្នែកម្ភូត្រសាស្ត្រ ហើយនិងផ្នែករោគកុមារខ្លះៗ ហើយដល់ឆ្នាំ៩៤ ខ្ញុំបានទទួលការបណ្តុះបណ្តាលដោយសាកលវិទ្យាល័យអូស្លូនៃប្រទេសន័រវេស ដើម្បីឲ្យក្លាយខ្លួនទៅគ្រូពេទ្យឯកទេសវិកលវិទ្យាជំនាន់ទី១ នៅកម្ពុជា ក្នុងជំនាន់នោះមានគ្នាដប់នាក់។ បន្ទាប់មកទៀត ខ្ញុំត្រូវបានក្រសួងសុខាភិបាលជ្រើសរើសឲ្យទៅបន្តការសិក្សានៅប្រទេសអូស្ត្រាលី ដោយឆ្លងកាត់ការប្រឡងប្រជែងជាច្រើន ដើម្បីខ្ញុំបាទបានទទួលអាហារូបករណ៍ពីអូសអេដ គឺវាវាអក្សរកាត់វាអង្គការជំនួយអន្តរជាតិរបស់ប្រទេសអូស្ត្រាលី ដើម្បីឲ្យខ្ញុំបាទទៅរៀនយកថ្នាក់អនុបណ្ឌិតជំងឺផ្លូវចិត្តនៅសាកលវិទ្យាល័យមូណាស ហើយខ្ញុំបានបញ្ចប់នៅខែ៤ ឆ្នាំ២០០១ ហើយខ្ញុំបញ្ចប់ឯកទេសផ្នែកវិកលវិទ្យា ដែលបណ្តុះបណ្តាលដោយសាកលវិទ្យាល័យអូស្លូវនោះនៅឆ្នាំ៩៨ ហើយ៩៩ ខ្ញុំបន្តសិក្សាផ្នែកអនុបណ្ឌិត ចាប់ពី៩៩ រហូតដល់២០០១។ បន្ទាប់មក ខ្ញុំបាទធ្វើការនៅមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត ហើយសព្វថ្ងៃនេះខ្ញុំមានឋានៈជាប្រធានផ្នែកជំងឺផ្លូវចិត្តនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។ សូមអរគុណ។

[១៣:៥០:០០]

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកវេជ្ជបណ្ឌិត។

មុននឹងចាប់ផ្តើមនូវការធ្វើបង្ហាញអំពីរបាយការណ៍ និងកិច្ចពិភាក្សាដេញដោល យើងខ្ញុំសូមធ្វើការបញ្ជាក់ដល់លោកអ្នកជំនាញទាំងពីររូបថា នៅក្នុងការធ្វើរបាយការណ៍ ក៏ដូចជាការឆ្លើយតបនឹងសំណួរទាំងឡាយដែលអង្គជំនុំជម្រះ និងភាគីនឹងតាំងសំណួរសួរចំពោះអ្នកជំនាញបន្ទាប់ពីមានការបង្ហាញ

ខ្លីនេះទៅ។ អស់លោកអ្នកជំនាញអាចធ្វើការរួមគ្នា ដោយធ្វើការបែងចែកគ្នាតាមការស្ម័គ្រចិត្តឬតាមការស្រុះស្រួលគ្នារវាងអ្នកជំនាញទាំងពីរ ឬម្នាក់ក្នុងចំណោមអ្នកទាំងពីរជាអ្នកធ្វើការបង្ហាញ ឬឆ្លើយតបជាសរុបក៏បាន។ ទាក់ទងនឹងការឆ្លើយនឹងសំណួរដែលអង្គជំនុំជម្រះ ហើយនិងភាគីនឹងធ្វើការសួរប្រសិនបើសំណួរមានលក្ខណៈទូទៅ មិនសំដៅទៅលើអ្នកជំនាញណាមួយទេ អ្នកជំនាញម្នាក់ក្នុងចំណោមអ្នកទាំងពីរ អាចឆ្លើយនឹងសំណួរនោះ ហើយអ្នកជំនាញម្នាក់ទៀតអាចបំពេញបន្ថែម ឬក៏នៅស្ងៀមមិនឆ្លើយតបក៏បាន។

[១៣:៥១:១១]

ទាក់ទងនឹងបញ្ហានៃការធ្វើបទបង្ហាញសង្ខេប ក៏ដូចជាការឆ្លើយតបនឹងសំណួរអ្នកជំនាញទាំងពីរអាចកំណត់ដោយខ្លួនឯងថា អ្នកណាជាអ្នកធ្វើការបង្ហាញ ឬជាអ្នកធ្វើការឆ្លើយតប។ អង្គជំនុំជម្រះសូមរំឭកផងដែរថា វាជាការសំខាន់ខ្លាំងណាស់នៅក្នុងការនិយាយឱ្យបានយឺតៗ តាមលំដាប់លំដោយដើម្បីងាយស្រួលដល់អ្នកបកប្រែភាសាផ្លូវការ និងគប្បីចៀសវាងផងដែរក្នុងការប្រើប្រាស់បច្ចេកទេសមានលក្ខណៈជ្រៅពេក ប្រសិនបើអាចធ្វើទៅបាន ដើម្បីបង្កលក្ខណៈឱ្យបានច្បាស់លាស់ និងងាយយល់។

ហើយជាកិច្ចបន្តនេះ ដើម្បីឱ្យដំណើរការប្រព្រឹត្តទៅឱ្យបានល្អនោះ អង្គជំនុំជម្រះយើងខ្ញុំសូមប្រគល់នាទីនេះជូនទៅលោកស្រីចៅក្រម ស៊ីលវៀល ខាតវ៉ាយថ៍ ដើម្បីបន្តតាំងសំណួរចំពោះអ្នកជំនាញទាំងពីររូប។ សូមអញ្ជើញលោកស្រី!

**សួរដោយចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ជាបឋមលោកវេជ្ជបណ្ឌិត លីនណា ហើយនិងលោក ហ្វាស៊ែល អង្គជំនុំជម្រះសូមអរគុណលោកទាំងពីរដែលបានធ្វើការងារនេះ ហើយនិងជួយដល់អង្គជំនុំជម្រះ ហើយបានមកធ្វើសក្ខីកម្មលើការងារពិនិត្យនោះនៅថ្ងៃនេះ។

**ស៖** លោកទាំងពីរជាសមាជិកក្នុងចំណោមអ្នកជំនាញទាំងបួន តាមពិតនោះដែលជាអ្នកធ្វើការពិនិត្យ ហើយនិងធ្វើរបាយការណ៍លើរូបអ្នកស្រី អៀង ធីរិទ្ធ អំពីស្ថានភាពផ្លូវចិត្ត និងរបស់គាត់ តើត្រឹមត្រូវទេលោក? ហើយលោកមានអ្នកពីរនាក់ទៀត គឺ កើត ឈុនលី ហើយនិងលោក កាល់វីន ហ្វូន ។

[១៣:៥៣:០៨]

**លោក ស៊ីណា ហ្វាស៊ែល៖**

**ឆ៖** ត្រឹមត្រូវហើយ។

**ស៖** ហើយនៅក្នុងនោះដែរ ដែលទទួលបានការអប់រំមកពីប្រទេស ន័រវ៉េស ហើយគាត់ក៏បានធ្វើការនៅក្នុងវិស័យវិកលវិទ្យានៅសហភាពសូវៀត មិត្តភាពសូវៀត-ខ្មែរ លោក កើត ឈុនលី ហើយគាត់ជាសាស្ត្រាចារ្យអមផ្នែកវិកលវិទ្យា នៅក្នុងវិទ្យាល័យវិជ្ជាសាស្ត្រសុខាភិបាលនៅភ្នំពេញ តើមែនដែរឬទេ?

**ឆ៖** ពិតមែន។

**ស៖** សូមអរគុណ។ ហើយបន្ទាប់ពីយើងទុកចន្លោះពេលបន្តិច ទុកឲ្យភ្លើងពណ៌ក្រហមទើបលោកវេជ្ជបណ្ឌិតអាចឆ្លើយទៅចូលប្រព័ន្ធ។ ហើយលោកវេជ្ជណ្ឌិត កាល់វីន ហ្វូន ជាអ្នកជំនាញខាងចិត្តសាស្ត្រព្យាបាល ហើយជាសាស្ត្រាចារ្យអមនៃសាកលវិទ្យាល័យ យ៉ុងឡូលិន នៃសាកលវិទ្យាល័យសិង្ហបុរី តើមែនដែរឬទេ?

**ឆ៖** បាទ, ពិតមែនហើយ។

**ស៖** ជាបឋមខ្ញុំនឹងសួរលោកឲ្យលោកបញ្ជាក់ថា តើការងាររបស់លោកទាំងពីរដូចម្ដេច ហើយខ្ញុំនឹងនិយាយសង្ខេប បន្ទាប់មកខ្ញុំនឹងចូលទៅដល់ចំណុចទូទៅ ខ្លឹមសារទូទៅមុននឹងចូលទៅដល់ពិភាក្សាលម្អិតជាមួយលោកវេជ្ជបណ្ឌិតអំពីរោគវិនិច្ឆ័យ ហើយនិងការឆ្លើយតបទាក់ទងទៅនឹងសំណួរជាក់លាក់និងបញ្ហាមួយចំនួនដែលលើកឡើងដោយសហព្រះរាជអាជ្ញា ហើយនិងដោយមេធាវីការពារក្ដីរបស់អ្នកស្រី អៀង ធីរិទ្ធ។ ហើយក្នុងការធ្វើបែបនោះ ខ្ញុំនឹងធ្វើការផ្អែកលើរបាយការណ៍របស់លោក ចុះថ្ងៃទី១៩ តុលា ឆ្នាំ២០១១ ហើយខ្ញុំនឹងដាក់ជូនរបាយការណ៍នេះដល់អង្គជំនុំជម្រះ។

ជាបឋមការងាររបស់លោកទាំងពីរ លោកទាំងបួនហ្នឹងគឺថា សូមឲ្យលោកបញ្ជាក់ដូចខាងក្រោមនេះ៖

តុលាការបានស្នើឲ្យលោកធ្វើការសហការគ្នា នៃអ្នកជំនាញចិត្តសាស្ត្រវិកលវិទ្យាទាំងបួនទៅពិនិត្យលោកស្រី អៀង ធីរិទ្ធ ហើយតុលាការបានបង្គាប់ឲ្យលោកធ្វើរបាយការណ៍រួមមួយ តើមែនដែរឬទេ?

**ឆ៖** បាទ, មែន។

**ស៖** សូមកោតសរសើរចំពោះការងារដែលអស់លោកបានធ្វើបែបនោះ គឺថាខ្ញុំមិនគិតថាមេធាវីអាចនឹងធ្វើការងារដ៏លំបាកនេះបានទេ។

[១៣:៥៥:៤០]

នៅក្នុងរបាយការណ៍នោះ ការងារនោះគឺបាន តុលាការបានស្នើសុំឲ្យធ្វើរបាយការណ៍លើបញ្ហាមួយចំនួន សូមឲ្យបន្ថែមសេចក្តីសន្និដ្ឋានដែលបញ្ជាក់ទៅលើរបាយការណ៍របស់លោក ខាំប៊ែល នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំនេះ ដែលនិយាយអំពីការចុះខ្សោយសតិបញ្ញារបស់អ្នកស្រី អៀង ធីរិទ្ធ ហើយដោយសារលោកជាសាស្ត្រាចារ្យអ្នកជំនាញខាងវិកលវិទ្យា ដើម្បីពិនិត្យមើលសម្បទារបស់គាត់ក្នុងការចូលរួមការជំនុំជម្រះមើលអំពីសម្បទានៃការសតិបញ្ញា ថាតើមានទិដ្ឋភាពណាមួយនៃស្ថានភាពផ្លូវចិត្តដែលថាផ្សារភ្ជាប់ទៅនឹងស្ថានភាពផ្លូវវេជ្ជសាស្ត្រ ដែលអាចនឹងធ្វើឲ្យមានការកែប្រែស្ថានភាពដែរឬទេ? ហើយតុលាការ ក៏បានសួរដើម្បីឲ្យផ្តល់យោបល់ថា តើវាមានការចុះខ្សោយ ឬក៏វាយតម្លៃពីការកើនឡើងពីស្ថានភាពផ្លូវចិត្តដែរឬទេ?

[១៣:៥៦:៤២]

**ធ៖** បាទ, មែនហើយ។

**ស៖** សូមអរគុណ។ តុលាការក៏បានសូមឲ្យលោកវាយតម្លៃអំពីស្ថានភាពផ្លូវចិត្ត អំពីប្រាំចំណុចដែលត្រូវបញ្ជាក់លម្អិតនៅពេលក្រោយនៅក្នុងការពិនិត្យ តើដូច្នេះដែរឬទេ?

**ធ៖** បាទ, មែនហើយ។

**ស៖** តាមពិតចៅក្រមបានសូមឲ្យលោកឆ្លើយទៅបញ្ហាមួយចំនួន ដែលលើកឡើងដោយសហព្រះរាជអាជ្ញា ហើយនិងមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ?

[១៣:៥៧:១៨]

**ធ៖** បាទ។

**ស៖** ហើយតុលាការក៏បានស្នើឲ្យលោកពិនិត្យមើល របាយការណ៍វេជ្ជសាស្ត្រពីមុនៗ ហើយហើយនិងរបាយការណ៍របស់សាស្ត្រាចារ្យ ខាំប៊ែល ផងដែរ ដើម្បីពិភាក្សាជាមួយអ្នកជំនាញខាងវេជ្ជសាស្ត្រ ហើយនិងអ្នកជំនាញមុនៗដែលបានព្យាបាលអ្នកស្រី អៀង ធីរិទ្ធ នៅក្នុងការឃុំខ្លួនដើម្បីផ្តល់គំនិតមកតុលាការអំពីរបាយការណ៍ ហើយនិងវិធីធ្វើតេស្តដែលលោកម្នាក់ៗបានធ្វើនៅក្នុង-- ជាពិសេសតេស្តដែលបានធ្វើពីមុនៗ ដែលលោកយកមកប្រើជាមូលដ្ឋាន ដើម្បីបញ្ចប់របាយការណ៍របស់អស់លោក។ តុលាការក៏បានស្នើសុំឲ្យផ្តល់មតិមកវិញ ថាតើត្រូវមានការវិភាគផ្លូវវេជ្ជសាស្ត្រផ្សេងទៀតទេដែលត្រូវការមកប្រើ ដើម្បីឲ្យអង្គជំនុំជម្រះអាចកំណត់សេចក្តីសម្រេច តើចំណុចទាំងអស់នេះជាសេចក្តីសង្ខេបពីការងាររបស់អស់លោកទាំងអស់គ្នាដែរឬទេ?

**ឆ៖** បាទ, មែន។

[១៣:៥៨:១៧]

**ស៖** សូមអរគុណ។ ដូច្នេះមុននឹងចូលដល់ទៅនឹងការតេស្តដែលលោកម្នាក់ៗបានធ្វើ ហើយនិងសម្រេចដល់សេចក្តីសន្និដ្ឋាននោះ ខ្ញុំសូមឲ្យខ្លឹមសារទូទៅអំពីការត្រៀមរៀបចំរបស់លោក ដែលលោកបានធ្វើ ហើយថាតើមើលឯកសារអ្វីខ្លះទាក់ទងទៅនឹងរបាយការណ៍ផ្ទាល់មាត់ ទាក់ទងទៅនឹងវេជ្ជបណ្ឌិតអ្នកដែលព្យាបាលថែទាំ អៀង ធីរិទ្ធ នោះ។ ដោយមិនទាន់បានប្រាប់អំពីលទ្ធផលអំពីការពិគ្រោះយោបល់ថាតើលោកអាចបញ្ជាក់ប្រាប់យើងខ្ញុំបានទេ តើលោកបានធ្វើការពិនិត្យ អៀង ធីរិទ្ធ ដោយខ្លួនឯងដែរឬទេ?

**ឆ៖** យើងបានពិនិត្យលោកស្រី អៀង ធីរិទ្ធ នៅក្នុងឱកាសបីដង គឺថានៅថ្ងៃទី១២ កញ្ញា នៅពេលល្ងាច ហើយនិងពីរដង ព្រឹកផងល្ងាចនៅថ្ងៃនោះ។

[១៣:៥៩:១៤]

**ស៖** សូមអរគុណ។ តើលោកអាចបញ្ជាក់ថាតើលោកបានពិភាក្សា ជាមួយអ្នកណាខ្លះជាឧទាហរណ៍នៅពេលដែលលោកពិនិត្យ អៀង ធីរិទ្ធ អំពី ស៊ីធីស្កេន ចុងក្រោយថ្មីបំផុត ដែលថាអ្នកណាខ្លះដែលបានផ្តល់យោបល់ដល់លោក? ហើយទាក់ទងទៅនឹងគ្រូពេទ្យ ដែលជាផ្នែកនៃអ្នកផ្តល់ការព្យាបាលវេជ្ជសាស្ត្រដល់អ្នកស្រី អៀង ធីរិទ្ធ នោះ?

**លោក ហ្វួត លីនណា៖**

**ឆ៖** ជាដំបូងខ្ញុំ ក្រុមឯកទេសទាំងបួននាក់ហ្នឹងបានជួបលោកដុកទ័រ ចំរើន ដែលជាគ្រូពេទ្យធ្វើការនៅមន្ទីរពេទ្យកាល់ម៉ែត ហើយគាត់បានពិនិត្យព្យាបាលអ្នកស្រី អៀង ធីរិទ្ធ។ បន្ទាប់ក្រុមយើងខ្ញុំទាំងបួននាក់បានជួបលោកវេជ្ជបណ្ឌិត ហៃ លៀង គាត់ឯកទេសខាងរូបភាពវេជ្ជសាស្ត្រដែលធ្វើការនៅមន្ទីរពេទ្យកាល់ម៉ែត ហើយគាត់បានបង្ហាញ និងបកស្រាយ ហ្វីលស៊ីធីស្កេន បីដល់ពួកយើងខ្ញុំបាទ។

ហើយជាបន្ថែមទៀតខ្ញុំបានសាកសួរលោក ម៉ៅ សុភារម្យ ដែលជាប្រធានមន្ទីរឃុំឃាំងនៅ អ.វ.ត.ក នេះ។

**ស៖** សូមអរគុណ។ ឥឡូវនេះ យើងបានពិនិត្យរួចហើយនូវរបាយការណ៍ដែលទាក់ទងទៅនឹងលោកស្រី អៀង ធីរិទ្ធ នៅក្នុងសវនាការពីមុន នៅពេលដែលយើងពិនិត្យរបាយការណ៍របស់សាស្ត្រាចារ្យ ខាំប៊ែល ប្រហែលជាលោកអាចបន្ថែមអំពីរបាយការណ៍ផ្សេងៗទៀត ដែលលោកយល់ថាមាន

សារៈសំខាន់នៅក្នុងរបាយការណ៍ជំនាញ។ លោកអាចនឹងពង្រីកការបកស្រាយទៅលើរបាយការណ៍ទាំងអស់នៅក្នុងដំណាក់កាលក្រោយ ប៉ុន្តែសូមគ្រាន់តែរាប់ថាតើមានរបាយការណ៍អីខ្លះ?

ចំណុចទីមួយ របាយការណ៍ដែលថាគាត់ចូលព្យាបាលនៅបំរ៉ុងរ៉ាត់នៅក្នុងខែមករា ឆ្នាំ២០០៦ តើលោកអានពិនិត្យរបាយការណ៍នោះដែរឬទេ ជារបាយការណ៍វេជ្ជសាស្ត្រ?

[១៤:០១:៤២]

**ឆ៖** យើងខ្ញុំបានពិនិត្យសេចក្តីសង្ខេបនៃការថែទាំក្នុងរយៈពេលប៉ុន្មានខែក្រោយពីការចូលព្យាបាលដោយរាប់បញ្ចូលទាំងរោគវិនិច្ឆ័យ ហើយនិងការថែទាំនៅដើមឆ្នាំ២០០៦ នោះភាគច្រើន។

**ស៖** សូមអរគុណ។ លោកក៏មានឱកាសក្នុងការពិនិត្យរបាយការណ៍ជាទៀងទាត់ដែលរាប់បញ្ចូលទាំងចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧ ហើយថ្ងៃទី២៨ កុម្ភៈ ឆ្នាំ២០០៨ ដែលមានសេចក្តីសង្ខេបអំពីសុខភាពផ្លូវកាយរបស់គាត់ តើលោកបានធ្វើដូច្នោះទេ?

**ឆ៖** បាទ, មែន។

**ស៖** ហើយតាមពិតលោកបានពិនិត្យ ស៊ីធីស្កេន ខួរក្បាលបីជាមួយលោក ហេង លាង ហើយវេជ្ជបណ្ឌិតម្នាក់ទៀតដែលគេបានថតពីមុន តើមែនដែរឬទេ?

**ឆ៖** បាទ, មែន។

[១៤:០២:៤៧]

**ស៖** ហើយការពិនិត្យអំពីប្រព័ន្ធប្រសាទដោយសាស្ត្រាចារ្យ ខាំប៊ែល ជាផ្នែកមួយ ការវាយតម្លៃលើ អៀង ធីរិទ្ធ ដើមឆ្នាំនេះ តើលោកបានពិនិត្យមើលរបាយការណ៍នោះដែរឬទេ?

**ឆ៖** បាទ, មែន។

**ស៖** សូមអរគុណ។ ជាលទ្ធផលនៃការពិភាក្សារបាយការណ៍ទាំងអស់នោះ ការពិនិត្យហើយនិងការពិនិត្យដែលលោកបានធ្វើ តើលោកអាចផ្តល់មតិដល់សេចក្តីសន្និដ្ឋានរបស់លោកដល់តុលាការអំពីសម្បទាផ្លូវកាយរបស់គាត់ ថាតើមានការព្រួយបារម្ភអ្វីជាក់លាក់ ដោយពិនិត្យមើលការងារដែលលោកបានធ្វើហ្នឹង នៅពេលដែលលោកបានពិនិត្យរបាយការណ៍ផ្ទៀងផ្ទាត់របស់គាត់មកនោះ?

**ឆ៖** យើងខ្ញុំរកឃើញថា មានការយោងដោយស្របគ្នាទាក់ទងទៅនឹងសុខភាពផ្លូវកាយរបស់គាត់ ដោយរាប់បញ្ចូលទាំងសម្ពាធឈាមខ្ពស់ ជាបញ្ហាសន្លាក់ឆ្អឹង ឈឺជង្គង់ ហើយនិងប្រវត្តិពីមុនអំពីការរំលាយអាហារ ដែលទទួលបានការព្យាបាលដោយប្រើថ្នាំ ហើយនិងមិនមានបញ្ហាអ្វីក្រៅពីហ្នឹងដែល

សំខាន់នោះទេ។

**ស៖** តាមមតិរបស់លោក តើបច្ចុប្បន្ននេះគាត់បានទទួលការព្យាបាលគ្រប់គ្រងត្រឹមត្រូវទេ?

**ឆ៖** បាទ, មែន។

**ស៖** បន្ទាប់មកទៀត គឺថារបាយការណ៍បន្ទាប់ពីគាត់ចូលទៅមន្ទីរពេទ្យនៅថ្ងៃនោះដែលបានបញ្ជាក់ខាងដើមនៅបំរុងរ៉ាត់នោះ ខ្ញុំសូមឲ្យលោកបញ្ចេញមតិយោបល់ទៅលើរបាយការណ៍ដែលគេបញ្ជាក់ថា គាត់មានស្ថានភាពជំងឺខាងផ្លូវចិត្ត តើលោកមានយោបល់អ្វីដែរ?

**ឆ៖** លោកស្រី អៀង ធីរិទ្ធ គឺត្រូវបានរកឃើញរោគវិនិច្ឆ័យថា គឺជាជំងឺបញ្ហាសរសៃប្រសាទទាក់ទងទៅនឹងសរីរាង្គ ដែលទាក់ទងទៅនឹងចំណាត់ថ្នាក់ជំងឺរបស់អន្តរជាតិនោះគឺថាជំងឺវង្វេងវង្វាយគឺថាអាចកើតឡើងចំពោះមនុស្សគឺថា ដោយមិនរងការបះពាល់ខាងការចុះខ្សោយអារម្មណ៍នោះទេ។ ប៉ុន្តែគឺថាជំងឺដែលវាកើតឯកឯង ប៉ុន្តែចំពោះមនុស្សចាស់វាជារឿងទូទៅទេ។ ប៉ុន្តែជំងឺនេះមិនទាក់ទងជាចាំបាច់ទៅលើបញ្ហាជំងឺផ្លូវចិត្ត ជំងឺ--។ តាមយោបល់របស់យើងការវង្វេងវង្វាយនេះត្រូវបានព្យាបាលហើយលោកស្រី អៀង ធីរិទ្ធ មិនមានរោគសញ្ញាផ្លូវចិត្ត អំពីជាបន្តមកទេតាំងពីឆ្នាំ២០០៦ មកនោះ។

**ស៖** សូមអរគុណ។ លោកក៏បានពិភាក្សាការងារជាមួយបុគ្គលមួយចំនួនដែលបានព្យាបាលលោកស្រី អៀង ធីរិទ្ធ តាមគោលការណ៍ទៀងទាត់ ហើយអ្នកផ្សេងទៀតដែលថា អ្នកមិនមែនជាវេជ្ជបណ្ឌិតដូចជា លោក សុភារម្យ ដែលលោកវេជ្ជបណ្ឌិត លីនណា បានលើកឡើងខាងដើម។ តើលោកអាចបញ្ជាក់ពីបញ្ហាជាក់លាក់ដែលទាក់ទងទៅនឹងការពិគ្រោះយោបល់អ្នកទាំងនោះដែរឬទេ?

[១៤:០៦:២៦]

**ឆ៖** ខ្ញុំគិតថា ខ្ញុំសូមបញ្ជាក់ចំណុចបី ទីមួយគឺថាមក ដុកទ័រ សំរិន មកពីមន្ទីរពេទ្យកាល់ម៉ែតគាត់បានផ្តល់-- វេជ្ជបណ្ឌិត ចំរើន នោះគាត់បានផ្តល់ឧទាហរណ៍ព័ត៌មានថាស្ថានភាពរបស់លោកស្រីអៀង ធីរិទ្ធ នោះគឺថាមិនកែប្រែទេ គឺចាប់ផ្តើមតាំងពីមានការបន្ថយថ្នាំក្នុងរយៈពេលមួយខែ ពីរខែមកនេះ ទស្សនៈរបស់គាត់នោះគឺថា មិនមានការកែប្រែជាក់ស្តែងទាក់ទងទៅនឹងសតិបញ្ញាយល់ដឹង ហើយនិងអាកប្បកិរិយារបស់គាត់ទេ។

[១៤:០៧:១២]

ទាក់ទងទៅនឹងការជួបជាមួយលោក សុភារម្យ ដែលគាត់បានផ្តល់ឲ្យយើងនូវព័ត៌មានមួយចំនួនដែលយើងអាចដាក់បញ្ចូលជាមួយនឹងការពិនិត្យ និងអ្នកផ្សេងទៀតនៅក្នុង ជាពិសេសគឺយើងឃើញថា

គាត់មានបញ្ហានៅក្នុងការចងចាំ នៅទីបំផុតនោះយើងបានជួបនិយាយជាមួយអ្នកជំនាញខាងវិទ្យុសាស្ត្រ លោកវេជ្ជបណ្ឌិត ហេង លាង លោកបានពន្យល់ជួយយើងពន្យល់ពិនិត្យមើលស៊ីធីស្កេន ហើយការចាប់អារម្មណ៍របស់យើង បន្ទាប់ពីការពិភាក្សាជាមួយគាត់នោះ គឺថាអ្វីដែលពិពណ៌នាថា ជំងឺដំណើររួមតូចនៃខួរក្បាលនោះគឺថា យើងយល់តាមការសន្និដ្ឋាននោះ ហើយវាមានលទ្ធភាពនៃជំងឺខួរក្បាល បើនិយាយអំពីភស្តុតាងនៃការដុំពក សាច់ពក ឬក៏ដុំសាច់នោះគឺថា មិនបានបង្ហាញច្បាស់ទេនៅក្នុងរបាយការណ៍ទាំងនោះ។

[១៤:០៨:២៤]

**ស៖** សូមអរគុណ។ នៅក្នុងកថាខណ្ឌ២០ ទៅដល់ ២៥ របស់របាយការណ៍របស់លោកនោះ លោកបានពន្យល់អំពីប្រភេទនៃការសម្ភាសន៍ជាមួយលោកស្រី អៀង ធីរិទ្ធ នៅក្នុងឱកាសបីដាច់ៗពីគ្នានៅក្នុងរយៈពេលពីរថ្ងៃ។ វាអាចនឹងមានប្រយោជន៍ ប្រសិនបើលោកអាចពន្យល់អំពីតេស្ត អំពីការវាយតម្លៃដែលលោកទាំងអស់បានធ្វើ ជាពិសេសនិយាយជាសង្ខេប។ ហើយបន្ទាប់មក យើងនឹងត្រឡប់មកពេលក្រោយទៅនឹងរោគវិនិច្ឆ័យដែលឆ្លើយតបទៅនឹងសំណួរជាក់លាក់នោះ។

**ឆ៖** ខ្ញុំបាទបានពិនិត្យគាត់ បានសាកសួរគាត់ ហើយបានធ្វើតេស្តខ្លះដូចជាគេហៅថា *មីនីមេនសិន ស្តេត អ៊ិចសាមីណេសិន* (និយាយភាសាអង់គ្លេស) អាហ្នឹងមិនដឹងថាខ្មែរយើងបកថាម៉េចទេ ប៉ុន្តែធ្វើតេស្តទាក់ទងទៅជាមួយនឹង *ខកនីធីវ ហ្វាំងសិន* (cognitive function) ទាក់ទងជាមួយនឹងបញ្ហាស្មារតីរបស់គាត់ ហើយយើងយកអាតេស្តនេះ គេហៅថា *មីនីមេនសិន ស្តេត អ៊ិចសាមីណេសិន (MMSE)* ហ្នឹងគឺជាតេស្តមួយដែលគេប្រើជាញឹកញាប់ដើម្បីរកឲ្យឃើញថា តើបុគ្គលម្នាក់ហ្នឹងមានការចុះខ្សោយផ្នែកបញ្ហាស្មារតីដែរឬទេ? ហើយនៅក្នុងធ្វើតេស្តហ្នឹង គឺថានៅថ្ងៃទីមួយ គឺថាយើងធ្វើតេស្តវាទាក់ទងទីមួយ គឺគេហៅថា *អូរៀន ថេសិន* (orientation)។ *អូរៀន ថេសិន* នេះ យើងក្នុងនោះមានជាពីរផ្នែក សំណួរទាក់ទងពីយើងសួរអំពីថា តើគាត់មិនដឹងពីឆ្នាំ? ពីរដូវ? ពីកាលបរិច្ឆេទ ពីថ្ងៃ ពីខែឬទេ? នៅលើកទីមួយហ្នឹងសួរទៅ គាត់អត់ឆ្លើយអត់បានទេ គាត់អត់ដឹងទេ។ ដូច្នេះបានពិន្ទុសូន្យ។ ហើយលើកទីពីរ ក្នុង *អូរៀន ថេសិន* ហ្នឹងដែរ យើងសួរពីរឿងថា គាត់នៅកន្លែងណា? សួរពីប្រទេស ពីខេត្ត ពីទីក្រុង ពីផ្លូវ ឬក៏ពីការិយាល័យអី សួរទៅគាត់ឆ្លើយបានពីរចំណុច គាត់ដឹងថា គាត់នៅភ្នំពេញ គាត់ដឹងថា គាត់នៅប្រទេសកម្ពុជា។ ដូច្នេះគាត់បានពីរពិន្ទុបាទ។

[១៤:១០:៥២]

ហើយលើកទីពីរ យើងសួរដែរគាត់បានពីរពិន្ទុដែរ គាត់ឆ្លើយត្រូវបានតែពីរ។ ដូច្នេះគាត់បើគាត់ឆ្លើយត្រូវទាំងអស់ ត្រូវបានដប់ អ៎!មួយៗបានប្រាំ ប៉ុន្តែគាត់ឆ្លើយត្រូវបានតែពីរ។ ហើយជាកិច្ចបន្តយើងនឹងបានសួរគាត់ឲ្យគាត់រាប់ឈ្មោះវត្ថុ និយាយតាមយើងនូវវត្ថុបី។ វត្ថុបីៗ ហើយគាត់ឆ្លើយបាន ហើយគាត់រាប់តាមយើងបាន ហើយគាត់បានពិន្ទុពេញនៅថ្ងៃទីមួយ។ ហើយថ្ងៃទីពីរសួរដែរ ក៏គាត់បានពិន្ទុពេញដែរ គឺបី។

ជាបន្តមកទៀត យើងធ្វើតេស្តទៅលើ គេហៅថា *អាត់ថិនសិន* និង *កាល់ឃូលេសិន* គឺការផ្ចង់អារម្មណ៍ និងការគិតលេខ។ ហើយពេលនោះយើង ឬ-- យើងឲ្យសួរគាត់ សួរគាត់ឲ្យ អាហ្នឹងសួរអាហ្នឹងក៏បាន ឬក៏យើងឲ្យ គាត់ ដោយសារគាត់ចេះភាសាអង់គ្លេស យើងឲ្យគាត់*ស្ពែល* ឲ្យគាត់ប្រកបពាក្យ *វើល* ហ្នឹង *វើល* ដែលបកប្រែជាភាសាខ្មែរថា ពិភពលោក ហ្នឹង *ស្ពែល ហ្វ័រវត* ហើយ *ប៉ែកវត* មានន័យថាប្រកបទៅមុខ ហើយប្រកបមកក្រោយវិញ។ ហើយយើងឲ្យគាត់ធ្វើទៅ នៅថ្ងៃមួយគាត់និយាយបានត្រូវតែមួយពាក្យទេ ដូច្នេះបានពិន្ទុតែមួយទេ។

[១៤:១២:០០]

ហើយដល់ថ្ងៃទីពីរ យើងសួរគាត់ដដែលទៀត ធ្វើតេស្តដដែលទៀត គាត់ឆ្លើយត្រូវទាំងអស់ គាត់បាន ដូច្នេះគាត់បានប្រាំពិន្ទុ។ ដល់ពេល រយៈពេលក្រោយមកយើងសួរឡើងវិញៗ តើគាត់មានចាំទេអាវត្ថុបីយ៉ាងដែលយើងសួរកាលពីលើកមុនហ្នឹង កាលពីប៉ុន្មាននាទីមុនហ្នឹង។ គាត់អត់អាចរំឭកឡើងវិញបានទេ នូវរបស់បីយ៉ាងដែលយើងប្រាប់គាត់ឲ្យថាតាមហ្នឹង គាត់ភ្លេចគាត់ថា អត់កើតទេ។ ដូច្នេះបើសិនជាគាត់ឆ្លើយត្រូវ គាត់ត្រូវបានបីពិន្ទុ ប៉ុន្តែឆ្លើយអត់បាន គាត់ដូច្នេះគាត់បានពិន្ទុសូន្យ។ លើកទីពីរយើងសួរធ្វើតេស្តដូចគ្នាដែរ គាត់ឆ្លើយអត់បានដែរ ហើយបានពិន្ទុសូន្យដដែល។

[១៤:១២:៤៧]

ហើយទាក់ទងនឹងភាសា យើងសួរឲ្យគាត់ស្គាល់ទេ? ស្គាល់ យើងលើកប៊ិចទៅ លើកនាឡិកាទៅឲ្យគាត់ឆ្លើយ គាត់ស្គាល់ គាត់ឆ្លើយបាន។ ដូច្នេះថ្ងៃទីមួយ ក៏គាត់ឆ្លើយត្រូវគាត់បានពីរពិន្ទុ ហើយថ្ងៃក្រោយមកទៀតគាត់ឆ្លើយបានទៀត បានពីរទៀត ដូច្នេះគាត់បានពីរពិន្ទុទៀត។ ហើយយើងឲ្យគាត់ថាតាមនូវឃ្លាមួយថា *ណូ- អ៊ីស- អ៊ែន- អ័រ- បាត់* ហ្នឹងយើងថាអ៊ីចឹងទៅ គាត់ថាតាមយើងបាន។ ដូច្នេះគាត់បានមួយពិន្ទុ។ ហើយថ្ងៃទីពីរ យើងសួរគាត់ទៀត គាត់ក៏បានក៏ឆ្លើយបានទៀត គាត់បានមួយពិន្ទុទៀត។

[១៤:១៣:២៣]

ហើយយើងបានធ្វើការ *អ៊ិនស្ត្រាក់* មានន័យថា ធ្វើបង្គាប់ឲ្យគាត់ធ្វើតាមបញ្ជារបស់យើង គឺថាឲ្យយកដៃស្តាំទៅកាន់ក្រដាសមួយសន្លឹក ហើយបត់ពាក់កណ្តាល ហើយដាក់នៅលើឥដ្ឋ។ ហើយគាត់ធ្វើតាមការណែនាំរបស់យើងបានទាំងបីដំណាក់កាល។ ដូច្នេះគាត់ធ្វើបាន ដូច្នេះគាត់បានបីពិន្ទុ។ ហើយលើកទីពីរ ថ្ងៃទីពីរយើងធ្វើអ៊ីចឹងទៀត គាត់ធ្វើបានទៀត គាត់ធ្វើតាមយើងបាន ដូច្នេះគាត់បីពិន្ទុទៀត។ ហើយតេស្តមួយទៀតយើងឲ្យគាត់សរសេរអក្សរថា បិទភ្នែក អ៊ីចឹង ហើយគាត់អានបាន ហើយគាត់ធ្វើតាម ហើយគាត់បិទភ្នែកតាមពាក្យហ្នឹងទៀត។ ដូច្នេះគាត់បាន ថ្ងៃទីមួយក៏បានបានមួយពិន្ទុ ហើយថ្ងៃទីក៏គាត់ធ្វើបានដែរ បានមួយពិន្ទុទៀត។

[១៤:១៤:២០]

ហើយបន្ទាប់មកទៀត យើងឲ្យគាត់សរសេរជាឃ្លាៗ គឺសំដៅលើមានប្រធាន មានកិរិយាស័ព្ទនិងមានកម្មបទ។ ចង់និយាយថា ជាឃ្លា ជាឃ្លាពេញ ហើយគាត់សរសេរបាន។ គាត់សរសេរជាភាសាអង់គ្លេសផង ពេលនុ៎ងគាត់សរសេរ *អាយ វ៉ន ធូ ស្លីក អ៊ីងគ្លីស* គាត់ក៏សរសេរជាភាសាអង់គ្លេស អ៊ីចឹងគាត់សរសេរបាន។ ដូច្នេះថ្ងៃទីមួយគាត់សរសេរបាន គាត់បានមួយពិន្ទុ។ ហើយដល់ពេលថ្ងៃពីរ ឲ្យគាត់សរសេរទៅ គាត់សរសេរអត់កើត គាត់អត់សរសេរទេ ដូច្នេះគាត់បានសូន្យពិន្ទុ។

[១៤:១៤:៥៣]

ហើយតេស្តបន្តបន្ទាប់យើងឲ្យគាត់គូពីនូវរូបបញ្ចកោណពីរ ដែលខ្វែងគ្នាដែលជាប់គ្នាហ្នឹង។ យើងឲ្យគាត់គូរហើយគាត់គូរបានគាត់គូរតាមបាន ហើយគាត់គូរបានថ្ងៃទីមួយក៏គាត់គូរកើត ថ្ងៃទីពីរក៏គាត់គូរកើត។ អ៊ីចឹងគាត់បានមួយពិន្ទុថ្ងៃមួយ ថ្ងៃទីពីរក៏គាត់បានមួយពិន្ទុដែរ ហើយយើងសរុបពិន្ទុគាត់ថ្ងៃទីមួយគឺបាន១៥លើ៣០ ហើយថ្ងៃទីពីរបាន១៨លើ៣០។ ហើយក្នុងនេះគេបកស្រាយថា ប្រសិនបើយើងបានពិន្ទុពី២១ ទៅ ២៦ មានន័យថាអាការបញ្ញាស្មារតីរបស់យើងចុះខ្សោយដែរ ប៉ុន្តែនៅក្នុងកម្រិតតិចតួច។ តែបើសិនជាយើងនៅចន្លោះពី១០ ទៅ ២០ គឺអាហ្នឹងការចុះខ្សោយខាងបញ្ញាស្មារតីយើងហ្នឹង *អា ខកនីធីវ ហ្វាំងសិន* យើងហ្នឹងវាថយចុះកម្រិតមធ្យម។ តែពិន្ទុយើងបានតិចជាង១០ មានន័យថាកម្រិតនៃការបាត់បង់បញ្ញាស្មារតីយើងហ្នឹង គឺយើងធ្ងន់ធ្ងរ។ ហើយលោកស្រី អៀង ធីរិទ្ធ គាត់បានពិន្ទុ១៥ថ្ងៃទីមួយ ១៨នៅថ្ងៃទីពីរ គឺគាត់នៅចន្លោះពី១០ ទៅ២០នេះគឺនៅក្នុងកម្រិតមួយមធ្យម។

[១៤:១៦:២៥]

**លោក ស៊ីណា ហ្វាស៊ែល៖**

**ឆ៖** ខ្ញុំសូមអនុញ្ញាតបន្ថែមចំណុចមួយចំនួន។ បើនិយាយតាមន័យទូទៅ យើងបានការពិនិត្យប្រភេទបី។ ទីមួយ គឺយើងពិនិត្យមើលស្ថានភាពផ្លូវចិត្តបញ្ញាស្មារតីរបស់គាត់ ជាការសម្ភាសន៍ខាងពេទ្យវិកលវិទ្យាទាក់ទងទៅនឹងអាកប្បកិរិយា អារម្មណ៍ ហើយនិងរោគសញ្ញាខាងជំងឺផ្លូវចិត្ត ហើយនិងសម្តីសំឡេងនិយាយនេះជាប្រភេទនេះដែលយើងត្រូវធ្វើ កាលណាយើងនិយាយអំពីមុខងារសតិបញ្ញារបស់គាត់។ បន្ទាប់មក យើងត្រូវធ្វើតេស្តជាក់លាក់និយាយអំពីសតិបញ្ញានេះ ទាក់ទងទៅនឹងអ្វីដែលលោកវេជ្ជបណ្ឌិត ហ្វូត លីនណា បាននិយាយអម្បាញ់នេះគឺថា ដែលនិយាយថា ការពិនិត្យទៅលើស្ថានភាពផ្លូវចិត្តកម្រិតអប្បបរមាហៅថា អឹម.អេស.អ៊ី ហើយនិងមានប្រភេទមួយទៀត ដែលវាយតម្លៃអំពីមុខងារសតិបញ្ញាដែរនោះគឺ រៀបរាប់អំពីមុខងារប្រតិបត្តិដែលជាលទ្ធភាពនៃសតិបញ្ញាក្នុងការវិនិច្ឆ័យការគិតគូរ ហើយនិងការធ្វើសេចក្តីសម្រេច ហើយនិងការផ្តល់ហេតុផលដែលមិនត្រូវបានវាស់វែងគ្រប់គ្រាន់តាមវិធី អឹម.អឹស.អេស.អ៊ី នេះទេ។

[១៤:១៧:៥៨]

បន្ទាប់មកទៀត ដែលយើងបន្ថែមតេស្តអំពីសតិបញ្ញានេះ ជាមួយនឹងការចោទសួរទាក់ទងទៅនឹងការចងចាំដែលមិនមែនផ្នែកនៃឧបករណ៍ធ្វើតេស្តផ្លូវការទេ ប៉ុន្តែយើងគិតថាវាមានការទាក់ទងឧទាហរណ៍យើងសួរសំណួរ ដែលទាក់ទងទៅនឹងការចងចាំរយៈពេលយូរ ការចងចាំរយៈពេលខ្លីយើងសួរអំពីឱកាសបីដាច់ពីគ្នាដើម្បីរកឲ្យឃើញ ដើម្បីវាស់វែងមើលថាតើកម្រិតតើវាមានការចុះខ្សោយសតិបញ្ញាកម្រិតណា ហើយនៅទីបំផុតយើងសួរសំណួរមួយចំនួនទាក់ទងទៅនឹងសម្បទាក្នុងការចូលរួមក្នុងការជំនុំជម្រះលក្ខណៈវិនិច្ឆ័យមួយចំនួននោះ។ ម្តងទៀត ដែលយើងសួរតាមវិធីផ្សេងៗនៅក្នុងការជួបគាត់បីដងដាច់ពីគ្នា ហើយយើងគោរពទៅតាមលក្ខណៈវិនិច្ឆ័យមួយចំនួន ដែលចែងនៅក្នុងដីកាចាត់តាំងអ្នកជំនាញរបស់យើង ហើយសំណួររបស់យើងហ្នឹងគឺថា យើងនឹងនិយាយលម្អិតទាក់ទងទៅនឹងលក្ខណៈវិនិច្ឆ័យនីមួយៗ។

[១៤:១៩:០៨]

ដូច្នេះនិយាយដោយសង្ខេបគឺយើងប្រើប្រភេទបី។ ទីមួយគឺថា តេស្តដើម្បីវាយតម្លៃពីមុខងារសតិបញ្ញាហៅថា អឹម.អឹម.អេស.អ៊ី ហើយមួយទៀត គឺតេស្តទាក់ទងទៅនឹងការណែនាំបង្គាប់របស់អង្គជំនុំជម្រះនោះឯង។

**ស៖** សូមអរគុណ។ នេះជាសេចក្តីពន្យល់សង្ខេបដ៏មានសារប្រយោជន៍ដល់យើងខ្ញុំ។ លោកទាំងពីរ ដូចជាបានដល់សេចក្តីសន្និដ្ឋានមួយ ទាក់ទងទៅនឹងការចុះខ្សោយសតិបញ្ញារបស់លោកស្រី អៀង ធីរិទ្ធ តើនៅក្នុងដំណាក់កាលតេស្តពីមួយទៅមួយ តើលោកបញ្ជាក់ថាថ្ងៃមួយនោះគាត់អន់ ថ្ងៃមួយទៀតនោះគាត់ប្រសើរ ហើយមានថ្ងៃមួយទៀតគាត់មិនព្រមឆ្លើយ ថាតើចំណុចនេះជាកត្តាចង្អុលបង្ហាញពីបញ្ហាសេចក្តីសន្និដ្ឋានខាងផ្លូវចិត្តរបស់គាត់ដែរឬទេការដែលជួបបែបនេះ?

**ឆ៖** បាទ, វាជាបញ្ហាទូទៅចំពោះបុគ្គលដែលមានបញ្ហាសតិបញ្ញាចុះខ្សោយ ឬឡើងចុះដែលថាវាស្របទៅនឹងបុគ្គលផ្សេងៗទៀតដែលមានបញ្ហាផ្លូវចិត្តដែរ មិនទាក់ទងតែការចុះខ្សោយមុខងារសតិបញ្ញានោះទេ។ ប៉ុន្តែក៏វាមានជំងឺវិបល្លាសនៃបញ្ញាស្មារតីដែរ ដែលវាមានចុះឡើងនោះ ដែលវាថាមិនមែនជាអចិន្ត្រៃយ៍ ប៉ុន្តែវាស្របគ្នាដែលថា ម្តងចាំ ម្តងមិនចាំនោះ។

**ស៖** សូមអរគុណ ខ្ញុំសូមសួរបន្ថែមទៀត។ នៅក្នុងរបាយការណ៍របស់លោក លោកបានលើកឡើងអំពីការប្រើប្រាស់ផ្លាស់ប្តូរពាក្យរវាងការចុះខ្សោយសតិបញ្ញា និងបញ្ហាវិកលចរិត។ ហើយលោកបានលើកឡើងថា លោកបានលើកឡើងលក្ខណៈវិនិច្ឆ័យរោគជាលក្ខណៈអន្តរជាតិ។

ដូច្នេះថាតើលោកអាចពន្យល់អំពីគោលការណ៍ណែនាំចំពោះលក្ខណៈវិនិច្ឆ័យនោះដែរឬទេ? ហើយគោលបំណងនោះគឺដើម្បីអ្វី?

**ឆ៖** ខ្ញុំអាចពន្យល់បានទាំងអស់នេះ។ គឺជាការណែនាំដែលបានបង្កើតឡើងនៅក្នុងអង្គការសុខភាពពិភពលោក។ ខ្ញុំប្រើប្រាស់គោលការណ៍ណែនាំនេះ ជាអន្តរជាតិដើម្បីធ្វើការរកអំពីបញ្ហាវិកលចរិត និងបញ្ហាផ្លូវចិត្ត។ គោលការណ៍ណែនាំនេះ គឺវាមានលក្ខខណ្ឌចំនួនដប់ ហើយវាបានបង្កើតនិងវិវត្តន៍ក្នុងរយៈពេលដប់ ឬក៏ម្ភៃឆ្នាំចុងក្រោយនេះ។ ខ្ញុំក៏មិនដឹងថា ឆ្នាំដំបូងដែលគេប្រើប្រាស់នៅក្នុងឆ្នាំណានោះដែរ។ យើងហៅវាថាជា អាយ.ស៊ី.ឌី-ថេន (ICD-10) វាគឺជាការកំណត់ប្រភេទជំងឺជាលក្ខណៈអន្តរជាតិចំនួនដប់ថ្នាក់។

[១៤:២២:០៨]

គោលការណ៍ណែនាំទាំងនេះគឺវាផ្តល់ជាលក្ខណៈវិនិច្ឆ័យសម្រាប់ការវិនិច្ឆ័យរោគ ហើយគោល-ការណ៍ណែនាំនេះ គឺវាផ្តល់ព័ត៌មានថាតើបុគ្គលម្នាក់នោះ បានត្រូវតែលក្ខខណ្ឌនេះត្រឹមកម្រិតណា ហើយចំពោះលក្ខខណ្ឌដែលខ្ញុំបានពិនិត្យមើលទៅលើប្រវត្តិទាំងឡាយនោះ វាមានចំណុចមួយចំនួនដែលយើងត្រូវដក មិនដាក់បញ្ចូលនោះទេក្នុងការវិនិច្ឆ័យ។

ដូច្នេះជាការសង្ខេបមកវិញ អាយ.ស៊ី.ឌី នេះគឺជាគោលការណ៍ណែនាំលក្ខណៈវិនិច្ឆ័យអន្តរជាតិ វាជាសំណុំលក្ខណៈវិនិច្ឆ័យ គេប្រើនៅអាមេរិកខាងជើង ហើយគេបានយោងទៅលើចំណុចលក្ខខណ្ឌ វិនិច្ឆ័យទៅលើបញ្ជីកំណត់លក្ខណៈវិនិច្ឆ័យដែលវាមានលក្ខណៈស្រដៀងគ្នា។ ដូច្នេះយើងប្រើ *អាស៊ីឌី ថេន* នេះដោយសារតែវាជាលក្ខណៈវិនិច្ឆ័យជាលក្ខណៈអន្តរជាតិ។ ហើយគេបានប្រើប្រាស់ជាលក្ខណៈ អន្តរជាតិនៅក្នុង ឌី.អេស.អ៊ឹម ផងដែរ។

**ស៖** សូមអរគុណលោកច្រើន។ លោកវេជ្ជបណ្ឌិត លីនណា និងលោកវេជ្ជបណ្ឌិត ហ្វាស៊ែល ផលវិបាកក្រោយពីការធ្វើកោសល្យវិច័យ និងពិនិត្យទៅលើរបាយការណ៍ លោកបានធ្វើការពិគ្រោះ យោបល់ជាបុគ្គលិកពេទ្យផងដែរ ហើយអ្នកដែលនៅកៀកនឹងលោកស្រី អៀង ធីរិទ្ធ ហើយលោកក៏បាន ធ្វើការកោសល្យវិច័យជំនាញទៅលើលោកស្រី អៀង ធីរិទ្ធ ផងដែរ។ ហើយលោកក៏បានធ្វើការវិនិច្ឆ័យ ទៅលើលោកស្រី អៀង ធីរិទ្ធ។

ដូច្នេះ តើលោកអាចធ្វើការរៀបរាប់អំពីរោគវិនិច្ឆ័យបានដែរឬទេ? ហើយអាចជួយពន្យល់ឲ្យ យើងយល់តាមកថាខណ្ឌម្ដងៗ មួយកថាខណ្ឌម្ដងៗ ចាប់ពីកថាខណ្ឌទី២៧ទៅនៅក្នុងរបាយការណ៍ កោសល្យវិច័យរបស់លោក។

[១៤:២៤:១៣]

ដោយសារតែការវិនិច្ឆ័យរោគនេះ គឺវាពាក់ព័ន្ធទៅនឹងការចាត់តាំង ការងារទៅកាន់លោកដែល លោកត្រូវឆ្លើយតបទៅនឹងសំណួរដែលបានលើកឡើងដោយខាងមេធាវីការពារក្ដី និងខាងសហព្រះរាជ អាជ្ញា។ ដូច្នេះហើយសូមឲ្យលោកជួយពន្យល់នៅក្នុងរបាយការណ៍របស់លោក ដែលលោកបានលើក ឡើង។ សូមអរគុណ។

**ឆ៖** ខ្ញុំសូមធ្វើការពន្យល់ យើងយល់ឃើញថា លោកស្រីមានជំងឺខាងផ្នែកវិកលចរិត។ ដូច្នេះ យើងបានធ្វើការពិនិត្យមើលរបាយការណ៍មុនៗ ហើយយើងប្រមូលព័ត៌មានឲ្យបានច្រើនអំពីប្រវត្តិបុគ្គល រូបនេះជាមួយនឹងប្រវត្តិវេជ្ជសាស្ត្ររបស់លោកស្រី អៀង ធីរិទ្ធ ផងដែរ។ ហើយយើងធ្វើកោសល្យវិច័យ ដោយផ្អែកតាមជំនាញរបស់យើងក្នុងរយៈពេលពីរថ្ងៃ។ ហើយយើងក៏បានពិភាក្សាក្នុងចំណោមអ្នក ជំនាញរបស់យើងខ្ញុំ។ ដូច្នេះហើយយើងរកឃើញជាឯកច្ឆន្ទទៅលើចំណុចនេះ ជាពិសេសដើម្បីបំពេញ ទៅតាម អាយ.ស៊ី.ឌី លក្ខណៈវិនិច្ឆ័យ អាយ.ស៊ី.ឌី នេះ យើងឃើញមានចំណុចចំនួនប្រាំដែលយើង ត្រូវបំពេញ ហើយយើងបានពិនិត្យទៅលើលក្ខណៈចំនួនប្រាំនោះ។

ដូច្នេះយើងឯកភាពគ្នាជាឯកច្ឆន្ទនៅក្នុងក្រុមរបស់យើង លក្ខខណ្ឌទីមួយគឺការធ្លាក់ចុះនៃការចងចាំដែលយើងរកឃើញ ដែលវាបានបង្ហាញតាមរយៈព័ត៌មានថ្មីៗដែលយើងទទួលបាន។ ដូច្នេះហើយព័ត៌មានទាំងអស់នេះគឺយើងឃើញថា វាមានការធ្លាក់ចុះនៃការចងចាំនៅពេលដែលយើងធ្វើកោសល្យ-វិច័យ យើងយល់ឃើញថាលោកស្រី អៀង ធីរិទ្ធ មានការធ្លាក់ចុះនៃការចងចាំព័ត៌មានទាំងអស់នេះយើងទទួលបានតាមរយៈការធ្វើកោសល្យវិច័យរបស់យើងជាមួយនឹងការសម្ភាសន៍ ជាមួយនឹងបុគ្គលិកដែលជាមន្ត្រីអនុរក្សមន្ទីរឃុំឃាំង រួមជាមួយនឹងការធ្វើកោលសល្យវិច័យតេស្តមួយចំនួនដែលយើងបានធ្វើឡើង។

[១៤:២៦:១៩]

ដូច្នេះ ហើយយើងលើកឡើងថា ការចុះខ្សោយសតិបញ្ញានេះ មានលក្ខណៈមធ្យម ហើយវាក៏អាចជាបញ្ហាលំបាកខ្លាំងក្នុងការរស់នៅដោយខ្លួនឯងជារៀងរាល់ថ្ងៃ ប្រសិនបើមិនមានការជួយជ្រោមជ្រែងពីបុគ្គលដទៃ។ លក្ខណៈវិនិច្ឆ័យទីពីរ ដែលយើងរកឃើញគឺយើងឃើញថាមានការធ្លាក់ចុះនៃសមត្ថភាពនៃសតិបញ្ញាដទៃទៀត ដែលវាពាក់ព័ន្ធទៅនឹងការវិនិច្ឆ័យ និងការគិតគូរ។ ដូច្នេះ ការធ្លាក់ចុះនេះវាអាចពាក់ព័ន្ធទៅនឹងការធ្លាក់ចុះការសមត្ថភាពសតិបញ្ញា ពាក់ព័ន្ធទៅនឹងការរៀបចំផែនការចាត់តាំង និងការប្រឹងប្រែងយល់ព័ត៌មានទូទៅ។

[១៤:២៧:០៨]

ដូច្នេះ ខ្ញុំសូមលើកឡើងម្តងទៀតថា យើងរកឃើញថាមានភស្តុតាងបង្ហាញនូវការធ្លាក់ចុះសតិបញ្ញានេះ ជាពិសេសនៅក្នុងការវិនិច្ឆ័យការគិតគូរ និងការផ្តល់ហេតុផលតាមប្រវត្តិព័ត៌មានដែលយើងទទួលបានពីលើកមុន ហើយតាមការកោលសល្យវិច័យរបស់យើងមុខនាទីសតិបញ្ញារបស់លោកស្រីអៀង ធីរិទ្ធ យើងលើកឡើងថា វាមានលក្ខណៈធ្ងន់ធ្ងរមធ្យម។ ដូច្នេះហើយការធ្លាក់ចុះសតិបញ្ញានេះគឺវារារាំងសកម្មភាពមួយចំនួន ប៉ុន្តែយើងមិនបានធ្វើកោសល្យវិច័យថាតើសកម្មភាពរារាំងនោះ វារារាំងសកម្មភាពទាំងអស់ របស់គាត់ជាពិសេសគឺសកម្មភាពការងារប្រចាំថ្ងៃរបស់គាត់នៅក្នុងមន្ទីរដែរឬទេ?

[១៤:២៨:០០]

លក្ខណៈវិនិច្ឆ័យទីបី គឺការដឹងអំពីបរិយាកាសជុំវិញ វាគឺជាចំណុចមួយដែលយើងបានបង្ហាញឲ្យឃើញថា វាមិនមានការផ្លាស់ប្តូរនៃការដឹងដោយវិញ្ញាណរបស់គាត់នោះទេ។ ដូច្នេះយើងឃើញថាវាមានសភាពធម្មតា ហើយវាមិនមានការឡើងចុះនោះទេ។ យើងយល់ឃើញថា ការរវើរវាយនៅឆ្នាំ

២០០៦ នៅទីក្រុងបាងកកពុំមានភស្តុតាងបង្ហាញអំពីភាពប្រែប្រួលនៃស្ថានភាពការដឹងដោយវិញ្ញាណរបស់គាត់នោះឡើយ ក្នុងរយៈពេលពីរថ្ងៃដែលយើងបានធ្វើកោសល្យវិច័យទៅលើលោកស្រី អៀង ធីរិទ្ធ។ ដូច្នេះហើយមិនមានភស្តុតាងទាល់តែសោះ អំពីការប្រែប្រួលស្ថានភាពដឹងដោយវិញ្ញាណរបស់គាត់។

[១៤:២៨:៥១]

ចំណុចទីបី លក្ខខណ្ឌទីបីនេះ បានបំពេញទៅតាមលក្ខខណ្ឌដែលយើងរកឃើញ។

លក្ខខណ្ឌទីបួន លក្ខណៈវិនិច្ឆ័យទីបួន គឺការធ្លាក់ចុះក្នុងសមត្ថភាពគ្រប់គ្រងអារម្មណ៍ ឬក៏ការចង់ដឹងចង់យល់នូវហេតុផល ឬក៏ការប្រែប្រួលនៃឥរិយាបថសង្គម។ ដូច្នេះវាបង្ហាញឲ្យឃើញច្បាស់ថាអារម្មណ៍របស់គាត់ សមត្ថភាពគ្រប់គ្រងអារម្មណ៍របស់គាត់នោះវាមានលក្ខណៈខុសគ្នាទៅតាមអារម្មណ៍របស់គាត់។ យើងក៏រកឃើញមានភាពមិននឹងនរនៃអារម្មណ៍ ភាពព្រងើយកន្តើយ និងការធ្វើឲ្យបាត់បង់នូវឥរិយាបថសង្គម។

នៅក្នុងការវាយតម្លៃរបស់យើង យើងឃើញមានភស្តុតាងជាពិសេស ដែលយើងបានរកឃើញតាមរយៈរបាយការណ៍ពេទ្យ ដែលរបាយការណ៍ទាំងអស់នោះបានបង្ហាញនូវហេតុការណ៍ឆ្នាំ២០០៨ និងឆ្នាំ២០០៩ ដែលហេតុការណ៍ទាំងអស់នោះ វាអាចជាការបង្ហាញអំពីការធ្លាក់ចុះនៃសមត្ថភាពគ្រប់គ្រងអារម្មណ៍របស់គាត់។ ប៉ុន្តែសភាពនេះវាមិនមានភាពធ្ងន់ធ្ងរក្នុងពេលបច្ចុប្បន្ននោះទេ ទោះបីជាយ៉ាងនេះក្តីវាអាច ជាការប៉ះពាល់ទៅដល់ការងារអារម្មណ៍របស់គាត់។ យើងបានរកឃើញលក្ខណៈវិនិច្ឆ័យទីបួននេះផងដែរ។

លក្ខណៈវិនិច្ឆ័យទីប្រាំ ដែលជាលក្ខណៈវិនិច្ឆ័យចុងក្រោយ គឺវាពាក់ព័ន្ធទៅនឹងការធ្លាក់ចុះនៃការចងចាំរបស់បុគ្គលនេះដែលត្រូវកើតយ៉ាងហោចណាស់រយៈពេលប្រាំមួយខែ។ ដូច្នេះយើងរកឃើញថាការធ្លាក់ចុះការចងចាំរបស់លោកស្រីវាបានធ្លាក់ចុះរយៈពេលជាងមួយឆ្នាំមកហើយ ដូច្នេះវាយូរជាងរយៈពេលប្រាំមួយខែដែលយើងត្រូវកំណត់។

**ស៖** សូមអរគុណ។ លោកបានលើកឡើងផងដែរថា មានរបាយការណ៍មួយដែលលោកបានយកមកធ្វើការពិចារណា ដែលមានលក្ខណៈខុសពីរបាយការណ៍ផ្សេង ហើយសេចក្តីសន្និដ្ឋាននៅក្នុងរបាយការណ៍ចុងក្រោយវាដាច់ចេញពីរបាយការណ៍នេះ ហើយថាតើវាមានលក្ខណៈស៊ីសង្វាក់គ្នាទៅនឹងរបាយការណ៍កោសល្យវិច័យរបស់លោកដែរឬទេ?

**ឆ៖** វាមានលក្ខណ:ស៊ីសង្វាក់គ្នា។ របាយការណ៍អ្នកជំនាញមុន គឺមានភាពស៊ីសង្វាក់គ្នាទៅនឹងកោសល្យវិច័យរបស់ខ្ញុំ ដែលថាលោកស្រី អៀង ធីរិទ្ធ មានបញ្ហាវិកលចរិត។

**ស៖** របាយការណ៍មួយដែលផ្ទុយទៅនឹងរបាយការណ៍មុននោះ ថាតើវាមានភាពខុសគ្នាច្រើនដែរឬទេ ដែលលោកចង់លើកឡើងពិភាក្សានៅក្នុងពេលនេះ?

**ឆ៖** យោបល់មួយដែលយើងសុំលើកឡើងអំពីរបាយការណ៍នោះ គឺចុះថ្ងៃទី១៦ ខែមករា ឆ្នាំ ២០១១ នៅក្នុងរបាយការណ៍នោះមិនបានលើកព័ត៌មានលម្អិតអំពីតេស្តផ្សេងៗពាក់ព័ន្ធទៅនឹងសតិបញ្ញាដែលគេបានធ្វើឡើងនោះឡើយ។ ដូច្នេះហើយយើងហាក់ដូចជាមានការពិបាកក្នុងការផ្តល់យោបល់បន្ថែមទៅលើរបាយការណ៍ដែលលោកស្រីចៅក្រមបានលើកឡើង។

**ស៖** សូមអរគុណ។ មានបញ្ហាមួយចំនួន និងជាក់លាក់ ដែលលោកបានស្នើសុំឱ្យផ្តល់យោបល់ ហើយបញ្ហាជាក់លាក់នោះលើកឡើងដោយខាងមេធាវីការពារក្តី និងសហព្រះរាជអាជ្ញា។ សំណួរជាក់លាក់ទីមួយនោះ វាពាក់ព័ន្ធទៅនឹងយោបល់របស់លោកក្នុងកថាខណ្ឌទី១២ ជាពិសេសលទ្ធភាពរបស់លោកស្រី អៀង ធីរិទ្ធ ក្នុងការយល់អំពីគោលបំណងនៃកោសល្យវិច័យរបស់លោក តើលោកអាចផ្តល់យោបល់លើបញ្ហាហ្នឹងដែរ ឬទេ?

[១៤:៣២:៥៦]

**ឆ៖** ខ្ញុំសូមផ្តល់យោបល់។ នៅក្នុងកថាខណ្ឌទី១២-- កថាខណ្ឌទី២៨ ទំព័រ១២ យើងបានបង្ហាញថា លោកស្រី អៀង ធីរិទ្ធ មានការយល់ដឹងក្នុងលក្ខណ:កម្រិតអំពីការសម្ភាសន៍របស់យើង លោកស្រីទទួលយកការសម្ភាសន៍ ប៉ុន្តែនៅថ្ងៃទីពីរ គាត់មិនបានចងចាំអំពីគោលបំណងនៃការសម្ភាសន៍របស់យើងនោះទេ។

**ស៖** ចំណុចមួយទៀត នៅក្នុងកថាខណ្ឌ២៩ គឺលទ្ធភាពក្នុងការផ្តង់អារម្មណ៍ និងការចូលរួមក្នុងកិច្ចសម្ភាសន៍ សូមលោកធ្វើការពន្យល់។

**ឆ៖** យើងខ្ញុំយល់ឃើញថា លោកស្រីបង្ហាញអំពីលទ្ធភាពក្នុងការផ្តង់អារម្មណ៍មួយចំនួន និងការចូលរួមក្នុងការសម្ភាសន៍។ យើងសម្ភាសន៍គាត់ជាងពីរម៉ោងក្នុងរយ:ពេលពីរដងនេះ ហើយលោកស្រីមិនបានបង្ហាញថា លោកស្រីអស់កម្លាំង ឬក៏វាមិនមានការដាក់បន្ទុកណាមួយទៅលើលោកស្រីនោះទេ។ លោកស្រីគាត់មិនបានតវ៉ារអ៊ូរទាំមកកាន់យើងថា គាត់ហត់អស់កម្លាំងនៅពេលដែលយើងបញ្ចប់ការសម្ភាសន៍របស់យើងនោះទេ។ ដូច្នេះយើងយល់ឃើញថា លោកស្រីមានលទ្ធភាពក្នុងការផ្តង់

អារម្មណ៍ ហើយយើងកត់សម្គាល់ឃើញថា នៅក្នុងពេលមួយនោះ គឺគាត់ហាក់ដូចជាមិនអាចផ្តល់អារម្មណ៍។ ដូច្នេះ យើងយល់ឃើញថា ពេលខ្លះលោកស្រីមិនអាចឆ្លើយតបជាក់លាក់ទៅនឹងសំណួរដែលយើងបានសួរ។

**ស៖** លោកក៏បានលើកឡើងអំពីការចងចាំផងដែរ ក៏ប៉ុន្តែលោកត្រូវបានចោទសួរអំពីរយៈពេលចងចាំវែង ពីខាងសហព្រះរាជអាជ្ញា។ ថាតើលោកអាចផ្តល់ការពន្យល់ត្រង់កថាខណ្ឌ៣០ នៃរបាយ-ការណ៍របស់លោកដែរ ឬទេ?

[១៤:៣៥:០០]

**លោក ហ្វូត លីនណា៖**

**ឆ៖** អ្នកស្រី អៀង ធីរិទ្ធ គាត់ថាគាត់មានៗការចងចាំរយៈពេលវែងនោះគឺគាត់មានភាពចុះខ្សោយ ដោយសារគាត់អត់បានចងចាំពីឈ្មោះសាលានៅពេលដំបូង ពេលដែលយើងជួបថ្ងៃទីមួយគាត់ឈ្មោះសាលាដែលគាត់រៀននោះគាត់ឈ្មោះអី សាលា គាត់អត់ចាំ ហើយប៉ុន្តែដល់តែពេលដែលលើកទីពីរទើប គាត់ចងចាំសាលាដែលគាត់រៀន វិទ្យាល័យដែលគាត់រៀន គាត់ថាវិទ្យាល័យព្រះស៊ីសុវត្ថិ។ ហើយគាត់ បន្ទាប់មកគាត់អត់ចងចាំឈ្មោះរបស់សាលាបឋមសិក្សាទេ ប៉ុន្តែគាត់ហើយគាត់ក៏អត់ចងចាំឈ្មោះរបស់ព្រះមហាក្សត្រនៅពេលសម្ភាសន៍លើកទីមួយដែរ។ ហើយគាត់អត់បានចងចាំអំពីទីកន្លែងអាសយដ្ឋាន ហើយទោះបីជាយើងសួរគាត់ជាច្រើនដង គាត់អត់ចាំទេ ហើយគាត់អត់បានចងចាំថាតើគាត់កូនប៉ុន្មាននាក់? ហើយគាត់ៗមានការប្រែប្រួលក្នុងសមត្ថភាពរបស់គាត់ ក្នុងការរកនឹកឡើងវិញនូវព្រឹត្តិការណ៍សំខាន់ៗកាលពីអតីតកាល។ ហើយការដែលប្រែប្រួលការចងចាំរបស់គាត់នេះ គឺថាយើងរកឃើញថាវា *ខន់ស៊ីសស្តេន* មានន័យថា វាស៊ីសង្វាក់គ្នាជាមួយនឹងរោគវិនិច្ឆ័យរបស់ជំងឺ *ឌីមែនស្យា* (dementia) គឺជំងឺវង្វេងវង្វាន់នេះ។ យើងបានៗសួរអ្នកស្រី អៀង ធីរិទ្ធ គឺថាសំណួរដូចគ្នាក្នុងរយៈពេលពីរថ្ងៃនេះ ហើយយើងរកឃើញថា គាត់ៗមានភាពចុះខ្សោយនៅក្នុងការចងចាំរយៈពេលវែង។ សូមអរគុណ។

[១៤:៣៧:១៧]

**ស៖** ខ្ញុំមានសំណួរបន្ថែមមួយទៀត ទៅលើចម្លើយដែលលោកបានឆ្លើយគឺលោកវេជ្ជបណ្ឌិតលីនណា លោកទាំងពីរបានបញ្ជាក់ថា វាជាការវិភាគ វិនិច្ឆ័យរោគ ដូច្នេះតើលោកអាចធ្វើការពន្យល់ឲ្យបានច្បាស់ជូនអង្គជំនុំជម្រះសាលាដំបូង និងសាធារណជនដែរឬទេ ថាតើការវិនិច្ឆ័យនោះគឺយ៉ាងម៉េច

ដែរ? សូមអរគុណ។

**លោក ស៊ីណា ហ្វាសែល៖**

**ឆ៖** ចំពោះការវិនិច្ឆ័យរោគមួយចំនួន គឺយើងអាចផ្អែកទៅលើការធ្វើតេស្តឈាម ឬការធ្វើវិទ្យុសាស្ត្រ ក៏ប៉ុន្តែចំពោះការវិនិច្ឆ័យខាងផ្នែកវិកលវិទ្យា គឺយើងពិនិត្យទៅលើភស្តុតាងមួយចំនួនដែលវាដាក់រួមបញ្ចូលគ្នា។ ដូច្នេះហើយវាមិនមែនផ្អែកទៅលើព័ត៌មានតែមួយនោះទេ វាមិនគ្រប់គ្រាន់ឡើយ។ ដូច្នេះយើងផ្អែកទៅលើកត្តាជាច្រើនដែលជាលទ្ធភាពឲ្យយើងពិនិត្យ និងពិចារណាទៅលើរោគវិនិច្ឆ័យ ហើយចំពោះវិកលវិទ្យានេះ គឺយើងធ្វើការពិនិត្យទៅលើប្រវត្តិនៃការព្យាបាល និងការធ្វើតេស្តឈាម ការស្កេនខួរក្បាលនិងការធ្វើវេជ្ជសាស្ត្រផងដែរ។

[១៤:៣៨:៥៩]

ពេលខ្លះយើងផ្អែកទៅលើជំងឺ ដូច្នេះយើងធ្វើកោសល្យវិច័យពិនិត្យទៅលើនោះជាច្រើនលើកជាច្រើនសា ការយល់ឃើញរបស់យើងនេះទៅតាម ទទួលព័ត៌មានតាមរយៈការធ្វើកោសល្យវិច័យមុនៗរបស់លោកស្រី អៀង ធីរិទ្ធ ដូច្នេះហើយវាបង្ហាញឲ្យយើងតាមរយៈឯកសារទាំងអស់នុំងដែលគេបានកត់ត្រាយ៉ាងត្រឹមត្រូវ។

**ស៖** សូមអរគុណច្រើន។ សំណួរជាក់លាក់មួយទៀត ដែលលោកបានស្នើសុំឲ្យធ្វើការឆ្លើយតបនៅក្នុងកថាខណ្ឌទីមួយ វាពាក់ព័ន្ធទៅនឹងការស្គាល់សមាជិករបស់លោកស្រី អៀង ធីរិទ្ធ ជាពិសេសចំពោះបុគ្គលដែលគាត់ស្គាល់ ថាតើលោកអាចធ្វើការពន្យល់ទៅលើចំណុចហ្នឹងបានដែរឬទេ?

[១៤:៣៩:៤២]

**លោក ហ្វូត លីនណា៖**

**ឆ៖** បាទ, គាត់-- យើងបានរកឃើញថាគាត់ៗមិនសូវមានការចងចាំ អំពីការសមាជិកគ្រួសាររបស់គាត់ទេ សូម្បីតែឈ្មោះក៏អីចឹងដែរ ហើយដូចជាស្វាមីរបស់គាត់លើកទីមួយនោះ គាត់អត់ចាំទេ ហើយលើកក្រោយទៀត គាត់និយាយថាស្វាមីរបស់គាត់ លោក អៀង សារី នេះជាបងទៅវិញ។

ហើយដំបូងនោះ គាត់អត់អាចចងចាំឈ្មោះម្តាយរបស់គាត់ទេ បងប្អូនក៏អត់ចាំដែរ ហើយកូនក៏អត់ចាំដែរ។ ហើយនៅពេលយើងសម្ភាសន៍លើកទីពីរ គាត់ចាំ ចាំឈ្មោះម្តាយរបស់គាត់។ ហើយម្តាយរបស់គាត់ គាត់ថាគាត់ឈ្មោះអី-- ប៉ុន្តែដល់ពេលគាត់បាននិយាយថា ម្តាយគាត់នៅរស់នៅឡើយ។ អានេះហាក់ដូចជាខុសពីការពិត ហើយគាត់មិនអាចរកនឹកឈ្មោះកូនគាត់ទេ។ កូនគាត់សួរទៅ គាត់អត់

អាចឆ្លើយបានថាកូនគាត់ឈ្មោះអីខ្លះ។ ហើយគាត់អត់ដឹងថាគាត់ហ្នឹងមានកូនប្រុសមួយទេ។

[១៤:៤០:៥៦]

ហើយនៅថ្ងៃទីពីរ យើងបានសួរគាត់ ហើយគាត់ៗចងចាំយើងទាំងអស់គ្នាដែលជាក្រុមជំនាញ ព្រមទាំងអ្នកបកប្រែហ្នឹង ហើយគាត់បានស្គាល់ៗច្បាស់ជាងគេ គឺថាអ្នកបកប្រែ ប៉ុន្តែដល់ពេលមុខងាររបស់យើងជាអ្នកណានោះ គឺថ្ងៃទីមួយយើងបានប្រាប់គាត់ ហើយដល់ថ្ងៃទីពីរយើងទៅសួរគាត់វិញ គាត់ក៏អត់ចាំថាមិនដឹងថា ក្រុមយើងទាំងអស់គ្នាហ្នឹងជាអ្នកណាទេ គាត់អត់ចាំទេ។ ហើយគាត់ ខ្ញុំបានពិនិត្យឃើញថា គាត់ហ្នឹងគាត់អាចសរសេរអី សរសេរឈ្មោះអីត្រឹមត្រូវ ហើយគាត់បានប្រឹងប្រែងសរសេរឈ្មោះយើង ប្រាប់ពេលដែលលើកទីមួយប្រាប់ឈ្មោះអីៗ គាត់ខំសរសេរឈ្មោះយើងទាំងអស់គ្នាដែលជាក្រុមអ្នកជំនាញទៅហ្នឹង គាត់កត់ឈ្មោះយើងហើយ ប៉ុន្តែដល់ពេលទៅសួរគាត់ ដល់ពេលថ្ងៃទីពីរទៅសួរគាត់ គាត់អត់ចាំទេ អត់ចាំអ្នកណាជាអ្នកណាទេ គាត់អត់ចាំទេ។

ហើយគាត់អត់បានចាំឈ្មោះយើង ហើយគាត់និយាយរួមទៅ គាត់ចាំៗតែអ្នកបកប្រែម្នាក់ ដែលគាត់ស្គាល់ អ៎!លោកហ្នឹងអ្នកបកប្រែ គាត់ចាំតែប៉ុណ្ណឹង ក្រៅពីហ្នឹងគាត់ដូចអត់ចាំទេ។ សូមអរគុណ។

**ស៖** តុលាការក៏បានសួរលោកអំពីសមត្ថភាពរបស់លោកស្រីក្នុងការធ្វើប្រាស្រ័យទាក់ទង។ តើលោកអាចពន្យល់បន្ថែមទៅលើចំណុចហ្នឹងបានដែរឬទេ?

**លោក ស៊ីណា ហ្វាស៊ែល ៖**

**ឆ៖** យើងខ្ញុំយល់ឃើញថា លោកស្រីអាចធ្វើទំនាក់ទំនងយ៉ាងច្បាស់លាស់ ហើយគាត់មិនមានការលំបាកក្នុងការនឹករកពាក្យនោះឡើយចំពោះវេយ្យាករណ៍និងទម្រង់នៃការប្រើប្រាស់ឃ្លា គឺវាសាមញ្ញ ហើយចំពោះល្បឿននៃការប្រើប្រាស់ពាក្យក៏សាមញ្ញ ការឆ្លើយតបទៅនឹងសំណួរក៏វាមានសភាពធម្មតា ហើយគាត់អាចឆ្លើយសំណួរដែលបានសួរទៅកាន់លោកស្រី។ ក៏ប៉ុន្តែយើងកត់សម្គាល់ឃើញវាមានការពាក់ព័ន្ធមួយចំនួនទៅនឹងការសន្ទនារបស់យើងជាមួយនឹងគាត់។ ហើយវាមានការមិនអាចឆ្លើយតបភ្លាមៗទៅនឹងសំណួរមួយចំនួនក្នុងរយៈពីរថ្ងៃ ដែលយើងសួរសំណួរជាក់លាក់ចង់ឲ្យគាត់ឆ្លើយសំណួរជាក់លាក់នោះ។

[១៤:៤៣:៤៩]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដោយសារមូលហេតុនៃបញ្ហាបច្ចេកទេសនៃការធ្វើប្រតិចារឹក វាមានបញ្ហារអាក់រអួល

ប្រព័ន្ធបច្ចេកទេសកុំព្យូទ័រ ដូច្នេះម៉្យាងទៀតសមស្របនឹងពេលវេលាផង ដើម្បីទុកឱកាសឲ្យអ្នកជំនាញរៀបចំឡើងវិញផង។ ដូច្នេះអង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការរបស់យើង។

**លោក ឌុច ផារី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៥នាទី ដល់ម៉ោង ១៥:១២នាទី)*

[១៥:១២:០៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្តនេះ សូមផ្តល់វេទិកាជូនទៅលោកស្រី ខាតវ៉ាយថ៍ ដើម្បីបន្តសំណួរ តាំងសំណួរដល់អ្នកជំនាញទាំងពីររូប។

សូមអញ្ជើញលោកស្រី!

**សួរដោយចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។

**ស៖** ឥឡូវនេះ ខ្ញុំសូមបន្តទៅនឹងសំណួរជាក់លាក់ទាក់ទងទៅនឹងបញ្ហាមួយចំនួនដែលលើកឡើងដោយសហព្រះរាជអាជ្ញា និងមេធាវីការពារក្តី អៀង ធីរិទ្ធ ហើយយើងបានសួរអំពី នៅក្នុងកថាខណ្ឌ ៣៣ និយាយអំពីការចំណាំរបស់គាត់ ថាតើលោកអាចបញ្ជាក់ដល់តុលាការបានដូចម្តេចខ្លះ?

**លោក ហួត លីនណា៖**

**ឆ៖** ក្រុមជំនាញខ្ញុំបានរកឃើញថា គាត់ៗដឹងពីខ្លួនគាត់ មានន័យថាគាត់មាន *អូរៀនថេសិន អ៊ិនភើស៊ិន* (និយាយភាសាអង់គ្លេស) នៅក្នុងពេលដែលយើងសួរគាត់ទាំងបីលើកហ្នឹង គាត់ស្គាល់ គឺមានន័យថាគាត់អាចរកនឹកឡើងវិញអំពីឈ្មោះរបស់គាត់។ ប៉ុន្តែបើសិនជាយើងសួរពីពេលវេលាវិញ គឺថាគាត់ភាពចុះខ្សោយក្នុងការដឹងពីពេលវេលា។ គាត់អាចថាពេលវេលានេះជាពេលថ្ងៃ ប៉ុន្តែមិនអាចដឹងថាពេលនេះជាពេលយប់ទេ។ ហើយគាត់អត់អាចដឹងថាថ្ងៃនេះជាថ្ងៃច័ន្ទ, អង្គារ ឬក៏ ពុធ អីទេ គាត់អត់ដឹងទេ។ ហើយខែអីក៏គាត់អត់ដឹង សួរទៅថាជារដូវអី ជាឆ្នាំអីក៏គាត់អត់ដឹងដែរ។

[១៥:១៤:០៧]

ហើយទាក់ទងនឹងការដឹង ការយល់ដឹងអំពីទីកន្លែងនេះ ក្រុមជំនាញយើងខ្ញុំបានរកឃើញថាគាត់មិនអាចដឹងថា អគារដែលគាត់កំពុងស្នាក់នៅហ្នឹងជាអគារអ្វី ហើយមានមុខងារជាអគារស្អីទេ គាត់អត់ដឹងទេ។ ប៉ុន្តែគាត់ដឹងថា គាត់ហ្នឹងគាត់នៅភ្នំពេញ នៅប្រទេសកម្ពុជា។ បាទ, សូមអស់យោបល់។

**ស៖** សូមអរគុណ។ ឥឡូវនេះទាក់ទងនឹងភាពធ្ងន់ធ្ងរនៃការចោទប្រកាន់ដែលគាត់ប្រឈមនោះ ហើយក៏មានការព្រួយបារម្ភជាទូទៅថា ដែលសហព្រះរាជអាជ្ញាលើកឡើងអំពីថាតើគាត់អាច ឬក៏មិនអាច ឬក៏មិនអាចផ្សារភ្ជាប់ទៅនឹងចម្លើយរបស់គាត់ទៅនឹងសំណួរ ឬក៏ការវាយតម្លៃដើម្បីអាចឱ្យបានទទួលលទ្ធផលល្អបំផុតសម្រាប់ខ្លួនគាត់ តើលោកគិតថាអាចទៅរួចទេដោយផ្អែកទៅលើតេស្តផ្សេងៗ និងការវាយតម្លៃដែលលោកអ្នកជំនាញបានធ្វើ ហើយលោកបានពិភាក្សាចំណុចនេះនៅកថាខណ្ឌទី៣៤ នៃរបាយការណ៍របស់អស់លោកនោះ។

[១៥:១៥:៣៤]

**លោក ស៊ីណា ហ្វាសែល៖**

**ឆ៖** យើងមានការលំបាកក្នុងការសួរទៅគាត់ យើងពិចារណាចំណុចនេះយ៉ាងប្រុងប្រយ័ត្ន ហើយយើងពិនិត្យមើលចំណុចពិស្តារ ហើយយើងយកចិត្តទុកដាក់ និងលើកឡើងពីបញ្ហាទាំងអស់នេះ។ យើងយល់ថា វាមិនមានទំនងថា គាត់អាចធ្វើពុតថា ឬក៏ក្លែងបន្លំថាគាត់មានជំងឺវង្វេងស្មារតីនេះណាស់ ហើយយើងសួរសំណួរផ្សេងៗនៅពេលខុសៗគ្នា ចម្លើយរបស់គាត់នោះគឺ មិនជាក់ស្តែងទេគឺថា ទាក់ទងទៅនឹងចំណុចមួយគឺថា យើងអាចពិនិត្យមើលឃើញអាចនឹងមានបង្ហាញច្បាស់ ដែលថាយើងមិននឹកឃើញអ្វីៗ បើប្រៀបធៀបទៅនឹងអ្វីទៀត ហើយយើងមិនឃើញច្បាស់ថា ដែលថាយើងសង្កេតឃើញថាគាត់កែប្រែចម្លើយ អាចនឹងកែលម្អនៅថ្ងៃទីពីរ បើគាត់ប្រកបបានល្អនៅថ្ងៃទីមួយ ប៉ុន្តែថ្ងៃទីពីរមិនបានល្អ។ ប៉ុន្តែថ្ងៃទីមួយ គាត់អាចចាំឈ្មោះព្រះមហាក្សត្រ ប៉ុន្តែថ្ងៃទីមួយគាត់មិនចាំ ប៉ុន្តែមតិយោបល់ខាងផ្លូវពេទ្យរបស់យើងគឺថា គាត់មិនមានការធ្វើពុតថាគាត់មានបញ្ហាខាងការវង្វេងវង្វាន់ ឬក៏ជំងឺបាត់បង់ស្មារតីនេះទេ ដែលថាអ្នកជំងឺធ្វើពុតថា បន្លំនោះគឺយើងមិនឃើញទេ។

[១៥:១៦:៥៧]

ចំពោះការឆ្លើយស្របគ្នាពីពេលមួយទៅពេលមួយវិញហ្នឹងគឺថា ចម្លើយមួយចំនួនរបស់គាត់ទៅនឹងសំណួរនោះដែលអ្នកជំនាញពីមុនសួរទៅគាត់នោះ ក៏វាមានលក្ខណៈស្រដៀង ឬក៏ដូចគ្នា គឺថាបង្ហាញ

ពីភាពចុះខ្សោយគឺថា វាមានការចុះឡើងនៃការយល់ដឹងសតិបញ្ញារបស់គាត់នោះ។ មិនអាចច្បាស់១០០ភាគរយទេតាមផ្លូវវេជ្ជសាស្ត្រ គឺថាយើងថាវាមិនទំនងទាល់តែសោះដែលថាគាត់បញ្ឆោត ឬគាត់ធ្វើពុតថាមានជំងឺហ្នឹងនោះ។

**ស៖** សូមអរគុណ។ ឥឡូវនេះយើងបានពិភាក្សាដោយសង្ខេបអំពី ស៊ីធីស្កេន ចំនួនបី ហើយលោកបានជួយពីអ្នកជំនាញក្នុងការអាន តើមានចំណុចអ្វីត្រូវបន្ថែមទៅនឹង ស៊ីធីស្កេន ជាហ្វីមហ្នឹងទេទាក់ទងទៅនឹងមតិ ឬក៏បញ្ហាដែលលើកឡើងទាំងសហព្រះរាជអាជ្ញា និងមេធាវីការពារដែរឬទេ?

**ឆ៖** ចំណុចគឺថា យើងមិនមែនជាអ្នកជំនាញខាងវិទ្យុសាស្ត្រទេ ប៉ុន្តែយើងទាំងបួននាក់ហ្នឹងយើងបានទទួលការបណ្តុះបណ្តាលនៅក្នុងការរៀនសូត្រពីការពិនិត្យ ប៉ុន្តែយើងបានទទួលអ្នកជំនាញខាងវិទ្យុសាស្ត្រនេះ ហើយគាត់ក៏បានបញ្ជាក់ថា លទ្ធផលស្កេននោះគឺមិនជួយយើងថា ក្រៅពីរោគវិនិច្ឆ័យនោះទេ ប៉ុន្តែស្របទៅនឹងជំងឺវង្វេងវង្វាន់នេះទេ ប៉ុន្តែវាស្របទៅនឹងអាយុដែលថា មនុស្សអាយុ៧៩ឆ្នាំបែបនេះវាមានលក្ខណៈដែរ ចំណុចសំខាន់នោះគឺថា ដោយបន្ថែមទៅលើបញ្ហាចងចាំរបស់លោកស្រី អៀង ធីរិទ្ធ គឺថាមិនឃើញថាមានការរលាកជាលិកា ឬក៏ដុំសាច់ដុះក្នុងខួរក្បាលអ្វីនោះទេ ដែលថាអាចឃើញថា មានការខូចផ្នែកណាមួយនៃខួរក្បាលក៏មិនមានទេ។

[១៥:១៩:១៨]

**ស៖** សូមអរគុណ។ ដូច្នេះ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យលោកបញ្ជាក់អំពីជំងឺបាត់បង់សតិបញ្ញាហៅថា *អាល់ហ្សៃមើ* ផងដែរតើលោកបានពិនិត្យ តើលោកមានមតិយោបល់ដូចម្តេចអំពីជំងឺនេះ?

**ឆ៖** ការពិនិត្យរបស់យើងហ្នឹងគឺថា ជាទម្រង់ដែលអាចមានជំងឺវង្វេងវង្វាន់មួយ ហៅថា *ឌីមែនស្យា* ប៉ុន្តែរោគវិនិច្ឆ័យនៃជំងឺ*អាល់ហ្សៃមើ* នៃការបាត់បង់ស្មារតីនេះគឺថា លុះត្រាណាតែយើងធ្វើការវះកាត់ទៅលើអ្នកជំងឺដូចថាស្លាប់ហើយ គេវះកាត់មើល ទើបបានដឹង។ ប៉ុន្តែអ្វីដែលយើងពិនិត្យឃើញនៅទីនេះ គឺថាភាគច្រើន គឺយើងផ្អែកទៅលើការមើលប្រវត្តិនៃជំងឺ ហើយការរីកចម្រើននៃជំងឺ ហើយចំពោះអ្នកជំងឺដែលមានជំងឺ *អាល់ហ្សៃមើ* ដែលថាបាត់បង់សតិបញ្ញានេះគឺ ថាវាចុះខ្សោយបន្តិចម្តង គឺថាវាមិនបង្ហាញការចុះជាលំដាប់អ្វីនោះទេ។ ប៉ុន្តែជំងឺគេហៅថាជំងឺវង្វេងវង្វាន់ដោយជំងឺសរសៃឈាមខួរក្បាលវិញ គឺថាវាជាប្រភេទមួយដែលអាចឃើញច្បាស់។

**ស៖** ទាក់ទងទៅនឹងបញ្ហានេះគឺនៅក្នុងរបាយការណ៍របស់លោកអ្នកជំនាញនោះ លោកបានយោងទៅរកការពិនិត្យ និងរបាយការណ៍វេជ្ជសាស្ត្រផ្សេងៗទៀតដែលទាក់ទងទៅនឹងអ្នកស្រី អៀង ធី

រិទ្ធ។ ចំណុចនេះនៅក្នុងកថាខណ្ឌ២៧ ចំណុចទី៥ ខ្ញុំពិនិត្យឃើញថា លោកបានផ្តល់សេចក្តីសន្និដ្ឋានថា ដំណើរការចុះខ្សោយវង្វេងវង្វាន់ ឬសតិបញ្ញាហ្នឹង គឺស្របទៅតាមអ្វីតាមរបាយការណ៍ឆ្នាំ២០០៩ គឺថា គឺវាមានការចុះខ្សោយជាលំដាប់។ ថាតើលោកមានមតិយោបល់អ្វីទៀតដែលថាប្រើពាក្យដូចម្តេចដែលត្រឹមត្រូវតាមក្បួនវេជ្ជសាស្ត្រនោះ។

**ឆ៖** ខ្ញុំគិតថា យើងមានភស្តុតាងអំពីការកើនឡើង ហើយយើងបានឯកភាពគ្នាថា ការជំងឺហ្នឹងវាកើនឡើង បានន័យថាធ្ងន់ឡើងការចុះខ្សោយនៃការចងចាំតាមវិធីវេជ្ជសាស្ត្រ ប៉ុន្តែវាមានពិនិត្យមើលស៊ីធីស្កេន លើខួរក្បាលរបស់គាត់ គឺយើងឃើញថាមានភស្តុតាងបង្ហាញថាបែបនោះ។ ហើយយើងអាចហៅថាជាកម្រិតនៃជំងឺវង្វេងវង្វាន់កម្រិតធ្ងន់មធ្យម ដែលជាប្រភេទនៃជំងឺ ដែលយើងមើលគោលការណ៍ណែនាំពីប្រភេទជំងឺនោះ យើងឃើញថាជំងឺវង្វេងវង្វាន់នេះ គឺយើងហៅថាភាពធ្ងន់ធ្ងរស្រាលហើយនិងមធ្យម។ បើសិនជាវាប៉ះពាល់ទៅដល់ធ្វើឲ្យគាត់មិនអាចរស់ធ្វើកាយវិការរៀងរាល់ថ្ងៃជាប្រចាំបាន អាហ្នឹងគឺជាទម្រង់មួយដែលថាធ្ងន់។

[១៥:២២:៣៥]

**ស៖** សូមអរគុណ។ ឥឡូវនេះលក្ខណៈមួយនៅក្នុងរបាយការណ៍របស់សាស្ត្រាចារ្យ ខាំប៊ែល នៅក្នុងការពិនិត្យដែលគាត់រាយការណ៍នោះ គឺគាត់បានស្នើឲ្យប្តូរការប្រើថ្នាំចំពោះអ្នកស្រី អៀង ធីរិទ្ធ ហើយគាត់បានបញ្ជាក់ ហើយគាត់និយាយប្រើពាក្យមួយចំនួនដែលមិនសូវសុទិដ្ឋិនិយមនោះទេ។ ប៉ុន្តែតើលោកអាចនឹងមានមតិយោបល់ដូចម្តេចនៅក្នុងកថាខណ្ឌ៣៧ នៃរបាយការណ៍របស់លោក គឺថានឹងចំណុចនេះក៏ឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា និងមេធាវីការពារក្តីរបស់លោកស្រី អៀង ធីរិទ្ធ។

**ឆ៖** ខ្ញុំឃើញថា សាស្ត្រាចារ្យ ខាំប៊ែល បានស្នើឲ្យមានការប្រើថ្នាំ សុំឲ្យបញ្ឈប់ការប្រើថ្នាំមួយចំនួន ដូចជាទាក់ទងទៅនឹងផ្លូវអារម្មណ៍ គឺថាលទ្ធភាពមួយទៀតឲ្យការប្រើនូវ *ដូនេប៉េហ្ស៊ីល* (Donepezil) ដែលថាគេអាចប្រើដើម្បីចំពោះមុខងារសតិបញ្ញាចុះខ្សោយមធ្យម។ ចំពោះទីមួយ និងពីរ យើងឯកភាពជាមួយសាស្ត្រាចារ្យ ខាំប៊ែល គឺថាជាទម្លាប់ល្អដែលយើងបន្ថយថ្នាំមួយចំនួនដែលគាត់លើកឡើងហ្នឹង ហើយតាមដានឲ្យបានហ្មត់ចត់ ថាតើមានការកែប្រែអ្វីទាក់ទងទៅនឹងស្ថានភាពសតិបញ្ញា ឬក៏មុខងារសតិបញ្ញាហ្នឹង ដែលមានន័យថា យើងត្រូវពិចារណាឡើងវិញក្រោយពីការកែប្រែថ្នាំនេះ។ ហើយយើងខ្ញុំយល់ថាការទាក់ទងទៅនឹងការកត់បន្ថយថ្នាំដែលប៉ះពាល់ដល់សរសៃប្រសាទនោះ

គឺមិនឃើញមានការកែប្រែអ្វីល្អជាដុំកំភួនទេ វាមានលទ្ធភាពថាអាចកែលម្អមុខងារសតិបញ្ញា ប៉ុន្តែការមតិយោបល់របស់យើងគឺថាមិនឃើញថាមានភស្តុតាងណាមួយបង្ហាញច្បាស់ទេក្រោយពីការបន្ថយមក។

[១៥:២៤:៤៥]

ចំណុចទីពីរ និយាយពីថ្នាំ *កេត្យាពីន* (quetiapine) នេះវិញ នៅក្នុងពេលដែលយើងសម្ភាសគាត់បានប្រើតែពាក់កណ្តាលដូសទេ គឺថាប៉ុន្តែមិនឃើញមានប៉ះពាល់ ឬក៏កែប្រែទៅលើស្ថានភាពបញ្ញារបស់គាត់។ ប៉ុន្តែនេះគឺថាថ្នាំហ្នឹង គឺជាការប្រើត្រូវពីព្រោះថាវាទាក់ទងទៅនឹងការព្យាបាលសតិបញ្ញាមិនមានផលប៉ះពាល់អ្វីនោះទេ។

ហើយចំណុចមួយទៀត ទាក់ទងទៅនឹងការសាកល្បងនូវថ្នាំ ដុនណេប៉េហ្ស៊ីល វិញ គឺថាគេប្រើចំពោះអ្នកជំងឺដែលមានជំងឺវង្វេងវង្វាន់ស្រាលទេ ប៉ុន្តែក្រុមយើងមិនមានបទពិសោធន៍ច្រើន ហើយកម្រនឹងបានប្រើថ្នាំនេះញឹកញាប់នោះទេ។ យើងយល់ថា ស្របទៅនឹងអ្វីដែលសាស្ត្រាចារ្យ ខាំ ប៉ែលបានលើកឡើងហ្នឹងគឺថាយើងមាន មិនសូវមានបទពិសោធន៍ការប្រើថ្នាំនេះ។ ប៉ុន្តែអាចនឹងជាលទ្ធភាពតិចតួចណាស់ បើយើងប្រើថ្នាំនេះទៅនៅក្នុងការកែប្រែសតិបញ្ញា។

[១៥:២៥:៥៨]

**ស៖** ប្រសិនបើលោកព្យាបាលអ្នកជំងឺវិកលចរិតវិញ គឺថាលោកមិនឲ្យយោបល់ឲ្យប្រើថ្នាំ *ដុនណេប៉េហ្ស៊ីល* នេះ។ បាទ, ដុនណេប៉េហ្ស៊ីល នេះទេ តើឬយ៉ាងម៉េច?

**ឆ៖** នៅក្នុងករណីពិសេសនេះ ខ្ញុំមិនឲ្យអនុសាសន៍ឲ្យប្រើថ្នាំនេះទេ។

**ស៖** នៅក្នុងចំណុចនេះខ្ញុំគិតថា លោកក៏បានពិចារណាទៅលើបទពិសោធន៍ ដែលគេប្រើនៃថ្នាំនេះ ហើយនិងឧបករណ៍ជុំវិញដែលប្រើទៅលើអ្នកជំងឺមុននឹងចេញឲ្យប្រើថ្នាំនេះនៅកម្ពុជា តើលោកពិនិត្យមើលអ្វីខ្លះ?

**ឆ៖** បាទ, គឺត្រូវហើយ។

[១៥:២៦:៤៥]

**ស៖** សូមអរគុណ។ នៅចំណុចមួយទៀត សហព្រះរាជអាជ្ញាបានស្នើសុំថាតើមានការជម្រើសអ្វីក្នុងការព្យាបាលអ្វីផ្សេងទេ ដើម្បីកែសម្រួលឲ្យស្ថានភាពបញ្ញារបស់គាត់កែប្រែបានទេ នៅក្នុងកថាខណ្ឌ៣៨របស់លោក? ហើយលោកកត់សម្គាល់ឃើញថា គឺថាមានឧបសគ្គមួយចំនួនក្នុងវិធានការដែលយើងមាននៅក្នុងប្រទេសផ្សេង ឬក៏ប្រទេសផ្សេងមិនមាននោះ។ តើលោកអាចបន្ថែមយោបល់អ្វី

បានទេ?

**ឆ:** ខ្ញុំគិតថា ខ្ញុំសូមចាប់ផ្ដើមម្ដងទៀត។ ខ្ញុំគិតថាចំណុចសំខាន់បំផុតនោះ នៃវិធានការទាំងនេះ គឺថាអាចគឺការព្យាបាលនូវជំងឺមួយចំនួន គឺថាអាចត្រូវបានធ្វើតាមមតិរបស់យើង ប៉ុន្តែការព្យាបាលជំងឺឈឺចាប់ទើបតែបានធ្វើហើយ ការតាមដានសុខភាពទៀតទាត់របស់គាត់នោះដើម្បីឲ្យឃើញថា តើមានជំងឺផ្សេងទៀតត្រូវបានព្យាបាលឲ្យបានឆាប់ ហើយសមស្របនោះ។ ដូច្នេះ នេះជាវិធីមួយដែលជាចំណុចសំខាន់ វិធានការសំខាន់ដែលអាចនឹងមានប្រយោជន៍ចំពោះលោកស្រី អៀង ធីរិទ្ធ ស្ថានភាពសុខភាពរបស់គាត់ ហើយនិងមុខងារបញ្ញារបស់គាត់។

[១៥:២៨:១២]

ប៉ុន្តែចំណុចមួយទៀត ដែលអាចមានប្រយោជន៍ គឺថាអាចរាប់បញ្ចូលទាំងឲ្យមានបុគ្គលិកដែលដដែលៗ ហើយអាចនឹងបុគ្គលិក និងបុគ្គលិក រក្សាឲ្យគាត់មានបរិស្ថានដដែលឲ្យគាត់អាចឆ្លើយតបបានតាមរបៀបមួយ គាត់បត់បែនទៅតាមទីកន្លែង ឬក៏បរិយាកាសជុំវិញហ្នឹង ដែលរាប់បញ្ចូលទាំងការគាំទ្រគាត់នៅក្នុងសកម្មភាពមួយចំនួនដែលគាត់ពេញចិត្ត។

យើងយល់ឃើញថា គាត់ពេញចិត្តក្នុងការទទួលសារព័ត៌មានប្រចាំថ្ងៃ ហើយគាត់ចូលចិត្តអ្នកមកលែងរបស់គាត់ ហើយឲ្យមានការគាំទ្រសកម្មភាពបែបនោះ ហើយបញ្ហាផ្សេងទៀតដែលអាចមានប្រយោជន៍ដែរនោះ ប៉ុន្តែវាមានលំបាកបន្តិចនៅក្នុងស្ថានភាពបច្ចុប្បន្ននេះក្នុងការលំហាត់ប្រាណដែលថាអាចមានប្រយោជន៍។

[១៥:២៩:២២]

សកម្មភាពមួយចំនួនដែលជំរុញឲ្យទឹកចិត្តរបស់គាត់ ដែលថាការរំញោចបញ្ញាស្មារតីរបស់គាត់ ប៉ុន្តែ ជាសកម្មភាពមួយដែលត្រូវធ្វើឡើងជាក្រុមដែលអាចនឹងជំរុញការគិតគូរ ហើយនិងការបង្ហាញហេតុផល នៅក្នុងផ្លូវវិញ្ញាណ ឬក៏ការចងចាំ។

ចំណុចទាំងអស់ហ្នឹងគឺថាអាចមានប្រយោជន៍ ហើយនៅទីបំផុតនោះ ប្រសិនបើមានការកែប្រែនូវបរិយាកាសនោះ ជុំវិញគាត់នោះ ជាពិសេសការរស់នៅប្រចាំថ្ងៃរបស់គាត់ យើងខ្ញុំអាចនឹងបញ្ជាក់ថាបុគ្គលដែលមានបញ្ហាច្រើនដូចលោកស្រី អៀង ធីរិទ្ធ នេះយើងសូមស្នើសុំការផ្ដល់យោបល់អំពីគ្រូពេទ្យព្យាបាលខាងចលនាហ្នឹង។ ប៉ុន្តែខ្ញុំមិនគិតថា នៅកម្ពុជាមានអ្នកជំនាញបែបនេះនោះទេ។ ប៉ុន្តែចំណុចពេលនេះ យើងមិនគិតថាចាំបាច់ទេ ប៉ុន្តែនៅក្នុងអានាគតអាចជាកត្តាចាំបាច់ត្រូវពិចារណា។

**ស៖** ដើម្បីត្រឡប់មកដោយសង្ខេបឲ្យផ្តល់យោបល់ពីចំណុចតូចលម្អិតមួយ បញ្ហាដែលយើងសួរទាក់ទងទៅថា គាត់ចាំសមាជិកក្រុមគ្រួសារ តើលោកវេជ្ជបណ្ឌិល លីនណា លោកបានបញ្ជាក់ខាងដើមថា គាត់ហៅប្តីរបស់គាត់ថា ជាបងប្រុសវិញនោះ។ តើខ្ញុំត្រូវទេពេលខ្លះជាទំនៀមទម្លាប់របស់កម្ពុជាដែលហៅអ៊ីចឹង? តើវាមានអ្វីខុសគ្នានៅក្នុងវាយតម្លៃរបស់លោកវេជ្ជបណ្ឌិតទេថា ជាទម្លាប់របស់ខ្មែរទេដែលហៅបែបនោះ?

**លោក ហួត លីនណា៖**

**ឆ៖** ខ្ញុំសូមជម្រាបលោកស្រីចៅក្រមថា តាមទម្លាប់គឺថា បើហៅបងគឺត្រូវត្រឹម អានេះគាត់ហៅ គាត់ចាត់ទុកថា ឈ្មោះលោក អៀង សារី ដែលជាស្វាមីរបស់គាត់ជាបងប្រុស។ ដូច្នេះ តាមទំនៀមទម្លាប់កម្ពុជាយើងមិនត្រឹមត្រូវទេ បើសិនជាហៅបង ហៅអូន ហ្នឹងជាការ ជាពាក្យផ្អែមល្ហែមគ្នាអាហ្នឹងវាសមស្រប ប៉ុន្តែនេះគាត់និយាយថា លោក អៀង សារី ហ្នឹងជាបងប្រុសរបស់គាត់។ ដូច្នេះវាច្បាស់ណាស់ថា លោក អៀង សារី ជាប្តីរបស់គាត់ទេ។ ដូច្នេះត្រង់នេះគឺថា ក្នុងទំនៀមទម្លាប់ខ្មែរ គឺមិនទម្លាប់ហៅប្តីជាបងប្រុសទេ។ សូមអរគុណ។

**ស៖** សូមអរគុណច្រើនដែលលោកឆ្លើយបំភ្លឺ។ នៅក្នុងការចាត់តាំងឲ្យលោកធ្វើកោសល្យវិច័យលោកបានស្នើសុំសួរសំណួរចំនួនប្រាំ នៅពេលនេះគឺខ្ញុំសូមលើកឡើងសំណួរចំនួនប្រាំនេះដោយសារលោកបានផ្តល់យោបល់ទៅលើសំណួរចំនួនប្រាំ។ លោកមានយុត្តិសាស្ត្រនានាផ្សេងទៀតដែលលោកបានលើកឡើង ក៏ប៉ុន្តែខ្ញុំសូមលើកឡើងចំណុចចំនួនប្រាំដែលអង្គជំនុំជម្រះសាលាដំបូងបានលើកឡើង។

ទីមួយ គឺថាតើ អៀង ធីរិទ្ធ គាត់មានលទ្ធភាពក្នុងការយល់បទចោទដែលដាក់បន្ទុកដែរឬទេ? លោកបានលើកឡើងនៅក្នុងកថាខណ្ឌ៤២ នៃរបាយការណ៍របស់លោក តើលោកអាចពន្យល់បន្ថែមដោយសង្ខេបដែរឬទេ?

[១៥:៣៣:០៣]

**លោក ស៊ីណា ហ្វាស៊ែល៖**

**ឆ៖** ជាសង្ខេបយើងយល់ឃើញថា លោកស្រីគាត់មានលទ្ធភាពក្នុងការយល់អំពីបទចោទ។ វាមានការពិបាកក្នុងការវិនិច្ឆ័យផងដែរ ដោយសារតែលោកស្រីគាត់បដិសេធមិនលើកឡើងបញ្ហានេះនៅពេលដែលយើងលើកឡើងក្នុងកិច្ចសម្ភាសន៍របស់យើងចំនួនបីដង។ ក៏ប៉ុន្តែ នៅក្នុងពេលដែលយើងសម្ភាសលោកស្រី បានលើកឡើងអំពីអត្ថន័យយ៉ាងច្បាស់អំពីបទចោទពីរ ឬក៏បីបទចោទ។ ឧទាហរណ៍

បទចោទមួយដែលលោកស្រីប្រាកដយល់អត្ថន័យរបស់វានោះ គឺវាពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ លោកស្រីបានលើកឡើង នៅពេលមួយនោះលោកស្រីបានលើកឡើង ក្នុងសេចក្តីដកស្រង់នេះជាសេចក្តីដកស្រង់។ គាត់លើកឡើងថា "ប្រជាជននៃប្រទេសទាំងមូលត្រូវបានបាត់ខ្លួន" ហើយយើងសួរគាត់អំពីមនុស្សឃាត គាត់បានលើកឡើងថា "គាត់មិនដែលបានសម្លាប់មនុស្សម្នាក់ណាទេ"។ ហើយចំណុចមួយទៀត លោកស្រីបានលើកឡើងថា "ការសម្លាប់នោះ គឺមានន័យថា-- ខ្ញុំសូមដកស្រង់សម្តីគាត់៖ "មនុស្សម្នាក់សម្លាប់មនុស្សម្នាក់ទៀត"។ ដូច្នេះយើងយល់ថា លោកស្រីគាត់យល់ថាអ្វីទៅជាការសម្លាប់?

[១៥:៣៤:៣៤]

នៅពេលដែលយើងពិភាក្សា និងលើកឡើងអំពីអ្វីទៅជាបទប្រល័យពូជសាសន៍? លោកស្រីបានលើកឡើងថា លើកឡើងអំពីប្រជាជនទាំងមូល។ នៅពេលដែលយើងនិយាយពាក់ព័ន្ធទៅនឹងពាក្យ "ទារុណកម្ម" គាត់លើកឡើងថា "មិនមាននរណាម្នាក់ដាក់ការគ្រោះថ្នាក់ដូច្នោះទេ"។ ដូច្នេះ ខ្ញុំយល់ឃើញថាពាក្យទាំងអស់នោះគឺគាត់យល់។ ហើយពាក់ព័ន្ធទៅនឹងការធ្វើទុក្ខបុកម្នេញផ្នែកសាសនាវិញ លោកស្រីគាត់ឆ្លើយដោយស្រពេចស្រពិល។ លោកស្រីបានលើកឡើងថាប្រជាជនកម្ពុជាមិនមែនមានមហិច្ឆតាដូច្នោះនោះទេ ដូច្នេះហើយយើងមិនមានលទ្ធភាពក្នុងការធ្វើការបកស្រាយទៅលើចំណុចនេះឡើយ។

តាមការយល់ឃើញរបស់ខ្ញុំលោកស្រី គឺគាត់មានលទ្ធភាពយល់ទៅលើបទចោទទាំងអស់នេះ ក៏ប៉ុន្តែការឆ្លើយតបរបស់គាត់មិនមែនឆ្លើយតបដោយផ្ទាល់នោះឡើយ។ នៅក្នុងពេលសម្ភាសមួយនោះ ក្នុងរយៈពេលការសម្ភាសចំនួនបីដង គឺខ្ញុំចាប់អារម្មណ៍ថាលោកស្រីគឺគាត់បានយល់អំពីបទចោទនោះ នៅពេលដែលខ្ញុំនិយាយជាន័យទូទៅ។

[១៥:៣៦:០៩]

**ស៖** សូមអរគុណ។ សំណួរមួយទៀតនោះដែលលោកតុលាការបានសួរលោកថាតើលោកស្រីអៀង ធីរិទ្ធ អាចមានលទ្ធភាពយល់សមស្របទៅលើនីតិវិធីរបស់តុលាការដែរឬទេ? នៅក្នុងរបាយ-ការណ៍របស់លោកបានលើកឡើងយ៉ាងជាក់លាក់ ហើយលោកលើកឡើងថា គាត់មិនដឹងលម្អិតទេ អំពីកិច្ចដំណើរការនីតិវិធី ប៉ុន្តែគាត់ដឹងអំពីកិច្ចដំណើរការនីតិវិធីទូទៅដែលវាអាចបះពាល់ទៅដល់គាត់ តើលោកអាចពន្យល់ទៅលើចំណុចហ្នឹងបានដែរឬទេ?

**ឆ៖** យើងយល់ឃើញថាលោកស្រី អៀង ធីរិទ្ធ មានការពិបាកយ៉ាងច្រើនចំពោះការយល់អំពីកិច្ចដំណើរការនីតិវិធីនេះ ជាពិសេសលោកស្រី គឺគាត់ហាក់ដូចជាយល់អំពីតួនាទីរបស់ចៅក្រម ហើយគាត់មិនយល់អំពីដំណើរការតទល់មុខគ្នានោះទេ។ យើងបានពន្យល់ថាតើមានអ្វីកើតឡើងនៅក្នុងតុលាការពាក់ព័ន្ធទៅនឹងសំណួរពីខាងសហព្រះរាជអាជ្ញា និងខាងមេធាវីការពារក្តី លោកស្រីហាក់ដូចជាមិនយល់នោះឡើយ។

[១៥:៣៧:១៤]

លើសពីនេះទៀត យើងយល់ឃើញថាលោកស្រីមិនអាចរក្សាទុកព័ត៌មានបានយូរវែងនោះទេ។ ហើយលោកស្រីក៏មិនមានលទ្ធភាពក្នុងការបង្ហាញហេតុផលទៅលើព័ត៌មានទាំងអស់នេះក្នុងលក្ខណៈជាបញ្ញាជន។ ដូច្នេះយើងយល់ឃើញថា លោកស្រីមានការពិបាកយ៉ាងច្រើនក្នុងការស្វែងយល់អំពីកិច្ចដំណើរការនីតិវិធីតុលាការ។ ជាពិសេសចំពោះអ្វីដែលបានលើកឡើងតាមរយៈសក្ខីកម្មរបស់សាក្សី និងមេធាវី ដូច្នេះហើយគាត់មានការពិបាកក្នុងការប្រាស្រ័យទាក់ទងនឹងអ្វីដែលបានលើកឡើង ជាពិសេសពីខាងមេធាវីនិងភាគី។

[១៥:៣៨:០៣]

**ស៖** សូមអរគុណ។ ចំណុចមួយទៀតដែលបានសួរនោះគឺថា តើលោកស្រីនោះមានលទ្ធភាពក្នុងការបង្គាប់ណែនាំទៅដល់មេធាវីដែរឬទេ? ថាតើសូមឲ្យលោកជួយពន្យល់ចំណុចហ្នឹងបានដែរឬទេ?

**ឆ៖** ខ្ញុំអាចពន្យល់បាន។ យើងយល់ឃើញថា យើងអាចធ្វើការបំបែកសញ្ញាណហ្នឹងចេញពីគ្នា ជាពិសេសសមត្ថភាពហ្នឹង ជាពិសេសពាក់ព័ន្ធទៅនឹងមេធាវី។ ការផ្តល់ព័ត៌មានទៅដល់មេធាវី និងការជួយមេធាវីក្នុងការរៀបចំការពារខ្លួនសម្រាប់លោកស្រី ពាក់ព័ន្ធទៅនឹងចំណុចចំនួនបី ខ្ញុំគិតថាលោកស្រីមានលទ្ធភាពក្នុងការសហការជាមួយនឹងមេធាវី លោកស្រីបានលើកឡើងថាមេធាវីរបស់គាត់បានជួយជ្រោមជ្រែងទៅដល់គាត់។ ក៏ប៉ុន្តែយើងមិនច្បាស់លាស់ យើងក៏មិនប្រាកដថា តើគាត់មានការពិបាកច្រើននៅក្នុងការជួយជ្រោមជ្រែងទៅដល់មេធាវីរបស់គាត់ ទៅដល់ការរៀបចំការការពារក្តីរបស់គាត់នោះទេ។ ដោយហេតុថាលោកស្រីគាត់មានការចុះខ្សោយសតិបញ្ញាធ្ងន់ធ្ងរចំពោះសកម្មភាព និងការចូលរួមរបស់គាត់ក្នុងការការពារក្តី ជាពិសេសនៅក្នុងជីវិតរបស់គាត់ក្នុងពេលនេះ។ យើងឃើញមានលទ្ធ-ភាពរបស់គាត់មួយចំនួន ដែលគាត់អាចធ្វើការណែនាំជាមួយមេធាវីអាចសហការជាមួយមេធាវី ក៏ប៉ុន្តែវាមានការពិបាកក្នុងការជួយជ្រោមជ្រែងទៅដល់មេធាវីរបស់គាត់ ក្នុងការរៀបចំការពារក្តីរបស់គាត់

ដោយសារគាត់មានការចុះខ្សោយសតិបញ្ញា។

[១៥:៣៩:៥៣]

**ស៖** សូមអរគុណ។ លោកក៏បានលើកឡើងអំពីលទ្ធភាពរបស់គាត់ ក្នុងការបង្ហាញអំពីអត្ត-សញ្ញាណ និងការដេញដោលទៅលើសាក្សីថាតើ លោកស្រីគាត់មានលទ្ធភាពក្នុងការសម្រេចនិយាយ ឬក៏មិននិយាយនៅក្នុងសវនាការ។ គឺលោកលើកឡើងនៅក្នុងកថាខណ្ឌ៤៨។ ដូច្នេះថាតើលោកអាចធ្វើការបង្ហាញទស្សនៈយោបល់របស់គាត់ត្រង់ចំណុចហ្នឹងបានដែរឬទេ?

**ឆ៖** បាទបាន។ យើងយល់ឃើញថា លោកស្រី អៀង ធីរិទ្ធ អាចមានលទ្ធភាពស្គាល់បុគ្គលដែលលោកស្រីស្គាល់ ទោះបីជាលោកស្រីមិនអាចប្រាប់ឈ្មោះ ប្រាប់តួនាទី ក៏ដោយ។ យើងយល់ឃើញថា លោកស្រីអាចលើកឡើងសំណួរដែលមានវាមានការជាប់ពាក់ព័ន្ធ និងលោកស្រីក៏អាចយល់អំពីអត្ថន័យនៅក្នុងសំណួរនោះផងដែរ។ លោកស្រីអាចផ្តល់ការការពារក្តីទៅដល់រូបគាត់។ ទោះបីជាចម្លើយរបស់គាត់ពេលដែលលើកឡើងឆ្លើយតបមួយចំនួនវាអាចផ្ទុយគ្នាក៏ដោយ ក៏ប៉ុន្តែក៏វាមានលក្ខណៈស៊ីសង្វាក់ផងដែរ។ ក្នុងពេលមួយចំនួនលោកស្រីលើកឡើងថា គាត់នៅក្មេងកាលដែលឧក្រិដ្ឋកម្មនោះបានកើតឡើង ព័ត៌មានបែបនេះ គឺវាមិនស៊ីសង្វាក់គ្នាទៅនឹងព័ត៌មានមួយចំនួន។

**ស៖** សូមអរគុណ។ សំណួរ និងចំណុចមួយទៀត ដែលយើងសួរនោះ ថាតើលោកស្រី អៀង ធីរិទ្ធ មានលទ្ធភាពក្នុងការផ្តល់សក្ខីកម្មដែរឬទេ?

[១៥:៤១:៣២]

**ឆ៖** ការយល់ឃើញរបស់យើងខ្ញុំនេះ គឺថាលោកស្រីនោះអាចយល់សំណួរដែលបានតាំងទៅកាន់គាត់ ដែលបានសួរទៅកាន់គាត់ លោកស្រីក៏អាចឆ្លើយតបទៅនឹងសំណួរហ្នឹងផងដែរ។ លោកស្រីមិនមានការពិបាកក្នុងការយល់ទៅលើសំណួរ និងឆ្លើយតបទៅនឹងសំណួរនោះទេ។ យើងយល់ឃើញថាលោកស្រីមានលទ្ធភាពក្នុងការផ្តល់សក្ខីកម្មនៅក្នុងតុលាការនេះ។ យើងកត់សម្គាល់ថាទោះបីជាចម្លើយរបស់លោកស្រីមិនអាចជឿជាក់បានក៏ដោយ ក៏ប៉ុន្តែលោកស្រីនៅតែមានលទ្ធភាពក្នុងការឆ្លើយតបទៅនឹងសំណួរ ហើយអាចផ្តល់ការការពារខ្លួនសម្រាប់គាត់។

ដូច្នេះហើយគឺចម្លើយរបស់គាត់ គឺមិនពាក់ព័ន្ធទៅនឹងការផ្តល់សក្ខីកម្មនោះទេ។ ប៉ុន្តែលោកស្រីគាត់មានលទ្ធភាពឆ្លើយសំណួរ និងយល់ទៅកាន់សំណួរ។

**ស៖** ចំណុចមួយទៀត គឺថាតើគាត់អាចយល់អំពីផលវិបាកនៃការកាត់ទោសទៅលើរូបគាត់ដែរឬទេ? ដែលលោកលើកឡើងនៅក្នុងកថាខណ្ឌ៤៦ នៃរបាយការណ៍របស់លោក សូមលោកជួយពន្យល់។

**ឆ៖** លោកស្រីគាត់បដិសេធមិនឆ្លើយតបសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងផលវិបាកកើតចេញពីការកាត់ទោសទៅលើរូបគាត់ ក៏ប៉ុន្តែលោកស្រីបានបង្ហាញលទ្ធភាពរបស់គាត់ក្នុងការលើកឡើងអំពីផលវិបាកដែលវាពាក់ព័ន្ធទៅនឹងបញ្ហាទាក់ទងមួយចំនួន ជាពិសេសលោកស្រីយល់អំពីផលវិបាកក្នុងការរកឃើញថា គាត់ឆ្កួត ជាសម្តីរបស់គាត់។

[១៥:៤៣:២០]

យើងបានបង្ហាញរូបថតរបស់គាត់ក្នុងពេលដែលគាត់ចូលខ្លួននៅក្នុងតុលាការនេះលើកដំបូង។ លោកស្រីបានអានអក្សរនៅក្រោមរូបថតនុ៎ង ដែលវានៅក្រោមរូបថត លោកស្រីបានលើកសម្តីថា ពួកគេ តុលាការបាន មិនកោះហៅខ្ញុំម្តងទៀតទេឲ្យចូលតុលាការនេះ ដោយសារតែមានប្រជាជនច្រើនណាស់គាត់គាំទ្រខ្ញុំ។ បន្ទាប់មកយើងបង្ហាញអត្ថបទមួយទៀត ដែលអត្ថបទនោះបានបង្ហាញថា ពាក្យវង្វេងវង្វាន់ស្មារតីនៅក្នុងចំណងជើងឯកសារ។ លោកស្រីបានចង្អុលទៅលើពាក្យ *ឌីម៉ែនស្យា* (Dementia) ហ្នឹង ជនជាប់ចោទអាចឆ្កួតហើយ ដូច្នេះហើយគ្មានអ្នកណាមកកាត់ទោសមនុស្សឆ្កួតនោះឡើយ។ នេះជាសម្តីរបស់គាត់។

តាមចំណុចនេះ គឺយើងយល់ឃើញថា លោកស្រីអាចយល់អំពីផលវិបាកដែលកើតចេញពីពាក្យថាឆ្កួតនោះ។ ដូច្នេះហើយ យើងអាចទាញការសន្និដ្ឋានថា លោកស្រីអាចយល់អំពីផលវិបាកដែលកើតចេញពីការកាត់ទោសនេះបាន។

**ស៖** សូមអរគុណ។ តុលាការបានសួរលោកឲ្យពិចារណាសំណួរមួយចំនួនពីមេធាវីការពារក្តីជាពិសេសចំពោះលទ្ធភាពរបស់លោកស្រី អៀង ធីរិទ្ធ ក្នុងការតាមដាន និងចូលរួមឲ្យបានសមស្របតាមរយៈមធ្យោបាយសោតទស្សន៍។ ថាតើលោកអាចពន្យល់ទៅលើលទ្ធភាពហ្នឹងបានដែរឬទេ?

[១៥:៤៤:៥៤]

**ឆ៖** ខ្ញុំអាចពន្យល់បាន។ យើងយល់ឃើញថា មួយផ្នែកនោះគឺយើងមិនបានដឹង និងមិនឃើញមានភស្តុតាងណាមួយបង្ហាញថា មធ្យោបាយមួយនេះគឺ វាអាចលើកកម្ពស់លទ្ធភាពដែលយើងបានពិភាក្សាដេញដោលនៅទីនេះនោះទេ។ ក៏ប៉ុន្តែយើងអាចយល់ឃើញថា លោកស្រីមានលទ្ធភាពអាចតាមដានតាមធ្យោបាយសោតទស្សន៍បាន ជាពិសេសប្រសិនបើមានមេធាវីដែលនិយាយភាសាខ្មែរនោះនៅ

ជាមួយគាត់។ យើងមិនអាចនិយាយថាតើមធ្យោបាយនេះ វាអាចជួយជំរុញលើកកម្ពស់ការយល់របស់គាត់ទៅលើកិច្ចដំណើរការនីតិវិធីនោះទេ ខ្ញុំមិនបានឃើញការសិក្សាស្រាវជ្រាវណាមួយដែលបានលើកឡើងអំពីមធ្យោបាយសោតទស្សន៍នេះ ដែលវាអាចជួយជំរុញឲ្យបុគ្គលហ្នឹងអាចយល់ដំណើរការជំនុំជម្រះនោះទេ។

[១៥:៤៥:៥៧]

**ស៖** សូមអរគុណ។ នៅក្នុងរបាយការណ៍របស់លោកចុងក្រោយ លោកបានធ្វើការសន្និដ្ឋានជាសរុប ហើយលោកបានកត់សម្គាល់នៅក្នុងគំនិតវិជ្ជាជីវៈរបស់លោកនៅក្នុងក្រុមទាំងបួននាក់នេះជាពិសេសពាក់ព័ន្ធទៅនឹងសម្បទារបស់លោកស្រី អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះថាតើវាមានតុល្យភាពដែរឬទេ? លោកបានធ្វើការពន្យល់ចំណុចហ្នឹងមួយចំនួន។ លោកបានលើកឡើងថា អាស្រ័យទៅលើលក្ខខណ្ឌដែលតុលាការប្រើប្រាស់ ហើយវាអាស្រ័យទៅលើតុល្យភាពដែលបានប្រើប្រាស់ ហើយលោកបានសន្និដ្ឋានថា តាមកោសល្យវិច័យរបស់លោក លោកមិនយល់ឃើញថា លោកស្រីមិនមានលទ្ធភាពយល់ទៅលើសវនាការនោះទេ។

**ឆ៖** ត្រឹមត្រូវ។

**ស៖** លោកបានលើកឡើងថា សេចក្ដីសន្និដ្ឋានរបស់លោកនោះគឺវាអាច វាពាក់ព័ន្ធទៅនឹងការឡើងចុះនៃការវង្វេងវង្វាន់ស្មារតី និងសតិបញ្ញារបស់គាត់ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ គឺពិតជាត្រឹមត្រូវ។

**ស៖** ដូច្នេះហើយវាមិនមែនជាជំងឺវង្វេងវង្វាន់មួយដែលកើតឡើងដោយវាចៃដន្យនោះទេ តាមអ្វីដែលខ្ញុំយល់។ លោកបានឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា ដែលនៅក្នុងហ្នឹងលើកអំពីសេចក្ដីសង្ខេបនៅក្នុងសវនាការ ហើយលោកបានលើកឡើងអំពីមេធាវីដែលនិយាយភាសាខ្មែរនៅជាមួយគាត់ លោកយល់ឃើញថា ពិចារណាទៅលើការប្រសើរឡើងនៃកម្រិតយល់ដឹងរបស់គាត់នោះ គឺលោកបានលើកឡើងអំពីការតាមដាន និងយល់អំពីនីតិវិធីតុលាការរបស់លោកស្រី។ តើពិតជាត្រឹមត្រូវដែរឬទេ?

[១៥:៤៧:៥០]

**ឆ៖** ត្រឹមត្រូវ។

**សៈ** ចំណុចចុងក្រោយ គឺលោកបានលើកឡើងថា វាមានលទ្ធភាពក្នុងការធ្វើឲ្យសតិបញ្ញារបស់គាត់នេះប្រសើរឡើង ហើយវាអាចឲ្យលទ្ធភាពសតិបញ្ញារបស់គាត់នោះឡើងល្អឡើងវិញ ហើយឲ្យគាត់យល់អំពីកិច្ចដំណើរការនីតិវិធីផ្លូវច្បាប់ ថាតើលោកមានការយល់ឃើញដូច្នោះដែរឬទេ?

**ផៈ** ខ្ញុំយល់ដូច្នោះមែន។

**សៈ** ខ្ញុំមានសំណួរមួយចំនួន ដែលវាពាក់ព័ន្ធទៅនឹងអនាគត និងពេលខាងមុខនៃអ្នកជំនាញទាំងពីរ។ ជាបឋមប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចថា លោកស្រី អៀង ធីរិទ្ធ មានសម្បទាក្នុងការចូលរួមការជំនុំជម្រះថាតើលោកអាចពន្យល់អំពីផលប៉ះពាល់នៃលក្ខខណ្ឌរបស់លោកស្រីដែរឬទេ? ដូចដែលលោកបានរៀបរាប់នៅក្នុងរបាយការណ៍ ជាពិសេសនៅក្នុងសវនាការនេះ ដែលមានជាប់ពាក់ព័ន្ធទៅនឹងជនជាប់ចោទវ័យចំណាស់ៗចំនួនបីរូប ហើយមានបញ្ហាសុខភាពដែរនោះ?

[១៥:៤៩:០៦]

**ផៈ** ខ្ញុំសូមបញ្ជាក់ថា នៅក្នុងសវនាការនេះលោកស្រីមានន័យយ៉ាងម៉េច? បានន័យថាពេលវេលាដែលត្រូវជំនុំជម្រះ ឬក៏យ៉ាងណា?

**សៈ** លក្ខខណ្ឌស្ថានភាពរបស់លោកស្រី លោកបានរៀបរាប់ហើយ។ ដូច្នេះហើយស្ថានភាពសុខភាពរបស់គាត់ហ្នឹងវាអាចប៉ះពាល់ដែរឬទេទៅនឹងដំណើរការសវនាការដែលវាមានជនជាប់ចោទវ័យចំណាស់ចំនួនបីរូបទៀត។ ដូច្នេះថាតើលោកគិតថា ស្ថានភាពសុខភាពស្មារតីរបស់គាត់នោះ វាអាចប៉ះពាល់ទៅដល់ដំណើរការដោយរលូននៃសវនាការនេះដែរឬទេ?

**ផៈ** ខ្ញុំគិតថាវាអាចប៉ះពាល់ ជាពិសេសវាទំនងដែលវាពាក់ព័ន្ធទៅនឹងលទ្ធភាពសមត្ថភាពរបស់ជនជាប់ចោទរូបនេះដែលវាមានការឡើងចុះ។ ដូច្នេះ ពេលខ្លះទៅលោកស្រីមិនអាចចូលរួមសវនាការបាន ហើយពេលខ្លះទៅលោកស្រីអាចត្រូវការពេលវេលា និងព័ត៌មានមួយចំនួនពីក្រុមច្បាប់ ដើម្បីឲ្យការចងចាំរបស់គាត់នឹកឃើញឡើងវិញ។ ហេតុដូច្នេះ ខ្ញុំគិតថាលទ្ធភាពរបស់គាត់ ស្ថានភាពបញ្ញារបស់គាត់ អាចវាជាការរារាំង និងបង្អាក់សវនាការផងដែរ។

[១៥:៥០:២៧]

**សៈ** លោកលើកឡើងថា សេចក្ដីសម្រេចរបស់សាលាក្ដីនេះគឺជាសេចក្ដីសម្រេចចុងក្រោយចំពោះសម្បទារបស់លោកស្រី អៀង ធីរិទ្ធ។ ដូច្នេះប្រសិនបើសាលាដំបូងសម្រេចថាលោកស្រី អៀង ធីរិទ្ធ មានសម្បទាចូលរួមការជំនុំជម្រះក្ដី ថាតើលោកអាចនឹងស្នើសុំឲ្យមានការធ្វើកោសល្យវិច័យជាញឹក

ញាប់បន្ថែមទៀតដែរឬទេ? ហើយថាតើរយៈពេលប៉ុន្មានដែលយើងត្រូវធ្វើការកោសល្យវិច័យគាត់។

**ឆ៖** ខ្ញុំគិតថា វាជាប្រយោជន៍ក្នុងការតាមដានស្ថានភាពសតិបញ្ញារបស់គាត់ ហើយអ្នកចិត្តសាស្ត្រ អ្នកវិកលវិទូអាចធ្វើការតាមដានទៅលើស្ថានភាពសតិបញ្ញារបស់គាត់។ ដូច្នេះ ខ្ញុំចាប់អារម្មណ៍ដែលត្រូវតាមដានទៅលើរូបគាត់នោះ គឺត្រូវតែធ្វើការតាមដានគាត់ ថាតើវាមានការប្រែប្រួលច្បាស់លាស់ទៅលើស្ថានភាពសតិបញ្ញាដែរឬទេ? ថាតើយើងធ្វើកោសល្យវិច័យរយៈពេលប៉ុន្មាន? ហើយរយៈពេលប៉ុនណាដែលត្រូវធ្វើកោសល្យវិច័យម្តងនោះ? គឺវាអាស្រ័យទៅលើការដែលស្ថានភាពបង្ហាញចេញពីរូបគាត់ ក៏ប៉ុន្តែខ្ញុំគិតថាវាសមហេតុផល យើងត្រូវធ្វើកោសល្យវិច័យបីខែម្តង។ សូមអរគុណច្រើន។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

លោកបណ្ឌិត លីនណា និងលោកវេជ្ជបណ្ឌិត ហ្វាស៊ែល នៅពេលនេះខ្ញុំបញ្ចប់ការដេញដោលរបស់ខ្ញុំហើយ ហើយខ្ញុំសូមផ្តល់វេទិកានេះទៅកាន់លោកប្រធានវិញ។ សូមអរគុណច្រើនដែលលោកបានផ្តល់ព័ត៌មានលម្អិតជួយជ្រោមជ្រែងដល់សាលាដំបូងរបស់យើងខ្ញុំ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីចៅក្រម។ អរគុណលោកអ្នកជំនាញទាំងពីររូប។

ហើយជាកិច្ចបន្ត អង្គជំនុំជម្រះប្រគល់វេទិកាទៅចៅក្រមផ្សេងទៀត ប្រសិនបើមានសំណួរអ្វីចង់សួរបន្ថែមចំពោះអ្នកជំនាញរូបនេះ។ សូមអញ្ជើញ!

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់អរគុណចំពោះអ្នកជំនាញដែលបានឆ្លើយតបនៅក្នុងវសៀលនេះ។ ចំពោះខ្ញុំផ្ទាល់ខ្ញុំមានតែសំណួរពីរបី តែខ្លីទេសម្រាប់សួរអ្នកជំនាញ។

**ស៖** ជាដំបូងគឺសំណួរពាក់ព័ន្ធនឹងបញ្ហារោគវិនិច្ឆ័យនៃរោគរបស់លោកស្រី អៀង ធីរិទ្ធ។ លោកបានបញ្ជាក់ថា លោកមិនគិតថា អៀង ធីរិទ្ធ អាចនឹងមានជំងឺ *អាល់ហ្សៃមើ* ជំងឺភ្លេចភ្លាំង។ ប៉ុន្តែលោកបានបញ្ជាក់ថា គឺថាគាត់អាចមានកម្រិតទីប្រាំ នៃ*អាយស្បើក* *(Reisberg)* ដែលបញ្ជាក់ពីកម្រិតនៃជំងឺនេះ។ សំណួរទីមួយរបស់ខ្ញុំនេះ គឺថាតើអាកម្រិត *អាយស្បើក នេះ* គឺជាកម្រិតដែលជាក់លាក់ច្បាស់លាស់នៃជំងឺ*អាល់ហ្សៃមើ* ឬគ្រាន់តែជាការវាយតម្លៃតាមបែបគ្លីនិក ដែលអនុវត្តចំពោះគ្រប់អ្នកដែលមានជំងឺបាត់បង់សតិបញ្ញានេះដូចគ្នាទាំងអស់ ដោយសារជំងឺសរសៃឈាមនេះ។

តើការវាយតម្លៃនេះគឺជាការវាយតម្លៃតាមបែបគ្លីនិក ឬក៏យ៉ាងម៉េច?

**លោក ស៊ីណា ហ្វាស៊ែល៖**

**ឆ៖** ពាក់ព័ន្ធទៅនឹងផ្នែកទីមួយនៃសំណួររបស់លោក វាមិនពាក់ព័ន្ធជាក់លាក់ទៅនឹងជំងឺ *អាល់ហ្សៃម៉ើ* នោះទេ។ ពាក់ព័ន្ធទៅនឹងកម្រិតដែលគេវាយតម្លៃ ដែលក្នុងហ្នឹងគេលើកឡើងថា លើកឡើងអំពីការវង្វេងស្មារតី ក៏ប៉ុន្តែវាមានការប្រែប្រួលអាស្រ័យទៅលើស្ថានភាពសតិបញ្ញា និងការវង្វេងវង្វាន់ស្មារតីរបស់បុគ្គល។ គេអាចប្រើប្រាស់កម្រិតវិនិច្ឆ័យនេះ ចំពោះអ្នកដែលមិនមានជំងឺ *អាល់ហ្សៃម៉ើ* ក៏ប៉ុន្តែគេអាចប្រើប្រាស់ចំពោះអ្នកដែលមានប្រវត្តិកត់ត្រាអំពីជំងឺ *អាល់ហ្សៃម៉ើ* នោះផងដែរ។ ដូច្នេះហើយវា ខ្ញុំសូមលើកឡើងថា ជាមូលដ្ឋានគេអាចប្រើប្រាស់វាបាន វាមានកម្រិតរបស់វាច្រើន ក៏ប៉ុន្តែតាមការដឹងរបស់ខ្ញុំគឺ គេប្រើប្រាស់ការវិនិច្ឆ័យនេះសម្រាប់ជំងឺភ្លេចភ្លាំងគឺ *អាល់ហ្សៃម៉ើ* ។ បាទ, ខ្ញុំភ្លេចសំណួរទីពីរ ផ្នែកទីពីររបស់លោកចៅក្រម ខ្ញុំភ្លេចហើយ។

**ស៖** លោកបានបញ្ជាក់ថា គឺគាត់ស្ថិតនៅក្នុងកម្រិតទីប្រាំ ហើយប្រសិនបើយល់ពីរបាយការណ៍របស់លោកនោះគឺលោកបានបញ្ជាក់យ៉ាងច្បាស់ថា កម្រិតទីប្រាំនេះគឺជាកម្រិតនៃការបាត់បង់សតិបញ្ញាឆាប់រហ័ស ហើយនិងមានការថយចុះនូវផ្នែកសតិបញ្ញាធ្ងន់ធ្ងរគួរសម។ តើអ្វីដែលយល់នេះ ថាវាត្រឹមត្រូវទេ ឬក៏លោកថាត្រូវមានការបញ្ជាក់បន្ថែមទៀត? ដើម្បីសម្រួលដល់ការងារនេះខ្ញុំគិតថា ផ្នែកពាក់ព័ន្ធនៃរបាយការណ៍របស់លោកនោះ គឺថាស្ថិតនៅចុងក្រោយនៃកថាខណ្ឌទី៣៦។

[១៥:៥៦:២៨]

**ឆ៖** អត់ទេ។ ខ្ញុំមិនមានអ្វីបន្ថែមនោះទេ ក៏ប៉ុន្តែខ្ញុំសូមបំភ្លឺបន្ថែមពាក្យថា ការវង្វេងវង្វាន់ស្មារតីពេលខ្លះគេប្រើប្រាស់វាតាមពាក្យឡាតាំង។ ដូច្នេះហើយយើងធ្វើការបែងចែករវាងពាក្យហ្នឹង ខ្ញុំគិតថាកម្រិតប្រាំ គឺជាការវង្វេងវង្វាន់កម្រិតស្រាល ដែលយើងអាចថាវាជាការចុះខ្សោយសតិបញ្ញាធ្ងន់ធ្ងរមធ្យម។

**ស៖** អត្ថប្រយោជន៍មួយគឺថា យើងមានរយៈពេលណាមួយគឺថា យើងក៏មានរបាយការណ៍កោសល្យវិច័យច្រើន។ ហើយខ្ញុំសូមយោងទៅលើរបាយការណ៍កោសល្យវិច័យរបស់សាស្ត្រាចារ្យប្រ៊ីនឌីង ហើយនិងសាស្ត្រាចារ្យ កាស៊ុន បូណាត គឺដែលបានបង្ហាញ ដែលបានធ្វើឡើងកាលពីពីរឆ្នាំមុននោះ គឺយើងកត់សម្គាល់ឃើញថា អ្នកជំនាញការទាំងពីរនេះបានចាត់ទុកថា អៀង ធីរិទ្ធ នេះគាត់មានវិបត្តិផ្នែកសតិបញ្ញាស្រាលគឺថាគាត់អាចចងចាំបានខ្លីៗ ហើយវិបត្តិនេះគឺថាវាមានលក្ខណៈធម្មតាទេ

យោងទៅលើអាយុរបស់ជនជាប់ចោទ ហើយដូចជាវាមិនមានការវិវត្តន៍អីធ្ងន់ធ្ងរទេ តាំងពីឆ្នាំ២០០៦ មកនោះ។

[១៥:៥៨:១៤]

ចំពោះវិបត្តិនៃសតិបញ្ញានេះគឺថាគាត់បានបញ្ជាក់ជូនថាដូចតទៅនេះ៖

គាត់និយាយថា គឺថានៅក្នុងរបាយការណ៍របស់គាត់គឺនៅទំព័រទីប្រាំបី គាត់បានលើកឡើងថា បញ្ហានៃការចងចាំរយៈពេលខ្លីនោះគឺថាបានកើតឡើងនៅពេលសម្ភាសន៍ទោះបីជា អៀង ធីរិទ្ធ គាត់បាន គិតថាគាត់មានមេធាវីបីនាក់ ហើយគាត់អាចបញ្ជាក់ពីតួនាទីរបស់មេធាវីទាំងអស់នោះ ប៉ុន្តែគាត់ត្រូវតែ ពិនិត្យមើលសៀវភៅកំណត់ត្រារបស់គាត់ ដើម្បីរំឭពីឈ្មោះរបស់មេធាវីទាំងអស់នោះ។ ក៏ប៉ុន្តែ ពេល នោះ គាត់បានចងចាំពីឈ្មោះរបស់យើងពីអ្នកសម្ភាសន៍ ហើយនិងពេលវេលានៃការសម្ភាសន៍នោះ។ ហើយគាត់បានរំឭកពីរឿងរ៉ាវដែលកើតឡើងកាលពីអតីតកាល ហើយវាមានបទពិសោធន៍នៃការបាក់ ស្បាតមួយចំនួនដែលយើងបានលើកឡើង។

[១៥:៥៩:១៤]

ទោះបីជាគាត់មានការលំបាកក្នុងការរំឭក ឬចងចាំនៅលំដាប់កាលប្បវត្តិនៃហេតុការណ៍មួយ ចំនួនក៏ដោយ ក៏ប៉ុន្តែក្រៅពីហ្នឹងគឺថាគាត់អាចផ្តល់នូវហេតុការណ៍សំខាន់ៗ ឬក៏អាចនិយាយរឿងរ៉ាវ វែងៗ ហើយនិងលម្អិតដែលគាំទ្រទៅលើទស្សនៈរបស់គាត់ទៅលើតួនាទី និងមុខងារនៅក្នុងសម័យរបប ខ្មែរក្រហម-- របបកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំរំឭករឿងទាំងអស់នេះ គឺថាដើម្បីឲ្យមានការយល់ឲ្យកាន់ តែច្បាស់។ លោកបាននិយាយថា ការវិវត្តន៍ក្នុងរយៈពេលពីរឆ្នាំនេះ គឺជាការវិវត្តន៍មានភាពធ្ងន់ធ្ងរមាន សារៈសំខាន់ ឬក៏គ្រាន់តែជាការវិវត្តន៍មួយដែលមានលក្ខណៈធម្មតាដែលសមស្របទៅនឹងការរោគវិនិច្ឆ័យ នៃជំងឺ*អាល់ហៃម៉ឺ* ឬក៏លោកមានការកត់សម្គាល់អ្វីបន្ថែមទៀតសម្រាប់ជម្រាបជូនអង្គជំនុំជម្រះ។

[១៦:០០:១៥]

**ឆ៖** វាពិបាកក្នុងការលើកឡើងឲ្យបានជាក់លាក់ទៅលើបញ្ហានេះ យើងឃើញមានភស្តុតាង បង្ហាញថាមានការធ្លាក់ចុះនៃការចងចាំរបស់គាត់។ លោកចៅក្រមអាចមើលនៅក្នុងរបាយការណ៍ ដូច ដែលលោកបានចង្អុលបញ្ជាក់ពាក់ព័ន្ធទៅនឹងសំណួរដែលសួរនៅក្នុងឆ្នាំ២០០៩ ដែលក្នុងនោះមានការ ឆ្លើយទៅកាន់សំណួរដែលបានដាក់មកកាន់យើងផងដែរ។ លោក ខាំប៊ែល បានលើកឡើងបញ្ហាហ្នឹងដូច ដែរយើងបានបញ្ជាក់អំពីការចងចាំពេលវេលានឹងទីតាំងផងដែរ ថាតើយើងរំពឹងថាតើវាយ៉ាងម៉េចនោះ

វាពិបាកក្នុងការដឹងណាស់ ដោយសារតែវាស្រ័យទៅលើប្រភេទនៃជំងឺ។ វាមិនមានវិធីតែមួយដែលយើងអាចកំណត់ឲ្យបានជាក់លាក់ណាស់ ថាតើវាមានការចុះថយលឿន ឬក៏យឺត? វាមានការពិបាកក្នុងការយល់ដូច្នេះ ហើយថា តើការធ្លាក់ចុះការចងចាំនោះវាលឿនប៉ុនណា វាយឺតប៉ុនណា? ក៏ប៉ុន្តែ ខ្ញុំសូមបញ្ជាក់ថា មានភស្តុតាងបង្ហាញថា មានការធ្លាក់ចុះនូវការចងចាំរបស់គាត់ដែលវាពាក់ព័ន្ធទៅនឹងការដែលយើងសួរអំពីទីកន្លែងនឹងពេលវេលា ហើយការចងចាំរយៈពេលយូរក៏មានការធ្លាក់ចុះផងដែរ។

ចំណុចមួយទៀត ដែលយើងសូមលើកឡើងនោះ គឺថារបាយការណ៍លោកសាស្ត្រាចារ្យ ប្រ៊ីនឌីង និង កាស៊ីន បូណាត នៅតែប្រើប្រាស់ *ឌីមែនស្យា* គឺវង្វេងស្មារតី។ ដូច្នេះយើងមិនយល់ថា ជំងឺវង្វេងវង្វាន់ស្មារតីនេះវាពាក់ព័ន្ធទៅនឹងវ័យ ហើយវាលក្ខណៈសាមញ្ញនោះទេ វាកើតឡើងដោយសារជំងឺៗវាប្រែប្រួល។ ដូច្នេះនៅពេលដែលយើងចងចាំដូច្នេះ យើងជឿថា វាមានភាពស៊ីសង្វាក់គ្នាក្នុងការវិនិច្ឆ័យរោគរបស់យើងក្នុងចន្លោះឆ្នាំ២០០៩ និង២០១១។ សូមអរគុណ។

**សៈ** លោកនិយាយថា វាមានការលំបាកក្នុងការដឹងថាតើនៅក្នុងជំងឺនេះវិវត្តន៍ក្នុងល្បឿនកម្រិតណានោះ គឺពិបាកណាស់។ ប៉ុន្តែបើខ្ញុំយល់ច្បាស់នោះ ទោះជាយ៉ាងណាក៏ដោយគឺថាវាមានភាពច្បាស់លាស់ណាស់ថា ជំងឺនោះគឺនឹងបណ្ដាលឲ្យមាននូវការធ្លាក់ចុះជាលំដាប់នៃការចងចាំរបស់គាត់ ហើយនិងមុខងារសតិបញ្ញារបស់គាត់។ តើយើងអាចនិយាយថាករណីនេះវាច្បាស់លាស់ដែរឬទេលោក?

[១៦:០៣:១០]

**ឆៈ** ចំពោះអ្នកជំងឺដែលមានជំងឺ*អាល់ហ្សៃមើ* គឺថាបាត់បង់សតិបញ្ញា នឹងគឺជាទម្រង់នៃជំងឺវង្វេងវង្វាន់ដែលបង្កឡើងដោយជំងឺមួយ ហើយបើយើងមិនព្យាបាលហ្នឹងទេ ជំងឺវង្វេងវង្វាន់គឺមិនចុះថយទេ។ ប្រសិនបើនេះជាករណីនេះយើងមានទស្សនៈថា លោកស្រី អៀង ធីរិទ្ធ ហ្នឹង គឺថារោគវិនិច្ឆ័យរបស់គាត់ហ្នឹង គឺថាវាអាចនឹងមានការធ្លាក់ចុះ ប៉ុន្តែមិនមែននិយាយថា អ្នកជំងឺគ្រប់រូបដែលមានជំងឺវង្វេងវង្វាន់នោះសុទ្ធតែអាចបន្ថយបាននោះទេ។ ប៉ុន្តែលោកស្រី អៀង ធីរិទ្ធ នោះគឺមានមូលដ្ឋានមួយចំនួននៃប្រភេទជំងឺវង្វេងវង្វាន់ ហើយយើងកត់សម្គាល់ថា យើងមើលតេស្តឈាម គឺថាវាមាន ត្រូវធ្វើតេស្តឈាមហ្នឹងបន្ថែមទៀតដែរ។

**សៈ** ចំពោះការបាត់បង់ស្មារតីដោយសារតែជំងឺសរសៃឈាមនោះ តើវាមានលក្ខណៈអីដូចជានឹងប្រភេទជំងឺ *អាល់ហ្សៃមើ* ដែរឬទេ?

[១៦:០៤:៣១]

**ឆ៖** តើលោកចៅក្រុមមានន័យថា តើយើងអាចធ្វើរោគវិនិច្ឆ័យម៉េចឬក៏ថាយើងធ្វើរោគវិនិច្ឆ័យបញ្ជាក់បន្ថែម?

**ស៖** បាទ, គឺយើងចង់និយាយអំពីការទស្សន៍ទាយការប្រមើលមើលនៃការវិវត្តន៍នៃជំងឺ។

**ឆ៖** បាទ, ខ្ញុំយល់ឃើញថា ចំពោះជំងឺវង្វេងវង្វាន់ទាក់ទងនឹងសរសៃឈាមខួរក្បាលនោះ គឺថាវាអាចចុះថយទៅតាមពេលវេលា ប៉ុន្តែវាមានការប្រែប្រួលចុះគំហុកនៅក្នុងមុខងារសតិបញ្ញា ដែលវាផ្សារភ្ជាប់ទៅនឹងហេតុការណ៍សរសៃរឈាមនៅក្នុងខួរក្បាល ឧទាហរណ៍ថាមានស្ត្រូកខ្លាំង ឬក៏ស្ត្រូកខ្សោយ ឬក៏ជំងឺដាច់សរសៃឈាមហ្នឹងបាទ។ គឺថាវាអាចមានការចុះខ្សោយដូចជាមានការស្ពាប់មួយចំហៀងខ្លួន ឬក៏បាត់សំឡេង ឬក៏សំឡេងនិយាយលឿន អ៊ីចឹងគឺថាជំងឺវង្វេងវង្វាន់ដោយសារដាច់សរសៃឈាមនេះ គឺថាវាកែប្រែទៅតាមដំណាក់ជំហានៗ ប៉ុន្តែបើនិយាយពីជំងឺវង្វេងស្មារតីតាមវ័យវិញ គឺថាវាចុះជាលំដាប់ទៅតាមវ័យ។

**ស៖** សំណួរចុងក្រោយ យើងមានអារម្មណ៍ថានៅក្នុងរបាយការណ៍វេជ្ជសាស្ត្រ គឺមានការលើកឡើងអំពីធាតុផ្សំដែលមានលក្ខណៈជា *ប៉ារ៉ាណូយ៉ា* (paranoia) តើលោកមានបានលើកឡើងអំពីអ្វីដែលពាក់ព័ន្ធទៅនឹង អៀង ធីរិទ្ធ ដែរឬទេ? តើវាមានលក្ខណៈធ្ងន់ធ្ងរ ឬក៏យើងអាចយល់ស្របទៅតាមការវិភាគវិនិច្ឆ័យ ទៅតាមជំងឺ *អាល់ហ្សៃមឺ* នេះ?

[១៦:០៦:២១]

**ឆ៖** គឺថាវាមិនមែនជាលក្ខណៈវិនិច្ឆ័យច្បាស់នៅក្នុងការវាយតម្លៃរបស់យើង គឺនៅទស្សនៈរបស់គឺថាមិនមានអ្វីដែលច្បាស់ គឺដែលថាការមមើមមាយ ឬក៏ការជឿខុសទៅលើអ្នកផ្សេង ចំណុចមួយដែលយោងទៅរកជនជាប់ចោទម្នាក់ទៀតដែលគាត់ថា ជាជនក្បត់ តាមយើងខ្ញុំៗយល់ឃើញថាមិនមែនជាកត្តាចាំបាច់នៃជំងឺខ្លាច-- *ប៉ារ៉ាណូយ៉ា* នោះទេ។ ហើយមិនមានអ្វីដែលច្បាស់លាស់ដែលថាជាគំនិតភ័យខ្លាចដែលថា គាត់ ដោយសារអារម្មណ៍ភ័យខ្លាចគាត់បកស្រាយព័ត៌មានខុសនោះទេ។ ហើយយើងនឹងរកមើលថានូវអ្វីធ្វើឲ្យគាត់មានការមមើមមាយ ឬក៏ថាធ្វើឲ្យជំនឿក្នុងញាណរបស់គាត់ហ្នឹងបត់បែន។ ហើយចំណុចនេះមិនអាចពន្យល់ទៅតាមប្រវត្តិសុខភាព ហើយយើងមិនរកភស្តុតាងដែលច្បាស់លាស់ដែលបង្ហាញពីបញ្ហានេះដែរ។

**ចៅក្រុម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណច្រើន។ លោកប្រធាន! ខ្ញុំអត់មានសំណួរអីដែលសួរទៅកាន់អ្នកជំនាញទៀតទេ។

[១៦:០៧:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណលោកចៅក្រម។ អរគុណអ្នកជំនាញដែលបានប្រឹងប្រែងនៅក្នុងការឆ្លើយតបទៅនឹងសំណួរអស់រយៈពេលមួយរសៀលនេះ។ ហើយខ្ញុំគិតថាចៅក្រមនៃអង្គជំនុំជម្រះទំនងមិនមានសំណួរអីបន្ថែមទៀតទេ ហើយដោយសារពេលវេលាវាសមល្មមនឹងសម្រាកហើយ ដោយសារការបន្តទៀតដូចជាមិនអាចដំណើរការទៅបានល្អដែរ។ ប៉ុន្តែ មុននឹងសម្រាកអង្គជំនុំជម្រះសូមជម្រាបជូនទៅភាគីមេធាវីការពារក្ដីឲ្យលោកស្រី អៀង ធីរិទ្ធ សហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានជ្រាបថា កាលពីព្រឹកមិញអង្គជំនុំជម្រះបានជម្រាបជូនពីលំដាប់លំដោយនៃការតាំងសំណួរចំពោះក្រុមនីមួយៗ ចំពោះអ្នកជំនាញទាំងពីររូប ប៉ុន្តែដោយការពិគ្រោះពិភាក្សាគ្នា ឯកភាពជាឯកច្ឆន្ទនូវដំណើរការនេះ អង្គជំនុំជម្រះសូមជម្រាបនូវការកែប្រែលំដាប់នៃការសួរ តាំងសំណួរចំពោះអ្នកជំនាញសម្រាប់ប្រព្រឹត្តទៅនៅព្រឹកថ្ងៃស្អែកដូចតទៅ៖ នៅថ្ងៃស្អែកនេះព្រលឹមឡើងចូលមកវិញ គឺត្រូវតាំងសំណួរដោយមេធាវីការពារក្ដី អៀង ធីរិទ្ធ មុនគេបង្អស់ដោយកំណត់ពេលវេលាសរុបមួយម៉ោង ហើយបន្ទាប់មកទៀត គឺអង្គជំនុំជម្រះនឹងប្រគល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដែលមានពេលវេលាមួយម៉ោងសម្រាប់សួរ ហើយបន្ទាប់មកទៀតអង្គជំនុំជម្រះនឹងផ្ដល់វេទិកាជូនទៅមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីរយៈពេលសាមសិបនាទី។ នេះដើម្បីឲ្យកិច្ចដំណើរការប្រព្រឹត្តទៅបានល្អនៅថ្ងៃស្អែកនោះ គឺអង្គជំនុំជម្រះសូមជម្រាបជូនព័ត៌មានប៉ុណ្ណឹង។ ហើយចំណែកឯកិច្ចដំណើរការផ្សេងទៀតដែលអាចមាននោះគឺអង្គជំនុំជម្រះនឹងបញ្ជូនបន្តបន្ទាប់នៅពេលក្រោយ។

[១៦:១០:១៧]

នេះគឺជាការជម្រាបជូនបន្ថែមដែរ ដោយសារបញ្ហាដូចខ្ញុំបានជម្រាបអម្បាញ់មិញនេះ គឺនីតិវិធីអាចបញ្ចប់ដោយភាគីនឹងធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់នូវកិច្ចពិភាក្សាដេញដោលនេះ។ ដូច្នេះ សូមត្រៀមលក្ខណៈនៃការសម្រាប់ពេលវេលានិងលទ្ធភាពក្នុងការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់។ ចំណែកឯពេលវេលានោះ អង្គជំនុំជម្រះនឹងជូនដំណឹងនៅពេលស្អែក មូលហេតុនៅប្រមើលមើលនូវរយៈពេលនៅដំណើរការកម្រិតណា ដើម្បីឲ្យការប្រព្រឹត្តទៅនឹងសមស្របទៅនឹងពេលវេលាដែលបានកំណត់ ហើយម៉្យាងទៀតក៏ធានាផងដែរនូវការចូលរួមមតិយោបល់របស់មេធាវីនៅក្រុមផ្សេងទៀត ចំពោះចំណុចទីបួនដែលយើងបានកំណត់ និងអត្ថិភាពឲ្យគាត់ផ្ដល់មតិយោបល់ ពាក់ព័ន្ធនឹងសំណួរទីបួនដែលយើងបានជម្រាបជូន

កាលពីព្រឹកមិញ។

[១៦:១១:០៩]

ដូច្នេះ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកបន្តទៅព្រឹកថ្ងៃស្អែកចាប់ពីវេលាម៉ោងប្រាំបួន។ អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ អៀង ធីរិទ្ធ និង អៀង សារី ទៅកាន់មន្ទីរឃុំឃាំងនៅ អ.វ.ត.ក វិញ ហើយនិងឲ្យនាំគាត់មកកាន់សាលសវនាការវិញនៅថ្ងៃស្អែកចំពោះលោកស្រី អៀង ធីរិទ្ធ ហើយឡែកចំពោះលោក អៀង សារី គឺអាស្រ័យលើគាត់ បើគាត់សម្រេចចិត្តមកចូលរួម គឺនាំគាត់មក បើសិនគាត់សម្រេចការផ្លាស់ប្ដូរមិនមកទេ គឺអាស្រ័យលើគាត់ដូចអនុវត្តដីកាបង្គាប់ឲ្យយកខ្លួនគាត់មកអ៊ីចឹង៕

**លោក ឌុច ផារី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:១២នាទី)*